**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# អត្ថប្រយោជន៍នៃការចូលជាសមាជិកបេឡាជាតិរបបសន្តិសុខសង្គម

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៦

តាក់តែងឡើងដោយ
និស្សិតឈ្មោះ៖ **ក. លឿន ម៉ុនលី**
**ក. កែវ លីដា**

សាស្ត្រាចារ្យណែនាំ
**លោក ម៉ាន់ គឹមឡេង**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១២
ឆ្នាំសរសេរសារណា ២០១៦

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **លឿន ម៉ុនលី** និង **កែវ លីដា** ជានិស្សិតដែលកំពុងសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី ១៦ ឆ្នាំសិក្សា ២០១៥-២០១៦ ក្រុម **L4B1** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមធ្វើការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖

លោកឪពុក **ឈ្មោះ លឿន គប** និង អ្នកម្តាយ **ឈ្មោះ សុខ មុំ**

លោកឪពុក **ឈ្មោះ កែវ សុជាតិ** និង អ្នកម្តាយ **ឈ្មោះ ម៉ន សុវណ្ណឌី**

លោកទាំងពីរមានគុណដ៏ធំធេងដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ព្រមទាំងផ្គង់ផ្គង់ការសិក្សារបស់កូនតាំងពីតូចរហូតដល់ធំ ជាពិសេសលោកទាំងពីរបានអប់រំ ប្រៀនប្រដៅកូនឱ្យចេះដឹង ខុសត្រូវ ស្គាល់ល្អ និងអាក្រក់ ទាំងកិរិយាមាយាទ សីលធម៌ និងសុជីវធម៌ ដើម្បីឱ្យកូនក្លាយទៅជាកូនល្អ ពលរដ្ឋល្អ និងសិស្សល្អ ដែលជាទីស្រលាញ់រាប់អាននៃអ្នកផងទាំងពួង។ ការអប់រំរបស់លោកទាំងពីរ គឺជាគុណតម្លៃដ៏ធំបំផុតដែលមិនអាចកាត់ថ្លៃបាន ទើបធ្វើឱ្យកូនទទួលបានលទ្ធផលល្អប្រសើរ ដូចថ្ងៃនេះ។

សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ដើម្បីនាំមកនូវ ឯករាជ្យភាពជាតិ សុខសន្តិភាព សេរីភាព ការបង្រួបបង្រួមជាតិ ស្ថេរភាពនយោបាយ និងការអភិវឌ្ឍន៍ប្រទេសជាតិទាំងមូលប្រកបទៅដោយជោគជ័យ។

ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក លោកស្រីសាស្ត្រាចារ្យ បុគ្គលិកការិយាល័យស្រាវជ្រាវ បុគ្គលិកការិយាល័យសិក្សា និងបណ្ណារក្ស ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំប្រឹង យកចិត្តទុកដាក់ ក្នុងការគ្រប់គ្រង ដឹកនាំ និងបង្ហាត់បង្រៀនយើងខ្ញុំឱ្យទទួលបាននូវចំណេះដឹង និងចំណេះធ្វើជាច្រើន មុននឹងឈានមកដល់ថ្ងៃនេះ។

លោកសាស្ត្រាចារ្យ ម៉ាន់ គឹមឡេង ជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានយកចិត្តទុកដាក់ក្នុងការបង្ហាត់បង្រៀន ណែនាំ និងជួយជ្រោមជ្រែងព្រមទាំងផ្តល់នូវការពន្យល់យ៉ាងក្បោះក្បាយ អំពីប្រធានបទដែលយើងខ្ញុំសរសេរ និងចងក្រងឡើង។

ជាទីបញ្ចប់នាងខ្ញុំសូមធ្វើការបួងសួងទៅដល់ វត្ថុស័ក្តសិទ្ធទាំងអស់នៅក្នុងលោកតាមថែរក្សា អ្នកមានគុណទាំងទ្វេរ ឱ្យទទួលបាននូវសេចក្តីសុខ សុខភាពមាំមួន អាយុយឺនយូ ព្រមទាំងជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្នុងនាមយើងខ្ញុំជាសិស្សនិស្សិត កុលបុត្រ និងកុលធីតាខ្មែរ ពួកយើងមានតួនាទីយ៉ាងសំខាន់ដើម្បីជាជំនួយដល់ការអភិវឌ្ឍន៍ប្រទេសជាតិរបស់យើង។ ក្នុងគោលបំណងដ៏ពិសេសនេះក្រុមស្រាវជ្រាវរបស់យើងខ្ញុំ ដែលជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាញ **នីតិសាស្ត្រ** ក្រុម **L4B1**នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានរួបរួមសាមគ្គីគ្នាក្នុងការរៀបចំចងក្រងនូវឯកសារមួយឡើងដែលមានចំណងជើងថា "**អត្ថប្រយោជន៍នៃការចូលជាសមាជិកបេឡាជាតិរបបសន្តិសុខសង្គម**" ដើម្បីជាជំនួយស្មារតីដល់ការសិក្សារបស់សិស្សនិស្សិតប្រជាពលរដ្ឋ ជាពិសេសគឺកម្មករនិយោជិតគ្រប់រូបជុំវិញបញ្ហាផ្សេងៗដែលទាក់ទងទៅនឹងផលប្រយោជន៍ដែលបុគ្គលម្នាក់ៗត្រូវទទួលបានពីបេឡាជាតិរបបសន្តិសុខសង្គម។

ជាការពិតប្រជាពលរដ្ឋគ្រប់រូបគួរតែយល់ដឹងឱ្យបានច្បាស់ អំពីទិដ្ឋភាពនៅក្នុងសង្គមដែលពួកគេកំពុងរស់នៅ រួមទាំងផលប្រយោជន៍ផ្សេងៗ ដែលបុគ្គលម្នាក់ៗត្រូវទទួលបានផងដែរ។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការខាងលើ ក្រុមរបស់យើងខ្ញុំបានខិតខំធ្វើការបកស្រាយយ៉ាងច្បាស់លាស់ទាក់ទងទៅនឹងការទទួលបានអត្ថប្រយោជន៍ពី "**របបធានារ៉ាប់រងសន្តិសុខសង្គម**" ដែលផ្តល់ដោយបេឡាជាតិរបបសន្តិសុខសង្គម ទៅដល់កម្មករនិយោជិតទាំងអស់ដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

យើងខ្ញុំមានសេចក្តីជឿជាក់ និងសង្ឃឹមថាឯកសារនេះនឹងផ្តល់នូវផលប្រយោជន៍ទៅដល់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ព្រមទាំងផ្តល់នូវពុទ្ធិដល់អ្នកសិក្សាទាំងអស់ ក៏ដូចជាចូលរួមចំណែកក្នុងការអភិវឌ្ឍន៍វិស័យអប់រំនៅក្នុងប្រទេសកម្ពុជាឱ្យមានការរីកចំរើនផងដែរ។ ជាទីបញ្ចប់យើងខ្ញុំសូមធ្វើការអភ័យទោស នូវរាល់ចំណុចខ្វះខាត និងកំហុសឆ្គងទាំងឡាយណាដែលកើតមានដោយអចេតនា ហើយយើងខ្ញុំក៏សូមធ្វើការទទួលស្វាគមន៍នូវរាល់មតិរិះគន់ស្ថាបនាផ្សេងៗ និងដើម្បីធ្វើការកែរលម្អរ ព្រមទាំងបន្ថែមនូវគំនិតថ្មីៗជាច្រើនទៀត សម្រាប់បន្សល់ទុកដល់កូនខ្មែរជំនាន់ក្រោយ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........................................ ១

## ជំពូក ១

## ទំនាក់ទំនងនិយោជក និងកម្មករនិយោជិត និងការចុះបញ្ជិកា

**ផ្នែកទី ១ ចំណងគតិយុត្តរវាងនិយោជក និងកម្មករនិយោជិត**

**កថាខណ្ឌ ១ កិច្ចសន្យាការងារ**

ក. និយមន័យ ........................................ ៤

ខ. លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យា ........................................ ៥

ខ.១ លក្ខខណ្ឌគ្រឹះ........................................ ៥

ខ.១.១ កិច្ចព្រមព្រៀងដោយសេរី និងពិតប្រាកដ ........................................ ៦

ខ.១.២ សមត្ថភាពនៃការចុះកិច្ចសន្យា ........................................ ៦

ខ.១.៣ កម្មវត្ថុនៃកិច្ចសន្យា........................................ ៧

ខ.២ លក្ខខណ្ឌទម្រង់........................................ ៧

ខ.២.១ កិច្ចសន្យាផ្ទាល់មាត់........................................ ៨

ខ.២.២ កិច្ចសន្យាលាយលក្ខអក្សរ ........................................ ៨

**កថាខណ្ឌ ២ ប្រភេទនៃកិច្ចសន្យាការងារ**

ក. កិច្ចសន្យាការងារមានថិរវេលាកំណត់ ........................................................................ ៩

ក.១ ល័ក្ខខ័ណ្ឌនៃកិច្ចសន្យាមានថិរវេលាកំណត់ ........................................................... ៩

ក.២ ការផុតរលត់នៃកិច្ចសន្យាមានថិរវេលាកំណត់ .................................................... ១០

ខ. កិច្ចសន្យាការងារមានថិរវេលាមិនកំណត់ ................................................................... ១១

ខ.១ ការចុះកិច្ចសន្យាការងារសាកល្បង ............................................................................ ១១

ខ.២ ការព្យួរកិច្ចសន្យាការងារ .......................................................................................... ១២

ខ.៣ ការរំលាយកិច្ចសន្យាការងារដែលមានថិរវេលាមិនកំណត់................................. ១៣

**ផ្នែកទី ២ ការចុះបញ្ជិកា និងបែបបទនៃការបង់ភាគទាន**

**កថាខណ្ឌ ១ បញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត** ............................. ១៥

ក. យន្តការនៃចុះបញ្ជិកា................................................................................................... ១៦

ក.១ ការចុះបញ្ជិការបស់សហគ្រាស គ្រឹះស្ថាន............................................................ ១៦

ក.២ ការចុះបញ្ជិការបស់កម្មករនិយោជិត ..................................................................... ១៧

ខ. លក្ខខណ្ឌនៃការចុះបញ្ជិការរបស់សហគ្រាស គ្រឹះស្ថាន ............................................. ១៨

គ. លក្ខខណ្ឌនៃការចុះបញ្ជិការរបស់កម្មករនិយោជិត....................................................... ១៩

ឃ. កាលបរិច្ឆេទនៃការចុះបញ្ជិកា ..................................................................................... ១៩

ឃ.១ ថិរវេលានៃការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន................................................. ១៩

ឃ.២ ថិរវេលានៃការចុះបញ្ជិកាសកម្មករនិយោជិត...................................................... ២០

**កថាខណ្ឌ ២ ការកំណត់អត្រាភាគទាន និងការបង់ភាគទាន** ................................ ២០

ក. កាតព្វកិច្ចបង់ភាគទាន......................................................................................២១

ខ. ការកំណត់អត្រាបង់ភាគទានរបស់សហគ្រាស គ្រឹះស្ថាន ........................................២១

គ. ចិរវេលានៃការបង់ភាគទានសហគ្រាស គ្រឹះស្ថាន ................................................ ២៣

ឃ. បែបបទនៃការបង់ភាគទាន ...................................................................................២៤

## ជំពូកទី ២

## គាងកាលិក(អត្ថប្រយោជន៍) ផ្នែកហានិភ័យការងារ និង ផ្នែកសុខភាព

### ផ្នែកទី ១ គាងកាលិកហានិភ័យការងារ

**កថាខណ្ឌ ១ បទដ្ឋានគតិយុត្តិនៃការផ្តល់គាងកាលិកហានិភ័យការងារ**...............២៨

ក. ការជូនដំណឹងអំពីហានិភ័យការងារ .....................................................................២៨

ខ. ការអង្កេតហានិភ័យការងារ....................................................................................២៨

**កថាខណ្ឌ ២ ប្រភេទគាងកាលិកហានិភ័យការងារ**..................................................២៩

ក. គាវកាលិកផ្នែកសេវា ...........................................................................................២៩

ក.១ សេវាសង្គ្រោះបន្ទាន់....................................................................................... ៣០

ក.២ សេវាថែទាំ និងព្យាបាល ................................................................................. ៣០

ក.៣ សេវាបុននីតិសម្បទា ...................................................................................... ៣១

ខ. គាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន ............................. ៣១

គ. គាវកាលិកសម្រាប់ការបាត់បង់សម្ថភាពជាអចិន្ត្រៃយ៍.................................................៣៣

គ.១ វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ .....................................៣៣

គ.២ ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ................................ ៣៤

ឃ. តាវកាលិកមរណភាពចំពោះអ្នករងហានិភ័យការងារ ................................................ ៣៤

ឃ.១ តាវកាលិកឧត្តរជីវី........................................................................................ ៣៤

ឃ.២ វិភាជន៍បូជាសព .......................................................................................... ៣៧

**ផ្នែកទី ២ តាវកាលិកថែទាំសុខភាព**

**កថាខណ្ឌ ១ ការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព** ........................... ៣៧

ក. ស្ថាប័នមានសមត្ថកិច្ច......................................................................................... ៣៨

ខ. ភាគទាន តាវកាលិក និងប្រាក់បម្រុងផ្នែកថែទាំសុខភាព ............................................ ៣៨

ខ.១ ភាគទានផ្នែកថែទាំសុខភាព............................................................................ ៣៩

ខ.២ តាវកាលិកផ្នែកថែទាំសុខភាព.......................................................................... ៣៩

ខ.៣ ប្រាក់ត្រៀបបម្រុងផ្នែកថែទាំសុខភាព ................................................................. ៤០

គ. ការទទួលស្គាល់ និងការត្រួតពិនិត្យគុណភាព សេវារបស់មូលដ្ឋានសុខាភិបាល .......... ៤០

គ.១ ការទទួលស្គាល់គុណភាពសេវា ....................................................................... ៤០

គ.២ ការត្រួតពិនិត្យគុណភាពសេវា និងសេវារបស់មូលដ្ឋានសុខាភិបាល .................... ៤១

**កថាខណ្ឌ ២ យន្តការនៃការអនុវត្តរបបសន្តិសុខផ្នែកថែទាំសុខភាព** .................. ៤១

ក. ដំណាក់កាល និងកាលបរិច្ឆេទនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព................... ៤២

ក.១ ការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពចំពោះសមាជិក ប.ស.ស ......... ៤២

ក.២ ការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពចំពោះឧត្តរជីវី....................... ៤៣

ខ. ការផ្តល់តាវកាលិកថែទាំសុខភាព ........................................................................... ៤៤

ខ.១ កញ្ចប់តារកាលិកថែទាំសុខភាព និងសេវាថែទាំសុខភាព .................................... ៤៥
ខ.១.១ សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ.......................................................... ៤៥
ខ.១.២ សេវាបញ្ជូនអ្នកជម្ងឺ ឬជនរងគ្រោះនិងសេវាបញ្ជូនសព ............................... ៤៧
ខ.១.៣ ប្រាក់បំណាច់ប្រចាំថ្ងៃ ......................................................................... ៤៧
គ. លក្ខខណ្ឌ និងផលប្រយោជន៍ក្នុងការទទួលបានតារកាលិកថែទាំសុខភាព ................. ៤៨
គ.១ លក្ខខណ្ឌក្នុងការទទួលបានតារកាលិកថែទាំសុខភាព ......................................... ៤៩
គ.១.១ លក្ខខណ្ឌក្នុងការទទួលបានសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ ................. ៤៩
គ.១.២ លក្ខខណ្ឌក្នុងការទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃ...................................... ៥០

## ជំពូក ៣

## តារកាលិកផ្សេងៗ និងការដោះស្រាយវិវាទ

**ផ្នែកទី ១ ការផ្តល់តារកាលិកសោធន**

**កថាខណ្ឌ ១ ប្រភេទតារកាលិកផ្នែកសោធនសម្រាប់សមាជិកប.ស.ស**................. ៥២
ក. សោធនជរាភាព ............................................................................................ ៥២
ខ. វិភាជន៍ជរាភាព............................................................................................ ៥៣
គ. សោធនកាលាទិករណ៍....................................................................................... ៥៣
ឃ. សោធនទុព្វលភាព.......................................................................................... ៥៤
**កថាខណ្ឌ ២ តារកាលិកសម្រាប់សិទ្ធិវន្ត**.............................................................. ៥៤
ក. សោធនចំពោះអ្នកនៅក្នុងបន្ទុក....................................................................... ៥៤

ខ. វិភាជន៍ចំពោះអ្នកនៅក្នុងបន្ទុក ........................................................................ ៥៥

**ផ្នែកទី ២ ដំណោះស្រាយវិវាទ ឬបណ្តឹងដែលប្រព្រឹត្តទៅដោយគណៈកម្មការប.ស.ស**

**កថាខណ្ឌ ១ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ** ........................................ ៥៥

ក. សមាសភាពគណៈកម្មការដោះស្រាយវិវាទ ................................................................ ៥៦

ក.១ ការតែងតាំងសមាជិករបស់គណៈកម្មការនៃ ប.ស.ស .......................................... ៥៦

ក.២ លក្ខណៈសម្បត្តិសមាជិកគណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹងនៃប.ស.ស............... ៥៧

ខ. នីតិវិធីក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ...................................................... ៥៨

ខ.១ កម្មវត្ថុនៃការដោះស្រាយវិវាទ ឬ បណ្តឹង ប.ស.ស ................................................ ៥៨

ខ.២ ការកោះហៅគូរភាគី និងការបង្ហាញខ្លួនរបស់ភាគីវិវាទ......................................... ៥៩

**កថាខណ្ឌ ២ ការដោះស្រាយវិវាទតាមផ្លូវតុលាការ**............................................... ៦០

ក. សមត្ថកិច្ចតុលាការរដ្ឋប្បវេណី........................................................................... ៦១

ខ. សមត្ថកិច្ចតុលាការព្រហ្មទណ្ឌ............................................................................ ៦១

**សេចក្តីសន្និដ្ឋាន**

**អនុសាសន៍**

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

ប្រទេសកម្ពុជាត្រូវបានគេស្គាល់ថា ជាប្រទេសមួយក្នុងចំណោមប្រទេសទាំងឡាយនៅជុំវិញអាស៊ី ដែលមានការអភិវឌ្ឍន៍យ៉ាងខ្លាំងខ្លាគួរឱ្យកត់សម្គាល់ បន្ទាប់ពីសតវត្សទី១៩ក្រោយការបញ្ចប់សង្គ្រាមលោកលើកទី២។ កំឡុងពេលនៃការអភិវឌ្ឍន៍ដ៏ក្លាំងក្លាស្ទើរគ្រប់វិស័យ ប្រទេសកម្ពុជាបានជួបវិបត្តិមួយដ៏ធ្ងន់ធ្ងរគឺ វិបត្តិសង្គ្រាមនាឆ្នាំ **១៩៧៥-១៩៧៩** ដែលត្រូវបានគេស្គាល់ថាជា **របបកម្ពុជាប្រជាធិតេយ្យ** ឬ **របបប្រល័យពូជន៍សាសន៍ប៉ុលពត** ជាហេតុធ្វើឱ្យប្រជាជនកម្ពុជាជាច្រើននាក់បាត់បង់ជីវិតនាសម័យនោះ។ ក្រោយពីឆ្លងកាត់នូវសង្គ្រាមអស់រយៈកាលច្រើនឆ្នាំ ប្រទេសកម្ពុជាបានបាត់បង់នូវហេដ្ឋារចនាសម្ព័ន្ធស្ទើរតែទាំងស្រុង មិនត្រឹមតែផ្លូវថ្នល់ ស្ពាន ឬសាលារៀនប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជះឥទ្ធិពលយ៉ាងខ្លាំងទៅដល់ វិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិស័យផ្សេងៗផងដែរ។ កត្តាទាំងអស់នេះគឺជាបញ្ហាដ៏ធំ ដែលប្រទេសកម្ពុជាត្រូវប្រឈមមុខក្រោយពីទទួលរងនូវសង្គ្រាមរ៉ាំរ៉ៃក៏ដូចជាការសម្លាប់រង្គាលនា **របបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)** ដែលជាហេតុធ្វើឱ្យប្រទេសកម្ពុជាបានបាត់បង់នូវធនធានមនុស្សដ៏សំខាន់ៗជាច្រើន។

ទោះបីជាយ៉ាងណាក៏ដោយ ប្រទេសកម្ពុជាក៏បានវិលត្រលប់មករកសភាពដើមវិញបន្តិចម្តងៗ ក្រោយពីការដួលរលំនូវរបបកម្ពុជាប្រជាធិបតេយ្យតាមរយៈការវាយរំដោះពីសំណាក់ **កងទ័ពរណៈសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា** និង **កងទ័ពស្ម័គ្រចិត្តវៀតណាម** ដែលជាហេតុធ្វើឱ្យប្រទេសកម្ពុជាត្រលប់មករកសុខសន្តិភាពវិញផងដែរ។ ជាការពិតណាស់ក្រោយពីបាត់បង់នូវហេដ្ឋារចនាសម្ព័ន្ធក៏ដូចជាធនធានសំខាន់ៗជាច្រើន រាជរដ្ឋាភិបាលកម្ពុជាបានព្យាយាមយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការថែរក្សា អភិវឌ្ឍន៍ ជ្រោមជ្រែង និងលើកតម្កើងប្រទេសកម្ពុជាទាំងមូលឱ្យក្លាយទៅជាប្រទេសមួយ ដែលមានការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិស័យផ្សេងៗទៀតជុំវិញអាស៊ី ដែលការពង្រឹងនូវវិស័យទាំងអស់នេះ រដ្ឋាភិបាលបានចាប់ផ្តើមធ្វើការផ្សារភ្ជាប់នូវទំនាក់ទំនងរវាងបណ្តាប្រទេសនានាដែលស្ថិតនៅជុំវិញខ្លួនទៅលើវិស័យផ្សេងៗដូចជា សេដ្ឋកិច្ច ពាណិជ្ជកម្ម ជាពិសេសនោះគឺវិស័យការងារផ្ទាល់តែម្តង។ យ៉ាងណាមិញ ក្រៅពីប្រទេសកម្ពុជា ក៏នៅមានប្រទេសជាច្រើនទៀត កំពុងធ្វើអភិវឌ្ឍន៍ប្រទេសរបស់ខ្លួនដូចគ្នា ដែលនៅក្នុងនោះការអភិវឌ្ឍន៍របស់បណ្តាប្រទេសនានាដែលនៅជុំវិញប្រទេសកម្ពុជា ក៏ដូចជាប៉ែកខាងអឺរ៉ុបផងដែរនោះ បានធ្វើការចាប់ផ្តើមពីវិស័យការងារដូចគ្នាផងដែរ ដោយហេតុថាវិស័យនេះគឺជាវិស័យចំបងរបស់ប្រទេសនីមួយៗមុននឹងឈានដល់ការអភិវឌ្ឍន៍វិស័យផ្សេងៗ។

ដោយសារតែទីផ្សារការងារទាំងក្នុងនិងក្រៅប្រទេសកំពុងតែរីកដុលដាលខ្លាំង យើងសង្កេតឃើញថាទីផ្សារការងារនៅក្នុងប្រទេសកម្ពុជានានេះ ក៏កំពុងតែមានភាពរីកចម្រើនជាមួយគ្នាផងដែរ ជាហេតុធ្វើរាជរដ្ឋាភិបាលកម្ពុជាសម្រេចបង្កើតនូវច្បាប់មួយឡើង ដើម្បីជួយសម្រួលទៅការអនុវត្តនូវវិស័យការងារនៅក្នុងប្រទេស ក៏ដូចជាការពារនូវសិទ្ធិក្នុងការឈប់សម្រាករបស់កម្មករនិយោជិត ជៀសវាងការកេងចំណេញនូវកម្លាំងពលកម្មពីកម្មករនិយោជិត ជាពិសេសគឺទៅលើស្ត្រី និង កុមារផងដែរ។ ច្បាប់នេះត្រូវបានគេស្គាល់ថាជា **ច្បាប់ការងារ** ដែលត្រូវបានអនុម័តដោយរដ្ឋសភានៅថ្ងៃទី **១០** ខែ**មករា ឆ្នាំ ១៩៩៧** និងប្រកាសឱ្យប្រើនៅថ្ងៃទី **២៧** ខែ**កុម្ភៈ ឆ្នាំ ១៩៩៧**។ បន្ទាប់ពីបង្កើតនូវច្បាប់ការងាររួចមកយើងសង្កេតឃើញថា ប្រទេសកម្ពុជាមានការផ្លាស់ប្តូរជាច្រើនទៅលើទម្រង់នៃវិស័យការងារ ជាពិសេសគឺការទទួលបានការវិនិយោគពីបណ្តាប្រទេសផ្សេងៗ ជាហេតុនាំឱ្យកើតមាននូវសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតជាច្រើនរីកដុលដាលស្ទើរពាសពេញប្រទេស។ ប៉ុន្តែទោះបីជាមានកំណើននៃវិនិយោគកើនឡើងយ៉ាងណាក៏ដោយ នៅតែមានគ្រឹះស្ថាន សហគ្រាស ក៏ដូចជានិយោជកមួយចំនួននៅតែ ធ្វើការគាបសង្កត់ និងកេងចំណេញនូវកម្លាំង ពលកម្ម ព្រមទាំងប្រាក់ឈ្នួលរបស់កម្មករនិយោជិតដដែល ជាហេតុធ្វើឱ្យកម្មកនិយោជិតស្ទើរតែទាំងស្រុងបានបាត់បង់នូវសិទ្ធិរបស់ខ្លួនក្នុងការធ្វើការ ព្រមទាំងសិទ្ធិក្នុងការទទួលបានប្រាក់ឧបត្ថម្ភផ្សេងៗផងដែរ។ ផ្អែកលើមូលហេតុទាំងអស់នេះ យើងអាចកត់សម្គាល់បានថា ការអនុវត្តវិស័យការងារនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន តែងតែកើតមាននូវវិវាទផ្សេងៗរវាងនិយោជក និងកម្មករនិយោជិតនាពេលបំពេញការងារ ដូចជាបញ្ហាប្រាក់បៀវត្ស ការផ្តល់សេវាថែទាំសុខភាព និងហានិភ័យការងារជាដើម ហេតុដូច្នេះហើយ ទើបរាជរដ្ឋាភិបាលសម្រេចបង្កើតឲ្យមាននូវច្បាប់ថ្មីមួយទៀតដើម្បីដោះស្រាយនៅបញ្ហាដែលកើតមាន **គឺច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារ** ដែលគ្រប់គ្រងដោយបេឡាជាតិរបបសន្តិសុខសង្គមដើម្បីសម្រួលទៅដល់ការធានារ៉ាប់រងហានិភ័យការងារ ការផ្តល់សេវាថែទាំសុខភាព និងតាវកាលិកផ្សេងៗរួមមាន ជរាភាព ទុព្វភាព ភាពជាដើម។

យោងតាមតថភាពជាក់ស្តែង នៅក្នុងសង្គមកម្ពុជាយើងអាចសង្កេតបានថា និយោជកនិងកម្មករនិយោជិតមួយចំនួននៅតែពុំទាន់បានយល់ច្បាស់អំពី ការអនុវត្តនូវច្បាប់របបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញតិនៃច្បាប់ស្តីពីការងារនៅឡើយ ដោយនៅក្នុងនោះ នៅតែមានសំណួរចោទសួរជារឿយៗទាក់ទងទៅនឹងផលប្រយោជន៍ ក៏ដូចជានីតិវិធីដែល

បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ធ្វើការសម្រេចផ្តល់ជូនកម្មករនិយោជិតទាំងអស់ដែលបានចុះបញ្ជិកា។

**ថាតើត្រូវធ្វើដូចម្តេចដើម្បីក្លាយជាសមាជិកនៃបេឡាជាតិរបបសន្តិសុខសង្គម? ហើយថាតើការចូលជាសមាជិកនៃបេឡាជាតិរបបសន្តិសុខសង្គមនេះមាននីតិវិធីអ្វីខ្លះ? តើវាបេឡាជាតិរបបសន្តិសុខសង្គមបានផ្តល់ផលប្រយោជន៍អ្វីខ្លះជូនទៅដល់កម្មករនិយោជិតក៏ដូចជាសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជិកា?**

ដើម្បីធ្វើការបកស្រាយឱ្យបានក្បោះក្បាយ ក៏ដូចជាធ្វើការឆ្លើយតមទៅនឹងសំណួរដែលបានចោទសួរឡើងខាងលើនោះ កិច្ចការស្រាវជ្រាវនេះបានកំណត់នូវប្រធានបទជាមុនសិនមុននឹងឈានទៅដល់ការបកស្រាយលើប្រធានបទនេះ ក្រុមយើងខ្ញុំបានលើកយកនូវនីតិវិធីក្នុងការចូលជាសមាជិកនៃបេឡាជាតិរបបសន្តិសុខសង្គមមកធ្វើការបកស្រាយមុនគេ បន្ទាប់មកនឹងធ្វើការបកស្រាយទៅលើប្រភេទតាវកាលិក (ផលប្រយោជន៍) ដែលបេឡាជាតិរបបសន្តិសុខសង្គមផ្តល់ជូនទៅកាន់សមាជិករបស់ខ្លួន និងចុងក្រោយយើងខ្ញុំនឹងធ្វើការបកស្រាយទៅលើការដោះស្រាយវិវាទទាក់ទងនឹងផលប្រយោជន៍របស់ ប.ស.ស ។ ដូច្នេះយើងបានធ្វើការបែងចែកជាបី (៣) ជំពូក៖

**ជំពូក ១ ទំនាក់ទំនងនិយោជក និងកម្មករនិយោជិត និងការចុះបញ្ជិកា**

**ជំពូក ២ តាវកាលិកផ្នែកហានិភ័យការងារ និង តាវកាលិកផ្នែកសុខភាព**

**ជំពូក ៣ តាវកាលិផ្សេងៗ និង ការដោះស្រាយវិវាទ ឬ បណ្តឹង**

# ជំពូក ១

# ទំនាក់ទំនងនិយោជក និងកម្មករនិយោជិត និងការចុះបញ្ជិកា

ជាការពិតណាស់ ការសិក្សាអំពីទំនាក់ទំនងនិយោជក និងកម្មករនិយោជិត គឺជាកត្តាចម្បងមុននឹងឈានដល់ការចុះឈ្មោះចូលជាសមាជិកនៃប.ស.ស។ ហេតុដូច្នេះហើយទើបក្រុមរបស់យើងខ្ញុំសម្រេចធ្វើការបកស្រាយអំពីចំណងគតិយុត្តរវាងនិយោជក និងកម្មករនិយោជិត (**ផ្នែកទី១**) ជាមុនសិនមុននឹងឈានដល់ ការចុះបញ្ជិកា (**ផ្នែកទី២**) ។

## ផ្នែកទី ១ ចំណងគតិយុត្តរវាងនិយោជក និងកម្មករនិយោជិត

ចំណងគតិយុត្តរវាងនិយោជក និងកម្មករនិយោជិតគឺជាចំណុចចំបងនៃការចាប់ផ្តើមនូវទំនាក់ទំនងរវាងគ្នានឹងគ្នា ហើយទំនាក់ទំនងនេះនឹងត្រូវបានចងភ្ជាប់គ្នាតាមរយៈកិច្ចសន្យាមួយដែលត្រូវបានគេស្គាល់ថាជាកិច្ចសន្យាការងារ (**កថាខណ្ឌ១**)។ ផងដែរនោះក្នុងច្បាប់ស្តីពីការងារក៏បានកំណត់អំពីប្រភេទកិច្ចសន្យាការងារ (**កថាខណ្ឌ២**) ក្នុងនោះរួមមានកិច្ចសន្យាមានថេរវេលាកំណត់ និងកិច្ចសន្យាគ្មានថេរវេលាកំណត់ ដែលត្រូវបានបកស្រាយនៅខាងក្រោម៖

### កថាខណ្ឌ ១ កិច្ចសន្យាការងារ

ដើម្បីធ្វើការស្វែងយល់ឱ្យបានច្បាស់អំពីកិច្ចសន្យាការងារ យើងខ្ញុំនឹងផ្តល់និយមន័យទៅលើកិច្ចសន្យាការងារ ដោយអនុលោមទៅតាមច្បាប់ស្តីពីការងារ ដែលត្រូវបានអនុម័តដោយរដ្ឋសភាជាតិនៅ ថ្ងៃទី១០ ខែមករា ឆ្នាំ ១៩៩៧ និងប្រកាសឱ្យប្រើនៅថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ ១៩៩៧ ព្រមទាំងនិយមន័យនៃកិច្ចសន្យាការងារទៅតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

#### ក. និយមន័យ

**កិច្ចសន្យាការងារ** គឺជាកិច្ចសន្យាដែលបង្កើតឱ្យមានការទាក់ទងផ្នែកការងារ រវាងកម្មករនិយោជិត និងនិយោជក។ កិច្ចសន្យានេះត្រូវនៅក្រោមវិធានអាជ្ញាគតិ ហើយអាចនឹងធ្វើទៅតាមទម្រង់ដែលភាគីទាំងសងខាងព្រមព្រៀងគ្នា[1]។

[1] ច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ មាត្រា ៦៥

**កិច្ចសន្យាការងារ** ត្រូវបានបង្កើតឡើង ដោយការសន្យារបស់ភាគីម្ខាងថា ធ្វើពលកម្មឱ្យភាគីម្ខាងទៀត ហើយភាគីម្ខាងទៀតសន្យាថា ផ្តល់ប្រាក់ឈ្នួល ទៅលើកិច្ចការពលកម្មនោះ ហើយភាគីដែលបានសន្យាថាធ្វើពលកម្ម ហៅថាកម្មករនិយោជិត ឯភាគីម្ខាងទៀតនោះហៅថានិយោជក[2]។

តាមរយៈនិយមន័យកិច្ចសន្យាការងារខាងលើនេះ បានបង្ហាញឱ្យឃើញថា ការបង្កើតកិច្ចសន្យាការងារ ត្រូវមានភាគីម្នាក់ដែលហៅថានិយោជិត មានឆន្ទៈចង់ធ្វើការ ចំនែកភាគីម្ខាងទៀតដែលហៅថានិយោជកមានឆន្ទៈក្នុងជ្រើសរើសកម្មករដើម្បីធ្វើការងារឱ្យខ្លួន ដូនេះនាំឱ្យមាននូវជំនួបនៃឆន្ទៈដូចគ្នារវាងនិយោជក និងនិយោជិតដែលអាចឈានទៅរកនូវការបង្កើតកិច្ចសន្យាការងារបាន។ ដូច្នេះយើងត្រូវស្វែងយល់អំពីលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាការងារ ថាតើលក្ខខណ្ឌអ្វីខ្លះដែលអាចធ្វើឱ្យកិច្ចសន្យាមានសុពលភាពបាន?

### ខ. លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាការងារ

ជាគោលការណ៍ អនុភាពនៃកិច្ចសន្យាកើតឡើងត្រឹមតែមានវត្តមាននៃការព្រមព្រៀងគ្នារបស់ភាគីកិច្ចសន្យាប៉ុណ្ណោះ [3] ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ភាគីនៃកិច្ចសន្យាត្រូវបង្កើតកិច្ចសន្យាដោយគោរពទៅតាមវិធានគតិយុត្តផ្សេងទៀត ដើម្បីឱ្យកិច្ចសន្យានោះមានសុពលភាព។ ដូច្នេះដើម្បីកិច្ចសន្យាមាន អនុភាព និង សុពលភាពអនុវត្ត ភាគីកិច្ចសន្យាត្រូវគោរពនូវលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យា។ ហើយលក្ខណៈទាំងនោះរួមមាន៖ លក្ខខណ្ឌគ្រឹះ **(ខ.១)** និងលក្ខខណ្ឌទម្រង់ **(ខ.២)** ដែលជាចំណុចចម្បងនៃការចុះកិច្ចសន្យា។ ចំនែកឯកិច្ចន្យាការងារវិញ ដើម្បីបង្កើតអានុភាពក៏ត្រូវមានទាវឱ្យមានឆន្ទៈនៃការព្រមព្រៀងគ្នា ហើយកិច្ចសន្យានេះក៏បានទាមទារឱ្យអនុវត្តតាមទំរង់ អាចធ្វើជាលាយលក្ខអក្សរ និង ផ្ទាល់មាត់[4]។

#### ខ.១ លក្ខខណ្ឌគ្រឹះ

លក្ខខណ្ឌគ្រឹះ គឺជាលក្ខខណ្ឌចម្បងបំផុតនៃកិច្ចសន្យា ដែលលក្ខខណ្ឌនេះត្រូវបានកំណត់ដោយវិធានគតិយុត្ត និងតម្រូវអោយភាគីទាំងសងខាងគោរពនឹងអនុវត្តតាម។ លក្ខខណ្ឌដែលធ្វើឱ្យកិច្ចសន្យានោះមានសុពលភាព និងអានុភាព ហើយការអនុវត្តទៅតាមលក្ខខណ្ឌគ្រឹះភាគីនៃកិច្ចសន្យាការងារ នឹងទទួលបាននូវកិច្ចសន្យាមួយប្រកបទៅដោយភាពត្រឹមត្រូវតាមបទដ្ឋានគតិយុត្តដោយអាចធានាបាននូវសុពលភាពនៃកិច្ចសន្យាការងារ ហើយជាពិសេសដើម្បីអោយកិច្ចសន្យា

[2] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៦៦៤ ស្តីពីកិច្ចសន្យាការងារ

[3] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៣១០ ស្តីពីនិយមន័យនៃការបង្ហាញឆន្ទៈ

[4] មាត្រា ៦៥ នៃច្បាប់ស្តីពីការងារ ឆ្នាំ ១៩៩៧

នេះប្រព្រឹត្តទៅដោយគ្មានវិការៈទៀតនោះ ភាគីចាំបាច់ត្រូវធ្វើការអនុវត្តប្រកបដោយឆន្ទៈពិតប្រាកដ និងដោយគ្មានបង្ខិតបង្ខំពីសំណាក់ភាគីម្ខាងទៀតឡើយ។ ដូច្នេះដើម្បីឱ្យកិច្ចសន្យាមាននូវអនុភាព និងសុពលភាពដូចដែលបានរៀបរាប់ខាងលើនេះ ភាគីទាំងសងខាងត្រូវបង្កើតកិច្ចសន្យាដោយមាន ៖ ការព្រមព្រៀងដោយសេរី និងពិតប្រាកដ **(ខ.១.១)** សមត្ថភាពនៃចុះកិច្ចសន្យា **(ខ.១.២)** និង កម្មវត្ថុនៃកិច្ចសន្យា **(ខ.១.៣)** ។

### ខ.១.១ កិច្ចព្រមព្រៀងដោយសេរី និងពិតប្រាកដ

កិច្ចព្រមព្រៀងដោយសេរី គឺជាកិច្ចព្រមព្រៀងមួយ ដែលធ្វើឡើងដោយឆន្ទៈរបស់ភាគីទាំងសងខាងដោយពិតប្រាកដ និងគ្មានការបង្ខិតបង្ខំ ពោលគឺជាការព្រមព្រៀងមួយដែលភាគីនៃកិច្ចសន្យាសម្រេចទទួលយករៀងៗខ្លួនមុននឹងចុះកិច្ចសន្យា។

ក្នុងករណីដែលភាគីបង្កើតកិច្ចសន្យាមិនមានឆន្ទៈនៃការព្រមព្រៀងពិតប្រាកដទេនោះ នាំឱ្យកិច្ចសន្យានោះមានវិការៈនឹងមានការលុបចោលនៃកិច្ចន្យា[5]។

ការព្រមព្រៀង កើតឡើងនៅពេលដែល សំណើ និង ស្ទីការជួបគ្នា ដែលការជួបគ្នានៃសំណើ និងស្ទីការនេះ គឺសំដៅទៅលើភាពស៊ីសង្វាក់គ្នានៃឆន្ទៈរបស់ភាគីនៃកិច្ចសន្យាថាខ្លួនពិតជាយល់ព្រមទទួលយកនូវសំណើ ដែលបានកំណត់ក្នុងកិច្ចសន្យាពិតប្រាកដមែន។

ចំណែកឯការព្រមព្រៀងដោយសេរី គឺសំដៅដល់ការព្រមព្រៀទាំងឡាយណាដែល ពុំមានការបង្ខិតបង្ខំ ឬគំរាមគំហែងនោះឡើយ ពោលគឺជាការព្រមព្រៀងដោយឆន្ទៈផ្ទាល់របស់ភាគីនៃកិច្ចសន្យាតែម្តង ប៉ុន្តែការព្រមព្រៀងដោយសេរីនេះអាចនឹងបាត់បង់នូវសុពលភាពរបស់វា ប្រសិនបើកិច្ចសន្យាត្រូវបានគេរកឃើញថា មានវិការៈ[6]ដូចជា ការភ័ន្តច្រឡំ ការគំរាមគំហែង ការឆបោក ពត៌មានមិនពិត ការរំលោភបំពានលើស្ថានភាព ការបង្ហាញឆន្ទៈមិនពិត បបនីយផ្លូវចិត្ត អំពើកេងចំណេញហួសហេតុ និង ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈជាដើម។

### ខ.១.២ សមត្ថភាពនៃការចុះកិច្ចសន្យា

ផ្អែកតាមគោលការណ៍ច្បាប់ រាល់ការចុះកិច្ចសន្យាតម្រូវអោយបុគ្គល ដែលជាភាគីនៃកិច្ចសន្យានោះត្រូវមានសិទ្ធ និង កាតព្វកិច្ច ជាមុនសិនទើបអាចធ្វើការចុះកិច្ចសន្យាបាន ពោលគឺភាគីទាំង

[5] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៣៩៥ ការបង្ហាញឆន្ទៈដែលមានវិការៈ

[6] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ គន្ថីទី៤ ជំពូកទី២ ផ្នែកទី២ ស្តីពីវិការៈនៃការបង្ហាឆនៈនិងសុពលភាពនៃកិច្ចសន្យា

សងខាងត្រូវតែមានបុគ្គលភាពគតិយុត្តត្រឹមត្រូវទៅតាមការកំណត់របស់ច្បាប់ [7] ។ ផ្ទុយទៅវិញ ប្រសិនបើភាគីនៃកិច្ចសន្យាជា **ជនវិបលាសស្មារតី ឬ អសមត្ថជន** នោះ ច្បាប់មិនទទួលស្គាល់នូវសមត្ថភាពធ្វើសកម្មភាពរបស់ពួកគាត់ទេ ព្រោះច្បាប់ចង់ការពារនូវផលប្រយោជន៍របស់ពួកគាត់ ដូចនេះបើកិច្ចសន្យាដែលបានបង្កើតដោយជនខាងលើនេះ ត្រូវចាត់ទុកថាគ្មានសុពលភាពឡើយ។ ក្នុងករណីដែលភាគីនៃកិច្ចសន្យា គឺជាអនីតិជនដែលមានអត្តាធិនភាពអនីតិជននោះ អាចមានសិទ្ធិក្នុងការចុះកិច្ចសន្យាបាន និងពុំចាំបាច់មានការយល់ព្រម ពីសំណាក់អាណាព្យាបាលឡើយ ដោយហេតុថាបុគ្គលដែលទទួលបានអត្តាធិនភាពគឺជាបុគ្គល ដែលមានបុគ្គលភាពគតិយុត្តដូចជានីតិជនដែរ [8] ។ ម្យ៉ាងវិញទៀតចំពោះអនីតិជនដែលមានអាយុក្រោម ១៨ឆ្នាំ ក៏អាចចុះកិច្ចសន្យាការងារបានដែរ ប៉ុន្តែតម្រូវឱ្យការងារនោះមិនបង្កើតគ្រោះថ្នាក់ និងលើសពីកម្លាំងរបស់អនីតិជននោះ[9]។ អាយុដែលអនីតិជន អាចធ្វើការចុះកិច្ចសន្យាបាន គឺចាប់ពី ១៥ ឆ្នាំ[10]។

### ខ.១.៣ កម្មវត្ថុនៃកិច្ចសន្យា

ជាទូទៅរាល់កិច្ចសន្យាការងារដែលភាគីនិយោជក និងកម្មករនិយោជិតបានបង្កើតឡើង គឺសុទ្ធតែមានកម្មវត្ថុនៅក្នុងនោះរួចជាស្រេចដើម្បីកំណត់ ថាតើភាគីទាំងសងខាងនៃកិច្ចសន្យាចង់បានអ្វីពីការបង្កើតកិច្ចសន្យានេះ។ ក្នុងករណីនេះ កម្មវត្ថុនៃកិច្ចសន្យាចាំបាច់ត្រូវប្រតិបត្តិទៅតាមវិធានគតិយុត្តជាកំហិត ពោលគឺមិនអាចផ្ទុយនឹងច្បាប់ ទំនៀមទំលាប់ ឬសណ្តាប់ធ្នាប់សាធារណៈនោះទេ។ ផ្ទុយទៅវិញ ប្រសិនបើភាគីទាំងសងខាងនៃកិច្ចសន្យាការងារ មិនបានកំណត់ឱ្យបានច្បាស់ និងត្រឹមត្រូវទៅតាមវិធានគតិយុត្តទេនោះ កិច្ចសន្យានោះនឹងត្រូវចាត់ទុកថាគ្មានសុពលភាពតាំងពីដំបូង។ ដូច្នេះកិច្ចសន្យាការងារទាំងឡាយណា ដែលមានកម្មវត្ថុផ្ទុយនឹងសណ្តាប់ធ្នាប់សារធារណៈ និងទំនៀមទំលាប់ល្អ ត្រូវចាត់ទុកថាមោឃៈ[11]។

### ខ.២ លក្ខខណ្ឌទម្រង់

នៅក្នុងលក្ខខណ្ឌទម្រង់ កិច្ចសន្យាត្រូវបានបែងចែកជាពីរប្រភេទផ្សេងគ្នា គឺកិច្ចសន្យាផ្ទាល់មាត់ និងកិច្ចសន្យាលាយល័ក្ខអក្សរ។ ភាគច្រើននៃកិច្ចសន្យាការងារដែលបានបង្កើតឡើងគឺសុទ្ធតែបានគោរពនូវវិធានណាមួយនៃលក្ខខណ្ឌទាំងពីរនេះ ជាពិសេសគឺកិច្ចសន្យាការងារ ឬ កិច្ចសន្យារវាង

[7] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៦

[8] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ២២ ស្តីពីអានុភាពនៃអត្តាធីនភាព

[9] មាត្រា ១៧៣ នៃច្បាប់ស្តីពីការងារ ឆ្នាំ ១៩៩៧

[10]មាត្រា ១៧៧ នៃច្បាប់ស្តីពីការងារ ឆ្នាំ ១៩៩៧

[11] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ៣៥៤

និយោជក និងកម្មករនិយោជិត ដែលអាចបង្ករឱ្យមានភាពងាយស្រួលក្នុងការប្រតិបត្តិវាទៅតាមវិធានគតិយុត្ត។

### ខ.២.១ កិច្ចសន្យាផ្ទាល់មាត់

អនុឡោមទៅតាមលក្ខខណ្ឌទម្រង់ កិច្ចសន្យាផ្ទាល់មាត់ក៏ត្រូវគេបានទទួលស្គាល់និងយកមកអនុវត្តនៅក្នុងកិច្ចសន្យាការងារផងដែរ ដោយកិច្ចសន្យានេះធ្វើឡើងរវាងភាគីទាំងសងខាងតាមរយៈការព្រមព្រៀងគ្នានឹងគ្នាក្នុងការបំពេញការងារធ្វើអ្វីមួយដោយផ្ទាល់មាត់ ដោយមិនបានធ្វើក្នុងលិខិតជាលាយលក្ខអក្សរឡើយ។ ជាឧទាហរណ៍ និយោជក សន្យាថានឹងផ្តល់ការងារសមស្របមួយទៅឱ្យកម្មករនិយោជិត ហើយកម្មករនិយោជិតផ្ទាល់ក៏យល់ព្រមទទួលយក និងបម្រើការងារទៅឱ្យនិយោជកផងដែរ។

### ខ.២.២ កិច្ចសន្យាលាយល័ក្ខអក្សរ

កិច្ចសន្យាដែលធ្វើឡើងជាលាយល័ក្ខអក្សរ គឺជាកិច្ចសន្យារវាងគូភាគីទាំងសងខាង ដោយមានការយល់ព្រមរវាងគ្នានឹងគ្នា ក្នុងការកំណត់នូវលក្ខខណ្ឌ ឬកម្មវត្ថុដែលភាគីនៃកិច្ចសន្យាចង់បាន ហើយការកំណត់នូវកម្មវត្ថុនៃកិច្ចសន្យានេះចាំបាច់ត្រូវតែអនុឡោមទៅវិធានគតិយុត្ត។

នៅក្នុងវិធាននៃនីតិការងារ កិច្ចសន្យាការងារមានថិរវេលាកំណត់ គឺជាកិច្ចសន្យាដែលធ្វើឡើងជាលាយល័ក្ខអក្សរ ដោយកិច្ចសន្យានេះប្រតិបត្តិដូចគ្នាទៅវិធាននៃកិច្ចសន្យាទូទៅដែរ ពោលគឺតម្រូវឱ្យមានហត្ថលេខាព្រមព្រៀងរវាងនិយោជិក និងកម្មករនិយោជិត ព្រមទាំងមានកំណត់នូវថិរវេលាច្បាស់លាស់ និងពិតប្រាកដ។ ជាពិសេសគឺកំណត់ឱ្យបានច្បាស់ពីកាលបរិច្ឆេទនៃការបញ្ចប់កិច្ចសន្យានេះ[12]។ កិច្ចសន្យានេះអាចសរសេរ និងចុះហត្ថលេខាទៅតាមទម្លាប់ស្រុកហើយប្រសិនជាត្រូវចុះបញ្ជិកាក៏ត្រូវធ្វើឥតបង់ពន្ធអ្វីឡើយ[13]។

## កថាខណ្ឌ ២ ប្រភេទនៃកិច្ចសន្យាការងារ

បន្ទាប់ពីបានសិក្សាយល់ដឹងនូវនិយមន័យ និងលក្ខខណ្ឌនៃបង្កើតកិច្ចសន្យាការងាររួចហើយនោះយើងក៏ត្រូវស្គាល់អំពីប្រភេទនៃកិច្ចសន្យាការងារផងដែរ ព្រោះការស្គាល់ច្បាស់ពីប្រភេទនៃកិច្ចសន្យាការងារអាចធ្វើឱ្យភាគីនឹងមិនមានការភ័ន្តច្រឡំ និងគ្មានការទទួលរងនូវការកេងប្រវ័ញ្ចណាមួយពីសំណាក់និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាននោះឡើយ។

---

[12] មាត្រា ៦៧ កថាខណ្ឌ១ ច្បាប់ស្តីពីការងារ ឆ្នាំ ១៩៩៧

[13] មាត្រា ៦៥ កថាខណ្ឌ២ វាក្យខណ្ឌ២ ច្បាប់ស្តីពីការងារ ឆ្នាំ ១៩៩៧

ផ្អែកតាមគោលការណ៍ទម្រង់ កិច្ចសន្យាជាទូទៅត្រូវបានបែងចែកជាពីរ គឺកិច្ចសន្យាផ្ទាល់មាត់ និងកិច្ចសន្យាលាយលក្ខអក្សរ។ យ៉ាងណាមិញ យោងតាមច្បាប់ស្តីពីការងារ កិច្ចសន្យាការងារក៏ធ្វើការបែងចែកដូចគ្នាទៅតាមគោលការណ៍ផងដែរ ដែលនៅក្នុងនោះកិច្ចសន្យាត្រូវបានបែងចែកជាពីរប្រភេទ គឺកិច្ចសន្យាការងារមានថិរវេលាកំណត់ (ក) និងកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ (ខ) ។ ការបែងចែកកិច្ចសន្យាជាពីរប្រភេទផ្សេងគ្នា គឺដើម្បីបង្ហាញឱ្យបានច្បាស់អំពីអានុភាពនៃកិច្ចសន្យា ក៏ដូចជាផ្តល់នូវផលប្រយោជន៍ទៅដល់ភាគីទាំងសងខាងក្នុងកិច្ចសន្យាផងដែរ និង ជាពិសេសការពារកុំឱ្យមានភាគីខិលខូចមួយចំនួន កេញយកផលប្រយោជន៍ពីភាគីម្ខាងទៀតដោយធ្វើឱ្យដំណើរការសង្គម ក៏ដូចជាការរកស៊ីមានភាពអសន្តិសុខ។

### ក. កិច្ចសន្យាការងារមានថិរវេលាកំណត់

កិច្ចសន្យាការងារមានថិរវេលាកំណត់គឺជាកិច្ចសន្យាមួយ ដែលធ្វើឡើងជាលាយល័ក្ខអក្សរ ដោយមានចុះហត្ថលេខាព្រមព្រៀងគ្នា និងកំណត់ថិរវេលាពិតប្រាកដ ព្រមទាំងមានចែងនូវកាលបរិច្ឆេទច្បាស់លាស់ នៃការបញ្ចប់កិច្ចសន្យានោះផងដែរ។

#### ក.១ ល័ក្ខខ័ណ្ឌនៃកិច្ចសន្យាមានថិរវេលាកំណត់

កិច្ចសន្យាមានថិរវេលាកំណត់ គឺជាកិច្ចសន្យាដែលមានការព្រមព្រៀងគ្នាដោយកំណត់នូវថិរវេលាពិតប្រាកដ។ ហើយថេរវេលាដែលត្រូវបានកំណត់តាមច្បាប់នោះ គឺមិនអាចលើសពី **ពីរ (២) ឆ្នាំ**បានឡើយ ប៉ុន្តែកិច្ចសន្យានេះអាចបន្តបានសារជាថ្មីម្តងទៀត ឬច្រើនដងបាន ដែលការបន្តនោះត្រូវមានថិរវេលាមិនលើសពី **ពីរ (២) ឆ្នាំ**ឡើយ។ ចំពោះការអនុវត្តផ្ទុយទៅនឹងវិធានខាងលើនាំឱ្យកិច្ចសន្យានោះក្លាយទៅជាកិច្ចសន្យា គ្មានកំណត់ថិរវេលាពិតប្រាកដ។

នៅពេលចុះកិច្ចសន្យា និយោជកត្រូវជូនដំណឹងទៅកម្មករនិយោជិតឱ្យបានយល់អំពីចំណុចសំខាន់ៗជាយថាហេតុ និងអំពីថិរវេលាប្រហាក់ប្រហែលនៃកិច្ចសន្យានោះ។

ចំពោះកិច្ចសន្យារបស់កម្មករនិយោជិតប្រចាំថ្ងៃ ឬប្រចាំម៉ោង សម្រាប់មុខរបរមួយ រយៈពេលខ្លី ដែលទទួលបានប្រាក់ឈ្នួលនៅចុងថ្ងៃ ចុងសប្តាហ៍ ឬចុងអឌ្ឍមាស[14] ក៏ត្រូវបានចាត់ទុកថាជាកិច្ចសន្យាដែលមានថេរវេលាកំណត់ដែរ។

[14] មាត្រា ៦៧ ចំណុចទី ៦ ច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧

## ក.២ ការផុតរលត់នៃកិច្ចសន្យាមានថិរវេលាកំណត់

កិច្ចសន្យាមានថិរវេលាកំណត់នេះ នឹងត្រូវផុតរលត់តាមធម្មតានៅពេលដល់ការកំណត់របស់វា ប៉ុន្តែកិច្ចសន្យានេះអាចរំលាយមុនកាលកំណត់បាន ប្រសិនបើភាគីទាំងសងខាងបានព្រមព្រៀងគ្នា ហើយការព្រមព្រៀងនេះត្រូវធ្វើជាលាយល័ក្ខអក្សរនៅចំពោះមុខអធិការការងារ និង ចុះហត្ថលេខាដោយភាគីទាំងពីរនៃកិច្ចសន្យាផងដែរ។ ប្រសិនបើគ្មានការព្រមព្រៀងគ្នារវាងភាគីទាំងសងខាងទេ កិច្ចសន្យានេះក៏អាចរំលាយមុនកាលកំណត់បានដែរ ក្នុងករណីដែលមានកំហុសធ្ងន់ ឬ ករណីប្រធានស័ក្តិ។

ចំពោះការរំលាយកិច្ចសន្យា ដោយឆន្ទៈរបស់និយោជកតែឯកឯងមុនកាលកំណត់ក្រៅពីមូលហេតុដែលបានកំណត់ខាងលើ កម្មករនិយោជិតមានសិទ្ធិទទួលបានសំណងជម្ងឺចិត្តដែលមានចំនួនយ៉ាងតិចស្មើនឹងប្រាក់ឈ្នួលដែលកម្មករនិយោជិត ត្រូវបានទទួលរហូតដល់ពេលចប់កិច្ចសន្យា។ ប៉ុន្តែប្រសិនបើការរំលាយកិច្ចសន្យានេះធ្វើឡើងដោយឆន្ទៈរបស់កម្មករនិយោជិតវិញ ហើយមូលហេតុនៃការរំលាយកិច្ចសន្យាផ្ទុយនឹងល័ក្ខខណ្ឌ ដែលបានកំណត់ខាងលើនោះនិយោជកក៏មានសិទ្ធិទទួលបានសំណងជម្ងឺចិត្តដូចគ្នា ដែលសំណងជម្ងឺចិត្តស្មើនឹងការខូចខាតរបស់ដែលបានផ្តល់ឱ្យកម្មករនិយោជិត[15]។

ក្នុងករណីដែលគ្មានការជូនដំណឹងមុនទេ កិច្ចសន្យាការងារនឹងនៅតែបន្តក្នុងថិរវេលា ស្មើគ្នានឹងថិរវេលាដែលបានចុះកិច្ចសន្យាកាលពីដំបូងដដែរ។

➢ **កាលបរិច្ឆេទនៃការកំណត់ថិរវេលាកិច្ចសន្យាការងារដែលត្រូវជូនដំណឹងជាមុន[16]**

| ថិរវេលានៃកិច្ចសន្យាការងារ | ការជូនដំណឹងមុននៃកិច្ចសន្យាការងារ |
|---|---|
| ៦ ខែ ឬតិចជាង | ០០ថ្ងៃ |
| ច្រើនជាង ៦ខែ | ១០ថ្ងៃ |
| ច្រើនជាង ១ឆ្នាំ | ១៥ថ្ងៃ |

[15] មាត្រា ៧៣ នៃច្បាប់ស្តីពីការងារ ឆ្នាំ ១៩៩៧

[16] មាត្រា ៧៥ នៃច្បាប់ស្តីពីការងារ ឆ្នាំ ១៩៩៧

នៅពេលបញ្ចប់កិច្ចសន្យាការងារ និយោជកត្រូវផ្តល់ឱ្យកម្មករនិយោជិតនូវប្រាក់បំណាច់បញ្ឈប់កិច្ចសន្យាដោយប្រាក់បំណាច់នោះត្រូវមានចំនួនសមាមាត្រទៅនឹងប្រាក់ឈ្នួលចិរវេលានៃកិច្ចសន្យាការងាររបស់កម្មករនិយោជិត ទៅតាមការកំណត់ក្នុងអនុសញ្ញារួម។ ក្នុងករណីពុំមានការកំណត់នៅក្នុងអនុសញ្ញារួមនោះទេ ប្រាក់បំណាច់នេះត្រូវមានចំនួនយ៉ាងតិចស្មើរនឹង ប្រាំភាគរយ (៥%) នៃប្រាក់ឈ្នួលដែលកម្មករនិយោជិតនោះដែលបានបើករយៈពេលនៃកិច្ចសន្យាការងារ[17]។ លើសពីនេះទៅទៀតកម្មករនិយោជិត ក៏អាចត្រូវឱ្យនិយោជកចេញនូវវិញ្ញាប័ត្រការងារដល់ខ្លួនបានដែរ ទោះបីក្នុងករណីនៃការរំលាយកិច្ចសន្យាការងារបែបណាក៏ដោយ[18]។

### ខ. កិច្ចសន្យាការងារមានចិរវេលាមិនកំណត់

កិច្ចសន្យាការងារមាចិរវេលាមិនកំណត់ គឺជាកិច្ចសន្យាដែលធ្វើឡើងដោយមាត់ទទេ ឬដោយលាយល័ក្ខអក្សរ ហើយអាចរំលាយដោយភាគីតែម្ខាងបាន[19]។ ទោះបីជាកិច្ចសន្យានេះគ្មានចិរវេលាកំណត់ក៏ដោយ ក៏កិច្ចសន្យានេះនៅតែមានល័ក្ខខ័ណ្ឌក្នុងការអនុវត្តដែរ ពោលគឺការចុះកិច្ចសន្យាសាកល្បងការងារ មិនអាចមានចិរវេលាលើសកាលបរិច្ឆេទចាំបាច់សម្រាប់ឱ្យនិយោជកវិនិច្ឆ័យវិជ្ជាជីវៈនៃកម្មករនិយោជិត និងកម្មករនិយោជិតដែលស្គាល់ជាក់លាក់នូវល័ក្ខខ័ណ្ឌនៃការងារដែលគេផ្តល់ឱ្យនោះឡើយ។

#### ខ.១ ការចុះកិច្ចសន្យាការងារសាកល្បង

ការចុះកិច្ចសន្យាការងារសាកល្បង គឺជារយៈពេលមួយដែលតម្រូវឱ្យនិយោជក និងកម្មករនិយោជិតបានស្វែងយល់ពីគ្នាទៅវិញទៅមក ក្នុងកំឡុងពេលនៃកាលបរិច្ឆេទដែលបានចុះក្នុងកិច្ចសន្យានោះ ហើយការចុះកិច្ចសន្យាសាកល្បងនេះក៏បានផ្តល់ផលប្រយោជន៍ដល់ភាគីទាំងសងខាង មិនថានិយោជក ឬកម្មករនិយោជិតនោះទេ ពោលចំពោះនិយោជក ការចុះកិច្ចសន្យាសាកល្បងបានផ្តល់ប្រយោជន៍ដល់ខ្លួនក្នុងការស្វែងយល់ ក៏ដូចជាសិក្សាឱ្យបានស៊ីជម្រៅអំពីសមត្ថភាពរបស់កម្មករនិយោជិតរបស់ខ្លួន ចំណែកឯនិយោជិតវិញ ការចុះកិច្ចសន្យាការងារសាកល្បងក៏បានផ្តល់ឱកាសឱ្យពួកគេបង្ហាញនូវសមត្ថភាព និងទទួលបានបទពិសោធន៍ក៏ដូចជាប្រាក់ឈ្នួលផងដែរ។

យ៉ាងណាមិញ ការចុះកិច្ចសន្យាការងារសាកល្បងនេះ ក៏មិនអាចលើសពីកាលបរិច្ឆេទខាងក្រោមនេះដូចខាងក្រោមនេះបានដែរ:

---

[17] មាត្រា ៧៣ កថាខណ្ឌ ៦ នៃច្បាប់ស្តីពីការងារ ឆ្នាំ ១៩៩៧

[18] មាត្រា ៧៣ កថាខណ្ឌ ៨ នៃច្បាប់ស្តីពីការងារ ឆ្នាំ ១៩៩៧

[19] មាត្រា ៧៤ កថាខណ្ឌ១ ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧

**ក.** ៣ខែ ចំពោះនិយោជិត

**ខ.** ២ខែ ចំពោះកម្មករឯកទេស

**គ.** ១ខែ ចំពោះកម្មករធម្មតា

ចំពោះសោហ៊ុយទៅមក របស់កម្មករនិយោជិតសាកល្បង ដែលត្រូវទៅធ្វើការឆ្ងាយពីលំនៅដ្ឋាន ធម្មតាត្រូវជាបន្ទុករបស់និយោជក។ សរុបមក យើងអាចធ្វើការសន្មតបានថា ការចុះកិច្ចសន្យាសាកល្បងការងារ ភាគីជាកម្មករនិយោជិតពុំមានជាប់កាតព្វកិច្ចក្នុងការបន្តទំនាក់ទំនងការងារនោះទេ ហេតុដូច្នេះហើយ ប្រសិនបើភាគីណាម្នាក់មិនពេញចិត្ត ពួកគេអាចធ្វើការបញ្ចាប់នូវទំនាកទំនងនោះបាន តាមរយៈការព្យួរកិច្ចសន្យា ឬការរំលាយកិច្ចសន្យា។

### ខ.២ ការព្យួរកិច្ចសន្យាការងារ

**ព្យួរ** គឺជាគឺជាការផ្អាកទុកមានកំណត់កាល ហេតុដូច្នេះនៅក្នុងន័យនេះការព្យួរកិច្ចសន្យាការងារសំដៅទៅលើការបញ្ឈប់ជាបណ្ដោះអាសន្ននៃកិច្ចសន្យាការងារ ប៉ុន្តែកិច្ចសន្យានេះនៅតែមានសុពលភាពដដែល គ្រាន់តែវាមិនត្រូវបានផ្អាកជាបណ្ដោះអាសន្នតែប៉ណ្ណោះ។ ក្រោយពីកាលបរិច្ឆេទនៃការព្យួរកិច្ចសន្យាការងារត្រូវបានបញ្ចប់ កម្មករនិយោជិត ឬនិយោជកមានសិទ្ធិត្រឡប់ទៅរកមុខងាររបស់ខ្លួនវិញដោយពុំមានការហាមឃាត់ណាមួយឡើយ។ ប៉ុន្តែការព្យួរកិច្ចសន្យាការងារចាំបាច់ត្រូវតែមានការកំណត់ ឬបញ្ជាក់ឱ្យបានច្បាស់លាស់អំពីមូលហេតុដែលខ្លួនសុំព្យួរកិច្ចសន្យាការងារក្នុងចិរវេលាណាមួយឱ្យបានត្រឹមត្រូវនឹងច្បាស់លាស់ ដោយមូលហេតុនៃការព្យួរកិច្ចសន្យានេះមានកំណត់ដូចខាងក្រោម:[20]

១. ការបិទគ្រឹះស្ថាន ដោយហេតុនិយោជកត្រូវបំពេញកាតព្វកិច្ចការពារមាតុភូមិ និងក្នុងរយៈពេលជាកាតព្វកិច្ចត្រូវរៀនវិជ្ជាយោធា។

២. អវត្តមាននៃកម្មករនិយោជិត ក្នុងពេលត្រូវបំពេញកាតព្វកិច្ចមាតុភូមិ និងក្នុងរយៈពេលជាកាតព្វកិច្ចត្រូវរៀនវិជ្ជាយោធា។

៣. អវត្តមាននៃកម្មករនិយោជិតក្នុងករណីមានជម្ងឺ ដែលមានគ្រូពេទ្យផ្លូវការបានបញ្ជាក់ត្រឹមត្រូវ។ ចិរវេលាអវត្តមាននោះត្រូវកំណត់ត្រឹមរយៈពេលមួយខែប៉ុន្តែអាចពន្យារហូតដល់មានអ្នកជំនួស។

៤. ពេលអាក់ខានធ្វើការដោយហេតុមានគ្រោះថ្នាក់ការងារ ឬមានជម្ងឺវិជ្ជាជីវៈ។

[20] មាត្រា ៧១ ច្បាប់ស្តីពីការងារ ឆ្នាំ ១៩៩៧

៥. ការឈប់សម្រាកដែលបានអនុញ្ញាតឱ្យស្ត្រីជាកម្មករនិយោជិត ក្នុងឱកាសមានគភ៌ និងសម្រាលកូន ព្រមទាំងមានជម្ងឺដែលបណ្តាលមកពីកាសម្រាលកូន។

៦. អវត្តមាននៃកម្មករនិយោជិត ដែលនិយោជកបានអនុញ្ញាតាមច្បាប់ តាមការព្រមព្រៀងរួម ឬការយល់ព្រមរៀងខ្លួន។

៧. ការបញ្ឈប់កម្មករនិយោជិតក្នុងមួយរយៈ ដោយមានមូលហេតុសមស្របតាមបទបញ្ជាផ្ទៃក្នុង។

៨. អវត្តមានកម្មករនិយោជិតក្នុងឱកាសឈប់សម្រាកដោយមានប្រាក់ឈ្នួលដោយគិតបន្ថែមទាំងថិរវេលាធ្វើដំណើរជាយថាហេតុផង។

៩. ការឃាត់ខ្លួននៃកម្មករនិយោជិត ដែលមិនបណ្តាលឱ្យជាប់ពិរុទ្ធ។

១០. ប្រធានសក្តិដែលបណ្តាលឱ្យភាគីណាមួយបំពេញកាតព្វកិច្ចមិនបានក្នុងរយៈពេលមិនលើសពីបីខែ។

១១. ពេលដែលសហគ្រាសជួបការលំបាកផ្នែកសេដ្ឋកិច្ច ឬសម្ភារៈ ធ្ងន់ធ្ងរ ឬការលំបាកជាពិសេសណាមួយ ដែលនាំឱ្យព្យួរសកម្មភាពសហគ្រាសមិនលើពី ពីរខែ។ ការព្យួរសកម្មភាពនេះត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អធិការការងារ។

យ៉ាងណាមិញការព្យួរកិច្ចសន្យាការងារ ក៏បានជះឥទ្ធិពលមកលើនិយោជកនិងកម្មករនិយោជិតផងដែរ។ ចំពោះនិយោជក នៅពេលមានកម្មករនិយោជិតព្យួរការងារ នោះនិយោជកពុំចាំបាច់បើកប្រាក់ឈ្នួលឱ្យកម្មកររបស់ខ្លួនទេ លើកលែងតែមានបទប្បញ្ញត្តិណាមួយបានចែងដាក់លាក់នៅក្នុងកិច្ចសន្យាការងាររវាងនិយោជក និងកម្មករនិយោជិតនោះ[21]។ ចំណែកឯកម្មករនិយោជិតវិញ រាល់ការព្យួរកិច្ចសន្យាការងាររបស់ខ្លួន ហើយត្រឡប់ចូលបម្រើការងារវិញ នោះកិច្ចសន្យាការងាររបស់កម្មករនិយោជិត នៅតែបន្តគិតចាប់ពីអតីតភាពការងាររបស់កម្មកនិយោជិតនោះដដែល លើកលែងតែមានបញ្ញត្តិចែងផ្ទុយពីនេះ។

## ខ.៣ ការរំលាយកិច្ចសន្យាការងារដែលមានថិរវេលាមិនកំណត់

ការរំលាយកិច្ចសន្យាការងារដែលមានថេរវេលាមិនកំណត់ អាចធ្វើទៅបានទៅតាមឆន្ទៈរបស់ភាគីតែម្ខាងបាន ប៉ុន្តែការរំលាយកិច្ចសន្យានេះត្រូវធ្វើឡើងជាលាយល័ក្ខអក្សរ និងមានការដឹងឮជាមុនដោយភាគីដែលមានបំណងចង់រំលាយកិច្ចសន្យា ទៅភាគីម្ខាងទៀតនៃកិច្ចសន្យា។ ផ្ទុយទៅវិញ

[21] មាត្រា ៧២ កថាខណ្ឌ១ ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧

ការរំលាយកិច្ចសន្យានេះ ក៏មិនអាចធ្វើឡើងដោយគ្មានទឡ្ហីករណ៍ណាមួយច្បាស់លាស់ឡើយលុះត្រាតែភាគីដែលមានបំណងចង់រំលាយនោះ មានមូលហេតុត្រឹមត្រូវ និងច្បាស់លាស់ ចំពោះកម្មករនិយោជិតនោះដោយយោងទៅលើភាពចាំបាច់នៃដំណើររបស់សហគ្រាស គ្រឹះស្ថាន ឬក្រុមហ៊ុនរបស់ខ្លួន។

រាល់ការរំលាយកិច្ចសន្យាមានថិរវេលាមិនកំណត់នេះ ភាគីដែលមានបំណងចង់រំលាយកិច្ចសន្យាមានកាតព្វកិច្ចជូនដំណឹងជាមុនទៅដល់ភាគីម្ខាងទៀត នូវការរំលាយនោះ បើទោះបីជាភាគីដែលចង់រំលាយនោះជានិយោជក ឬកម្មករនិយោជិតក៏ដោយ។

➢ **ថិរវេលាអប្បបរិមាក្នុងការជូនដំណឹងជាមុន នៃការបញ្ចប់កិច្ចសន្យាការងារ[22]៖**

| ថិរវេលានៃការកិច្ចសន្យាការងារ | ការជូនដំណឹងជាមុន |
|---|---|
| • តិចជាង ៦ខែ | ៧ថ្ងៃ |
| • ពី៦ខែរហូតដល់២ឆ្នាំ | ១៥ថ្ងៃ |
| • លើសពី២ឆ្នាំរហូតដល់៥ឆ្នាំ | ១ខែ |
| • លើសពី៥ឆ្នាំរហូតដល់១០ឆ្នាំ | ២ខែ |
| • លើសពី១០ឆ្នាំ | ៣ខែ |

ប្រសិនបើនិយោជកធ្វើការរំលាយកិច្ចសន្យាដោយឯកឯង ដោយគ្មានការជូនដំណឹងជាមុនទេ និយោជកតម្រូវឱ្យចេញប្រាក់ទូទាត់ ដល់កម្មករនិយោជិត ដែលមានចំនួនស្មើនឹងប្រាក់ឈ្នួលនឹងអត្ថប្រយោជន៍ផ្សេងៗដែលកម្មករនិយោជិត ត្រូវទទួលបានក្នុងរយៈពេលឱ្យដំណឹងមុន[23]។

យ៉ាងណាមិញ ការរំលាយកិច្ចសន្យានេះ ក៏អាចធ្វើដោយពុំចាំបាច់ជូនដំណឹងជាមុនក៏បានដែរ ក្នុងករណីដូចខាងក្រោម៖

➢ ករណីចូលធ្វើការសាកល្បង ឬកម្មសិក្សាដែលមានចែងនៅក្នុងកិច្ចសន្យា

➢ ករណីដែលមានកំហុសធ្ងន់ធ្ងរនៃភាគីណាមួយ

[22] មាត្រា ៧៥ នៃច្បាប់ស្តីពីការងារ ឆ្នាំ ១៩៩៧

[23] មាត្រា ៧៥ នៃច្បាប់ស្តីពីការងារ ឆ្នាំ ១៩៩៧

- ករណីប្រធានស័ក្តិដែលភាគីម្ខាងមិនអាចគោរពកិច្ចសន្យាបានតទៅទៀត
- ករណីនិយោជកគ្មានលទ្ធភាពក្នុងការបំពេញខសន្យា:
  - ការតម្រូវឱ្យបិទទ្វារសហគ្រាស គ្រឹះស្ថាន ឬក្រុមហ៊ុនដោយរាជការសាធារណ:
  - មហន្តរាយ ទឹកជំនន់ រញ្ជួយដី សង្គ្រាម ដែលបណ្តាលឱ្យអន្តរាយដល់សម្ភារ:មិនអាចបន្តការងារអស់រយ:ពេលយ៉ាងយូរ។
  - មរណ:ភាពនៃនិយោជក ដែលបណ្តាលឱ្យបិទទ្វារគ្រឹះស្ថានបើកសិទ្ធិឱ្យកម្មករនិយោជិតទទួលបានប្រាក់បំណាច់ស្មើនឹងរយ:ពេលឱ្យដំណឹងមុន។
- ករណីកម្មករនិយោជិតដែលគ្មានលទ្ធភាពក្នុងការបំពេញខសន្យា:
  - ជំងឺរុំារ៉ៃ វិកលចរិត ភាពពិការជានិច្ច និងការផ្តន្ទាទោសដាក់ពន្ធនាគារ។

ក្នុងករណីនេះនិយោជកមិនអាចរួចផុតពីកាតព្វកិច្ចដែលត្រូវ ឱ្យដំណឹងមុនពេលបញ្ឈប់នោះទេ។

## ផ្នែកទី ២ ការចុះបញ្ជិកា និងបែបបទនៃការបង់ភាគទាន

អនុឡោមតាមច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីទទួលបានអាជ្ញាប័ណ្ណក្នុងការបើកសហគ្រាស គ្រឹះស្ថាន ឱ្យត្រឹមត្រូវនិងស្របច្បាប់ និយោជកចាំបាច់ត្រូវធ្វើការចុះបញ្ជិកាទៅតាមគោលការណ៍គតិយុត្តដូចបានបញ្ញត្តិនៅក្នុងច្បាប់។ ហេតុដូច្នេះហើយ និយោជក ក៏ដូចជាម្ចាស់សហគ្រាស ឬ គ្រឹះស្ថានដែលស្ថិតក្រោមដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយណាដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ មានកាតព្វកិច្ចចុះបញ្ជិកាសហគ្រាស គ្រឹះស្ថានរបស់ខ្លួន នៅបេឡាជាតិរបបសន្តិសុខសង្គមមុនពេលប្រកាសបើកសហគ្រាស និងគ្រឹះស្ថានរបស់ខ្លួនជាស្ថាពរ [24] ។ ការចុះបញ្ជិកានេះមិនមែនមានត្រឹមតែការចុះបញ្ជិកាសហគ្រាស និងគ្រឹះស្ថាន (**កថាខណ្ឌ១**) តែប៉ុណ្ណោះទេ។ ប៉ុន្តែនៅក្នុងនោះក៏មានការចុះបញ្ជិការបស់កម្មករនិយោជិត (**កថាខណ្ឌ២**) ផងដែរ។

### កថាខណ្ឌ ១ បញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត

ការចុះបញ្ជិកាត្រូវបានបែងចែកជាពីរ គឺបញ្ជិកាសហគ្រាស ឬ គ្រឹះស្ថាន និង បញ្ជិកាកម្មករនិយោជិត។ ការចុះបញ្ជិកាទាំងពីរខាងលើនេះ មានគោលការណ៍ និង បែបបទនៃការប្រព្រឹត្តទៅខុសៗគ្នាដោយក្រុមយើងខ្ញុំនឹងលើកយកមកបកស្រាយនៅខាងក្រោមនេះ។

[24] ប្រការ១ នៃប្រកាសលេខ ០២១/០៨ កប/ប្រក ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត

### ក. យន្តការនៃការចុះបញ្ជិកា

ចំពោះបែបបទនៃការចុះបញ្ជិកាវិញ ក៏ត្រូវបានធ្វើការបែងចែកជាពីរផ្សេងគ្នាដូចទៅនឹងថេរវេលានៃការចុះបញ្ជិកាផងដែរ គឺបែបបទនៃចុះបញ្ជិការបស់សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត។

#### ក.១ ការចុះបញ្ជិការបស់សហគ្រាស គ្រឹះស្ថាន

បែបបទនៃកាចុះបញ្ជិការបស់សហគ្រាស គ្រឹះស្ថាន ត្រូវបានធ្វើឡើងទៅតាមទម្រង់ បញ្ជិកាសហគ្រាស គ្រឹះស្ថាន ឬហៅថា**ទម្រង់ ១.០១** ដូចបានចែងនៅក្នុង**ឧបសម្ព័ន្ធ១** នៃប្រកាសលេខ ០២១/០៨កប-ប្រក ដែលចេញដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និង កម្មករនិយោជិត ក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ។ និយោជក ឬ ម្ចាស់សហគ្រាសក៏ត្រូវផ្ញើរភ្ជាប់មកជាមួយនឹង **ទម្រង់ ១.០១** នូវ**បញ្ជិកាពាណិជ្ជកម្ម** ដែលចេញដោយក្រសួងពាណិជ្ជកម្ម ឬ លិខិតតុបករណ៍គតិយុត្តសមមូលដទៃទៀត[25]។ ចំពោះទម្រង់បញ្ជិកាកម្មករនិយោជិត ដែលត្រូវផ្ញើជូនបេឡាជាតិរបបសន្តិសុខសង្គមអាចធ្វើបានតាមទម្រង់ពីរ គឺ**ទម្រង់ក្រដាស** ឬ **ទម្រង់អេឡិចត្រូនិច** ដោយមានលិខិតបញ្ជូនដែលចុះហត្ថលេខាដោយនាយក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាននោះ[26]។

បន្ទាប់ពីទទួលបាននូវទម្រង់ នៃការស្នើសុំចុះ បញ្ជិកាសហគ្រាស គ្រឹះស្ថាន រួចមកបេឡាជាតិរបបសន្តិសុខសង្គម ត្រូវផ្តល់លេខអត្តសញ្ញាណសម្រាប់សហគ្រាស គ្រឹះស្ថាននីមួយៗ ដោយក្នុងនោះសហគ្រាស គ្រឹះស្ថានមួយត្រូវទទួលបានតែលេខអត្តសញ្ញាណតែមួយប៉ុណ្ណោះ ដែលត្រូវបានគេឱ្យឈ្មោះថា **អត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន**[27]។

ក្រោយពីផ្តល់នូវ **អត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន** រួចមកបេឡាជាតិរបបសន្តិសុខសង្គមត្រូវផ្តល់ **វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន** ជូនទៅដល់សហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជិការ រួច។ វិញ្ញាបនបត្រនេះ ចាំបាច់ត្រូវមានចុះលេខអត្តសញ្ញាណ សហគ្រាស គ្រឹះស្ថាន និងកាលបរិច្ឆេទចុះបញ្ជិកា[28]។

[25] ប្រការ៣ កថាខណ្ឌ១ នៃប្រកាសលេខ០២១/០៨កប/ប្រក របស់ក្រសួងការងារនិងបណ្តុលបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី១១ កុម្ភៈ ២០០៨ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម

[26] ប្រការ៥ កថាខណ្ឌ២ នៃប្រកាសលេខ ០២១/០៨ កប/ប្រក ស្តីពីបញ្ជិកាសហគ្រាស គ្រិះស្ថាន និងកម្មករនិយោជិត

[27] ប្រការ៤ កថខណ្ឌ១ នៃប្រកាសលេខ ០២១/០៨ កប/ប្រក ស្តីពីបញ្ជិកាសហគ្រាស គ្រិះស្ថាន និងកម្មករនិយោជិត

[28] ប្រការ៤ កថខណ្ឌ២ នៃប្រកាសលេខ ០២១/០៨ កប/ប្រក ស្តីពីបញ្ជិកាសហគ្រាស គ្រិះស្ថាន និងកម្មករនិយោជិត

បន្ទាប់ពីទទួលបានវិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន និយោជកត្រូវដាក់តាំងវិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាននោះ នៅនឹងការិយាល័យបើកប្រាក់ឈ្នួលរបស់សហគ្រាស គ្រឹះស្ថាននោះ។ លើសពីនេះទៅទៀត ជារៀងរាល់ខែ និយោជកដែលនាយក ឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវផ្ញើរបាយការណ៍អំពីចំនួនកម្មករនិយោជិត ដើម្បីផ្ដល់ពត៌មានបន្ថែមអំពីការកើនឡើង ឬ ការធ្លាក់ចុះនៃចំនួនកម្មករនិយោជិតនៅក្នុងសហគ្រាស គ្រឹះស្ថានរបស់ខ្លួនទៅបេឡាជាតិរបបសន្តិសុខសង្គមឱ្យបានមុន ថ្ងៃទី ១៥ នៃខែបន្ទាប់។ ដោយរបាយការណ៍នេះ ត្រូវធ្វើឡើងដូចគ្នាទៅនឹងទម្រង់បញ្ជិកាកម្មករនិយោជិតដែរ ពោលគឺធ្វើឡើងតាមទម្រង់ក្រដាស ឬអេឡិចត្រូនិច និងភ្ជាប់ជាមួយលិខិតបញ្ជូនដែលចុះហត្ថលេខាដោយនាយក ឬម្ចាស់សហគ្រាស គ្រឹះស្ថាននោះ[29]។

### ក.២ ការចុះបញ្ជិការបស់កម្មករនិយោជិត

ការចុះបញ្ជិកាកម្មករនិយោជិត ត្រូវធ្វើឡើងតាមរយៈនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានរបស់ខ្លួនដោយនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងនោះត្រូវផ្ញើបញ្ជីឈ្មោះកម្មករនិយោជិតនៅក្នុងសហគ្រាស គ្រឹះស្ថានរបស់ខ្លួនទៅបេឡាជាតិរបបសន្តិសុខសង្គម ក្នុងពេលជំណាលគ្នានិងការផ្ញើទម្រង់បញ្ជិកាសហគ្រាស គ្រឹះស្ថាន ដើម្បីចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម[30]។

ការចុះបញ្ជិកាកម្មករនិយោជិត ត្រូវធ្វើឡើងតាមទម្រង់ បញ្ជិកាកម្មករនិយោជិត ឬហៅថាទម្រង់ **១.០២** ដែលមាននៅក្នុង**ឧបសម្ព័ន្ធ ២**នៃប្រកាសស្ដីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម។ ចំពោះទម្រង់បញ្ជិកាកម្មករនិយោជិតដែលត្រូវផ្ញើជូនបេឡាជាតិរបបសន្តិសុខសង្គមនេះ អាចធ្វើតាម **ទម្រង់ក្រដាស** ឬ **ទម្រង់អេឡិចត្រូនិច** ដូចទៅនឹងទម្រង់បញ្ជិការបស់សហគ្រាស គ្រឹះស្ថាន ដោយទម្រង់បញ្ជិកាកម្មករនិយោជិតនេះត្រូវមានលិខិតបញ្ជូនដែលចុះហត្ថលេខានាយក ឬម្ចាស់សហគ្រាស គ្រឹះស្ថានផងដែរ[31]។

បន្ទាប់ពីទទួលបាននូវទម្រង់បញ្ជិកាកម្មករនិយោជិតរួចមក បេឡាជាតិរបបសន្តិសុខសង្គមត្រូវផ្ដល់**លេខអត្តសញ្ញាណ** និងចេញ**ប័ណ្ណធានារ៉ាប់រងហានិភ័យការងារ** ជូនទៅកម្មករនិយោជិតម្នាក់ៗដោយឥតគិតថ្លៃ។ ចំពោះការប្រគល់នូវប័ណ្ណធានារ៉ាប់រងហានិភ័យការងារត្រូវធ្វើឡើងតាមរយៈនិយោជកនៃសហគ្រាស គ្រឹះស្ថានរបស់កម្មករនិយោជិតទាំងនោះ[32]។

---

[29] ប្រការ៥ កថាខណ្ឌ២ នៃប្រកាសលេខ ០២១/០៨ កប/ប្រក ស្ដីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត

[30] ប្រការ២ នៃប្រកាសលេខ ០២១/០៨ កប/ប្រក ស្ដីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត

[31] ប្រការ៣ កថាខណ្ឌណ២ នៃប្រកាសលេខ ០២១/០៨ កប/ប្រក ស្ដីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត

[32] ប្រការ៤ កថាខណ្ឌ៣ នៃប្រកាសលេខ ០២១/០៨ កប/ប្រក ស្ដីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត

ក្នុងករណីដែលប័ណ្ណធានារ៉ាប់រង ខូច ឬ បាត់បង់ សាមីជនដែលជាម្ចាស់ប័ណ្ណត្រូវធ្វើការជូនដំណឹងជាបន្ទាន់ទៅនិយោជក និងត្រូវស្នើសុំទុតិយកា ក្នុងរយៈពេលយ៉ាងយូរ **៣០ ថ្ងៃ** បន្ទាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងខាងលើ។ ការផ្តល់ប័ណ្ណទុតិយកាថ្មីនេះ តម្រូវឱ្យសាមីជនបង់ប្រាក់ជូនទៅបេឡាជាតិរបបសន្តិសុខសង្គម[33]។

**ខ. លក្ខខណ្ឌនៃការចុះបញ្ជិការបស់សហគ្រាស គ្រឹះស្ថាន**

ការអនុវត្តផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម ដូចមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយណា ដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារត្រូវកំណត់ដូចក្រោម៖

- របបធានារ៉ាប់រងហានិភ័យការងារត្រូវចាប់ផ្តើមអនុវត្តនៅឆ្នាំ **២០០៨**
- ចំពោះរបបធានារ៉ាប់រង ផ្នែកសុខភាព និងផ្នែកប្រាក់សោធន នឹងត្រូវកំណត់ជាបន្តបន្ទាប់នៅពេលក្រោយ[34]។

នៅក្នុងដំណាក់កាលនៃការចាប់ផ្តើមដំបូងនៃផ្នែកធានារ៉ាប់រងហានិភ័យការងារត្រូវអនុវត្តចំពោះតែសហគ្រាស គ្រឹះស្ថានទាំងឡាយណាដែលមានកម្មករនិយោជិត **០៨នាក់** ឡើងទៅ។

ចំពោះសហគ្រាស គ្រឹះស្ថានផ្សេងពីនេះ ត្រូវបន្តអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងាររហូតដល់មានការកំណត់ថ្មី[35]។

សរុបមករាល់សហគ្រាស គ្រឹះស្ថានទាំងឡាយណាដែលដែលស្ថិតក្រោមដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយណាដែលស្ថិតក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារត្រូវមានកាតព្វកិច្ចចុះបញ្ជិកានៅបេឡាជាតិរបបសន្តិសុខសង្គម មិនថាសហគ្រាស គ្រឹះស្ថាននោះជាប្រភេទឧស្សាហកម្ម រ៉ែ ពាណិជ្ជកម្ម សិប្បកម្ម សេវា កសិកម្ម ដឹកជញ្ជូនតាមផ្លូវគោក ឬតាមផ្លូវទឹក ទោះជាប្រយោជន៍សាធារណៈ ពាក់កណ្តាលសាធារណៈឬឯកជន ក្រៅសាសនាក៏ដោយ ទោះមានលក្ខណៈជាការបង្រៀនវិជ្ជាជីវៈ ឬជាកុសលក៏ដោយ ព្រមទាំងវិជ្ជាជីវៈសេរីនៃសមាគម

[33] ប្រការ៤ កថាខណ្ឌ ៤ នៃប្រកាសលេខ ០២១/០៨ កប/ប្រក ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត

[34] ប្រការ១ នៃប្រកាសលេខ០២២ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីដំណាក់កាល និងវិសាលភាពនៃការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ

[35] ប្រការ២ នៃប្រកាសលេខ០២២ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីដំណាក់កាល និងវិសាលភាពនៃការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងា

ឬក្រុមហ៊ុនប្រភេទណាក៏ដោយ ត្រូវស្ថិតក្រោមវិសាលភាពនៃការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងាររបស់បេឡាជាតិរបបសន្តិសុខសង្គមទាំងអស់[36]។

### គ. លក្ខខណ្ឌនៃការចុះបញ្ជិការបស់កម្មករនិយោជិត

ចំពោះកម្មករនិយោជិត ការចុះបញ្ជិកានៅក្នុងបេឡាជាតិរបបសន្តិសុខសង្គម គឺមិនត្រូវបានគេបែងចែកពូជសាសន៍ ពណ៌សម្បុរ ភេទ ជំនឿ សាសនា អ្វីនោះឡើយ គឺរាល់កម្មករនិយោជិតទាំងអស់អាចចុះបញ្ជិកានៅក្នុងបេឡាជាតិរបបសន្តិសុខសង្គមបានគឺមានដូចខាងក្រោមៈ

- កម្មករនិយោជិតទាំងឡាយណា ដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារហើយធ្វើការងារនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីជាប្រយោជន៍ទៅដល់និយោជកម្នាក់ឬច្រើននាក់ដោយមិនគិតពីប្រភេទ ឬចំនួននៃប្រាក់ឈ្នួលដែលជននោះទទួលបានឡើយ[37]។
- កម្មករនិយោជិតរបស់រដ្ឋ កម្មករនិយោជិតនៃអង្គការសាធារណៈ និងបុគ្គលិកទាំងអស់ដែលមិនស្ថិតក្រោមការគ្រប់គ្រង ដោយច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល លក្ខន្តិកៈទូតឬភ្នាក់ងារ រាជការសាធារណៈដែលតែងតាំងជាបណ្តោះអាសន្ន។
- សិស្សសាលាវិជ្ជាជីវៈ និងជនដែលត្រូវបានគេដាក់ឱ្យធ្វើការក្នុងមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ សម្របសម្រួល និងការអប់រំវិជ្ជាជីវៈឡើងវិញ នៅក្នុងនោះកូនជាងក៏ត្រូវបានគេចាត់ទុកជា កម្មករនិយោជិតផងដែរ។
- ជនទាំងឡាយណាដែលប្រកបរបរវិជ្ជាជីវៈសេរី ត្រូវកំណត់ដោយប្រកាសនៃរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម។
- កម្មករនិយោជិតទាំងឡាយណាដែលធ្វើការ ម្តងម្កាល ឬតាមរដូវ។

### ឃ. កាលបរិច្ឆេទនៃការចុះបញ្ជិកា

កាលបរិច្ឆេទនៃការចុះបញ្ជិកាត្រូវបានបែងចែកជាពីរដាច់ដោយឡែកទៅតាមបញ្ជិកាសហគ្រាសគ្រឹះស្ថាន និងកម្មកនិយោជិត។

#### ឃ.១ ថិរវេលានៃការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន

ក្រឡេកទៅមើលវិស័យការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា យើងសង្កេតឃើញថា សហគ្រាសគ្រឹះស្ថាន ដែលកំពុងតែរីកដុលដាលនាពេលបច្ចុប្បន្នគឺមានទម្រង់ខុសៗគ្នាជាច្រើន ទោះជាយ៉ាង

[36] មាត្រា ១ នៃច្បាប់ស្តីពីការងារ ឆ្នាំ ១៩៩៧

[37] មាត្រា ៣ នៃច្បាប់ស្តីពីការងារ ឆ្នាំ ១៩៩៧

ណាក៏ដោយ ក្រសួងទទួលបន្ទុកការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏បានធ្វើការកំណត់យ៉ាងច្បាស់លាស់នូវរយៈពេលនៃការចុះបញ្ជិការបស់ សហគ្រាស គ្រឹះស្ថានផងដែរ៖

- ចំពោះសហគ្រាស គ្រឹះស្ថានដែលកំពុងដំណើរ ត្រូវមកចុះបញ្ជិកាក្នុងរយៈពេលយ៉ាងយូរ **៤៥ ថ្ងៃ** បន្ទាប់ពីប្រកាសនេះចូលជាធរមាន។
- ចំពោះសហគ្រាស គ្រឹះស្ថានដែលបើកដំណើរការក្រោយកាលបរិច្ឆេទចូលជាធរមាននៃប្រកាសនេះត្រូវមកចុះបញ្ជិកាក្នុងរយៈពេលយ៉ាងយូរ **៤៥ ថ្ងៃ** បន្ទាប់ពីកាលបរិច្ឆេទនៃការចាប់ផ្តើមបើកសហគ្រាស គ្រឹះស្ថានជាស្ថាពរ[38]។

### ឃ.២ ថិរវេលានៃការចុះបញ្ជិការបស់កម្មករនិយោជិត

ចំពោះការចុះបញ្ជិការបស់កម្មករនិយោជិត គឺត្រូវធ្វើឡើងតាមរយៈនិយោជក ឬម្ចាស់សហគ្រាសដែលកម្មករនិយោជិតទាំងនោះបម្រើការងារឱ្យ ដោយនិយោជក ឬ ម្ចាស់សហគ្រាសត្រូវធ្វើបញ្ជីឈ្មោះកម្មករនិយោជិតនៅក្នុងសហគ្រាសរបស់ខ្លួន មកបេឡាជាតិរបបសន្តិសុខសង្គម ដើម្បីចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម។

ការធ្វើបញ្ជីឈ្មោះកម្មករនិយោជិត ត្រូវធ្វើដំណាលគ្នានឹងការធ្វើទម្រង់បញ្ជិការបស់សហគ្រាស គ្រឹះស្ថានដូចបានកំណត់ខាងក្រោម[39]៖

- ចំពោះសហគ្រាស គ្រឹះស្ថានដែលកំពុងដំណើរ ត្រូវធ្វើបញ្ជីឈ្មោះកម្មករនិយោជិតរបស់ខ្លួនក្នុងរយៈពេលយ៉ាងយូរ **៤៥ ថ្ងៃ** បន្ទាប់ពីប្រកាសនេះចូលជាធរមាន។
- ចំពោះសហគ្រាស គ្រឹះស្ថាន ដែលបើកដំណើរការក្រោយកាលបរិច្ឆេទចូលជាធរមាននៃប្រកាសនេះ ត្រូវធ្វើបញ្ជីឈ្មោះកម្មករនិយោជិតរបស់ខ្លួនក្នុងរយៈពេលយ៉ាងយូរ **៤៥ ថ្ងៃ** បន្ទាប់ពីកាលបរិច្ឆេទនៃការចាប់ផ្តើមបើកសហគ្រាស គ្រឹះស្ថានជាស្ថាពរ។

## កថាខណ្ឌ ២ ការកំណត់អត្រាភាគទាន និងការបង់ភាគទាន

ការកំណត់នូវអត្រាភាគទាន និងការបង់ភាគទាន គឺជាកត្តាដ៏សំខាន់ដែលនិយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថានចាំបាច់ត្រូវដឹងមុននឹងធ្វើការអនុវត្តនូវការបង់ភាគទាន។ ហេតុដូច្នេះហើយ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវស្គាល់ឱ្យបាច្បាស់ពីទំហំនៃការទទួលខុសត្រូវរបស់ខ្លួន

[38] ប្រការ១ កថាខណ្ឌ២ នៃប្រកាសលេខ ០២១/០៨ កប/ប្រក ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត
[39] ប្រការ២ កថាខណ្ឌ២ នៃប្រកាសលេខ ០២១/០៨ កប/ប្រក ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត

ចំពោះការបង់ភាគទាន ថាតើពួកគាត់មានការទទួលខុសត្រូវត្រឹមកម្រិតណា? ហើយថាតើ ពួកគាត់ត្រូវធ្វើអ្វីខ្លះ ដើម្បីឱ្យការបង់ភាគទាននេះមានការប្រព្រឹត្តទៅត្រឹមត្រូវទៅតាមគោលការណ៍ដែលច្បាប់បានកំណត់?

ដើម្បីឱ្យកាន់តែច្បាស់អំពីការកំណត់អត្រាភាគទាន និងការបង់ភាគទាន ក៏ដូចជាបញ្ហាខាងលើ យើងខ្ញុំសូមធ្វើការលើកយក បីចំណុចសំខាន់ៗមកធ្វើកាបកស្រាយ ដែលចំណុចទាំងអស់នោះរួមមាន៖ កាតព្វកិច្ចបង់ភាគទាន (១) រយៈពេលនៃការបង់ភាគទាន (២) បែបបទនៃការបង់ភាគទាន (៣) ។

### ក. កាតព្វកិច្ចបង់ភាគទាន

ដើម្បីឱ្យបេឡាជាតិរបបសន្តិសុខសង្គមដំណើរការទៅមុខបានយ៉ាងល្អប្រសើរ ការជួយទំនុកបម្រុងពីសំណាក់រាជរដ្ឋាភិបាលគឺជាកត្តាចម្បងសម្រាប់ទ្រទ្រង់នូវប្រព័ន្ធហិរញ្ញវត្ថុ ព្រមទាំងដំណើរការនៃបេឡាជាតិរបបសន្តិសុខទាំងមូល។ លើសពីនេះទៅទៀតការបង់ភាគទានពីសំណាក់និយោជក ក៏ជាកត្តាចម្បងដូចគ្នាក្នុងការជួយទ្រទ្រង់ ក៏ដូចជាឧបត្ថម្ភដល់បេឡាជាតិរបបសន្តិសុខសង្គមក្នុងគោលដៅផ្តល់ជាប្រយោជន៍ដល់កម្មករនិយោជិតផងដែរ។

ការបង់ភាគទានត្រូវអនុវត្តតាមប្រកាសស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ ដែលក្នុងនោះ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ដែលស្ថិតក្រោមច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតក្រោមច្បាប់ការងារ បានចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម និងមានកម្មករនិយោជិតចាប់ពី **៨ នាក់** ឡើងទៅត្រូវមានកាតព្វកិច្ចបង់ភាគទានផ្នែកហានិភ័យការងារជូនដល់បេឡាជាតិរបបសន្តិសុខសង្គម[40]។

ភាគទានផ្នែកហានិភ័យការងារ គឺជាកាព្វកិច្ចដោយឡែករបស់និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន។ ចំនែកឯ កម្មករនិយោជិត មិនតម្រូវឱ្យមានកាតព្វកិច្ចបង់ភាគទានផ្នែកនេះទេ។

### ខ. ការកំណត់អត្រាបង់ភាគទានរបស់សហគ្រាស គ្រឹះស្ថាន

ចំពោះអត្រាបង់ភាគទានផ្នែកហានិភ័យការងារវិញ ត្រូវបានកំណត់ជាអត្រាឯកភាពដែលត្រូវស្មើនឹង **០.៨ ភាគរយ** នៃប្រាក់ឈ្នួលមធ្យមក្នុងលំដាប់ថ្នាក់នៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករ

[40] ប្រការ ១ នៃប្រកាសលេខ ១០៨ កប/ប្រក ស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ

និយោជិត[41]។ ក្នុងករណីដែល សហគ្រាស គ្រឹះស្ថាន បើកប្រាក់ឈ្នួលជារូបិយប័ណ្ណបរទេស អត្រានៃប្រាក់ឈ្នួលមធ្យមខាងលើត្រូវទូទាត់ទៅ តាមអត្រាប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជាអត្រាភាគទានត្រូវកំណត់ជាថ្មីដោយប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទៅតាមស្ថានភាពជាក់ស្តែងនៃការបម្រែបម្រួលវិស័យឧស្សាហកម្មនៅកម្ពុជា និង ទៅតាមចំណាត់ថ្នាក់ឧស្សាហកម្ម។ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ត្រូវបង់ភាគទានជាប្រចាំខែ ហើយចំពោះការគណនាប្រាក់ភាគទាន ត្រូវគិតនៅថ្ងៃចុងក្រោយនៃខែដែលត្រូវបង់នីមួយៗ។

យ៉ាងណាមិញ អត្រាឯកភាពនៃការបង់ភាគទានដែលស្មើនឹង **០.៨ ភាគរយ** នេះ ត្រូវបន្ថយមកនៅត្រឹម **០.៥ ភាគរយ** វិញចំពោះគ្រប់បណ្តា សហគ្រាស គ្រឹះស្ថានកាត់ដេរ និងស្បែកជើងទាំងអស់ រួមទាំងគ្រឹះស្ថានដេរប៉ាក់ ចាក់អាវ បោកគក់ និងបោះពុម្ព ដែលបម្រើដល់សកម្មភាពនៃអាជីវកម្ម សហគ្រាស គ្រឹះស្ថានកាត់ដេរ និងស្បែកជើងផងដែរ ដោយការបន្ថយអត្រាបង់ភាគទាននៃផ្នែកហានិភ័យការងារនេះ គឺដោយសារមានការជួយឧបត្ថម្ភ ពីសំណាក់រដ្ឋាភិបាលចំនួន **០.៣ ភាគរយ** នៃអត្រាភាគទានសរុបចំនួន ០.៨ ភាគរយ កំឡុង**ឆ្នាំ ២០០៩-២០១០** កន្លងទៅ នឹងដល់ពេលកំណត់នាបំណាប់**ខែធ្នូ** ឆ្នាំ **២០១០**។ ហេតុដូចនេះ អត្រាភាគទានផ្នែកហានិភ័យការងារនឹងត្រូវកំណត់ចំនួន **០.៨ ភាគរយ**វិញ ចំពោះសហគ្រាស គ្រឹះស្ថានកាត់ដេរ និងស្បែកជើងចាប់ពីខែ **មករា** ឆ្នាំ **២០១១** តទៅ។

ចំពោះអត្រាបង់ភាគទានផ្នែកហានិភ័យការងារ ត្រូវបានទូទាត់ដោយផ្អែកតាមតារាងខាងក្រោម ដោយការបង់ភាគទានជាអប្បបរមា ត្រូវគិតត្រឹម **១៦០០ រៀល** ហើយចំណែកឯអត្រាភាគទានជាអតិបរមាវិញត្រូវគិតត្រឹម **៨០០០ រៀល** ក្នុងកម្មករនិយោជិតម្នាក់ៗ។

| **ប្រាក់ឈ្នួលប្រចាំខែ (គិតជារៀល)** | **ប្រាក់ឈ្នួកមធ្យមប្រចាំខែ (គិតជារៀល)** | **ភាគទានប្រចាំខែសម្រាប់កម្មករនិយោជិត ១ នាក់ (គិតជារៀល)** |
|---|---|---|
| ២០០.០០០ចុះ | ២០០.០០០ | ១.៦០០ |
| ២០០.០០១ - ២៥០.០០០ | ២២៥.០០០ | ១.៨០០ |
| ២៥០.០០១ - ៣០០.០០០ | ២៧៥.០០០ | ២.២០០ |
| ៣០០.០០១ - ៣៥០.០០០ | ៣២៥.០០០ | ២.៦០០ |

[41] ប្រការ ១ នៃប្រកាសលេខ ១០៨ កប/ប្រក ស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ

| | | |
|---|---|---|
| ៣៥០.០០១ - ៤០០.០០០ | ៣៧៥.០០០ | ៣.០០០ |
| ៤០០.០០១ - ៤៥០.០០០ | ៤២៥.០០០ | ៣.៤០០ |
| ៤៥០.០០១ - ៥០០.០០០ | ៤៧៥.០០០ | ៣.៨០០ |
| ៥០០.០០១ - ៥៥០.០០០ | ៥២៥.០០០ | ៤.២០០ |
| ៥៥០.០០១ - ៦០០.០០០ | ៥៧៥.០០០ | ៤.៦០០ |
| ៦០០.០០១ - ៦៥០.០០០ | ៦២៥.០០០ | ៥.០០០ |
| ៦៥០.០០១ - ៧០០.០០០ | ៦៧៥.០០០ | ៥.៤០០ |
| ៧០០.០០១ - ៧៥០.០០០ | ៧២៥.០០០ | ៥.៨០០ |
| ៧៥០.០០១ - ៨០០.០០០ | ៧៧៥.០០០ | ៦.២០០ |
| ៨០០.០០១ - ៨៥០.០០០ | ៨២៥.០០០ | ៦.៦០០ |
| ៨៥០.០០១ - ៩០០.០០០ | ៨៧៥.០០០ | ៧.០០០ |
| ៩០០.០០១ - ៩៥០.០០០ | ៩២៥.០០០ | ៧.៤០០ |
| ៩៥០.០០១ - ១.០០០.០០០ | ៩៧៥.០០០ | ៧.៨០០ |
| ១.០០០.០០១ ឡើង | ១០០.០០០០ | ៨០០០ |

### គ. ថិរវេលានៃការបង់ភាគទានសហគ្រាស គ្រឹះស្ថាន

ដើម្បីអនុវត្តឱ្យបានត្រឹមត្រូវនូវ ការបង់ភាគទានរបស់និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន នៅក្នុងនោះបេឡាជាតិរបបសន្តិសុខសង្គម ក៏បានធ្វើការកំណត់អំពីថិរវេលាយ៉ាងជាក់លាក់ក្នុងការបង់ភាគទានសម្រាប់ខែនីមួយៗ។

កាលបរិច្ឆេទនៃការបង់ភាគទាន ត្រូវចាប់ផ្តើមក្នុងអំឡុងពេល **៣០ ថ្ងៃ** បន្ទាប់ពីកាលបរិច្ឆេទដែល ប.ស.ស បានចេញ វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន។ ការប្រគល់វិញ្ញាបនបត្រខាងលើត្រូវមានបញ្ជាក់កាលបរិច្ឆេទដែលសហគ្រាស គ្រឹះស្ថានបានទទួលពី ប.ស.ស។

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវបង់ភាគទានសម្រាប់ខែនីមួយៗយ៉ាងយូរបំផុតនៅ **ថ្ងៃទី ១៥** នៃខែបន្ទាប់។ ប្រសិនបើមានការយឺតយ៉ាវក្នុងការបង់ភាគទាន នោះបេឡាជាតិរបបសន្តិសុខសង្គមនឹងធ្វើសេចក្តីជូនដំណឹង ទៅដល់និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងនោះឱ្យធ្វើការអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួនឱ្យបានតឹងរឹង។

ក្នុងករណីដែលនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានមានការខកខានមិនបានបង់ភាគទាន តាមកាលបរិច្ឆេទខាងលើ នោះនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវបង់បន្ថែមនូវការប្រាក់ តាមចំនួនជាក់ស្តែង និងត្រូវទទួលការពិន័យជាប្រាក់តាមអត្រាអប្បរមាដូចមានចែងក្នុង**មាត្រា ៣៦** នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារ[42]។

**ឃ. បែបបទនៃការបង់ភាគទាន**

ចំពោះបែបបទនៃការបង់ភាគទានត្រូវបាន ប.ស.ស កំណត់យ៉ាងច្បាស់លាស់ ជាពិសេសគឺ ទម្រង់បែបបទក្នុងបង់ភាគទាន ដែលជាកាតព្វកិច្ចរបស់និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ដោយនៅក្នុងនោះ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវបង់ភាគទានដោយផ្ទាល់ចូលទៅ ក្នុងគណនីរបស់បេឡាជាតិរបបសន្តិសុខសង្គម ដែលស្ថិតក្នុងធនាគារដែលបានកំណត់។ ការបង់ ភាគទានត្រូវធ្វើឡើងតាមទម្រង់ **បែបបទបង់ភាគទាន ២.០១** ដូចបានកំណត់នៅក្នុង **ឧបសម្ព័ន្ធ ២** នៃប្រកាសស្តីពីការកំណត់អត្រាបង់ភាគទាន និងបែបបទបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ[43]។

- **ការកំណត់ជាក់លាក់អំពីការបង់ភាគទានៈ**

និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថានត្រូវមានកាតព្វកិច្ចបង់ភាគទានហានិភ័យការងារ ក្នុងរយៈពេល **៣០ ថ្ងៃ** យ៉ាងយូរគិតពីកាលបរិច្ឆេទការចុះបញ្ជិកា។

- ចំពោះសហគ្រាស គ្រឹះស្ថានដែលត្រូវបានចុះបញ្ជិកានៅ**ខែតុលា ឆ្នាំ ២០០៨** នេះត្រូវបង់ ភាគទានសម្រាប់ខែវិច្ឆិកា ឆ្នាំ **២០០៨** ចូលទៅក្នុងគណនីរបស់ ប.ស.ស នៅធនាគារអេ ស៊ីលីដា ភីអិលស៊ី **(ACLEEDA Bank Plc.)** ឬតាមបណ្តាសាខារបស់ធនាគារនេះ ចាប់ពី **ថ្ងៃទី១** ដល់**ថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០០៨** យ៉ាងយូរ។
- ចំពោះសហគ្រាស គ្រឹះស្ថានដែលត្រូវចុះបញ្ជិកានៅ**ក្នុងខែវិច្ឆិកា ឆ្នាំ ២០០៨** ត្រូវបង់ភាគ ទានសម្រាប់**ខែធ្នូ ឆ្នាំ ២០០៨** ចាប់ពី**ថ្ងៃទី១ ដល់ថ្ងៃទី១៥ ខែមករាឆ្នាំ ២០០៩** យ៉ាងយូរ។

សម្រាប់ខែបន្ទាប់ៗទៀត និយោជក ឬម្ចាស់សហគ្រាស ក៏ត្រូវអនុវត្ត តាមរបៀបដូចខាងលើដែរ។

ឧទាហរណ៍ បើសហគ្រាស គ្រឹះស្ថានចុះបញ្ជិកា នៅក្នុង**ខែធ្នូ ឆ្នាំ ២០០៨** ត្រូវបង់ភាគទាន សម្រាប់**ខែ មករា ឆ្នាំ ២០០៩** ចាប់ពី**ថ្ងៃទី១ ដល់ថ្ងៃទី ១៥ ខែកុម្ភៈឆ្នាំ ២០០៩**យ៉ាងយូរ។

---

[42] ប្រការ ៣ នៃប្រកាសលេខ ១០៨ កប/ប្រក ស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់ផ្នែក ហានិភ័យការងារ

[43] ប្រការ ៤ កថាខណ្ឌ១ នៃប្រកាសលេខ ១០៨ កប/ប្រក ស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទាន សម្រាប់ផ្នែកហានិភ័យការងារ

នៅក្នុងនោះដែរ និយោជក ឬម្ចាស់សហគ្រាសត្រូវផ្ញើបង្កាន់ដៃបង់ភាគទានដែលចេញដោយធនាគារមក **ប.ស.ស** បន្ទាប់ពីថ្ងៃដែលខ្លួនបានបង់។ បង្កាន់ដៃភាគទានត្រូវមានចុះលេខអត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន និងកាលបរិច្ឆេទបង់ភាគទាន[44]។

បន្ទាប់ពីទទួលបានបង្កាន់ដៃរួច និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានសាមីវិញ។ ក្នុងករណីដែល ប.ស.ស ពិនិត្យឃើញថា ភាគទានដែលបានបង់មិនគ្រប់ចំនួននោះ ប.ស.ស ត្រូវកំណត់ឱ្យសហគ្រាស គ្រឹះស្ថានបង់បង្គ្រប់តាមចំនួនជាក់ស្តែង តាមទម្រង់បែបបទបង់ភាគទានបង្គ្រប់ ឬហៅថាទម្រង់ **២.០២** ដូចមានចែងក្នុង **ឧបសម្ព័ន្ធ ៣** នៃប្រកាសស្តីពី **ការកំណត់អត្រាបង់ភាគទាន និងបែបបទបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ**[45]។

ផ្អែកតាមការលើកឡើងនៅ ក្នុងប្រកាសស្តីពី **ការកំណត់អត្រាបង់ភាគទាន និងបែបបទបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ** យើងអាចធ្វើការកំណត់ជារូបមន្តសម្រាប់ធ្វើការបង់ភាគទានបាន:

- **សម្រាប់កម្មករនិយោជិតម្នាក់:**

| |
|---|
| ប្រាក់ដែលត្រូវបង់ភាគទានសម្រាប់កម្មករនិយោជិតម្នាក់ៗ = |
| ប្រាក់ឈ្នួលមធ្យមរបស់កម្មករនិយោជិតម្នាក់ × ០,៨ (ភាគរយ) |

- **សម្រាប់កម្មករនិយោជិតសរុប:**

| |
|---|
| ប្រាក់ដែលត្រូវបង់ភាគទានសម្រាប់កម្មករនិយោជិតម្នាក់ៗ = |
| ប្រាក់ឈ្នួលមធ្យមរបស់កម្មករនិយោជិតសរុប × ០,៨ (ភាគរយ) |

[44] ប្រការ ៨ កថាខណ្ឌ២ នៃប្រកាសលេខ ១០៨ កប/ប្រក ស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ

[45] ប្រការ ១ នៃប្រកាសលេខ ១០៨ កប/ប្រក ស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ

# ជំពូកទី២

## តាវកាលិក(អត្ថប្រយោជន៍)ផ្នែកហានិភ័យការងារ និង ផ្នែកសុខភាព

តាវកាលិក (អត្ថប្រយោជន៍) របស់បេឡាជាតិសន្តិសុខសង្គម ដែលត្រូវផ្តល់ជូនទៅកាន់សមាជិករបស់ខ្លួន មានពីរប្រភេទ គឺ តាវកាលិកសំរាប់ហានិភ័យការងារ **(ផ្នែកទី១)** និង តាវកាលិកផ្នែកថែទាំសុខភាព **(ផ្នែកទី២)**។ តាវកាលិក **ហានិភ័យការងារ** ត្រូវបានផ្តល់ទៅឱ្យកម្មករនិយោជិតទាំងឡាយណា ដែលរងនូវហានិភ័យការងារ រួមមានគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ។ ចំនែកឯតាវកាលិកក្នុងផ្នែកថែទាំសុខភាពវិញ គឺត្រូវបានផ្តល់ឱ្យសមាជិករបស់បេឡាជាតិរបបសន្តិសុខសង្គមទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ព្រមទាំងជនរងគ្រោះថ្នាក់ការងារដែលបានបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ និងឧត្តរជីវី រួមមានប្តី ឬ ប្រពន្ធ និងកូននៅក្នុងបន្ទុកផ្ទាល់នៃសមីជន ជាសមាជិកនៃ ប.ស.ស ដែលទទួលមរណភាពដោយហានិភ័យការងារ។ ហើយជាពិសេសជាងនេះទៀតនោះ តាវកាលិកផ្នែកសុខភាពនេះនឹងធ្វើការអនុវត្តចំពោះអ្នកនៅក្នុងបន្ទុកនៃសមាជិក ប.ស.ស ដែលរួមមានប្រពន្ធ ឬ ប្តី និងកូន[46]។

### ផ្នែកទី១: តាវកាលិកហានិភ័យការងារ

តាវកាលិកផ្នែកហានិភ័យការងារ ត្រូវបានផ្តល់ជូនទៅឱ្យកម្មករនិយោជិត[47]ដែលរងនូវហានិភ័យការងារ តាមរយៈបេឡាជាតិរបបសន្តិសុខសង្គម ហើយ**ហានិភ័យការងារ**នេះទៀតសោតរួមមាន **គ្រោះថ្នាក់ការងារ** និង**ជំងឺវិជ្ជាជីវៈ**[48]។ដូច្នេះដើម្បីធ្វើការបកស្រាយយ៉ាងលម្អិតទៅលើផ្នែកតាវកាលិកហានិភ័យការងារនេះ យើងនឹងផ្តល់និយមន័យនៃគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ។ បើយោងទៅតាមច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារ បានផ្តល់និយមន័យនៃគ្រោះថ្នាក់ការងារ ព្រមទាំងជំងឺវិជ្ជាជីវៈថាៈ

**គ្រោះថ្នាក់ការងារ** : ត្រូវបានចាត់ទុកថាជាគ្រោះថ្នាក់ការងារ គឺជាគ្រោះថ្នាក់ទាំងឡាយណាដែលធ្លាក់ទៅលើរូបកាយរបស់កម្មករនិយោជិត ដោយធ្វើការ ឬក្នុងពេលធ្វើការ ទោះដោយហេតុយ៉ាងណាក៏ដោយ ហើយទោះមានកំហុសពីកម្មករនិយោជិត ឬគ្មានក៏ដោយ គឺគ្រោះថ្នាក់ដែលធ្លាក់

[46] ប្រការ២ នៃប្រកាសលេខ០៩៣/១៦ កប/ប្រក ស្តីពីការកំណត់ដំណាក់កាល និងកាលបរិច្ឆេទនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព

[47] កម្មករនិយោជិតដែលសហគ្រាស ឬគ្រឹះស្ថាន បានចុះបញ្ជិកានៅក្នុងបេឡាជាតិរបបសន្តិសុខសង្គម

[48] ប្រកាសលេខ១០៩កប/ប្រកស្តីពីតាវកាលិកហានិភ័យការងារប្រការ១ ចំណុច ១.២ដែលប្រកាសនៅថ្ងៃទី ១៦ខែមិថុនាឆ្នាំ២០០៨។

លើរូបរាងកាយកម្មករនិយោជិត ក្នុងពេលធ្វើការឱ្យនិយោជក ឬនាយកសហគ្រាស ឬធ្លាក់លើសិស្សវិជ្ជាជីវៈមានឈ្នួលក្តី ឥតឈ្នួលក្តី កាន់មុខងារជាអ្វី នៅទីកន្លែងណាក៏ដោយ។

ម្យ៉ាងទៀត ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារដែរ ចំពោះគ្រោះថ្នាក់ណាដែលធ្លាក់លើរូបកាយកម្មករនិយោជិតក្នុងពេលដែលសាមីខ្លួនធ្វើដំណើរពីលំនៅស្ថានរបស់ខ្លួនត្រង់ឆ្ពោះទៅទីកន្លែងធ្វើការ ឬវិលមកវិញដោយគ្មានឈប់ ឬដោយគ្មានវាងទៅកន្លែងផ្សេងជាប្រយោជន៍ផ្ទាល់ខ្លួន ឬក្រៅពីការងារដែលគេតម្រូវឱ្យទៅ។

**ជំងឺវិជ្ជាជីវៈ** : គឺជាជំងឺទាំងឡាយណា ដែលបណ្តាលមកពីវិជ្ជាជីវៈ ជំងឺទាំងនោះក៏ត្រូវចាត់ទុកថាជាហានិភ័យការងារដែរ។

ក្នុងករណីដែលកម្មករនិយោជិតណាម្នាក់ ទទួលរងហានិភ័យការងារ កម្មករនយោជិតទាំងនោះនឹងទទួលបាន នូវប្រភេទតាវកាលិកទៅតាមស្ថានភាពជាក់ស្តែង ដែលតាវកាលិកទាំងអស់នោះរួមមាន៖ តាវកាលិកផ្នែកសេវា ការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន ការផ្តល់ធនលាភ ឬប្រាក់វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍។ ហើយប្រសិនបើស្ថិតក្នុងករណីដែលសាមីជន បានទទួលរងនូវហានិភ័យការងាររហូតបាត់បង់ជីវិតនោះបេឡាជាតិរបបសន្តិសុខសង្គម ត្រូវផ្តល់នូវប្រាក់វិភាជន៍ជាសោហ៊ុយសម្រាប់បូជាសព និងធនលាភចំពោះឧត្តរជីវីនៃជនរងគ្រោះ។ ក្នុងពេលដែលកម្មករនិយោជិតទទួលរងនូវហានិភ័យការងារណាមួយ បេឡាជាតិរបបសន្តិសុខសង្គមតម្រូវឱ្យកម្មករនិយោជិត ឬក៏អ្នកតំណាងជនរងគ្រោះ ឬក៏ជាម្ចាស់សហគ្រាស ឬគ្រឹះស្ថានតំណាងឱ្យជនរងគ្រោះនោះ អនុវត្តនូវនីតិវិធីជូនដំណឹងទៅកាន់បេឡាជាតិរបបសន្តិសុខសង្គមដើម្បីទទួលបាននូវតាវកាលិកហានិភ័យការងារ។

ចំណែកឯបេឡាជាតិរបបសន្តិសុខសង្គមវិញ បន្ទាប់ពីទទួលបានដំណឹងអំពីហានិភ័យការងាររបស់កម្មករនិយោជិតហើយនោះ អធិការ ឬអភិបាលសន្តិសុខសង្គមចាប់ផ្តើមធ្វើការអង្កេតទៅលើគ្រោះថ្នាក់ការងារ ឬ ជំងឺទាំងនោះថាជាហានិភ័យការងារ ឬក៏អត់។ ក្នុងករណីដែលរកឃើញថាជាហានិភ័យការងារ បេឡាជាតិរបបសន្តិសុខសង្គម នឹងចាប់ផ្តើមធ្វើការរៀបចំនូវតាវកាលិកដើម្បីផ្តល់ជូនជនរងគ្រោះ ដែលទទួលរងហានិភ័យការងារនោះឱ្យបានឆាប់រហ័ស ប៉ុន្តែប្រសិនបើលទ្ធផលនៃការអង្កេតបានបង្ហាញថាមិនមែនជាហានិភ័យការងារនោះទេ បេឡាជាតិរបបសន្តិសុខសង្គមមិនផ្តល់ជូននូវតាវកាលិកហានិភ័យការងារឡើយ។ ដូច្នេះដើម្បីសិក្សាឱ្យបានលម្អិតនៅក្នុងផ្នែកនេះ

យើងខ្ញុំនឹងធ្វើបែងចែកជាពីរកថាខណ្ឌ ដោយ(**កថាខណ្ឌ១**) បកស្រាយអំពី បទដ្ឋានគតិយុត្តនៃការផ្តល់តាវកាលិកហានិភ័យការងារ និង(**កថាខណ្ឌ២**) បកស្រាយពីប្រភេទតាវកាលិកហានិភ័យការងារ។

## កថាខណ្ឌ១ : បទដ្ឋានគតិយុត្តនៃការផ្តល់តាវកាលិកហានិភ័យការងារ

ដើម្បីទទួលនូវតាវកាលិកហានិភ័យការងារ កម្មករនិយោជិតដែលជាសមាជិករបស់បេឡាជាតិរបបសន្តិសុខសង្គម ត្រូវធ្វើការជូនដំណឹងអំពីការទទួលរងនូវហានិភ័យរបស់ខ្លួន (ក) ទៅកាន់ **ប.ស.ស**។ នៅពេលបេឡាជាតិរបបសន្តិសុខសង្គមទទួលបាននូវដំណឹងនោះហើយ អធិការ ឬអភិបាលសន្តិសុខសង្គម នឹងធ្វើការបើកការអង្កេតហានិភ័យ (ខ)។

### ក. ការជូនដំណឹងអំពីហានិភ័យការងារ

នៅពេលដែលកម្មករនិយោជិត ទទួលរងគ្រោះថ្នាក់ការងារ ឬ ជំងឺវិជ្ជាជីវៈ កម្មករនិយោជិតត្រូវធ្វើការរាយការណ៍ទៅកាន់នាយក ឬអ្នកតំណាងនិយោជក ទាក់ទងនឹងគ្រោះថ្នាក់ ឬ ជំងឺនោះជាបន្ទាន់។ ហើយក្នុងករណី ដែលមានគ្រោះថ្នាក់រហូតដល់បាត់បង់ជីវិតនោះ កាតព្វកិច្ចនេះត្រូវធ្លាក់ទៅលើសិទ្ធិវន្តនៃជនរងគ្រោះ។ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលស្ថិតនៅក្រោមដែនអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីការងារ ជាពិសេសបានចុះបញ្ជិកា នៅក្នុងបេឡាជាតិរបបសន្តិសុខសង្គម មានរយៈពេលយ៉ាងយូរ **៤៨ (សែសិបប្រាំបី) ម៉ោង** នៃថ្ងៃធ្វើការបន្ទាប់ពីបានជូនដំណឹងហានិភ័យការងារដែលធ្លាក់មកលើកម្មករនិយោជិតរបស់ខ្លួន។

ក្នុងករណីអង្កេតឃើញថាជាគ្រោះថ្នាក់ការងារ ត្រូវផ្ញើរបាយការណ៍ហានិភ័យការងារដោយភ្ជាប់មកជាមួយនឹងឯកសារពាក់ព័ន្ធតាមរយៈសារអេឡិចត្រូនិត[49] ទៅកាន់បេឡាជាតិរបបសន្តិសុខសង្គម ។

### ខ. ការអង្កេតហានិភ័យការងារ

បន្ទាប់ពីបានទទួលរបាយការណ៍ហានិភ័យការងារ ការិយាល័យតាវកាលិកការិយាល័យ ខេត្ត ក្រុងនៃបេឡាជាតិរបបសន្តិសុខសង្គម ត្រូវជូនដំណឹងជាបន្ទាន់ទៅកាន់អធិការ ឬអភិបាលសន្តិសុខសង្គម។ បន្ទាប់មក អធិការ ឬអភិបាលសន្តិសុខសង្គម ត្រូវធ្វើអង្កេត និង ផ្តល់លទ្ធផលលើករណីនីមួយៗមកការិយាល័យតាវកាលិកឱ្យបានយ៉ាងឆាប់បំផុត។

[49] គេហទំព័ររបស់បេឡាជាតិរបបសន្តិសុខសង្គម របាយការណ៍ហានិភ័យការងារ benefit@nssf.gov.kh

ប្រសិនបើករណីនោះ មានលក្ខណៈស្មុគស្មាញ អធិការ ឬអភិបាលសន្តិសុខសង្គមអាចស្នើសុំជំនួយពីអ្នកឯកទេស ឬ សុំកិច្ចសហការពីអធិការ ឬអភិបាលការងារ។ ការចំណាយសម្រាប់ផ្នែកនេះគឺជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម។

ចំពោះគ្រោះថ្នាក់ ដែលកើតឡើងនៅពេលធ្វើដំណើរ អធិការ ឬអភិបាលសន្តិសុខសង្គមត្រូវស្នើសុំព័ត៌មានដែលទាក់ទងនឹងទីកន្លែង ពេលវេលា ជាពិសេសមូលហេតុនៃគ្រោះថ្នាក់នោះពីសាក្សី ឬអាជ្ញាធរមានសមត្ថកិច្ចនៅនឹងកន្លែងកើតហេតុ[50] ដើម្បីបញ្ជាក់ឱ្យបានច្បាស់ថាជាហានិភ័យការងារ ឬ ក៏មិនមែន។

បើអធិការ ឬ អភិបាលសន្តិសុខសង្គមរកឃើញថា គ្រោះថ្នាក់ ឬ ជំងឺនោះជាហានិភ័យការងារមែនការិយាល័យតាវកាលិករបស់ ប.ស.ស ត្រូវធ្វើការរៀបចំផ្តល់តាវកាលិកជូនកម្មករនិយោជិតដែលទទួលរងហានិភ័យការងារឱ្យបានឆាប់រហ័សបំផុត និងទាន់ពេលវេលា តាមរយៈកំណត់ហេតុគ្រោះថ្នាក់ការងារដែលអធិការ ឬ អភិបាលបានផ្តល់ជូន[51]។

### កថាខណ្ឌ ២ ប្រភេទតាវកាលិកហានិភ័យការងារ

តាវកាលិកហានិភ័យការងារ ដែលបេឡាជាតិរបបសន្តិសុខសង្គមត្រូវបានផ្តល់ជូនកម្មករនិយោជិតដែលជាសមាជិករបស់ខ្លួននោះរួមមាន៖ តាវកាលិកសេវា **(ក)** តាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពបណ្តោះអាសន្ន **(ខ)** និងតាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពអចិន្ត្រៃយ៍ **(គ)** ។

#### ក. តាវកាលិកផ្នែកសេវា

តាវលិកផ្នែកសេវា ត្រូវបានផ្តល់ឱ្យសមាជិករបស់បេឡាជាតិរបបសន្តិសុខសង្គមហើយនៅក្នុងនោះរួមមានទាំងសេវាសង្គ្រោះបន្ទាន់ សេវាថែទាំ និងព្យាបាល សេវាបុននីតិសម្បទាន ដែលសេវាទាំងអស់សុទ្ធតែជាសេវាសំខាន់ៗ សំរាប់ជួយសង្គ្រោះទៅដល់កម្មករនិយោជិតដែលទទួលរងនូវគ្រោះថ្នាក់ការងារ។

[50] ប្រកាសលេខ ១០៩ កប/ប្រក ស្តីពីតាវកាលិកហានិភ័យការងារ ប្រការ ៣

[51] ប្រកាសលេខ ០៨១/០៩ កប/ប្រក ស្តីពីការកំណត់តួនាទី ភារកិច្ចរបស់អធិការ និងអភិបាលរបបសន្តិសុខសង្គមនៃបេឡាជាតិរបបសន្តិសុខសង្គម

### គ.១ ការផ្តល់សេវាសង្គ្រោះបន្ទាន់

ជាធម្មតាប្រសិនបើ កម្មករនិយោជិតណាម្នាក់ជួបនឹងគ្រោះថ្នាក់ការងារ សាមីជនរូបនោះនឹងទទួលបាននូវការសំរាកព្យាបាលនៅក្នុងមន្ទីរពេទ្យ ឬ មន្ទីរពហុព្យាបាលដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម[52]។

ប៉ុន្តែក្នុងករណីដែលកម្មករនិយោជិតណាម្នាក់ ទទួលរងនូវគ្រោះថ្នាក់ការងារនៅនឹងកន្លែងធ្វើការ និយោជកត្រូវផ្តល់នូវការសង្គ្រោះបន្ទាន់ដែលស្ថិតនៅកន្លែងជិតបំផុត និង បន្ទាប់មកទើបត្រូវបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល ដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសង្គមវិញ។ ចំនែកការចំណាយលើការសង្គ្រោះបន្ទាន់ និងការបញ្ជូនកម្មករនិយោជិតដែលរងនូវគ្រោះថ្នាក់ការងារនេះជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម។ ក្នុងករណីដែលកម្មករនិយោជិតជួបគ្រោះថ្នាក់ការងារ នៅពេលដែលធ្វើដំណើរ សាមីជន ឬនិយោជក អាចទាមទារការទូទាត់សងលើការចំណាយសម្រាប់ការសង្គ្រោះនេះពីបេឡាជាតិរបបសន្តិសុខសង្គម[53]។

### គ.២ ការផ្តល់សេវាថែទាំ និង ព្យាបាល

កម្មករនិយោជិត ដែលទទួលរងនូវហានិភ័យការងារ មានសិទ្ធិទទួលបាននូវការពិនិត្យ ឬ ធ្វើការសម្រាកព្យាបាលនៅតាមបណ្តាមន្ទីរពេទ្យ ឬ មន្ទីរពហុព្យាបាលដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម ដោយផ្អែកតាមការព្រមព្រៀងរវាងបេឡាជាតិរបបសន្តិសុខសង្គមជាមួយនឹងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលសាមី[54]។ ក្នុងករណីដែលគ្រូពេទ្យតម្រូវឱ្យកម្មករនិយោជិតដែលជាជនរងនៃគ្រោះថ្នាក់ការងារ ទិញនូវឱសថ ឬ សំភារៈឧបករណ៍ដែលចំបាច់សម្រាប់ការថែទាំ និងព្យាបាលដែលពុំបានចែងនៅក្នុងកិច្ចព្រមព្រៀងបេឡាជាតិរបបសន្តិសុខសង្គមទេនោះ បេឡាជាតិរបបសន្តិសុខសង្គមអាចទូទាត់សងទៅជនរងគ្រោះ ឬអ្នកតំណាងជនរងគ្រោះវិញបាន លុះត្រាតែមានវេជ្ជបញ្ជា និងវិក្កយបត្រត្រឹមត្រូវ[55]។

ដើម្បីជាការងាយស្រួលដល់ការផ្តល់សេវាថែទាំ និងការព្យាបាល ទៅដល់ជនរងគ្រោះនៃគ្រោះថ្នាក់ការងារ បេឡាជាតិរបបសន្តិសុខសង្គមបានចុះកិច្ចព្រមព្រៀងជាមួយមន្ទីរពេទ្យ ឬមន្ទីរពហុ

---

[52] ប្រកាសលេខ ១០៩ កប/ប្រក ស្តីពីតារាវកាលិកហានិភ័យការងារ ក្នុងប្រការ ៥ ចំណុច ៥.១

[53] ប្រកាសលេខ ១០៩ កប/ប្រក ស្តីពីតារាវកាលិកហានិភ័យការងារ ក្នុងប្រការ ៤

[54] ប្រកាសលេខ ១០៩ កប/ប្រក ស្តីពីតារាវកាលិកហានិភ័យការងារ ក្នុងប្រការ ៥ ចំណុច ៥.២

[55] ប្រកាសលេខ ១០៩ កប/ប្រក ស្តីពីតារាវកាលិកហានិភ័យការងារ ក្នុងប្រការ ៥ ចំណុច ៥.៣

ព្យាបាលទូទាំងរាជធានីខេត្តក្រុង ដែលមានចំនួនសរុប ៩២ មន្ទីរពេទ្យ ឬមន្ទីពហុព្យាបាលដែលស្ថិត នៅក្នុង ២៤ ខេត្តក្រុងនៃព្រះរាជាណាចក្រកម្ពុជា[56]។

### ក.៣ ការផ្តល់សេវាមុននីតិសម្បទា

ប្រសិនបើកម្មករនិយោជិតដែលរងហានិភ័យការងារ រហូតដល់បណ្តាលឱ្យបាត់បង់សមត្ថភាព ការងារជាអចិន្ត្រៃយ៍ មានសិទ្ធិទទួលបាន **ឧបករណ៍** ឬ **អវៈយវៈសិប្បនិម្មិត** តាមការកំណត់របស់គ្រូពេទ្យផ្លូវការ ឬ គ្រូពេទ្យដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម និងមានសិទ្ធិទទួល បានសេវាសម្របសម្រួលមុខងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញស្របតាមលក្ខខណ្ឌដែល នឹងកំណត់ក្នុងប្រកាសដោយឡែករបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ[57]។

### ខ. តាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន

កម្មករនិយោជិត ដែលទទួលរងនូវហានិភ័យការងារនឹងធ្វើឱ្យបាត់បង់សមត្ថភាពការងាជាបណ្តោះ អាសន្ននោះមានសិទ្ធិទទួលនូវការពិនិត្យ និងសំរាកព្យាបាលនៅក្នុងមន្ទីរពេទ្យ ឬ មន្ទីពហុព្យាបាល ដែលបានចុះកិច្ចសន្យាជាមួយបេឡាជាតិរបបសន្តិសុខសង្គម។ ហើយរយៈពេលនៃការសម្រាក ព្យាបាលអាចជាការសំរាកក្នុងការព្យាបាលមុខរបួស ឬ ជំងឺវិជ្ជាជីវៈ ឬក៏អាចជាការសម្រាកក្រោយ ពេលមុខរបួសជាសះស្បើយតាមវេជ្ជបញ្ជា[58]។

នៅក្នុងអំឡុងពេលនៃការសម្រាកព្យាបាលនេះ កម្មករនិយោជិតដែលទទួលរងនូវហានិភ័យ ការងារមានសិទ្ធិទទួលបាននូវតាវកាលិកហានិភ័យការងារដូចជា៖

- **ប្រាក់បំណាច់ប្រចាំថ្ងៃ** ដែលត្រូវផ្តល់ជូនគិតចាប់ពីថ្ងៃទីពីរ បន្ទាប់ពីកាលបរិច្ឆេទនៃការ កើតឧបទ្ទវហេតុបណ្តាលឱ្យទទួលរងនូវហានិភ័យការងារ
- **ប្រាក់ឧបត្ថម្ភ** សម្រាប់អ្នកមើលថែទាំអ្នករងគ្រោះពេលសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬ មន្ទីពហុព្យាបាល ក្នុងករណីដែលស្ថានភាពគ្រោះថ្នាក់ធ្ងន់ធ្ងរតម្រូវឱ្យមានអ្នកចាំថែទាំ តាមការស្នើរសុំរបស់គ្រូពេទ្យព្យាបាល[59]។

[56] ដកស្រង់ពីរបាយការណ៍មន្ទីរពេទ្យ ឬមន្ទីពហុព្យាបាលរបស់គេហទំព័របេឡាជាតិរបបសន្តិសុខសង្គម

[57] ប្រកាសលេខ ១០៩ កប/ប្រក ស្តីពីតាវកាលិកហានិភ័យការងារ ក្នុងប្រការ ១២

[58] ប្រកាសលេខ ១០៩ កប/ប្រក ស្តីពីតាវកាលិកហានិភ័យការងារ ក្នុងប្រការ ៧ ចំណុច ៧.១

[59] ប្រកាសលេខ ១០៩ កប/ប្រក ស្តីពីតាវកាលិកហានិភ័យការងារ ក្នុងប្រការ ៧ ចំណុច ៧.២

ប្រាក់បំណាច់ប្រចាំថ្ងៃ សម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ននេះ ត្រូវបានផ្តល់ជូនទៅកាន់ឱ្យកម្មករនិយោជិតទាំងឡាយណា ដែលរងនូវហានិភ័យការងារ ហើយតម្រូវឱ្យសម្រាកព្យាបាលនៅក្នុងមន្ទីពេទ្យ ឬមន្ទីពហុព្យាបាល ដែលមានរយៈពេលលើសពី **០៤ (បួន)** ថ្ងៃឡើងទៅ[60]។

ប្រាក់បំណាច់សម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ននេះ ត្រូវគិតស្មើនឹង **៧០ (ចិតសិប)** ភាគរយ នៃប្រាក់ឈ្នួលប្រចាំថ្ងៃ។ ហើយប្រាក់ឧបត្ថម្ភសម្រាប់អ្នកមើថែទាំនៅក្នុងមន្ទីពេទ្យត្រូវស្មើនឹង **៥០ (ហាសិប)** ភាគរយ នៃប្រាក់បំណាច់ប្រចាំថ្ងៃរបស់ជនរងគ្រោះ[61]។

ដើម្បីធ្វើការស្រួលក្នុងការគណនានៃប្រាក់បំណាច់ប្រចាំថ្ងៃរបស់ជនគ្រោះ នៃគ្រោះថ្នាក់ការងារបណ្តោះអាសន្ន ក្រុមយើងខ្ញុំនឹងផ្តល់រូបមន្តដូចខាងក្រោម៖

- **ការគណនាប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ**

  - ❖ ប្រាក់ឈ្នួលមធ្យម គឺជាផលចែកមធ្យមភាគនៃប្រាក់ឈ្នួលជាប់ភាគទានក្នុងរយៈពេល **៦ (ប្រាំមួយ)** ខែ មុនកាលបរិច្ឆេទនៃគ្រោះថ្នាក់។

រូបមន្ត ៖ $\text{ប្រាក់ឈ្នួលមធ្យម} = \dfrac{\text{ផលបូកនៃប្រាក់ឈ្នួលជាប់ភាគទានក្នុងរយៈ ៦ ខែ}}{\text{៦}}$

  - ❖ ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ គឺជាផលចែកនៃប្រាក់ឈ្នួលមធ្យមនឹង **៣០ (សាមសិប)** ថ្ងៃ។

រូបមន្ត ៖ ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ[62] $= \dfrac{\text{ប្រាក់ឈ្នួលមធ្យម}}{\text{៣០ (សាមសិប) ថ្ងៃ}}$

- **ការគណនាប្រាក់បំណាច់ប្រចាំថ្ងៃរបស់ជនរងនៃគ្រោះថ្នាក់ការងារបណ្តោះអាសន្ន៖**

  - ❖ $\text{ប្រាក់បំណាច់ប្រចាំថ្ងៃ} = \dfrac{\text{ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ} \times \text{៧០}\%}{\text{១០០}\%}$

  - ❖ ប្រាក់ឧបត្ថម្ភសម្រាប់អ្នកថែទាំ

$$= \dfrac{\text{ប្រាក់បំណាច់ប្រចាំថ្ងៃរបស់ជនរងគ្រោះថ្នាក់ការងារបណ្តោះអាសន្ន}}{\text{២}}$$

[60] ប្រកាសលេខ ១០៩ កប/ប្រក ស្តីពីតាវកាលិកហានិភ័យការងារ ក្នុងប្រការ ៧ ចំណុច ៧.៣

[61] ប្រកាសលេខ ១០៩ កប/ប្រក ស្តីពីតាវកាលិកហានិភ័យការងារ ក្នុងប្រការ ៧ ចំណុច ៧.៤

[62] ប្រកាសលេខ ១០៩ កប/ប្រក ស្តីពីតាវកាលិកហានិភ័យការងារ ក្នុងប្រការ ៦

## គ. តាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍

តាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ត្រូវបានបែងចែកជាពីរប្រភេទ គឺ**ប្រាក់ធនលាភ** និង**ប្រាក់វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍**។

ប្រាក់ធនលាភ ត្រូវបានផ្តល់ទៅឱ្យកម្មករនិយោជិតដែលទទួលរងហានិភ័យការងារហើយ បញ្ជាក់យ៉ាងត្រឹមត្រូវពីគ្រូពេទ្យផ្លូវការ ឬ គ្រូពេទ្យដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម ថាបានបាត់បង់សមត្ថភាពការងារយ៉ាងតិចស្មើនឹង**ម្ភៃភាគរយ (២០%)**។

ចំណែកឯ វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍វិញ ត្រូវបានផ្តល់ជូនកម្មករនិយោជិតដែលជាសមាជិករបស់បេឡាជាតិរបបសន្តិសុខសង្គមទាំងឡាយណា ដែលបានបាត់បង់សមត្ថភាពការងារតិចជាង **ម្ភៃភាគរយ (២០%)**[63]។

### គ.១ វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍

កម្មករនិយោជិត ដែលបានបាត់សមត្ថភាពការងារតិចជាងម្ភៃភាគរយ (២០%) ដោយសារតែទទួលរងនូវហានិភ័យការងារមានសិទ្ធិទទួលបានប្រាក់វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍។ ហើយប្រាក់វិភាជន៍នេះត្រូវបានផ្តល់ជូនជនរងគ្រោះតែម្តងគត់ដោយគិតតាមរូបមន្តខាងក្រោម៖

**- វបក = បឈម x ៧០% x កបក x ២០%មតប**

- **វបក:** វិភាជន៍បាត់បង់សមត្ថភាពការងារ

- **បឈម** : ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់ជនរងគ្រោះ

- **កបក** : កម្រិតបាត់បង់សមត្ថភាពការងាររបស់ជនរងគ្រោះ

- **មតប** : មេគុណតម្លៃបច្ចុប្បន្ន[64]

[63] មាត្រា ១៨ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារ
[64] ប្រកាសលេខ ១០៩ កប/ប្រក ស្តីពីតាវកាលិកហានិភ័យការងារ ប្រការ ៨ ចំណុច ៨.១

### គ.២ ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍

កម្មករនិយោជិត ដែលបានបាត់សមត្ថភាពការងារចាប់ពី**ម្ភៃភាគរយ (២០%)** ឡើងទៅ ដោយសារតែទទួលរងនូវហានិភ័យការងារ មានសិទ្ធិទទួលបាននូវប្រាក់ធនលាភ។ ប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍នេះ ត្រូវបានគិតតាមរូបមន្តដូចខាងក្រោម៖

- **ធល = បឈម x ( កបក - ១/៥ កបក)**
- **ធល** : ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារ[65]

ប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ត្រូវចាត់ទុកជាបណ្ដោះអាសន្នជានិច្ច។ បេឡាជាតិរបបសន្តិសុខសង្គមត្រូវរៀបចំឱ្យមានការពិនិត្យសុខភាព និង សមត្ថភាពការងារ អ្នករងគ្រោះឡើងវិញក្នុងរយៈពេល **១(មួយ) ឆ្នាំ**យ៉ាងយូរ។ ជនរងគ្រោះ ដែលទទួលបានធនលាភត្រូវមានកាតព្វកិច្ចមកពិនិត្យសុខភាព តាមការកំណត់របស់បេឡាជាតិរបបសន្តិសុខសង្គម[66]។

ប្រសិនកម្មករនិយោជិត ដែលរងហានិភ័យការងារបណ្ដាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ក្នុងកម្រិត **១០០ ភាគរយ** មានសិទ្ធិទទួលបានប្រាក់បន្ថែមសម្រាប់អ្នកចាំថែរក្សាដល់ខ្លួន។ ហើយ**ប្រាក់បន្ថែមសម្រាប់អ្នកមើលថែ**នេះស្មើនឹង **៥០(ហាសិប) ភាគរយ**នៃប្រាក់ធនលាភរបស់ជនរងគ្រោះ[67]។

### ឃ. តាវកាលិកមរណភាពនៃអ្នករងហានិភ័យការងារ

ក្នុងករណីដែលកម្មករនិយោជិត ទទួលរងនូវហានិភ័យការងារ រហូតដល់បាត់បង់ជីវិតនោះ បេឡាជាតិរបបសន្តិសុខសង្គម នឹងផ្ដល់ជូនជនគ្រោះដែលបានបាត់បង់ជីវិតនោះ នូវប្រាក់វិភាជន៍សម្រាប់សោហ៊ុយបូជាសព និងប្រាក់ធនលាភចំពោះសិទ្ធិវន្តនៃជនរងគ្រោះ[68]។

### ឃ.១. តាវកាលិកឧត្តរជីវី

តាវកាលិកឧត្តរជីវី គឺជាប្រាក់ធនលាភដែលត្រូវផ្ដល់ឱ្យសិទ្ធិវន្តនៃជនរងគ្រោះ។ សិទ្ធិវន្តនៃជនរងគ្រោះមានលក្ខណៈសម្បត្តិដូចជា៖

[65] ប្រកាសលេខ ១០៩ កប/ប្រក ស្ដីពីតាវកាលិកហានិភ័យការងារ ប្រការ ៨ ចំណុច ៨.២

[66] ប្រកាសលេខ ១០៩ កប/ប្រក ស្ដីពីតាវកាលិកហានិភ័យការងារ ប្រការ ៨ ចំណុច ៨.៣

[67] ប្រកាសលេខ ១០៩ កប/ប្រក ស្ដីពីតាវកាលិកហានិភ័យការងារ ប្រការ ៩

[68] មាត្រា ១៩ នៃច្បាប់ស្ដីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារ

១. ប្តី ឬប្រពន្ធមិនមានការលែងលះ ឬបែកបាក់គ្នា ព្រមទាំងបានរៀបការតាមច្បាប់ និងបានចុះបញ្ជីអត្រានុកូលដ្ឋានមុនពេលមានគ្រោះថ្នាក់ ឬមុនពេលជនរងគ្រោះបាត់បង់ជីវិត ទោះជាការរៀបការនេះធ្វើឡើងក្រោយពេលដែលមានគ្រោះថ្នាក់ការងារក៏ដោយ [69] ។ ហើយសិទ្ធិធនលាភចំពោះឧត្តរជីវី និងសោធនចំពោះអ្នកនៅក្នុងបន្ទុករបស់សហព័ទ្ធត្រូវផុតរលត់ ក្នុងករណីដែលសហព័ទ្ធនោះបានរៀបការថ្មី[70] ។

២. កូនដែលមានអាយុត្រឹម **១៨ (ដប់ប្រាំបី) ឆ្នាំ** ចុះ ដែលមិនទាន់រៀបអាពាហ៍ពិពាហ៍ និងមានស្ថានមានភាពៈ

- កូននៃសហព័ទ្ធដែលបានរៀបអាពាហ៍ពិពាហ៍ ដោយមានចុះបញ្ជីអត្រានុកូលដ្ឋានត្រឹមត្រូវ។ ក្នុងករណីមានការលែងលះ ឬករណីមរណភាពនៃប្តីឬប្រព័ន្ធ កូននៃអាពាហ៍ពិពាហ៍ក៏មានសិទ្ធិ ដូចទៅនឹងកូននៃអាពាហ៍ពិពាហ៍ទី១ដែរ។
- កូនចិញ្ចឹមរបស់សមាជិក នៃបេឡាជាតិរបបសន្តិសុខសង្គម ហើយកូនចិញ្ចឹមនោះរួមមានកូនសុំធម្មតា និងកូនសុំពេញលេញ។

អាយុកូននៅក្នុងបន្ទុកអាចកំណត់ដល់ **២១ (ម្ភៃមួយ) ឆ្នាំ** ចំពោះកូនដែលកំពុងទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬ កូនកំពុងរៀននៅក្នុងគ្រឹះស្ថានសិក្សាសាធារណៈ ឬ ឯកជនដែលមានការទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច និងមានលិខិតបញ្ជាក់ការសិក្សាត្រឹមត្រូវ និងកូនពិការ ឬមានជំងឺរ៉ាំរ៉ៃមិនមានលទ្ធភាពធ្វើការងារដែលមានប្រាក់ឈ្នួល[71] ។

៣. ឪពុកម្តាយ ឬមនុស្សចាស់ជរា ដែលស្ថិតនៅក្រោមអាណាព្យាបាល និងនៅក្នុងបន្ទុកដោយផ្ទាល់នៃអ្នករងគ្រោះ ក្នុងឱកាសដែលមានគ្រោះថ្នាក់។

## ការគណនាប្រាក់សោធនឧត្តរជីវី

❖ **ក្នុងករណីសិទ្ធិវន្ត មានរួមទាំងប្រពន្ធ ឬប្តី កូន និងឪពុកម្តាយ ឬមនុស្សចាស់ជរានៅក្នុងបន្ទុក**

- ប្រពន្ធ ឬប្តី = ៣/៥ x ៦៣% បឈម

- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២/៥ x ៦៣% បឈម

- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ៧% បឈម

---

[69] មាត្រា ២០ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារ

[70] មាត្រា ៣៩ កថាខណ្ឌ៣ នៃអនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

[71] មាត្រា ៣៩ កថាខណ្ឌ១ ចំណុច ខ នៃអនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

### ❖ ក្នុងករណីសិទ្ធិវន្ត មានតែប្រពន្ធ ឬប្តី និង/ឬ កូន

- ប្រពន្ធ ឬ ប្តី = ៣/៥ x ៧០% បឈម

- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក =២/៥ x ៧០% បឈម

### ❖ ក្នុងករណីសិទ្ធិវន្តមានតែឪពុកម្តាយ ឬមនុស្សចាស់ជរា

- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុកចាស់ជរា = ២៨% បឈម

### ❖ ក្នុងករណីសិទ្ធិវន្ត មានតែកូន និងឪពុកម្តាយ ឬមនុស្សចាស់ជរា

- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២៨% បឈម
- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ២៨% បឈម

### ❖ ក្នុងករណីសិទ្ធិវន្តមានតែ ប្រពន្ធ ឬប្តី និងឪពុកម្តាយ ឬមនុស្សចាស់ជរា

- ប្រពន្ធ ឬប្តី = ២៨% បឈម
- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក= ២៨% បឈម

សិទ្ធិវន្ត ជាប្រពន្ធ ឬប្តីនៃជនរងគ្រោះ ត្រូវមានលិខិតបញ្ជាក់អាពាហ៍ពិពាហ៍។ សិទ្ធិទទួលធនលាភចំពោះ ប្រពន្ធ ឬប្តី ត្រូវបានរំលាយនៅពេលសាមីជនរៀបអាពាហ៍ពិពាហ៍ជាថ្មី។ ក្នុងករណីនៃការរៀបអាពាហ៍ជាថ្មី សាមីជនត្រូវជូនដំណឹងមកបេឡាជាតិរបបសន្តិសុខសង្គមយ៉ាងយូរបំផុត ៣០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការចុះលិខិតបញ្ជាក់អាពាហ៍ពិពាហ៍។ ការខកខានមិនបានជូនដំណឹងអំពីការរៀបអាពាហ៍ពិពាហ៍របស់ខ្លួន សាមីជននឹងត្រូវទទួលទោសដូចមានចែងក្នុងមាត្រា ៣៨ [72] នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។ រាល់សិទ្ធិវន្តទាំងអស់ត្រូវបានបាត់បង់នូវសិទ្ធិរបស់ខ្លួននៅពេលដែលសិទ្ធិទាំងអស់នោះបាត់បង់ជីវិត[73] ។

---

[72] ជនណាក៏ដោយដែលធ្វើឯកសារក្លែងបន្លំដោយចេតនា ដើម្បីចង់បានការផ្តល់តាវកាលិកសម្រាប់ខ្លួន ឬតតិយជនដែលមិនគួរត្រូវបាន ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ហុកសិប (៦០) ថ្ងៃ ទៅកៅសិប (៩០) ថ្ងៃនៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ និងផ្តន្ទាទោសដាក់ពន្ធនាគារពីប្រាំមួយ (៦) ថ្ងៃ ទៅមួយ (១) ខែ ឬក៏ត្រូវផ្តន្ទាទោសណាមួយក្នុងចំណោមទោសទាំងពីនៃ។ ការដាក់ទណ្ឌកម្មខាងលើនេះ ត្រូវធ្វើដោយមិនទាន់គិតដល់ទោសកំហុសដទៃទៀត ប្រសិនបើជននេះបានប្រព្រឹត្តផងដែរ។

ក្នុងករណីមិនរាងចាលក្នុងអំឡុងពេលមួយ (១) ឆ្នាំ ត្រូវទទួលការដាក់ទណ្ឌកម្មដល់កំរិតអតិបរមា គឺទណ្ឌកម្មទាំងពីររួមគ្នាតែម្តង។

[73] ប្រកាសលេខ ១០៩ កប/ប្រក ស្តីពីតាវកាលិកហានិភ័យការងារ ប្រការ ១១

### ឃ.២ វិភាជន៍បូជាសព

នៅពេលកម្មករនិយោជិត ដែលជាសមាជិកបេឡាជាតិរបបសន្តិសុខសង្គម បានទទួលរងហានិភ័យការងារដល់ថ្នាក់បាត់បង់ជីវិត អ្នកទទួលរ៉ាប់រងក្នុងការចាត់ចែងបូជាសព ត្រូវបានផ្ដល់ប្រាក់វិភាជន៍ជាសោហ៊ុយបូជាសព ដែលមានចំនួន ៩.០០០.០០០ **(មួយលាន)** រៀល។ ប្រាក់វិភាជន៍នេះត្រូវតែផ្ដល់ជូនទៅជន ដែលទទួលបន្ទុកផ្ទាល់ក្នុងការចាត់ចែងបូជាសពជនរងគ្រោះ[74] ។

## ផ្នែកទី២ : តាវកាលិកផ្នែកថែទាំសុខភាព

ក្រៅពីតាវកាលិកហានិភ័យការងារ ក៏នៅមានតាវកាលិកផ្សេងៗទៀតដែល ប.ស.ស សម្រេចផ្ដល់ឱ្យសមាជិករបស់ផងដែរ នៅក្នុងនោះតាវកាលិកផ្នែកថែទាំសុខភាពជាតាវកាលិកមួយដែលផ្ដល់នូវ សារៈប្រយោជន៍យ៉ាងច្រើនទៅដល់កម្មកនិយោជិត ក៏ដូចជាសមាជិកនៃបេឡាជាតិរបបសន្តិសុខសង្គម ដូច្នេះដើម្បីដឹងច្បាស់ថាតើតាវកាលិកផ្នែកថែទាំសុខភាពនេះផ្ដល់នូវអត្ថប្រយោជន៍អ្វីខ្លះទៅសមាជិក ប.ស.ស យើងចាំបាច់ត្រូវស្គាល់ឱ្យបានច្បាស់ថាតើការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព **(កថាខណ្ឌ១)** នេះក្នុងគោលដៅអ្វី ហើយមានយន្តការក្នុងការអនុវត្តដូចម្ដេចចំពោះរបបសន្តិសុខផ្នែកថែទាំសុខភាពនេះ? **(កថាខណ្ឌ២)**

### កថាខណ្ឌ១ : ការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព

របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ត្រូវបានបង្កើតឡើងគោលដៅផ្ដល់ជូនសមាជិក ប.ស.ស នូវសេវាបង្ការសុខភាព និងតាវកាលិកព្យាបាលនិងថែទាំវិជ្ជសាស្ត្រ និងការផ្ដល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលនៃការផ្អាកការងារដោយការព្យាបាលជម្ងឺ ឬ គ្រោះថ្នាក់ផ្សេងៗក្រៅពីហានិភ័យការងារ និងការសម្រាកមាតុភាព។

មុននឹងឈានដល់ ការបកស្រាយឱ្យច្បាស់លាស់ពី របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព យើងចាំបាច់ត្រូវស្គាល់ពីពាក្យ គន្លឹះជាមុនសិនៈ

- **ថែទាំសុខភាព** សំដៅដល់ការធានារ៉ាប់រងសុខភាពសង្គមដែលត្រូវបានផ្ដល់តាវកាលិកសេវាបង្ការសុខភាព តាវកាលិកព្យាបាលនិងថែទាំវេជ្ជសាស្ត្រ និងការផ្ដល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលនៃការផ្អាកការងារដោយការព្យាបាលជម្ងឺ ឬគ្រោះថ្នាក់ផ្សេងៗក្រៅពីហានិភ័យការងារ និងការសម្រាកមាតុភាព។

[74] ប្រកាសលេខ ១០៩ កប/ប្រក ស្ដីពីតាវកាលិកហានិភ័យការងារ ប្រាការ ១០

- **តាវកាលិក** សំដៅដល់ការផ្តល់សេវាបង្ការសុខភាព សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃនៅពេលសម្រាកព្យាបាលជម្ងឺ ឬ គ្រោះថ្នាក់ផ្សេងៗក្រៅពីហានិភ័យការងារ និងមាតុភាព។

### ក. ស្ថាប័នមានសមត្ថកិច្ច

ដើម្បីអនុវត្តនូវរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ឱ្យប្រព្រឹត្តទៅយ៉ាងរលូន និងត្រឹមត្រូវតាមច្បាប់ក្នុងនោះ **បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)** គឺជាស្ថាប័នតែមួយគត់ដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារ[75]។

ក្រៅពីនេះទៅទៀត ក៏មានក្រុមប្រឹក្សាជាន់ខ្ពស់មួយ ដែលជាបញ្ញត្តិករប្រព័ន្ធសន្តិសុខសង្គម ដើម្បីគ្រប់គ្រងធ្វើអធិការកិច្ច តាមដាន ត្រួតពិនិត្យរាល់ការគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពរបស់ ប.ស.ស និងកំណត់គោលនយោបាយអភិវឌ្ឍន៍ប្រព័ន្ធសន្តិសុខសង្គម[76]។

### ខ. ភាគទាន តាវកាលិក និងប្រាក់បម្រុងផ្នែកថែទាំសុខភាព

ដូចដែលបានរៀបរាប់ខាងលើ របបសន្តិសុខសង្គមផ្នែកហានិភ័យការងារត្រូវបានបង្កើតឡើងដើម្បីផ្តល់នូវសេវាបង្ការសុខភាព ក៏ដូចជាតាវកាលិកព្យាបាលនិងថែទាំវិជ្ជសាស្ត្រ និងការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់សមាជិក ប.ស.ស ដែលស្ថិតក្រោមបទប្បញ្ញត្តិស្តីពីការងារ និងសហព័ទ្ធព្រមទាំងកូនដែលស្ថិតក្រោមបន្ទុកផ្ទាល់នៃកម្មករនិយោជិតដែលជាសមាជិក ប.ស.ស។

នៅក្នុងនោះដែល ការផ្តល់ក៏ដូចជាទទួលបាននូវសេវាថែទាំសុខភាព ឬរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សមាជិក ប.ស.ស ទាំងអស់ត្រូវបង់ភាគទានផ្នែកថែទាំសុខភាព(១) ដើម្បីទទួលបាននូវ **តាវកាលិកផ្នែកថែទាំសុខភាព(២)** និង **ប្រាក់បម្រុងផ្នែកថែទាំសុខភាព(៣)**។

---

[75] មាត្រា ៥ នៃអនុក្រឹត្យលេខ ០១អនក្រ/បក ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

[76] មាត្រា ៦ នៃអនុក្រឹត្យលេខ ០១អនក្រ/បក ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

### ខ.១ ភាគទានផ្នែកថែទាំសុខភាព

ចំពោះនិយោជក និងកម្មករនិយោជិត ដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយណាដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវមានកាតព្វកិច្ចបង់ភាពទានផ្នែកថែទាំសុខភាពជូនដល់ ប.ស.ស។ ផ្នែកនៃភាគទានដែលជាបន្ទុករបស់កម្មករនិយោជិត មិនត្រូវលើសពីផ្នែកនៃភាគទានដែលជាបន្ទុករបស់និយោជកឡើយ។

ចំពោះបែបបទ និងនីតិវិធីនៃការបង់ភាគទាននៃអត្រាភាគទានផ្នែកថែទាំសុខភាព ត្រូវកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើររបស់ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស[77]។

### ខ.២ តាវកាលិកផ្នែកថែទាំសុខភាព

តាវកាលិកដែលត្រូវបានកំណត់ដើម្បីផ្តល់ឱ្យសមាជិក ប.ស.ស រួមមាន ការផ្តល់សេវាបង្ការសុខភាព ការព្យាបាល ការថែទាំវិជ្ជសាស្ត្រ និងការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលនៃការផ្អាកការងារដោយការព្យាបាលជម្ងឺ ឬគ្រោះថ្នាក់ផ្សេងៗក្រៅពីហានិភ័យការងារ និងការសម្រាកមាតុភាព។

ប្រភេទសេវា និងជម្ងឺដែលមិនទាន់បានដាក់បញ្ចូលក្នុងតាវកាលិកផ្នែកថែទាំសុខភាព ត្រូវកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើររបស់ក្រុមប្រឹក្សា ភិបាលនៃ ប.ស.ស។ ចំពោះបែបបទ និតនីតិវិធី នៃការផ្តល់តាវកាលិកផ្នែកថែទាំសុខភាព ក៏ដូចជាយន្តការនៃការទូទាត់ចំណាយសេវាបង្ការសុខភាព ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រក៏ត្រូវកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើររបស់ក្រុមប្រឹក្សាភិបាលនៃ ប.ស.សផងដែរ។

ការទទួលបានតាវកាលិកផ្នែកថែទាំសុខភាព ត្រូវអនុឡោមតាមលក្ខខណ្ឌដែលពាក់ព័ន្ធនឹងរយៈពេលធានារ៉ាប់រង និងរយៈពេលយោង ដែលលក្ខខណ្ឌទាំងនេះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណោះរបស់ក្រុមប្រឹក្សានៃ ប.ស.ស[78]។

---

[77] មាត្រា ៧ នៃអនុក្រឹត្យលេខ ០១អនក្រ/បក ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

[78] មាត្រា ៨ នៃអនុក្រឹត្យលេខ ០១អនក្រ/បក ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

### ខ.៣ ប្រាក់ត្រៀមបម្រុងផ្នែកថែទាំសុខភាព

ប្រាក់ត្រៀមបម្រុងផ្នែកថែទាំសុខភាព ក៏ជាកត្តាសំខាន់ក្នុងការអនុវត្តរបបសន្តិសុខផ្នែកថែទាំ ព្រោះការកំណត់ជាក់លាក់នៃប្រាក់ត្រៀមបម្រុងផ្នែកថែទាំសុខភាព បានផ្តល់ផលប្រយោជន៍យ៉ាងច្រើនទៅដល់សមាជិក ប.ស.ស ក្នុងការប្រឈមមុខនិងបញ្ហាណាមួយសម្រាប់នៃការចំណាយសម្រាប់តាវកាលិក។

ហេតុដូច្នេះហើយ ប្រាក់ត្រៀមបម្រុងផ្នែកថែទាំសុខភាព ត្រូវបានកំណត់ឱ្យស្មើទៅនឹងចំនួនទឹកប្រាក់ដែលបានចំណាយសម្រាប់តាវកាលិក ក្នុងអំឡុងពេល ០១ (មួយ) ឆ្នាំចុងក្រោយ[79] ដើម្បីជៀសវាងនូវការកើតមានហានិភ័យណាមួយកើតឡើងដែលធ្វើឱ្យ សមាជិក ប.ស.ស មិនអាចប្រឈមមុខភ្លាមៗបាន។

## គ. ការទទួលស្គាល់ និងការត្រួតពិនិត្យគុណភាព សេវារបស់មូលដ្ឋានសុខាភិបាល

បន្ទាប់ពីបានស្គាល់ច្បាស់អំពី ការបង្កើតនូវរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពក៏ដូចជាស្ថានប័នមានសមត្ថកិច្ច និងការបង់ភាពទានផ្នែកថែទាំសុខភាពរួចមក យើងចាំបាច់ត្រូវតែយល់ដឹងឱ្យបានច្បាស់បន្ថែមទៀតអំពី**ការទទួលស្គាល់ (គ.១)** ជាពិសេសគឺ**ការត្រួតពិនិត្យគុណភាព** និង **សេវារបស់មូលដ្ឋានសុខាភិបាល(គ.២)** ដើម្បីធានាឱ្យបាននូវគុណភាពក្នុងការអនុវត្តនូវរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពបានកាន់តែល្អប្រសើរ។

### គ.១ ការទទួលស្គាល់គុណភាពសេវា

ការទទួលស្គាល់គុណភាពសេវា គឺចំណុចចម្បងដែលមិនអាចខ្វះបាន ព្រោះវានឹងផ្តល់ភាពងាយស្រួលទាំងការអនុវត្តពីសំណាក់បេឡាជាតិរបបសន្តិសុខសង្គម និងការទទួលបានផលប្រយោជន៍របស់សមាជិក ប.ស.ស។

ហេតុដូចនេះ ដើម្បីផ្តល់នូវសេវាថែទាំសុខភាពប្រកបដោយគុណភាព និងការទទួលស្គាល់រាល់ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ចាំបាច់ត្រូវផ្តល់ដោយមូលដ្ឋានសុខាភិបាលណា ដែលមានការទទួលស្គាល់ពីក្រសួងសុខាភិបាល និងបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.សតែប៉ុណ្ណោះ[80]។

[79]មាត្រា ១០ នៃអនុក្រឹត្យលេខ ០១អនក្រ/បក ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

[80] មាត្រា ១១ នៃអនុក្រឹត្យលេខ ០១អនក្រ/បក ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

ការធ្វើបែបនេះ បានបង្ហាញឱ្យឃើញថា បេឡាជាតិរបបសន្តិសុខសង្គម ពិតធ្វើការត្រួតពិនិត្យ និងអនុវត្ត យ៉ាងជាក់លាក់ ដើម្បីធ្វើយ៉ាងណាធានាឱ្យបាននូវគុណភាពដ៏ល្អប្រសើរសម្រាប់ផ្តល់ជូន សមាជិក ប.ស.សពិតប្រាកដមែន។

ការទទួលស្គាល់គុណភាពសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ត្រូវអនុវត្តស្របតាមគោលការណ៍ ដែលកំណត់ដោយក្រសួងសុខាភិបាល។

## គ.២ ការត្រួតពិនិត្យគុណភាពសេវា និងសេវារបស់មូលដ្ឋានសុខាភិបាល

បើទោះបីជាមានការទទួលស្គាល់នូវគុណភាពសេវា ពីសំណាក់ក្រសួងសុខាភិបាលក៏ដោយ ក៏ការត្រួតពិនិត្យ តាមដាន និងឃ្លាំមើលនៅតែបន្តដដែល។ ការអនុវត្តបែបនេះ គឺមិនមែនបានន័យថាក្រសួងសុខាភិបាលខ្វះសមត្ថភាព ក្នុងការទទួលស្គាល់គុណភាពនោះឡើយ ផ្ទុយទៅវិញ សកម្មភាពទាំងនេះបានបង្ហាញឱ្យឃើញថា បេឡាជាតិរបបសន្តិសុខសង្គមពិតជាយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការផ្តល់នូវសេវាថែទាំសុខភាព និងសេវាព្យាបាលបានយ៉ាងល្អិតល្អន់ជូនទៅដល់សមាជិក ប.ស.ស ព្រមទាំងប្តេជ្ញាយ៉ាងម៉ុតមាំតាមរយៈការអនុម័តច្បាប់ និងសកម្មភាពផ្ទាល់ក្នុងការបម្រើផលប្រយោជន៍ដល់សមាជិក ប.ស.ស ទាំងអស់។

ផ្អែកតាមគោលការណ៍ ក៏ដូចជាការកំណត់ទៅតាមច្បាប់ និងអនុក្រឹត្យ ដែលបានកំណត់ដោយរាជរដ្ឋាភិបាល បានបញ្ជាក់ថា គុណភាពសេវារបស់មូលដ្ឋានសុខាភិបាល ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ តាមដាន និងឃ្លាំមើលរបស់គណៈកម្មការវេជ្ជសាស្ត្រនៃ ប.ស.ស ដើម្បីសម្រេចឱ្យបាននូវគុណភាពមួយដ៏ល្អប្រសើរ និងពិតប្រាកដជូនទៅដល់ សមាជិក ប.ស.ស ព្រមទាំងបង្ហាញឱ្យឃើញអំពីភាពសកម្មក្នុងការអនុវត្តនូវវិធានគតិយុត្តដែលរដ្ឋាភិបាលបានកំណត់ផងដែរ។

ចំពោះសមសភាព និងតួនាទីភារកិច្ចរបស់គណៈកម្មការវេជ្ជសាស្ត្រ នៃ ប.ស.ស ត្រូវកំណត់ដោយប្រកាស របស់អន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមសំណើររបស់ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស[81]។

## កថាខណ្ឌ ២ យន្តការនៃការអនុវត្តរបបសន្តិសុខផ្នែកថែទាំសុខភាព

ជាគោលការណ៍ ការអនុវត្តនូវវិធានគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជា តែងតែផ្សាភ្ជាប់មកជាមួយនូវនីតិវិធី ឬយន្តការនៃការអនុវត្តនៃរបបគតិយុត្តនោះ។ ជាក់ស្តែងនៅក្នុងរបបសន្តិសុខ

[81]មាត្រា ១២ នៃអនុក្រឹត្យលេខ ០១អនក្រ/បក ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

សង្គមផ្នែកថែទាំសុខភាព ក៏បានផ្សាភ្ជាប់មកជាមួយនូវយន្តការក្នុងការអនុវត្តដូចទៅនឹងវិធានគិតិយុត្តផ្សេងៗផងដែរ។ ក្នុងនោះវិធានគតិយុត្តនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព បានកំណត់នូវដំណាក់កាល និងកាលបរិច្ឆេទនៃការអនុវត្តនូវរបបនេះបានយ៉ាងជាក់លាក់។ លើសពីនេះទៅទៀត ប.ស.ស ក៏បានកំណត់យ៉ាងច្បាស់អំពីតារកាលិកដែលសមាជិករបស់ខ្លួនត្រូវទទួលបាន ព្រមទាំងលក្ខខណ្ឌ និងផលប្រយោជន៍នៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពទៅតាមគោលការណ៍ដែល ប.ស.ស បានកំណត់។

## ក. ការកំណត់ដំណាក់កាលនៃការអនុវត្ត និងកាលបរិច្ឆេទនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព

ដំណាក់កាលដំបូងនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព គឺនឹងត្រូវធ្វើការអនុវត្តដំបូងចំពោះតែសមាជិកប.ស.ស និងឧត្តរជីវីតែប៉ុណ្ណោះ។

ការផ្តល់សេវាថែទាំសុខភាពចំពោះសហព័ទ្ធ និងកូនដែលនៅក្នុងបន្ទុករបស់សាមីជនត្រូវអនុវត្តជាបន្តបន្ទាប់អនុឡោមតាមស្ថានភាព សង្គម សេដ្ឋកិច្ចជាក់ស្តែង ដែលត្រូវកំណត់ដោយប្រកាស ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមសំណើររបស់ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស[82]។

របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពត្រូវបានអនុវត្តចំពោះកម្មករនិយោជិត នៃសហគ្រាសគ្រឹះស្ថាន ដែលបានចុះបញ្ជិការក្នុងផ្នែកថែទាំសុខភាព និងត្រូវបានអនុវត្តតាមពីរដំណាក់ផ្សេងគ្នា គឺ **សមាជិក ប.ស.ស** ឬ កម្មករនិយោជិត និង **ឧត្តរជីវី** ឬ អ្នកនៅក្នុងបន្ទុកផ្ទាល់របសសាមីជនដែលជាសមាជិក ប.ស.ស[83]។

### ក.១ ការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពចំពោះសមាជិក ប.ស.ស

ដូចដែលបានរៀបរាប់ខាងលើ ដំណាក់កាលដំបូងនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ត្រូវបានគេអនុវត្តដំបូងបង្អស់ចំពោះតែ សមាជិកប.ស.ស ឬ កម្មករនិយោជិត ដែលបានចុះបញ្ជិកាផ្នែកថែទាំសុខភាព ជនរងគ្រោះថ្នាក់ការងារ ដែលបាត់បង់សមត្ថភាពអចិន្ត្រៃយ៍តែប៉ុណ្ណោះ។

[82]មាត្រា ១៣ នៃអនុក្រឹត្យលេខ ០១អនក្រ/បក ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

[83]ប្រការ ២ នៃប្រកាសលេខ ០៩៣/១៦ កប/ប្រក ស្តីពីការកំណត់ដំណាក់កាល និងកាលបរិច្ឆេទនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព

ការកំណត់បែបនេះ មិនមែនជាការរើសអើងចំពោះ អ្នកនៅក្នុងបន្ទុករបស់សាមីជនដែលជាសមាជិក ប.ស.ស ឬ កម្មករនិយោជិតដែលបានចុះបញ្ជិកាផ្នែកថែទាំសុខភាពទេ ប៉ុន្តែវាគឺសំដៅទៅដល់ការគោរព និងអនុវត្តយ៉ាងម៉ឺងម៉ាត់ទៅតាមគោលការណ៍ច្បាប់ និងឋានានុក្រមក្នុងការទទួលបានសេវាថែទាំសុខភាពដូចបានកំណត់ក្នុងអនុក្រឹត្យ លេខ ០១អនក្រ.បក ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារតែប៉ុណ្ណោះ។

និយាយជារួមមក ការអនុវត្តបែបនេះបានបង្ហាញឱ្យឃើញពីភាពស្មើគ្នា ក្នុងការប្រតិបត្តិនូវរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ឱ្យមានភាពត្រឹមត្រូវ និងច្បាស់លាស់ទៅតាមការកំណត់របស់រដ្ឋាភិបាល ពោលគឺផ្តល់នូវសេវាថែទាំសុខភាព ដ៏ល្អប្រសើរទៅដល់សមាជិក ប.ស.ស ទាំងអស់។

### ក.២ ការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពចំពោះឧត្តរជីវី

បន្ទាប់ពីអនុវត្តនូវដំណាក់កាលដំបូងចំពោះ សមាជិក ប.ស.ស ឬ កម្មករនិយោជិតដែលបានចុះបញ្ជិកាផ្នែកថែទាំសុខភាពរួចមក ដំណាក់កាលបន្ទាប់មកទៀតគឺជា ការអនុវត្តចំពោះឧត្តរជីវី ឬ អ្នកនៅក្នុងបន្ទុកផ្ទាល់របស់សាមីជនដែលជាសមាជិក ប.ស.ស ឬ សហព័ទ្ធ និងកូននៅក្នុងបន្ទុកផ្ទាល់របស់សាមីជនដែលជាសមាជិក ប.ស.ស។

ការអនុវត្តនូវរបបថែទាំសុខភាពនេះ ត្រូវចាប់ផ្តើមចេញពី សហគ្រាស គ្រឹះស្ថានដែលស្ថិតនៅក្នុងភូមិសាស្ត្រ រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ និងជាបន្តបន្ទាប់ឈានទៅកាន់ខេត្តដទៃទៀត ស្របតាមស្ថានភាពបច្ចេកទេស និងភូមិសាស្ត្រជាក់ស្តែង [84] ។ ចំពោះសហគ្រាស គ្រឹះស្ថាន ដែលបេឡាជាតិរបបសន្តិសុខសង្គមពុំទាន់បានចុះបញ្ជិកា ក្នុងផ្នែកថែទាំសុខភាពទេ ត្រូវបន្តអនុវត្តតាម **អនុសញ្ញារួម** បទបញ្ជាផ្ទៃក្នុងស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងាររហូតដល់មានចុះបញ្ជិកាជាផ្លូវការពី ប.ស.ស[85]។

[84]ប្រការ ៣ នៃប្រកាសលេខ ០៩៣/១៦ កប/ប្រក ស្តីពីការកំណត់ដំណាក់កាល និងកាលបរិច្ឆេទនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព

[85]ប្រការ ៤ នៃប្រកាសលេខ ០៩៣/១៦ កប/ប្រក ស្តីពីការកំណត់ដំណាក់កាល និងកាលបរិច្ឆេទនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព

របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយ ដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវចាប់ផ្តើមអនុវត្តចាប់ពី**ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ២០១៦**តទៅ[86]។

### ខ. ការផ្តល់តាវកាលិកថែទាំសុខភាព

តាវកាលិកថែទាំសុខភាពត្រូវបានបង្កើតឡើងក្នុងគោលបំណង ផ្តល់នូវការថែទាំសុខភាពជូនទៅសមាជិក ប.ស.ស ជាពិសេសគឺកម្មករនិយោជិតដែលបានចុះបញ្ជិកានៅបេឡាជាតិរបបសន្តិសុខសង្គមនេះតែម្តង។ ដោយឡែកមុននឹងឈានទៅដល់ការបកស្រាយយ៉ាងល្អិតល្អន់អំពីការផ្តល់សេវាថែទាំសុខភាពនេះ យើងចាំបាច់សិក្សានូវពាក្យស័ព្ទសំខាន់ៗជាមុនសិនៈ

- **តាវកាលិកថែទាំសុខភាព** គឺសំដៅដល់របបធានារ៉ាប់រង ដែលផ្តល់កញ្ចប់តាវកាលិកសុខភាព និងសេវាបង្ការដែលបានកំណត់។
- **កញ្ចប់តាវកាលិកសុខភាព** សំដៅដល់សេវាព្យាបាលថែទាំវេជ្ជសាស្ត្រ សេវាបញ្ជូនជនរងគ្រោះ សេវាបញ្ជូនសព និងប្រាក់បំណាច់ប្រចាំថ្ងៃ។
- **សេវាបង្ការសុខភាព** សំដៅដល់ការធ្វើរោគវិនិច្ឆ័យទាន់ពេលវេលា កំណត់អត្តសញ្ញាណអ្នកដែលមានហានិភ័យសុខភាព និងបញ្ហាសុខភាពជាក់លាក់ ការផ្តល់ប្រឹក្សា និងអន្តរាគមន៍ចាំបាច់ដទៃទៀត ដើម្បីការពារកុំឱ្យមានបញ្ហាសុខភាព មានជាអាទិ៍ ការស្រាវជ្រាវរកជម្ងឺ ការអប់រំសុខភាព និងកម្មវិធីចាក់ថ្នាំបង្ការ។
- **សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ** សំដៅដល់សេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ។
- **សេវាវេជ្ជសាស្ត្រ** សំដៅដល់សេវាពីគ្រោះជម្ងឺក្រៅ និងសេវាសម្រាកពេទ្យ។
- **សេវាអមវិជ្ជសាស្ត្រ** សំដៅដល់សេវាមន្ទីពិសោធន៍ និងរូបភាពវិជ្ជសាស្ត្រ
- **សេវាជំនួយវិជ្ជសាស្ត្រ** សំដៅដល់ការព្យាបាលដោយស្ពំ និងដោយចលនា។
- **បច្ចេកទេសវិជ្ជាជីវៈវិជ្ជសាស្ត្រ** សំដៅដល់ការវិធីសាស្ត្រ នៃការធ្វើរោគវិនិច្ឆ័យ ការផ្តល់សេវាព្យបាលថែទាំ ដែលផ្តល់ដោយអ្នកបញ្ចប់ការសិក្សាក្នុងវិស័យសុខាភិបាល ហើយត្រូវបានចុះបញ្ជិកាជាមួយគណៈវិជ្ជាជីវៈពេទ្យ និងត្រូវបានអនុញ្ញាតច្បាប់ឱ្យប្រកបមុខរបរតាមវិជ្ជាជីវៈដោយក្រសួងសុខាភិបាល។

[86] ប្រការ ៥ នៃប្រកាសលេខ ០៩៣/១៦ កប/ប្រក ស្តីពីការកំណត់ដំណាក់កាល និងកាលបរិច្ឆេទនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព

- **សេវាស្តារនីតិសម្បទា** គឺជាសេវាព្យាបាលថែទាំវេជ្ជសាស្ត្រសម្រាប់របបថែទាំសុខភាពក្នុងគោលបំណងជួយដល់ជនរងគ្រោះរក្សា ស្តារ ឬធ្វើឱ្យប្រសើរឡើងវិញនូវសមត្ថភាពជំនាញ និងមុខងារសម្រាប់ការរស់នៅប្រចាំថ្ងៃ និងជំនាញប្រាស្រ័យទាក់ទងដែលបានបាត់បង់ ឬខូចខាតដោយសារជម្ងឺ ការរងរបួស ឬពិការភាព
- **សល្យសាស្ត្រ** សំដៅដល់ការវះកាត់តាមរបៀបវិជ្ជាសាស្ត្រក្នុងបំណងព្យាបាល។
- **មូលដ្ឋានសុខាភិបាល** សំដៅដល់អង្គភាពសុខាភិបាលសាធារណៈ ឬឯកជន ដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល។
- **សម្រាកមាតុភាព** សំដៅដល់ការសម្រាកមុន និងក្រោយពេលសម្រាលកូន។
- **សេវាពិគ្រោះជម្ងឺក្រៅ** សំដៅដល់សេវាពិនិត្យ និងពិគ្រោះជម្ងឺក្រៅ ដោយមិនរាប់បញ្ចូលការសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ[87]។

ក្រោយពីបានយល់ច្បាស់អំពីអត្ថន័យនៃវាក្យស័ព្ទសំខាន់ៗខាងលើរួចមក យើងនឹងចាប់ផ្តើមធ្វើការបកស្រាយយ៉ាងជាក់លាក់ទាក់ទងទៅនឹងតារកាលិកផ្នែកថែទាំសុខភាព ថាតើវាបានផ្តល់នូវអត្ថប្រយោជន៍អ្វីខ្លះទៅសមាជិក ប.ស.ស? ហើយថាតើអ្វីទៅជាកញ្ចប់តាវកាលិក ថែទាំសុខភាព និងសេវាថែទាំសុខភាព?

### ខ.១ កញ្ចប់តាវកាលិកថែទាំសុខភាព និងសេវាថែទាំសុខភាព

កញ្ចប់តាវកាលិកថែទាំសុខភាព [88] គឺជាកញ្ចប់មួយដែលផ្តល់ទាំងសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ សេវាបញ្ជូនអ្នកជម្ងឺ ឬជនរងគ្រោះ សេវាបញ្ជូនសព និងប្រាក់បំណាច់ប្រចាំថ្ងៃផងដែរ។

ដើម្បីបញ្ជាក់ឱ្យបានច្បាស់នូវសេវាសេវា ដែលស្ថិតក្នុងកញ្ចប់តាវលិកថែទាំសុខភាពខាងលើ យើងនឹងធ្វើការបែងចែងនូវចំណុច បី តូចៗមកធ្វើការពន្យល់ និងពណ៌នាឱ្យបានក្បោះក្បាយ។

#### ខ.១.១ សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ

សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រត្រូវបានបែងចែកជាប្រាំមួយផ្នែកតូចទៀតគឺ ការព្យាបាលដោយសម្រាកនៅក្នុងមន្ទីរពេទ្យ សេវាពិគ្រោះជម្ងឺក្រៅ សេវាសង្គ្រោះបន្ទាន់ សេវាព្យាបាលដោយស្នំ និងដោយចលនា សេវាសម្រាលកូន និងព្យាបាលថែទាំមុន និងក្រោយពេលសម្រាលកូន និងសេវាស្តារនីតិសម្បទាន។

---

[87] ប្រការ ២ នៃប្រកាសលេខ ១០៩ ក.ប/ ប្រ.ក ស្តីពីពីតាវកាលិកថែទាំសុខភាព

[88] ប្រការ ៣ នៃប្រកាសលេខ ០៩៣/១៦ កប/ប្រក ស្តីពីការកំណត់ដំណាក់កាល និងកាលបរិច្ឆេទនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព

### ការព្យាបាលដោយសម្រាកនៅក្នុងមន្ទីរពេទ្យ

ចំពោះសេវាដែលត្រូវបានកំណត់ជា ការព្យាបាលដោយសម្រាកនៅក្នុងមន្ទីរពេទ្យ ហើយត្រូវបានចាត់ចូលទៅក្នុងកញ្ចប់តារាកាលិកថៃទាំសុខភាពមានដូចតទៅ៖

- សេវាព្យាបាលថៃទាំតាមបច្ចេកទេសវិជ្ជសាស្ត្រ
- សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ និងសេវាពិនិត្យវេជ្ជសាស្ត្រផ្សេងទៀត។
- ឧបករណ៍ផ្នែកសល្យសាស្ត្រ និងសម្ភារៈបរិក្ខាផ្នែកវេជ្ជសាស្ត្រផ្សេងៗដែលជាតម្រូវការចាំបាច់សម្រាប់ព្យាបាល។
- ឱសថតាមវេជ្ជបញ្ជា
- បន្ទប់ (**ធម្មតា**) និងអាហារដែលផ្តល់ដោយមូលដ្ឋានសុខាភិបាល។

### សេវាពិគ្រោះជម្ងឺក្រៅ

សេវាពិគ្រោះជម្ងឺក្រៅ ក៏បានកំណត់នូវលក្ខខណ្ឌ ឬសេវាដែលអាចរាប់បញ្ចូលទៅក្នុងកញ្ចប់តារាកាលិកផងដែរ ដោយនៅក្នុងនោះមានដូចជា៖

- សេវាព្យាបាលថៃទាំតាមបច្ចេកទេសវិជ្ជសាស្ត្រ
- សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ និងសេវាពិនិត្យវេជ្ជសាស្ត្រផ្សេងទៀត។
- បរិក្ខាសល្យសាស្ត្រ និងវេជ្ជសាស្ត្រផ្សេងៗដែលជាតម្រូវការចាំបាច់សម្រាប់ព្យាបាល។
- ឱសថតាមវេជ្ជបញ្ជា។

### សេវាសង្គ្រោះបន្ទាន់

សេវាសង្គ្រោះបន្ទាន់ គឺជាអន្តរាគមន៍ទាំងឡាយណា ដែលធ្វើឡើងក្នុងកាលៈទេសៈមួយដែលមិនបានគ្រោងទុក ហើយអន្តរាគមន៍ទាំងនោះអាចត្រូវធ្វើឡើងភ្លាមៗក្នុងគោលបំណងជួយសង្គ្រោះជីវិត ឬជួយការពារការបាត់បង់អវៈយវៈណាមួយនៃសរីរាង្គរបស់អ្នកជម្ងឺ ជនរងគ្រោះ។

### សេវាជំនួយវិជ្ជសាស្ត្រ

សេវាជំនួយវិជ្ជសាស្ត្រនេះគឺ សំដៅដល់ការព្យាបាលដោយស្តំ និងដោយចលនាដែលជាជំនួយបន្ថែមក្នុងការផ្តល់សេវាព្យាបាល។

**សេវាសម្រាលកូន**

សេវាសម្រាលកូន គឺសំដៅដល់សេវាព្យបាលថែទាំទាំងមុន និងក្រោយពេលសម្រាលកូន ពោលគឺជាការផ្តល់សេវាថែទាំសុខភាពចំពោះសមាជិក ប.ស.ស ទាំងឡាយណាដែលសម្រាលកូន ទាំងមុន និងក្រោយ។

**សេវាស្តារនីតិសម្បទា**

សេវាស្តារនីតិសម្បទា គឺជាការផ្តល់ដោយបេឡាជាតិសន្តិសុខសង្គមកម្មវិធីជាតិអង្គភាព ឬស្ថាប័ន និងអង្គការទាក់ទងទៅនឹងការស្តារ នីតិសម្បទាដទៃទៀត[៩១]។

សេវាស្តារនីតិសម្បទា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើររបស់ក្រុមប្រឹក្សាភិបាលបេឡាជាតិរបបសន្តិសុខសង្គម។

សរុបមក សេវានេះគឺជាសេវាព្យាបាលថែទាំវេជ្ជសាស្ត្រសម្រាប់របបថែទាំសុខភាព ក្នុងគោលបំណងជួយដល់ជនរងគ្រោះរក្សា ស្តារ ឬធ្វើឱ្យប្រសើរឡើងវិញនូវសមត្ថភាពជំនាញ និងមុខងារសម្រាប់ការរស់នៅប្រចាំថ្ងៃ និងជំនាញប្រាស្រ័យទាក់ទងដែលបានបាត់បង់ ឬខូចខាតដោយសារជម្ងឺ ការរងរបួស ឬពិការភាពដូចដែលបានរៀបរាប់ពីខាងលើ។

### ខ.១.២ សេវាបញ្ជូនអ្នកជម្ងឺ ឬជនរងគ្រោះនិងសេវាបញ្ជូនសព

សេវាបញ្ជូនអ្នកជម្ងឺ ឬជនរងគ្រោះនិងសេវាបញ្ជូនសព គឺជាសេវាមួយដែលស្ថិតនៅក្នុងកញ្ចប់តាវកាលិកផ្នែកថែទាំសុខភាព ពោលសេវានេះនឹងត្រូវបានផ្តល់ឱ្យសមាជិក ប.ស.ស ទាំងអស់ដែលជួបប្រទះនឹងហានិភ័យផ្នែកថែទាំសុខភាព ហើយចាំបាច់បញ្ជូនទៅសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យ ឬក៏ការបញ្ជូនសពរបស់ជនរងគ្រោះដែលជាសមាជិក ប.ស.ស ជាដើម។

### ខ.១.៣ ប្រាក់បំណាច់ប្រចាំថ្ងៃ

ប្រាក់បំណាច់ប្រចាំថ្ងៃ ដែលត្រូវបានរាប់បញ្ចូលនៅក្នុងកញ្ចប់តាវកាលិកផ្នែកថែទាំសុខភាព ត្រូវបានផ្តល់ជូនទៅសមាជិក ប.ស.ស ក្នុងពេលមានជម្ងឺ ឬជួបឧបទ្ទវហេតុផ្សេងៗដោយគិតបញ្ចូលទាំង**ចំណុច១** នៃ**ប្រការ៤** នៃប្រកាស ស្តីពីតាវកាលិកថែទាំសុខភាពនេះផងដែរ។

យ៉ាងណាមិញក៏មានសេវាមួយចំនួន ដែលគេមិនរាប់បញ្ចូលទៅក្នុងសេវាព្យាបាលវេជ្ជសាស្ត្រដែរ ដោយសេវានោះមានដូចជា៖

- ការព្យាបាលដោយមិនគិតថ្លៃ ដែលមានចែងនៅក្នុងគោលនយោបាយសុខាបាលសុខាភិបាលសាធារណៈ
- ការថែទាំធ្មេញ (ការសំអាតធ្មេញ ការប៉ះធ្មេញ និងការដាក់ធ្មេញ)
- ការព្យាបាល និងការវះកាត់ប្តូរភេទ
- ការផ្សាំ ឬប្តូរសរីរាង្គផ្សេងៗ
- សេវាបង្កកំណើតដោយសិប្បនិម្មិត
- ការព្យាបាលដោយខ្លួនឯង
- ការព្យាបាល ឬវះកាត់ដើម្បីជាប្រយោជន៍នៃការកែលម្អផ្នែកណាមួយនៃរាងកាយ
- ឧបករណ៍ជំនួយភ្នែកសិប្បនិម្មិត និងការព្យាបាលដោយកាំរស្មីឡាស៊ែ
- កាព្យាបាលញៀនសុរា និងផ្តាច់គ្រឿនញៀន
- ការព្យាបាលអសមត្ថភាពផ្តល់កំណើត
- ការវះកាត់ដោយដាក់គ្រាប់ភ្នែកសិប្បនិម្មិត
- ការវះកាត់បេះដូង និងសរសៃឈាមបេះដូង
- ការលាងឈាម
- ការព្យាបាលបហារីកដោយសារធាតុគីមី

ប្រភេទសេវាដែលមិនរាប់បញ្ចូល ដូចបានរៀបរាប់ខាងលើ អាចនឹងត្រូវបានពិនិត្យកែសម្រួលឡើងវិញដោយប្រការរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើររបស់ក្រុមប្រឹក្សា ភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម។ ក្នុងករណីសង្គ្រោះបន្ទាន់សេវាដូចមានចែងខាងលើត្រូវបានផ្តល់ជូន។

ការផ្តល់សេវាចំពោះជម្ងឺរ៉ាំរៃត្រូវធ្វើឡើងតែក្នុងមូលដ្ឋានសុខាភិបាលសាធារណៈនឹងត្រូវប្រើប្រាស់តែឱសថសារវន្តតែប៉ុណ្ណោះ។ ចំពោះឱសថក្រៅពីបញ្ជីឱសថសារវន្តជាបន្ទុកផ្ទាល់របស់អ្នកជម្ងឺ។

បញ្ជីជម្ងឺរ៉ាំរៃ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើររបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម។

## គ. លក្ខខណ្ឌ និងផលប្រយោជន៍ក្នុងការទទួលបានតាមការលិកថែទាំសុខភាព

អត្ថប្រយោជន៍គឺជាចំណុចសំខាន់ដែលសមាជិក ប.ស.ស ឬ កម្មករនិយោជិតទាំងអស់ទទួលបាន ពីរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ឬសេវាព្យាបាលថែទាំវេជ្ជសាស្ត្រ សមាជិក ប.ស.ស

ឬកម្មករនិយោជិតទាំងអស់ត្រូវបំពេញលក្ខខណ្ឌផ្សេងៗ ទៅតាមគោលការណ៍ដូចបានកំណត់ក្នុងប្រកាសរបស់ក្រសួង ក្នុងគោលដៅទទួលបានផលប្រយោជន៍ពីតាវកាលិកថែទាំសុខភាព។

### គ.១ លក្ខខណ្ឌក្នុងការទទួលបានតាវកាលិកថែទាំសុខភាព

ការទទួលបានតាវកាលិកថែទាំសុខភាព ក៏មានលក្ខខណ្ឌក្នុងការអនុវត្តរបស់វាផងដែរ ដោយនៅក្នុងនោះ ត្រូវបានបែងចែកជាពីគឺ ការទទួលបានផលប្រយោជន៍ពីសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ និងការទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃ។

#### គ.១.១ លក្ខខណ្ឌក្នុងការទទួលបានសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ

ដើម្បីទទួលបានសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ កម្មករនិយោជិតទាំងអស់ត្រូវបំពេញលក្ខខណ្ឌដូចតទៅ៖

- កំពុងបំពេញការងារក្នុងសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់របបថែទាំសុខភាព
- បានចុះបញ្ជិកានៅក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)
- បានបង់ភាគទានសម្រាប់ផ្នែកថែទាំសុខភាពក្នុងរយៈពេល ០២ (ពីរ) ខែជាប់គ្នា ឬបានបង់ភាគទានយ៉ាងតិច ០៦ (ប្រាំមួយ) ខែក្នុងអំឡុងពេល ១២ (ដប់ពីរ) ខែចុងក្រោយ គិតរហូតមកទល់ខែដែលមានបញ្ហាសុខភាព ឬមាតុភាព។

ក្នុងករណីដែលសមាជិកបានបង់ភាគទាន ០២ (ពីរ) ខែជាប់គ្នាហើយ ប៉ុន្តែអស់កាតព្វកិច្ចបង់ភាគទានដោយសារការបញ្ចប់កិច្ចសន្យាការងារ សមាជិកមានសិទ្ធិទទួលបានសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្ររយៈពេល ០២ (ពីរ) ខែថែមទៀត គិតចាប់ពីកាលបរិច្ឆេទនៃការបញ្ចប់កិច្ចសន្យាការងាររបស់សាមីជន។

សមាជិក ប.ស.ស ត្រូវទៅប្រើប្រាស់សេវាសុខាភិបាល នៅមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមជ្រៀងជាមួយ ប.ស.ស។ បេឡាជាតិរបបសន្តិសុខសង្គមនឹងទទួលខុសត្រូវទូទាត់ថ្លៃសេវាដូចមានកំណត់ក្នុងកញ្ចប់តាវកាលិកសុខភាព។ ប្រសិនបើសមាជិក ប.ស.ស ទៅប្រើប្រាស់សេវាក្រៅពីមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស នោះ ប.ស.ស នឹងទូទាត់សងវិញតែក្នុងករណីសង្គ្រោះបន្ទាន់តែប៉ុណ្ណោះ។ ការទាមតារតាវកាលិកត្រូវធ្វើតាមទម្រង់តាវកាលិកព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ឬហៅថាទម្រង់ ៥.០២ ដូចមានចែងក្នុងឧបសម្ព័ន្ធ២នៃ

ប្រកាសស្តីពីតារកាលិកថៃទាំសុខភាព។ បែបបទនៃការទាមទារនេះត្រូវមានភ្ជាប់នូវឯកសារវេជ្ជសាស្ត្រ និង វិក័យបត្រនានា ព្រមទាំងឯកសារពាក់ព័ន្ធចាំបាច់ដទៃទៀតផងដែរ។

### គ.១.២ លក្ខខណ្ឌក្នុងការទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃ

ដើម្បីទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃ កម្មករនិយោជិតទាំងអស់ត្រូវបំពេញលក្ខខណ្ឌដូចតទៅៈ

- ប្រាក់បំណាច់ប្រចាំថ្ងៃជាប្រាក់ដែលផ្តល់ជូនសម្រាប់រយៈពេលអាក់ខានការងារដោយសារការធ្លាក់ខ្លួនមានជម្ងឺ គ្រោះថ្នាក់ និងលំហែមាតុភាព
- បានបំពេញលក្ខខណ្ឌទាំងឡាយដូចមានចែងក្នុងចំណុច **៦.១** នៃប្រកាសស្តីពីតារកាលិកថែទាំសុខភាព
- ត្រូវសុំច្បាប់ឈប់សម្រាកពីនិយោជិកតាមទម្រង់ដែលកំណត់ដោយ ប.ស.ស
- បានបង់ភាគទានយ៉ាងតិច **០៤** (ប្រាំបួន) ខែជាប់គ្នាចំពោះប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការសម្រាកមាតុភាព។

ការទាមទារប្រាក់បំណាច់ប្រចាំថ្ងៃ ត្រូវធ្វើឡើងដោយអ្នកជម្ងឺ ឬជនរងគ្រោះ ឬអ្នកតំណាងតាមទម្រង់ **ប្រាក់បំណាច់ប្រចាំថ្ងៃ** ឬ ហៅថាទម្រង់ **៤.០៣** ដូចមានចែងក្នុងឧបសម្ព័ន្ធ៣ នៃប្រកាសស្តីពីតារកាលិកថែទាំសុខភាព។ បែបបទនៃការទាមទារនេះត្រូវមានភ្ជាប់ជាមួយនឹងលិខិតចេញពីមន្ទីពេទ្យដែលចេញដោយមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រព្រៀងជាមួយ ប.ស.ស ដែលជនរងគ្រោះបានចូលទៅទទួលសេវាថែទាំព្យាបាល។ លិខិតអនុញ្ញាតច្បាប់អាចចេញ ដោយគ្រូពេទ្យសហគ្រាស ដោយមានការយល់ព្រមពីនិយោជក ឬអ្នកតំណាងសហគ្រាស គ្រឹះស្ថាននោះ។

សិទ្ធិនៃការទាមទារតារកាលិកព្យាបាលនិងថែទាំវេជ្ជសាស្ត្រ និងប្រាក់បំណាច់ប្រចាំថ្ងៃមានអាជ្ញាយុកាលត្រឹមរយៈពេល ១២ (ដប់ពីរ) ខែ គិតចាប់ពីថ្ងៃមានបញ្ហាសុខភាពដំបូង។

សរុបមក រាល់កម្មករនិយោជិត ឬសមាជិក ប.ស.ស ទាំងឡាយដែលបានបំពេញនូវលក្ខខណ្ឌដូចបានកំណត់នៅក្នុងចំណុច ៦.១ និង ៦.២ នៃប្រការ៦ នៃប្រកាសស្តីពីតារកាលិកថែទាំសុខភាពមានសិទ្ធិទទួលបានៈ

- ការព្យាបាលដោយឥតគិតថ្លៃ នៅក្នុងមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) លើកលែងតែសេវាព្យាបាលដូចបានចែងក្នុងប្រការ៤ នៃប្រកាសស្តីពីតារកាលិកថែទាំសុខភាព ក្នុងរយៈពេលមិនលើស ១៨០ (មួយ

រយប៉ែតសិបថ្ងៃ) ក្នុងរយៈពេល ១២ (ដប់ពីរ) ខែ ដោយគិតទាំងរយៈពេលព្យាបាលដោយសម្រាក នៅក្នុងមន្ទីរពេទ្យ និងមិនសម្រាកក្នុងមន្ទីរពេទ្យ។

- ប្រាល់បំណាច់ប្រចាំថ្ងៃ ៧០% (ចិតសិបភាគរយ) នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់សាមីជនសម្រាប់រយៈពេលអាកខានការងារ ដោយាសារការសម្រាក ព្យាបាលថែទាំជម្ងឺ ឬរបួសតាមវេជ្ជបញ្ជាមានរយៈពេលជាប់គ្នាលើសពី ០៧ (ប្រាំពីរ) ថ្ងៃ។
- ប្រាក់ឈ្នួលពីនិយោជក ក្នុងករណីដែលការអាក់ខានធ្វើការងារ ដោយការឈប់សម្រាកព្យាបាលថែទាំជម្ងឺ ឬរបួសតាមវេជ្ជបញ្ជា ដែលមានរយៈពេលជាប់គ្នាត្រឹម ០៧ (ប្រាំពីរ) ថ្ងៃចុះ។
- ប្រាក់បំណាច់ប្រចាំថ្ងៃ ៧០% (ចិតសិបភាគរយ) នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់សាមីជន សម្រាប់រយៈពេល ៩០ (កៅសិប) ថ្ងៃនៃការឈប់សម្រាកមុន និងក្រោយពេលសម្រាលកូន។
- សេវាបញ្ជូនអ្នកជម្ងឺ ឬជនរងគ្រោះ និងបញ្ជូនសពះ
    - សេវាបញ្ជូនអ្នកជម្ងឺ ឬជនរងគ្រោះត្រូវផ្ដល់ជូនតែក្នុងករណីសង្គ្រោះបន្ទាន់ និងដោតរថយន្តគិលានសង្គ្រោះរបស់មូលដ្ឋានសុខាភិបាលតែប៉ណ្ណោះ។
    - សេវាបញ្ជូនអ្នជម្ងឺធ្ងន់ធ្ងរដែលមិនអាចព្យាបាលឱ្យជា ឬសពផ្ដល់ជូនទៅតាមតម្លៃមូលដ្ឋានសុខាភិបាល ដែលទទួលស្គាល់ដោយបេឡាយជាតិរបបសន្តិសុខសង្គម។

ចំពោះសហគ្រាស គ្រឹះស្ថាន ដែលបេឡាជាតិរបបសន្តិសុខសង្គមពុំទាន់បានចុះបញ្ជិកាក្នុងរបបថែទាំសុខភាព សហគ្រាស គ្រឹះស្ថានទាំងនោះ ត្រូវបន្តអនុវត្តតាមអនុសញ្ញារួម ឬ បទបញ្ជាផ្ទៃក្នុងរបស់ខ្លួនស្របតាមបទប្បញ្ញត្តិស្ដីពីច្បាប់ការងារ រហូតដល់មានការចុះបញ្ជិការពិបេឡាជាតិរបបសន្តិសុខសង្គម[90]។

[90]ប្រការ ១១ នៃប្រកាសលេខ ០៩៣/១៦ កប/ប្រក ស្ដីពីការកំណត់ដំណាក់កាល និងកាលបរិច្ឆេទនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព

# ជំពូក ៣

# តាវកាលិកផ្សេងៗ និងការដោះស្រាយវិវាទ

## ផ្នែកទី១ : ការផ្តល់តាវកាលិកសោធន

ក្រៅពីតាវកាលិកផ្នែកហានិភ័យការងារ និង តាវកាលិកសុខភាព បេឡាជាតិរបបសន្តិសុខសង្គមនឹងផ្តល់តាវកាលិកមួយប្រភេទទៀត គឺតាវកាលិកផ្នែកសោធនសំរាប់សមាជិករបស់បេឡាជាតិរបបសន្តិសុខសង្គម ដើម្បីធានានូវរបបសន្តិសុខសង្គមឱ្យប្រសើរ។ យ៉ាងណាមិញតាវកាលិកផ្នែកសោធនត្រូវបានបែងចែកជាពីរប្រភេទក្នុងនោះរួមមាន៖ តាវកាលិកដែលផ្តល់ជូនទៅឱ្យសមាជិក ប.ស.ស **(កថាខណ្ឌ១)** និង ប្រភេទតាវកាលិកដែលផ្តល់ទៅឱ្យសិទ្ធិវន្តនៃសមាជិកប.ស.សផង **(កថាខណ្ឌ២)**។

### កថាខណ្ឌ១ : ប្រភេទតាវកាលិកសោធនសម្រាប់សមាជិក ប.ស.ស

ដោយអនុលោមតាម ច្បាប់ស្តីពីបេឡាជាតិរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ សមាជិក ប.ស.សអាចទទួលបាននូវតាវកាលិកចំនួនបីប្រភេទរួមមាន៖ សោធនជរាភាព សោធនកាលាទិករណ៍ និងវិភាជន៍ជរាភាពទៅតាមលក្ខខ័ណ្ឌនីមួយៗ។ ដូច្នេះដើម្បីទទួលបាននូវតាវកាលិកទាំងអស់នេះ តើសមាជិករបស់បេឡាជាតិរបបសន្តិសុខសង្គមត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះ?

#### ក. សោធនជរាភាព

សោធនជរាភាព គឺជាប្រាក់ដែលសមាជិកបេឡាជាតិរបបសន្តិសុខសង្គមទទួលបាន នៅពេលដែលសមីជនទទួលបានដោយបំពេញលក្ខខ័ណ្ឌខាងក្រោម៖

- សមីជនបានចុះឈ្មោះនៅក្នុងបេឡាជាតិរបបសន្តិសុខសង្គមយ៉ាងតិចម្ភៃ (២០)ឆ្នាំ និងបានបង់ភាគទានយ៉ាងតិចបំផុតហុកសិប (៦០) ខែសម្រាប់បេឡាជាតិរបបសន្តិសង្គម ក្នុងអំឡុងពេលដប់ឆ្នាំចុងក្រោយ ដែលកាលបរិច្ឆេទនេះ គិតរហូតមកទល់ពេលដែលសាមីជនរូបនេះមានសិទ្ធិទទួលបាននូវប្រាក់សោធន។

### ខ. វិភាជន៍ជរាភាព

វិភាជន៍ជរាភាព គឺជាប្រាក់ឧបត្ថម្ភ សម្រាប់សមាជិកបេឡាជាតិរបបសន្តិសុខសង្គម ដែលដល់វ័យ ៥៥ (ហាសិបប្រាំ) ឆ្នាំ ហើយបានបង់ភាគទានតិចជាង ៦០ (ហុកសិប) ខែ សម្រាប់បេឡាជាតិរបបសន្តិសុខសង្គម ជាពិសេសបានបញ្ចប់ការងារ ដែលអាចទទួលបានប្រាក់ឈ្នួលព្រមទាំងមិនទាន់បានបំពេញលក្ខខណ្ឌផ្សេងទៀត ដើម្បីទទួលបាននូវសោធនជរាភាព ត្រូវមានសិទ្ធិទទួលបានវិភាជន៍ជរាភាព ដែលត្រូវបានបើកឱ្យម្តងគត់។

### គ. សោធនកាលាទិករណ៍

**សោធនកាលាទិករណ៍** ៖ គឺជាប្រាក់ដែលត្រូវផ្តល់ទៅឱ្យសមាជិករបស់បេឡាជាតិរបបសន្តិសុខសង្គម ដែលចុះខ្សោយសម្បទាមុនអាយុ ៥៥ (ហាសិបប្រាំ) ឆ្នាំ ទោះបីជាខាងផ្នែកស្មារតី ឬផ្នែករាងកាយក្តីឱ្យតែការចុះខ្សោយនោះអាចបណ្តាលឱ្យបាត់បង់សមត្ថភាពការងារ ដែលអាចទទួលបានប្រាក់ឈ្នួល។

ដើម្បីទទួលបាននូវសោធនកាលាទិករណ៍ សមាជិករបស់បេឡាជាតិរបបសន្តិសុខសង្គមត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- បានចុះឈ្មោះនៅក្នុងបេឡាជាតិរបបសន្តិសុខសង្គមរយៈពេល២០ (ម្ភៃ) ឆ្នាំ។ និងបានបង់ភាគទានទៅឱ្យបេឡាជាតិរបបសន្តិសុខសង្គម បាន ៦០ (ហុបសិប) ខែ ក្នុងអំឡុងពេលដប់ឆ្នាំចុងក្រោយ គិតរហូតមកទល់កាលបរិច្ឆេទ ដែលសាមីជនរូបនោះបានធ្វើការស្នើសុំប្រាក់សោធនកាលាទិករណ៍។ ហើយបែបបទនៃការកំណត់និងការត្រួតពិនិត្យភាពចុះទន់ខ្សោយសម្បទាមុនអាយុ ៥៥ (ហាសិបប្រាំ) ឆ្នាំ ត្រូវចេញដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គមបន្ទាប់ពីការផ្តល់យោបល់ពីក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម។

ជាទូទៅប្រាក់សោធនជរាភាព និងប្រាក់សោធនកាលាទិករណ៍មានប្រសិទ្ធិភាព នៅថ្ងៃទីមួយនៃខែតាមប្រតិទិន បន្ទាប់ពីកាលបរិច្ឆេទដែលសាមីជនបានបំពេញតាមលក្ខខណ្ឌត្រឹមត្រូវរួចហើយ ប្រសិនបើសាមីជនរូបនោះបានផ្ញើពាក្យសុំមកបេឡាជាតិរបបសន្តិសុខសង្គម ក្នុងរយៈពេលដប់ពីរ (១២) ខែ បន្ទាប់ពីកាលបរិច្ឆេទដែលត្រូវទទួលបានសោធនជរាភាព ឬសោធនកាលាទិករណ៍។ ក្នុងករណីដែលពាក្យសុំប្រាក់សោធនធ្វើនៅក្រោយថិរវេលា ដូចមានចែងខាងលើ ប្រាក់សោធននឹងត្រូវមានប្រសិទ្ធភាពនៅថ្ងៃទីមួយ នៃខែតាមប្រតិទិនបន្ទាប់ពីកាលបរិច្ឆេទ នៃថ្ងៃដែលបានទទួលពាក្យសុំ[91]។

[91] មាត្រា ៨ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារ

### ឃ. សោធនទុព្វលភាព

ក្នុងករណី ដែលសមាជិករបស់បេឡាជាតិរបបសន្តិសុខសង្គម មិនអាចបំពេញលក្ខខណ្ឌរបស់សោធនកាលិករណ៍បានទេ នោះសមាជិករបស់បេឡាជាតិរបបសន្តិសុខសង្គម អាចទទួលនូវសោធនមួយប្រភេទទៀត គឺសោធនទុព្វភាព។

**សោធនទុព្វលភាព** : គឺជាប្រាក់ត្រូវផ្តល់ទៅឱ្យសមាជិករបស់បេឡាជាតិរបបសន្តិសុខសង្គមនៅពេលដែល មានការចុះខ្សោយនូវកំលាំង ដែលធ្វើឱ្យបានបាត់បង់សមត្ថភាពការងារ។

សមាជិកបេឡាជាតិរបបសន្តិសុខសង្គម ដែលធ្លាក់ខ្លួនក្នុងទុព្វលភាពមុនអាយុ ៥៥ (ហាសិបប្រាំ) ឆ្នាំ មានសិទ្ធិទទួលនូវប្រាក់សោធនទុព្វភាព ប្រសិនបើសាមីជនបានបំពេញលក្ខខណ្ឌះ

- មានឈ្មោះក្នុងបញ្ជីនៃបេឡាជាតិរបបសន្តិសុខសង្គម យ៉ាងតិច ៥ (ប្រាំ) ឆ្នាំ និងបានបង់ភាគទានសម្រាប់របបសន្តិសុខសង្គមក្នុងអំឡុងពេល ១២ (ដប់ពីរ) ខែចុងក្រោយ ដោយគិតមកទល់ថ្ងៃដែលសាមីជនចាប់ផ្តើមបាត់បង់សមត្ថភាពការងារដោយសារទុព្វភាព[92]។

## កថាខណ្ឌទី២ : តាវកាលិកសម្រាប់សិទ្ធិវន្ត

របបសន្តិសុខសង្គមផ្នែកសោធន មិនត្រឹមតែផ្តល់ផលប្រយោជន៍ទៅឱ្យសមាជិករបស់ ប.ស.ស នោះទេ ប៉ុន្តែរបបនេះក៏ផ្តល់ផលប្រយោជន៍ជូនទៅដល់សិទ្ធិវន្តនៃសមាជិក ប.ស.សផងដែរ។ តាវកាលិកដែលបេឡាជាតិរបបសន្តិសុខសង្គមផ្តល់ឱ្យសិទ្ធិវន្តនៃសមាជិក ប.ស.ស ក្នុងនោះរួមានសោធនសម្រាប់អ្នកនៅក្នុងបន្ទុក **(ក)** និងវិភាជន៍សម្រាប់អ្នកនៅក្នុងបន្ទុក **(ខ)**។

### ក. សោធនសម្រាប់អ្នកនៅក្នុងបន្ទុក

ប្រសិនបើ សាមីជននៃសោធនជរាភាព ឬទុព្វភាព ឬសោធនកាលាទិករណ៍ ទទួលមរណភាព ឬក៏ក្នុងករណីដែលសមាជិករបស់បេឡាជាតិរបបសន្តិសុខសង្គម ទទួលមរណភាព ហើយនៅក្នុងកាលបរិច្ឆេទនៃមរណភាពនេះ ជននោះបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់សម្រាប់ទទួលបាននូវអត្ថប្រយោជន៍ពីសោធនជរាភាព ឬទុព្វភាព ឬក៏បានបង់ភាគទានចំនួនមួយប៉ែតសិប (១៨០) ខែសម្រាប់បេឡាជាតិរបបសន្តិសុខសង្គមរួចហើយ អ្នកសិទ្ធិវន្តមានសិទ្ធិទទួលបាននូវសោធនចំពោះអ្នកនៅក្នុងបន្ទុក[93]។

[92] មាត្រា ៩ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារ

[93] មាត្រា ១០ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារ

### ខ. វិភាជន៍ចំពោះអ្នកនៅក្នុងបន្ទុក

ប្រសិនបើសមាជិករបស់បេឡាជាតិរបបសន្តិសុខសង្គម មិនអាចមានសិទ្ធិទទួលបាននូវប្រាក់សោធនទុព្វលភាព និងមិនទាន់បានបង់ភាគទានគ្រប់ចំនួនមួយរយប៉ែតសិប (១៨០) ខែ ដល់បេឡាជាតិរបបសន្តិសុខសង្គម ដែលគិតមកទល់នឹងថ្ងៃដែលខ្លួនទទួលមរណភាពទេនោះ ប្តី ឬប្រពន្ធដែលជាទុព្វលជនក្តី ឬមិនមែនក្តី ព្រមទាំងកូនកំព្រានៃសាមីជនត្រូវមានសិទ្ធិទទួលអត្ថប្រយោជន៍ជាវិភាជន៍ ចំពោះអ្នកនៅក្នុងបន្ទុកដែលបើកឱ្យតែម្តងគត់ ក្នុងចំនួនមិនតិចជាងប្រាក់សោធនជរាភាពប្រចាំខែ សម្រាប់សមាជិកបេឡាជាតិរបបសន្តសុខសង្គម[94]។

## ផ្នែកទី ២ ដំណោះស្រាយវិវាទ ឬបណ្តឹងដែលប្រព្រឹត្តទៅដោយគណៈកម្មការប.ស.ស

ដើម្បីកាត់បន្ថយនូវការចំណាយពេលវេលា និងប្រាក់កាសច្រើនរបស់ភាគីនៃបណ្តឹង ទៅលើការធ្វើពាក្យបណ្តឹងទៅកាន់តុលាការ ជាពិសេសដើម្បីបញ្ចៀសនូវការកក់ស្ទះសំណុំរឿងនៅក្នុងតុលាការផងដែរនោះ គេបានបង្កើតនូវប្រព័ន្ធដោះស្រាយវិវាទក្រៅតុលាការឡើង។ វត្តមាននូវការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលារ បានជួយសម្រួលដល់ភាគីមួយផ្នែក ក៏ដូចជាជួយសម្រួលដល់ដល់ការកាត់បន្ថយសំណុំរឿងដែលបញ្ជូនទៅតុលាការដែរ។ យ៉ាងណាមិចនៅក្នុងវិវាទទាក់ទងនឹងផលប្រយោជន៍របស់បេឡាជាតិរបបសន្តិសុខសង្គមក៏ត្រូវបានដោះដោយគណៈកម្មការដោះស្រាយវិវាទ ប.ស.ស (ជាការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ) មុននឹងឈានដល់ការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ។ នៅទីនេះក្រុមយើងខ្ញុំនឹងធ្វើការបកស្រាយទៅលើ ការដោះស្រាយវិវាទរបស់គណៈកម្មការដោះស្រាយវិវាទ ប.ស.ស **(កថាខណ្ឌ១)** និងការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ **(កថាខណ្ឌ២)**។

### កថាខណ្ឌ ១ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

ដើម្បីសម្របសម្រួលដល់ដំណើរការរបស់បេឡាជាតិរបបសន្តិសុខសង្គម ក្នុងអនុវត្តការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព និងតម្លាភាព ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម បានដាក់សំណើទៅកាន់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីឱ្យរដ្ឋមន្ត្រីចេញប្រកាសស្តីពីសមាសភាព និងការប្រព្រឹត្តទៅរបស់គណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹងនៃបេឡាជាតិរបបសន្តិសុខសង្គម ដែលត្រូវសម្រេច និងមានប្រសិទ្ធភាពអនុវត្ត នៅថ្ងៃទី ១៨ ខែសីហា

[94] មាត្រា ១១ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារ

ឆ្នាំ២០១០ ក្នុងករណីដែលមានវិវាទកើតឡើងរវាងបេឡាជាតិរបបសន្តិសុខសង្គម ជាមួយសមាជិករបស់ខ្លួន។ គណៈកម្មការដោះស្រាយវិវាទរបស់បេឡាជាតិរបបសន្តិសុខសង្គម គឺជារចនាសម្ព័ន្ធមួយដែលត្រូវបានបង្កើតឡើងក្នុងគោលបំណង ដើម្បីធ្វើការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដោយប្រើប្រាស់នូវយុត្តិសាស្ត្រនៃការផ្សះផ្សា ចំពោះរឿងក្តីទាក់ទងទៅនឹងវិវាទរបស់បេឡាជាតិរបបសន្តិសុខសង្គម ជាមួយនឹងសមាជិករបស់ខ្លួន ឬវិវាទដែលទាក់ទងទៅនឹងការអនុវត្តរបបសន្តិសុខសង្គម។ សេចក្តីសម្រេចក្តីរបស់គណៈកម្មការដោះស្រាយវិវាទរបស់បេឡាជាតិរបបសន្តិសង្គម ពុំបានបិតផ្លូវតវ៉ានោះទេ ពោលប្រសិនបើភាគីណាមួយមិនសុខចិត្ត ចំពោះការសម្រេចរបស់គណៈកម្មការដោះស្រាយវិវាទរបស់ ប.ស.ស នោះទេ ភាគីនោះអាចធ្វើការប្តឹងទៅកាន់តុលាការដែលមានសមត្ថកិច្ចបាន ដើម្បីធ្វើការស្វែងរកនូវសេចក្តីសម្រេចណាមួយ ដែលភាគីមិនសុខចិត្តនឹងមិនអាចទទួលយកបាន។

ផ្ទុយទៅវិញ ការសម្រេចរបស់តុលាការ ឬហៅថាការសម្រេចតាមប្រព័ន្ធតុលាការមានលក្ខណៈចាប់បង្ខំ និងបិតផ្លូវតវ៉ាចំពោះភាគីវិវាទផងដែរ។ ដូច្នេះដើម្បីបកស្រាយទៅចំណុចនេះឱ្យបានក្បោះក្បាយ ក្រុមយើងខ្ញុំនឹងធ្វើការបែងចែកជាពីរចំនុចសខាន់ៗគឺ សមាសភាពរបស់គណៈកម្មការដោះស្រាយវិវាទរបស់បេឡាជាតិរបបសន្តិសុខសង្គម **(ក)** និងនីតិវិធីនៃការដោះស្រាយវិវាទរបស់គណៈកម្មការដោះស្រាយវិវាទនៃ ប.ស.ស **(ខ)**។

### ក. សមាសភាពគណៈកម្មការដោះស្រាយវិវាទ

សមាសភាពរបស់គណៈកម្មការដោះស្រាយវិវាទ ប.ស.ស កើតមានឡើងតាមរយៈការតែងតាំង **(ក.១)** ហើយដើម្បីក្លាយជាសមាជិករបស់គណៈកម្មការដោះស្រាយវិវាទនេះ ក៏ត្រូវមានលក្ខណៈសម្បត្តិមួយចំនួន **(ក.២)** ដែលត្រូវបានកំណត់ជាសារវន្តនៅក្នុងប្រកាសរបស់ក្រសួងដែរ។

#### ក.១ ការតែងតាំងសមាជិករបស់គណៈកម្មការនៃ ប.ស.ស

សមាជិករបស់គណៈកម្មការបេឡាជាតិរបបសន្តិសុខសង្គមត្រូវបានបែងចែកជាពីរ គឺ សមាជិកពេញសិទ្ធិ និងសមាជិកបម្រុង។ សមាជិកពេញសិទ្ធិ មានចំនួនបីរូប និងសមាជិកបម្រុង មានចំនួនប្រាំមួយរូប។ ហើយសមាជិកទាំងអស់ត្រូវបានតែងតាំងដូចខាងក្រោម:

- សមាជិកពេញសិទ្ធិមួយរូប និងសមាជិកបម្រុងពីររូប ត្រូវបានស្នើដោយនាយកបេឡាជាតិរបបសន្តិសុខសង្គម

- សមាជិកពេញសិទ្ធិមួយរូប និងសមាជិកបម្រុងពីររូប ត្រូវបានស្នើដោយសមាជិកក្រុមប្រឹក្សាភិបាលតំណាងកម្មករនិយោជិត

- សមាជិកពេញសិទ្ធិមួយរូប និងសមាជិកបម្រុងពីររូប ត្រូវបានស្នើដោយសមាជិកក្រុមប្រឹក្សាភិបាលតំណាងនិយោជក។

សមាជិកពេញសិទ្ធិមួយរូប ដែលត្រូវបានស្នើដោយនាយកបេឡាជាតិរបបសន្តិសុខសង្គមជាប្រធានមានឋានៈជាប្រធាននៃគណៈកម្មការ ចំណែកឯសមាជិកពេញសិទ្ធិមួយរូប ដែលត្រូវបានស្នើដោយសមាជិកក្រុមប្រឹក្សាភិបាលតំណាងកម្មករនិយោជិត ជាសមាជិក និងសមាជិកពេញសិទ្ធមួយរូបទៀត ដែលត្រូវស្នើដោយសមាជិកក្រុមប្រឹក្សាភិបាលតំណាងនិយោជក ជាសមាជិក។

ក្នុងករណីដែលប្រធានគណៈកម្មការអវត្តមាន សមាជិកបម្រុង ដែលស្នើឡើងដោយនាយកបេឡាជាតិរបបសន្តិសុខសង្គម ត្រូវទទួលតួនាទីជាប្រធានស្តីទី។ ក្នុងករណី ដែលសមាជិកគណៈកម្មការ នៃភាគីណាមួយអវត្តមាន ប្រធានគណៈកម្មការ ឬប្រធានស្តីទី អាចអញ្ជើញសមាជិកបម្រុងដែលតំណាងឱ្យភាគីអវត្តមានចូលប្រជុំបាន។ គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹងនៃបេឡាជាតិរបបសន្តិសុខសង្គម ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬប្រធានស្តីទី។

ចំពោះអាណត្តិរបស់គណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹង នៃបេឡាជាតិរបបសន្តិសុខសង្គម មានអាណត្តិរយៈពេលមួយឆ្នាំ[95]។

### ក.២ លក្ខណៈសម្បត្តិសមាជិកគណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹងនៃប.ស.ស

ដើម្បីក្លាយជាសមាជិកនៃគណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹងនៃបេឡាជាតិរបបសន្តិសុខសង្គម ដែលត្រូវបានសរសេរជាអក្សរកាត់ថា ប.ស.សនោះ ត្រូវមាននូវលក្ខណៈសម្បត្តិដូចខាងក្រោម៖

- មានអាយុយ៉ាងតិច ២៥ (ម្ភៃប្រាំ) ឆ្នាំ
- មានការទទួលស្គាល់ អំពីលក្ខណៈសម្បត្តិផ្នែកសីលធម៌
- មានបទពិសោធន៍ពាក់ព័ន្ធនឹងការងារយ៉ាងតិច ៣០(សាមសិប) ឆ្នាំ
- បរិញ្ញាបត្រផ្នែកច្បាប់ ឬ មានគុណវឌ្ឍន៍ផ្នែកច្បាប់

[95] ប្រការ៣ នៃប្រកាសលេខ១៧៧ កប/ប្រក ស្តីពីសមាសភាព និងការប្រព្រឹត្តទៅរបស់គណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹងនៃបេឡាជាតិរបបសន្តិសុខសង្គម

- មានចំណេះដឹងអំពីច្បាប់ស្តីពីការងារ ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ការងារ និង បទបញ្ហាផ្សេងៗ ពាក់ព័ន្ធទៅនឹងវិស័យសន្តិសុខសង្គម[96]។

### ខ. នីតិវិធីក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

សមត្ថកិច្ចតុលាការព្រហ្មទណ្ឌ កើតឡើងតាមរយៈបណ្តឹងអាជ្ញាដែលមានគោលបំណងពិនិត្យទៅលើ អត្តិភាពរបស់ជនល្មើសដែលប្រព្រឹត្តនូវបទល្មើស ព្រមទាំងធ្វើការផ្តន្ទាទោសជននោះទៅតាមច្បាប់កំណត់។

យ៉ាងណាមិញនៅក្នុងបណ្តឹង ឬវិវាទរបស់សមាជិក ប.ស.ស និយោជក និងប.ស.សក៏អាចជាកម្មវត្ថុនៃបណ្តឹងរបស់តុលាការព្រហ្មទណ្ឌតាមរយៈទោសប្បញ្ញត្តិ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារបានកំណត់អំពីបទល្មើសមួយចំនួន និងទោសដែលរួមមានទោសពិន័យជាប្រាក់ និងទោដាក់ពន្ធនាគារ។ បើយើងតាមមាត្រា ៣៩ នៃច្បាប់ស្តីពីបេឡាជាតិរបបសន្តិសុខសង្គមបានចែងថា ជនប្រព្រឹត្តបទល្មើសទាក់ទងទៅនឹងបទប្បញ្ញត្តិនៃច្បាប់នេះត្រូវផ្តន្ទាទោស ពិន័យជាប្រាក់ ឬត្រូវផ្តន្ទាទោសជាប់ពន្ធនាគារ ឬក៏ត្រូវផ្តន្ទាទោសទាំងពីរ។

ទោសពិន័យជាប្រាក់ ត្រូវកំណត់ដោយពហុគុណនៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ។ ប្រាក់ឈ្នួលប្រចាំថ្ងៃគឺជាប្រាក់ឈ្នួលអប្បបរមាដែលបានកំណត់ដោយ ប្រកាសរួមរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសន្តិសុខសង្គម និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ចំណែកទោសដាក់ពន្ធនាគារ កម្រិតនៅក្នុងទោសប្បញ្ញត្តិនៃច្បាប់ស្តីពីបេឡាជាតិរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

### ខ.១ កម្មវត្ថុនៃការដោះស្រាយវិវាទ ឬ បណ្តឹង ប.ស.ស

គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹងនៃ ប.ស.ស បង្កើតឡើងដើម្បីធ្វើការដោះស្រាយវិវាទ ឬ បណ្តឹងទាំងឡាយណាដែលទាក់ទងទៅនឹងការអនុវត្តបទប្បញ្ញត្តិ និង បទបញ្ហាខាងវិស័យសន្តិ

[96] ប្រការ៤ នៃប្រកាសលេខ១៧៧ កប/ប្រក ស្តីពីសមាសភាព និងការប្រព្រឹត្តទៅរបស់គណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹងនៃបេឡាជាតិរបបសន្តិសុខសង្គម

សុខសង្គម រវាងសមាជិកបេឡាជាតិរបបសន្តិសុខសង្គម និយោជក និងបេឡាជាតិរបបសន្តិសុខសង្គម[97]។

កម្មវត្ថុនៃការដោះស្រាយវិវាទរបស់គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង ប.ស.ស រួមមានៈ

- បណ្តឹងទាក់ទងនឹងការតវ៉ារបស់កម្មករនិយោជិតសមាជិក បេឡាជាតិរបបសន្តិសុខសង្គម ទាក់ទងនឹងការយល់ព្រម ឬ ភាពមិនត្រឹមត្រូវក្នុងការផ្តល់តាវកាលិករបបសន្តិសុខសង្គម។

- បណ្តឹងតវ៉ារបស់កម្មករនិយោជិតសមាជិក បេឡាជាតិរបបសន្តិសុខសង្គម ទាក់ទងទៅនឹងភាពមិនប្រក្រតី នៃការផ្តល់សេវារបបសន្តិសុខសង្គម។

-បណ្តឹងតវ៉ារបស់កម្មករនិយោជិតសមាជិកបេឡាជាតិរបបសន្តិសុខសង្គម ចំពោះការខកខានរបស់និយោជក ក្នុងការមិនបានរាយការណ៍ដើម្បីចុះឈ្មោះរបស់ខ្លួនក្នុងបេឡាជាតិរបបសន្តិសុខសង្គម។

- បណ្តឹងតវ៉ារបស់និយោជក ចំពោះការអនុវត្តមិនត្រឹមត្រូវតាមច្បាប់ ឬ បទបញ្ញាជាធរមានរបស់មន្ត្រីបេឡាជាតិរបបសន្តិសុខសង្គម។

- បណ្តឹងតវ៉ាផ្សេងទៀត ដែលទាក់ទងនឹងការអនុវត្តបេឡាជាតិរបបសន្តិសុខសង្គម[98]។

### ខ.២ ការកោះហៅគូរភាគី និងការបង្ហាញខ្លួនរបស់ភាគីវិវាទ

នៅពេលដែលមាន បណ្តឹង ឬ វិវាទដាក់ជូនទៅកាន់គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹងនៃ ប.ស.សនោះ ប្រធានរបស់គណៈកម្មការ ត្រូវធ្វើការកោះហៅ ឬកោះអញ្ជើញភាគីនៃបណ្តឹងតវ៉ាមកធ្វើការបំភ្លឺ និង ផ្តល់ឯកសារ ឬ ពត៌មានចាំបាច់ផ្សេងៗនៅចំពោះមុខគណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹងរបស់ប.ស.ស[99]។

ភាគីបណ្តឹង អាចធ្វើការបង្ហាញខ្លួន នៅចំពោះមុខគណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹងរបស់ ប.ស.ស ដោយផ្ទាល់ ដោយមានអម ឬ ការបង្ហាញខ្លួនដោយមានវត្តមានរបស់អ្នកតំណាងដែលទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីសាមីបណ្តឹង។

---

[97] ប្រការ១ នៃប្រកាសលេខ១៧៧ កប/ប្រក ស្តីពីសមាសភាព និងការប្រព្រឹត្តទៅរបស់គណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹងនៃបេឡាជាតិរបបសន្តិសុខសង្គម

[98] ប្រការ២ នៃប្រកាសលេខ១៧៧ កប/ប្រក ស្តីពីសមាសភាព និងការប្រព្រឹត្តទៅរបស់គណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹងនៃបេឡាជាតិរបបសន្តិសុខសង្គម

[99] ប្រការ៥ នៃប្រកាសលេខ១៧៧ កប/ប្រក ស្តីពីសមាសភាព និងការប្រព្រឹត្តទៅរបស់គណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹងនៃបេឡាជាតិរបបសន្តិសុខសង្គម

ក្នុងករណីដែលកម្មករនិយោជិត ត្រូវបានតម្រូវឱ្យចូលរួមក្នុងការផ្សះផ្សានៅក្នុងម៉ោងធ្វើការ និយោជកត្រូវតែអនុញ្ញាត បន្ទាប់ពីបានទទួលលិខិតកោះអញ្ជើញ ដោយមិនឱ្យទទួលផលប៉ះពាល់ជាអវិជ្ជមានដល់កម្មករនិយោជិតនោះឡើយ[100]។

ក្នុងករណីដែលភាគីនៃបណ្ដឹងតវ៉ា ខកខានមិនបានបង្ហាញខ្លួនតាមការអញ្ជើញ របស់គណៈកម្មការដោះស្រាយវិវាទ ឬ បណ្ដឹងនៃ ប.ស.ស ដោយគ្មានមូលហេតុត្រឹមត្រូវ គណៈកម្មការអាចធ្វើដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬ អាចបញ្ឈប់បណ្ដឹងតវ៉ាតាមការចេញនូវសម្រេចរបស់គណៈកម្មការបាន [101] ។ ប៉ុន្តែជាបដិប្បញ្ញាត្តិ ក្នុងករណីនេះ ប្រសិនបើភាគីដែលអវត្តមាន មាននូវមូលហេតុសមរម្យ និងត្រឹមត្រូវចំពោះការអវត្តមានក្នុងការបង្ហាញខ្លួននៃការអញ្ជើញរបស់គណៈកម្មការនោះ។ តើគណៈកម្មការដោះស្រាយវិវាទ ឬ បណ្ដឹងនៃ ប.ស.ស អាចធ្វើការពិចារណាអំពីបញ្ហានេះផងដែរ? ដោយសារនៅក្នុងប្រកាស ស្ដីពីសមាសភាព និងការប្រព្រឹត្តទៅរបស់គណៈកម្មការដោះស្រាយវិវាទ ឬ បណ្ដឹងនៃ ប.ស.ស មិនបានកំណត់លម្អិតអំពីបដិប្បញ្ញាត្តិខាងលើនេះទេ។

## កថាខណ្ឌ ២ ការដោះស្រាយវិវាទតាមផ្លូវតុលាការ

យោងតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាបានចែងថា អំណាចតុលាការ ធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ហើយអំណាចតុលាការធ្វើការគ្របដណ្ដប់ទៅលើរឿងក្ដីទាំងអស់រួមទាំង រឿងក្ដីរដ្ឋបាលផងដែរ[102]។ ដូច្នេះក្នុងករណីដែលវិវាទ ឬបណ្ដឹងទាំងឡាយណាដែលមិនអាចធ្វើការដោះស្រាយតាមការផ្សះផ្សាក្រៅតុលាការបានទេ នោះភាគីវិវាទ ឬបណ្ដឹងត្រូវរុញវិវាទ ឬបណ្ដឹងនោះទៅកាន់តុលាការដែលមានសមត្ថកិច្ចវិញ។

ប៉ុន្តែអ្វីដែលជាបញ្ហាប្រឈមនោះ គឺត្រូវដឹងថាតើតុលាការណាខ្លះដែលមានសមត្ថកិច្ចក្នុងការដោះស្រាយវិវាទ?

[100] ប្រការ៦ នៃប្រកាសលេខ១៧៧ កប/ប្រក ស្ដីពីសមាសភាព និងការប្រព្រឹត្តទៅរបស់គណៈកម្មការដោះស្រាយវិវាទ ឬបណ្ដឹងនៃបេឡាជាតិរបបសន្តិសុខសង្គម

[101] ប្រការ៧ នៃប្រកាសលេខ១៧៧ កប/ប្រក ស្ដីពីសមាសភាព និងការប្រព្រឹត្តទៅរបស់គណៈកម្មការដោះស្រាយវិវាទ ឬបណ្ដឹងនៃបេឡាជាតិរបបសន្តិសុខសង្គម

[102] មាត្រា ១២៨ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

ដើម្បីធ្វើការដោះស្រាយទៅលើចំណោទបញ្ហាខាងលើ ក្រុមយើងខ្ញុំនឹងលើកយកនូវចំណុចសំខាន់ៗ ពីរមកធ្វើការបកស្រាយពីសមត្ថកិច្ច នៃការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ ដោយក្នុងនោះរួមមានៈ សមត្ថកិច្ចតុលាការរដ្ឋប្បវេណី (ក) និងសមត្ថកិច្ចតុលាការព្រហ្មទណ្ឌ (ខ)។

### ក. សមត្ថកិច្ចតុលាការរដ្ឋប្បវេណី

បណ្តឹងរដ្ឋប្បវេណីកើតឡើងដោយសារ ភាគីដាក់ពាក្យបណ្តឹងដើម្បីធ្វើការបង្ហាញអំពី អត្ថិភាព និងនត្ថិភាពនៃសិទ្ធិរបស់សមីជន ឬតតិយជនណាមួយ។

ដូច្នេះដើម្បីកំណត់អំពី អត្ថិភាព នៃសមត្ថកិច្ចតុលាការរដ្ឋប្បវេណីក្នុងវិវាទ ឬបណ្តឹងរបស់ សមាជិក ប.ស.ស រវាងប.ស.ស យើងត្រូវកំណត់អំពីកម្មវត្ថុនៃវិវាទ ឬបណ្តឹងនោះថាវាពិតជា បណ្តឹងដែលទាក់ទងទៅនឹងអត្ថិភាព និងនត្ថិភាពនៃសិទ្ធិដែរឬទេ?

បើក្រឡេកមើលមាត្រា ២៧ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយណាដែល ស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារទាក់ទងនឹងអជ្ញាយុកាល នៃការទាមទារប្រាក់បំណាច់ ប្រចាំថ្ងៃសម្រាប់ហានិភ័យការងារ និងប្រាក់វិភាជន៍បូជាសព ត្រូវអស់សុពលភាពត្រឹមរយៈពេល មួយឆ្នាំ។ ហើយសិទ្ធិនៃការទាមទារប្រាក់ធនភាព និងប្រាក់សោធនព្រមទាំងវិភាជន៍ជរាភាព ទុព្វលភាព និងមរណភាពត្រូវអស់ត្រឹមរយៈពេល ៥ (ប្រាំ) ឆ្នាំ[103]។

ដូចនេះក្នុងករណីមានបណ្តឹងទាមទារទាក់ទងនឹង អត្ថិភាព និងនត្ថិភាពនៃសិទ្ធិដូចខាងលើនេះ គឺជាសមត្ថកិច្ចតុលាការរដ្ឋប្បវេណី។

### ខ. សមត្ថកិច្ចតុលាការព្រហ្មទណ្ឌ

សមត្ថកិច្ចតុលាការព្រហ្មទណ្ឌ កើតឡើងតាមរយៈបណ្តឹងអាជ្ញាដែលមានគោលបំណងពិនិត្យ ទៅលើអត្ថិភាពរបស់ជនល្មើសដែលប្រព្រឹត្តល្មើសទៅនឹងបទបញ្ញាត្តិនៃច្បាប់ ព្រមទាំងធ្វើការផ្តន្ទា ទោសជននោះទៅតាមច្បាប់កំណត់។

យ៉ាងណាមិញនៅក្នុងបណ្តឹង ឬវិវាទរបស់សមាជិក ប.ស.ស និយោជក និងប.ស.សក៏អាចជា កម្មវត្ថុនៃបណ្តឹងរបស់តុលាការព្រហ្មទណ្ឌតាមរយៈទោសប្បញ្ញត្តិ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារបានកំណត់អំពីបទ

[103] មាត្រា ២៧ នៃច្បាប់ស្តីពីបេឡាជាតិរបបសន្តិសុខសង្គម

ល្មើសមួយចំនួន និងទោសដែលរួមមានទោសពិន័យជាប្រាក់ និងទោដាក់ពន្ធនាគារ។ បើយើងតាមមាត្រា ៣៤ នៃច្បាប់ស្តីពីបេឡាជាតិរបបសន្តិសុខសង្គមបានចែងថា ជនប្រព្រឹត្ត បទល្មើសទាក់ទងទៅនឹងបទប្បញ្ញត្តិនៃច្បាប់នេះត្រូវផ្តន្ទាទោស ពិន័យជាប្រាក់ ឬត្រូវផ្តន្ទាទោសជាប់ពន្ធនាគារ ឬក៏ត្រូវផ្តន្ទាទោសទាំងពីរ។

ទោសពិន័យជាប្រាក់ ត្រូវកំណត់ដោយពហុគុណនៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ។ ប្រាក់ឈ្នួលប្រចាំថ្ងៃគឺជាប្រាក់ឈ្នួលអប្បបរមាដែលបានកំណត់ដោយ ប្រកាសរួមរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសន្តិសុខសង្គម និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ចំណែកទោសដាក់ពន្ធនាគារ កម្រិតនៅក្នុងទោសប្បញ្ញត្តិនៃច្បាប់ស្តីពីបេឡាជាតិរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សា និងស្រាវជ្រាវ ទៅលើប្រធានបទខាងលើនេះរួចមក យើងសង្កេតឃើញថា បេឡាជាតិជាតិរបបសន្តិសុខសង្គម គឺជាគ្រឹះស្ថានសាធារណៈមួយដែលដើរតួនាទីយ៉ាងសំខាន់ដើម្បីធ្វើការធានារ៉ាប់រងនូវរបបសន្តិសុខសង្គមចំពោះកម្មករនិយោជិត នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ តួរយ៉ាងក្នុងគោលបំណង ជាស្ថាប័នដែលបំរើផលប្រយោជន៍សាធារណៈ និងធ្វើការអភិបាលចំពោះកម្មករនិយោជិតដែលជួបនឹងហានិភ័យផ្សេងៗនៅក្នុងសង្គម ក៏ដូចជាវិធីសាស្ត្រក្នុងអនុវត្តគោលនយោបាយក្នុងការកាត់បន្ថយភាពក្រីក្រនោះ បេឡាជាតិរបបសន្តិសុខសង្គម បានធ្វើការផ្តល់តាវកាលិកចំនួនបីប្រភេទជូនទៅកាន់កម្មករនិយោជិត ដែលជាបានចុះបញ្ជិកាជាសមាជិករបស់ខ្លួន។ ហើយតាវកាលិកនោះរួមមាន តាវកាលិកផ្នែកហានិភ័យការងារ តាវកាលិកផ្នែកសុខភាព និងតាវកាលិកផ្នែកសោធន។

ទោះបីជាយ៉ាងណាក៏ដោយ តាវកាលិកទាំងបីនេះក៏ពុំទាន់ អនុវត្តទាំងស្រុងនៅឡើយ។ នៅក្នុងជំហានទីមួយ បេឡាជាតិរបបសន្តិសុខសង្គមបានធ្វើការអនុវត្តនូវតាវកាលិកផ្នែកហានិភ័យការងារមុនគេបង្អស់។ ដោយយល់ឃើញថាតាវកាលិកផ្នែកនេះ ជាតាវកាលិកចម្បងក្នុងការជួយសង្គ្រោះដល់កម្មករនិយោជិត នៅពេលទទួលរងនូវហានិភ័យណាមួយ (គ្រោះថ្នាក់ការងារ ឬ ជាជំងឺវិជ្ជាជីវៈ) បណ្តាលឱ្យពួកគាត់បាត់បង់នូវសមត្ថភាពការងារ ដែលអាចទទួលបាននូវប្រាក់ឈ្នួលនោះ ដូច្នេះដើម្បីពង្រឹងគោលនយោបាយនៃលុបបំបាត់ភាពក្រីក្រនោះ និងជួយកម្មករនិយោជិតឱ្យចាកចេញពីភាពទុកលំបាកនោះ ទើបបេឡាជាតិរបបសន្តិសុខសង្គមបានសំរេចធ្វើការអនុវត្តនូវតាវកាលិកផ្នែកហានិភ័យការងារមុនគេ។ បន្ទាប់មកនាពេលថ្មីៗនេះ បេឡាជាតិរបបសន្តិសុខសង្គម បានធ្វើការចាប់ផ្តើមអនុវត្តនូវតាវកាលិកផ្នែកសុខភាព ដែលជាជំហានបន្ទាប់ពីការទទួលបានជោគជ័យលើការអនុវត្តតាវកាលិកផ្នែកហានិភ័យការងារកន្លងមក។ តាវកាលិកផ្នែកសុខភាពនេះ មិនត្រឹមតែផ្តល់ផលប្រយោជន៍ផ្នែកថែទាំសុខភាព ទៅដល់កម្មករនិយោជិតដែលជាសមាជិកនៃប.ស.សប៉ុណ្ណោះទេ ប៉ុន្តែក៏បានផ្តល់នូវការថែទាំសុខភាពទៅដល់ឱ្យអ្នកនៅក្នុងបន្ទុករបស់សមាជិកនៃ ប.ស.សដែរ។ ជាពិសេសទៅទៀតនោះ ដើម្បីសំរេចនូវគោលនិយោបាយចតុកោណជំណាក់កាលទីបីរបស់រាជរដ្ឋាភិបាល ព្រមទាំងដើម្បីសម្រេចនូវគោលបំណងក្នុងនាមជាគ្រឹះស្ថានសាធារណៈបំរើផលប្រយោជន៍ជូនសាធារណៈជនផ្នែកធានារ៉ាបរងសន្តិសុខសង្គម នាយកបេឡាជាតិរបបសន្តិសុខសង្គមបានធ្វើដំណើរទស្សនៈទៅកាន់ប្រទេសជប៉ុន ក្នុងការស្វែងយល់អំពីប្រព័ន្ធគ្រប់គ្រងសោធន

ដើម្បីទុកជាមូលដ្ឋានគ្រឹះ ក្នុងការអនុវត្តប្រព័ន្ធសោធននៅក្នុងប្រទេសកម្ពុជាឱ្យមានប្រសិទ្ធភាពជាបន្តបន្ទាប់ទៀត។

យ៉ាងណាមិចទោះបីជាតាវកាលិកទាំងបីរបស់បេឡាជាតិរបបសន្តិសុខសង្គម ពុំទាន់អនុវត្តឱ្យបានពេញលេញក៏ដោយ ក៏បេឡាជាតិរបបសន្តិសុខសង្គមនៅតែពង្រឹងនូវការខិតខំប្រឹងប្រែងបន្ថែមដើម្បីពង្រីកនូវ ដំណើរការអនុវត្តផ្នែកធានារ៉ាបរងសន្តិសុខសង្គមដែរ។ ទាំងអស់នេះក៏ជាការរួមចំណែកមួយដ៏ធំក្នុងការគាំពារកម្មករនិយោជិត ដែលកំពុងប្រឈមមុខនឹងបញ្ហាផ្សេងៗនៅក្នុងសង្គម។

ក្រៅពីនេះបេឡាជាតិរបបសន្តិសុខសង្គមបង្កើតនូវ គណៈកម្មការមួយក្នុងការដោះស្រាយវិវាទជូនកម្មករនិយោជិត និង និយោជក ដែលមានវិវាទជាមួយគ្នា ឬ ជាមួយបេឡាជាតិរបបសន្តិសុខសង្គមទាក់ទងនឹងផលប្រយោជន៍ និង បទប្បញ្ញត្តិ ជាពិសេសបទបញ្ញាខាងវិស័យសន្តិសុខសង្គម។

សរុបមកបេឡាជាតិរបបសន្តិសុខពិតជាស្ថានប័នចម្បងមួយ ក្នុងការជួយនិងធ្វើការគាំពារដល់កម្មករនិយោជិត។ ហើយខ្ញុំសង្ឃឹមថាបេឡាជាតិរបបសន្តិសុខសង្គមនឹងធ្វើការអនុវត្តតាវកាលិកទាំងបីរបស់ខ្លួនឱ្យមានវិសាលភាពយ៉ាងទូលំទូលាយ ដើម្បីជាផលប្រយោជន៍របស់កម្មករនិយោជិតព្រមទាំងសង្គមជាតិទាំងមូល។

# អនុសាសន៍

ក្រោយពីបានផ្តល់ឱ្យនូវអត្ថប្រយោជន៍ជាច្រើន ដូចជាតាវកាលិកហានិភ័យការងារ តាវកាលិកសោធននិវត្តន៍ និងតាវកាលិកផ្សេងទៀតផងដែរនោះ បេឡាជាតិរបបសន្តិសុខសង្គមក៏នៅតែបន្តយកចិត្តទុកដាក់ក្នុងការផ្សព្វផ្សាយនូវ ការអនុវត្តតាវកាលោកទាំងអស់នោះជារឿយៗតាមរយៈការសិក្ខាសាលា ក៏ដូចជាតាមរយៈប្រព័ន្ធផ្សព្វផ្សាយផ្សេងៗផងដែរ។ នៅក្នុងនោះ បេឡាជាតិរបបសន្តិសុខសង្គមនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានធ្វើការផ្សព្វផ្សាយពីគោលនយោបាយសន្តិសុខសង្គម ដល់សិក្ខាកាមដែលមកពីបណ្តាសហគ្រាស គ្រឹះស្ថាននានា ជនរងគ្រោះដោយសារគ្រោះថ្នាក់ការងារនៅក្នុងខេត្ត ដើម្បីអោយពួកគាត់យល់ពីគោលនយោបាយថ្មីៗ និងវឌ្ឍនភាពរបស់ ប.ស.ស ជាពិសេសការពង្រឹងសេវា នៃការផ្តល់អត្ថប្រយោជន៍ការងារជូនកម្មករនិយោជិត។

លោក **ម៉េង ហុង** នាយករងបេឡាជាតិរបបសន្តិសុខសង្គម បានមានប្រសាសន៍ថា៖ ប.ស.ស មានគោលបំណងផ្សព្វផ្សាយគោលនយោបាយថ្មីៗ និងវឌ្ឍនភាពរបស់ ប ស ស ជាពិសេសធ្វើការពង្រឹងសេវានៃការផ្តល់អត្ថប្រយោជន៍ហានិភ័យការងារជូនកម្មករនិយោជិត ក្នុងនោះមានការផ្តល់សេវារបស់ មន្ត្រីសាខាខ័ណ្ឌ និងសេវាមន្ទីរពេទ្យចុះកិច្ចព្រមព្រៀង និងធនាគារអេស៊ីលីដា។ ជាពិសេសសហគ្រាសមានមន្ទីរពេទ្យ មណ្ឌលសុខភាព ចុះកិច្ចព្រមព្រៀងក្នុងការផ្តល់សេវាជូនសមាជិក ប.ស.ស ចំនួន៩៥ ព្រមទាំងការផ្តល់អត្ថប្រយោជន៍បានជាង១០ម៉ឺននាក់ផងដែរ។ អត្ថប្រយោជន៍ដែលសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតទទួលបានពី ប ស ស រួមមាន

- ការសង្គ្រោះបន្ទាន់
- ការថែទាំ និងព្យាបាល
- ការទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃ
- ការទទួលបានប្រាក់ធនលាភ និងប្រាក់វិភាជន៍ សោហ៊ុយបូជាសព
- អត្ថប្រយោជន៍ឧត្តរជីវី
- សេវាបុននីតិសម្បទានិងការសម្របសម្រួលវិជ្ជាជីវៈ។

ការចូលរួមពិភាក្សាពីគ្រប់ភាគីពាក់ព័ន្ធ ក្នុងការពិនិត្យតាមដាននូវកិច្ចដំណើរការ អនុវត្តន៍របបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ ដើម្បីជាចលករមួយក្នុងការវិវឌ្ឍន៍នូវការអនុវត្តន៍ កិច្ចដំណើរការផ្នែកហានិភ័យការងារអោយបានតែមានប្រសិទ្ធិភាពខ្ពស់ជានិរន្តរ៍។

ជាទីបញ្ចប់ខ្ញុំរំពឹងថារាជរដ្ឋាភិបាល នឹងបន្តខិតខំប្រឹងប្រែងយកចិត្តទុកដាក់ ដល់សុខទុកប្រជាជនកម្ពុជាទាំងអស់ ហើយនឹងអាចស្វែងរកនូវរបបសន្តិសុខសង្គមដែលធានារ៉ាប់រងមិនត្រឹមតែកម្មករនិយោជិតទេ គឺអាចបង្កើតនូវរបបធានារ៉ាប់រងជូនប្រជាជនទាំងអស់នៅពេលពួកគាត់ចាស់ជរា

និង មានជំងឺឈឺស្កាត់។ ហើយពួកយើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាលដែលបានយកចិត្តទុកចំពោះកម្មករនិយោជិតតាមការបង្កើតឱ្យមានរបបធានារ៉ាប់រងសន្តិសុខសង្គមនេះឡើង។

# ឯកសារពិគ្រោះ

## ឯកសារយោង

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣
- ច្បាប់ស្តីពីការងារ ឆ្នាំ ១៩៩៧
- ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០២
- អនុក្រឹត្យ លេខ ១៦ អនក្រ.បក ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម ថ្ងៃទី ០២ មីនា ឆ្នាំ ២០០៧
- អនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ការងារ
- ប្រកាសរួមលេខ ១១០ កប/ប្រក ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៨ ស្តីពីការជូនដំណឹងហានិភ័យការងារ
- ប្រកាសលេខ ០២១/០៨ កប/ប្រក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៨ ស្តីពីសហគ្រាសគ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម
- ប្រកាសលេខ ០២២/០៨ កប/ប្រក ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៨ ស្តីពីការកំណត់ដំណាក់កាល និងវិសាលភាពនៃការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ
- ប្រកាសលេខ ១០៩ កប/ប្រក ចុះថ្ងៃទី ១៦ មិថុនា ឆ្នាំ ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ
- ប្រកាសលេខ ១០៨ កប/ប្រក ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០០៨ ស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ
- ប្រកាសលេខ ០៩៣/១៦ ក.ប/ប្រ.ក ស្តីពីដំណាក់កាល និងកាលបរិច្ឆេទអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព
- ប្រកាសលេខ ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៦ ស្តីពីតាវកាលិកថែទាំសុខភាព
- សេចក្តីសម្រេចលេខ ០០៤ ប.ស.ស ចុះថ្ងៃទី ២៩ ខែ ឆ្នាំ ២០០៨ ស្តីពីបញ្ជីមន្ទីពេទ្យ ឬ មន្ទីពេទ្យព្យាបាលទទួលស្គាល់ដោយ ប.ស.ស

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

## ស្តីពី

## របបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ
## ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

# LAW

## ON

## SOCIAL SECURITY SCHEMES FOR PERSONS
## DEFINED BY THE PROVISIONS OF THE LABOUR LAW

# មាតិការឿង

ជំពូកទី ១ បទប្បញ្ញត្តិទូទៅ ........................... ២

ជំពូកទី ២ ផ្នែកប្រាក់សោធន ........................... ៥

ជំពូកទី ៣ ផ្នែកហានិភ័យការខារ ................... ៧

ជំពូកទី ៤ បទប្បញ្ញត្តិផ្សេងៗ ....................... ១៣

ជំពូកទី ៥ ទោសប្បញ្ញត្តិ ................................. ១៦

ជំពូកទី ៦ អវសានប្បញ្ញត្តិ ............................ ១៩

# ព្រះរាជក្រម

នស/ រកម/ ០៩០២ / ០១៨ **យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និកនរោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី ៨ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយ

គ្មានកែប្រែអ្វីឡើយ កាលពីថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី ៧ នីតិកាលទី ១ ។

ច្បាប់នេះ មានសេចក្តីទាំងស្រុងដូចតទៅ ៖

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១**.-

ច្បាប់នេះមានគោលបំណងបង្កើតឱ្យមានរបបសន្តិសុខសង្គម សំរាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចតទៅ ៖

១-ផ្នែកប្រាក់សោធន ដែលត្រូវទទួលបន្ទុកផ្តល់តាវកាលិក ជរាភាព ទុព្វលភាព និងមរណភាព ។

២-ផ្នែកហានិភ័យការងារ ដែលត្រូវទទួលបន្ទុកផ្តល់តាវកាលិក គ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ ។

ចំពោះផ្នែកដទៃផ្សេងទៀត នឹងត្រូវកំណត់ដោយអនុក្រឹត្យជាបន្តបន្ទាប់ ដោយផ្អែកលើស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចជាតិ ។

**មាត្រា ២**.-

សេវាដែលត្រូវបំពេញបន្ថែមលើតាវកាលិកទាំងនេះ រួមមានសកម្មភាពផ្នែកសុខាភិបាល និងសង្គមកិច្ចត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៣**.-

របបសន្តិសុខសង្គម ដែលបង្កើតដោយច្បាប់នេះត្រូវធានារ៉ាប់រងដោយបេឡាជាតិរបបសន្តិសុខសង្គម សរសេរកាត់ថា "**ប.ស.ស**" ។ បេឡាជាតិរបបសន្តិសុខសង្គមជាគ្រឹះស្ថានសាធារណៈ ដែលត្រូវបង្កើតដោយអនុក្រឹត្យអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ដែលប្រកាសឱ្យប្រើ

ដោយព្រះរាជក្រមលេខជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៦ និងព្រះរាជក្រឹត្យលេខនស/រកត/១២៩៧/៩១ ចុះ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្ដីពីលក្ខន្តិកៈគតិយុត្តិនៃគ្រឹះស្ថានសាធារណៈ ។

**មាត្រា ៤**.-

ជនដែលត្រូវដាក់បញ្ចូលឱ្យនៅក្នុងរបបសន្តិសុខសង្គម តាមច្បាប់នេះ ដោយមិនមានបែងចែកពីពូជសាសន៍ ពណ៌សម្បុរ ភេទ ជំនឿ សាសនា គំនិតនយោបាយ ជាតិ-កំណើត ដើមកំណើតសង្គម ការចូលជាសមាជិកសហជីព កម្មករនិយោជិត ឬ ការធ្វើសកម្មភាពក្នុងសហជីព គឺ ៖

-កម្មករនិយោជិតទាំងអស់ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ ស្ដីពីការងារ ប្រសិនបើជនទាំងនោះធ្វើសកម្មភាពការងារនៅក្នុងទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីជាប្រយោជន៍សម្រាប់និយោជកម្នាក់ ឬច្រើននាក់ដោយមិនគិតដល់ប្រភេទ ទម្រង់និងសុពលភាពនៃកិច្ចសន្យា ឬប្រភេទ និងចំនួននៃប្រាក់ឈ្នួលដែលជននោះបានធ្វើ ឬបានទទួលឡើយ ។

-កម្មករនិយោជិតរដ្ឋ កម្មករនិយោជិត នៃអង្គការសាធារណៈ និង បុគ្គលិកទាំងអស់ ដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងដោយសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ឬលក្ខន្តិកៈទូត ព្រមទាំងភ្នាក់ងារក្រុមរាជការសាធារណៈ ដែលតែងតាំងដោយបណ្ដោះអាសន្ន ។

-សិស្សសាលាវិជ្ជាជីវៈ ជនដែលដាក់ឱ្យធ្វើការងារនៅក្នុងមណ្ឌល បណ្ដុះបណ្ដាល សម្របសម្រួល និងអប់រំវិជ្ជាជីវៈសាឡើងវិញ និងកូនជាងត្រូវចាត់ទុកដូចជាកម្មករនិយោជិត ដូចមានចែងនៅក្នុងវាក្យខ័ណ្ឌ ១ នៃមាត្រានេះដែរ ។ បែបបទសម្រាប់អនុវត្តបទប្បញ្ញត្តិផ្នែកនេះ ត្រូវកំណត់ដោយប្រកាស នៃរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម ។

-ជនដែលប្រកបមុខរបរក្នុងវិជ្ជាជីវៈសេរី ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម ។

-កម្មករនិយោជិតធ្វើការម្ដងម្កាល ឬ តាមរដូវ ។ បែបបទចាំបាច់

ដោយឡែកផ្សេងទៀតសម្រាប់ការអនុវត្តបទប្បញ្ញត្តិនៃផ្នែកនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម បន្ទាប់ពីបានទទួលយោបល់ពីក្រុមប្រឹក្សាបច្ចេកទេស និងក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម ។

សមាសភាពនិងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាបច្ចេកទេសត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥**.-

១-ជនទាំងឡាយណា ដែលត្រូវបានចូលក្នុងរបបសន្តិសុខសង្គម ក្នុងរយៈពេលយ៉ាងតិចប្រាំមួយ (៦) ខែ ជាបន្តបន្ទាប់មកហើយៗអស់លទ្ធភាពបំពេញលក្ខខណ្ឌ នៃការបញ្ចូលក្នុងរបបសន្តិសុខសង្គមនៃច្បាប់នេះ ប៉ុន្តែចង់បន្តដោយស្ម័គ្រចិត្តនៅក្នុងផ្នែកសោធនតទៅទៀត ត្រូវដាក់ពាក្យសុំក្នុងរយៈពេលបីខែក្រោយពីថ្ងៃដែលខ្លួនបានបញ្ចប់កាលបរិច្ឆេទ តាមសេចក្តីតំរូវនៃការបញ្ចូលទៅក្នុងរបបនេះ ។

២-បន្ទាប់ពីបានទទួលយោបល់ពីក្រុមប្រឹក្សាបច្ចេកទេស និងក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម ត្រូវចេញប្រកាសកំណត់អំពីបែបបទអនុវត្ត ចំពោះការធានារ៉ាប់រងផ្នែកសោធនតាមការស្ម័គ្រចិត្ត ដូចមានចែងក្នុងមាត្រានេះ ។

**មាត្រា ៦**.-

និយោជក និងកម្មករនិយោជិតទាំងអស់ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវមានកាតព្វកិច្ចបង់ភាគទានជូនដល់ **ប.ស.ស** ។ បែបបទ និងនីតិវិធីនៃការបង់ភាគទាន និងការទទួលតាវកាលិក ត្រូវកំណត់ក្នុងអនុក្រឹត្យស្តីពីការបង្កើត **ប.ស.ស** ដូចមានចែងក្នុងមាត្រា ៣ ខាងលើ ។

# ជំពូកទី ២
# ផ្នែកប្រាក់សោធន

**មាត្រា ៧**.-

តាវកាលិកនៃផ្នែកប្រាក់សោធនមានជាអាទិ៍ សោធនជរាភាព វិភាជន៍ជរាភាព សោធនទុព្វលភាព សោធនចំពោះអ្នកនៅក្នុងបន្ទុក និងវិភាជន៍ចំពោះអ្នកនៅក្នុងបន្ទុក ។

**មាត្រា ៨**.-

១-សមាជិក **ប.ស.ស** ដែលមានអាយុ ៥៥ ឆ្នាំ មានសិទ្ធិទទួលនូវប្រាក់សោធនជរាភាព ប្រសិនបើជននោះបានបំពេញលក្ខខណ្ឌដូចតទៅ ៖

ក-ចុះឈ្មោះក្នុងបញ្ជីនៃ **ប.ស.ស** ក្នុងថិរវេលាយ៉ាងតិចម្ភៃ (២០) ឆ្នាំ ។

ខ-បានបង់ភាគទានយ៉ាងតិចបំផុតហុកសិប(៦០) ខែ សម្រាប់របបសន្តិសុខសង្គម ក្នុងអំឡុងពេលដប់ឆ្នាំចុងក្រោយ គិតរហូតមកទល់កាលបរិច្ឆេទ ដែលមានសិទ្ធិត្រូវបានទទួលប្រាក់សោធន ។

២-សមាជិក **ប.ស.ស** ដែលមានការចុះទន់ខ្សោយសម្បទាមុនអាយុ ៥៥ ឆ្នាំ ទោះជាខាងស្មារតីក្តី ឬរាងកាយក្តី បណ្តាលឱ្យបាត់បង់សមត្ថភាពការងារ ដែលទទួលបានប្រាក់ឈ្នួល ប៉ុន្តែបានបំពេញនូវលក្ខខណ្ឌដូចមានចែងក្នុងវាក្យខណ្ឌខាងលើនេះ អាចស្នើសុំប្រាក់សោធនកាលាទិករណ៍បាន។ បែបបទនៃការកំណត់និងការត្រួតពិនិត្យភាពចុះទន់ខ្សោយសម្បទាមុនអាយុ ៥៥ ឆ្នាំ ត្រូវចេញដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម បន្ទាប់ពីការផ្តល់យោបល់ពីក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ។

៣-ប្រាក់សោធនជរាភាព និងប្រាក់សោធនកាលាទិករណ៍មានប្រសិទ្ធភាព នៅថ្ងៃទីមួយនៃខែតាមប្រតិទិន បន្ទាប់ពីកាលបរិច្ឆេទដែលសាមីជនបានបំពេញតាមលក្ខខណ្ឌត្រឹមត្រូវរួចហើយ ប្រសិនបើសាមីជននោះបានផ្ញើពាក្យ

សុំមក **ប.ស.ស** ក្នុងរយៈពេលដប់ពីរ (១២) ខែ បន្ទាប់ពីកាលបរិច្ឆេទដូចពោលខាងលើ ។ ក្នុងករណីដែលពាក្យសុំប្រាក់សោធនធ្វើនៅក្រោយថិរវេលា ដូចមានចែងខាងលើ ប្រាក់សោធននឹងត្រូវមានប្រសិទ្ធភាពនៅថ្ងៃទីមួយ នៃខែតាមប្រតិទិនបន្ទាប់ពីកាលបរិច្ឆេទនៃថ្ងៃដែលបានទទួលពាក្យសុំ ។

៤-សមាជិក **ប.ស.ស** ដែលមានអាយុ ៥៥ ឆ្នាំ បានបង់ភាគទានតិចជាងហុកសិប (៦០) ខែ សម្រាប់របបសន្តិសុខសង្គម ថែមទាំងបានបញ្ចប់គ្រប់ការងារដែលអាចទទួលបានប្រាក់ឈ្នួល ប៉ុន្តែមិនទាន់បានបំពេញលក្ខខណ្ឌផ្សេងទៀតដើម្បីអាចទទួលបានប្រាក់សោធនជរាភាព ត្រូវមានសិទ្ធិទទួលវិភាជន៍ជរាភាពដែលត្រូវបើកឱ្យតែម្តងគត់ ។

**មាត្រា ៩**.-

សមាជិក **ប.ស.ស** ដែលធ្លាក់ក្នុងទុព្វលភាពមុនអាយុ ៥៥ ឆ្នាំ មានសិទ្ធិទទួលនូវប្រាក់សោធនទុព្វលភាព ប្រសិនបើសាមីជនបានបំពេញលក្ខខណ្ឌដូចតទៅ ៖

ក-មានឈ្មោះក្នុងបញ្ជីនៃ **ប.ស.ស** យ៉ាងតិចប្រាំ (៥) ឆ្នាំ ។

ខ-បានបង់ភាគទានចំនួនប្រាំមួយ (៦) ខែ សំរាប់របបសន្តិសុខសង្គមក្នុងអំឡុងពេលដប់ពីរ (១២) ខែចុងក្រោយ ដោយគិតមកទល់ថ្ងៃដែលសាមីជនចាប់ផ្តើមបាត់បង់សមត្ថភាពការងារដោយសារទុព្វលភាព ។

**មាត្រា ១០**.-

ប្រសិនបើ សាមីជននៃសោធនជរាភាព ឬទុព្វលភាព ឬសោធនកាលាទិករណ៍ទទួលមរណភាព ឬក៏ក្នុងករណីដែលសមាជិក **ប.ស.ស** ទទួលមរណភាព ហើយដែលនៅក្នុងកាលបរិច្ឆេទនៃមរណភាពនេះ ជននោះបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់សម្រាប់ការទទួលយកអត្ថប្រយោជន៍ពីសោធនជរាភាព ឬទុព្វលភាព ឬក៏បានបង់ភាគទានចំនួនមួយរយប៉ែតសិប (១៨០) ខែ សម្រាប់របបសន្តិសុខសង្គមរួចហើយ អ្នកសិទ្ធិវន្តនៃជនទាំងនោះមានសិទ្ធិទទួលបាននូវសោធនចំពោះអ្នកនៅក្នុងបន្ទុក ។

**មាត្រា ១១**.-

ប្រសិនបើសមាជិក **ប.ស.ស** មិនអាចមានសិទ្ធិទទួលនូវប្រាក់សោធនទុព្វលភាពបាន និងមិនទាន់បានបង់ភាគទានគ្រប់ចំនួនមួយរយប៉ែតសិប (១៨០) ខែសំរាប់របបសន្តិសុខសង្គម គិតមកទល់នឹងថ្ងៃដែលខ្លួនទទួលមរណភាពទេនោះ ប្តី ឬប្រពន្ធដែលជាទុព្វលជនក្តី ឬមិនមែនក្តី ព្រមទាំងកូនកំព្រានៃសាមីជនត្រូវមានសិទ្ធិទទួលអត្ថប្រយោជន៍ជាវិភាជន៍ ចំពោះអ្នកនៅក្នុងបន្ទុកដែលបើកឱ្យតែម្តងគត់ ក្នុងចំនួនមិនតិចជាងប្រាក់សោធនជរាភាពប្រចាំខែសំរាប់សមាជិក **ប.ស.ស** នោះ ។

## ជំពូកទី ៣
## ផ្នែកហានិភ័យការងារ

**មាត្រា ១២**.-

ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ដែលធ្លាក់លើរូបកាយកម្មករនិយោជិត ដោយធ្វើការ ឬក្នុងពេលធ្វើការ ទោះដោយហេតុយ៉ាងណាក៏ដោយ ហើយទោះមានកំហុសពីកម្មករនិយោជិត ឬគ្មានក៏ដោយ គឺគ្រោះថ្នាក់ដែលធ្លាក់លើរូបកាយកម្មករនិយោជិតក្នុងពេលធ្វើការឱ្យនិយោជក ឬនាយកសហគ្រាស ឬធ្លាក់លើសិស្សវិជ្ជាជីវៈមានឈ្នួលក្តី ឥតឈ្នួលក្តី កាន់មុខងារជាអ្វី នៅទីកន្លែងណាក៏ដោយ ។

ម្យ៉ាងទៀត ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារដែរ ចំពោះគ្រោះថ្នាក់ណាដែលធ្លាក់លើរូបកាយកម្មករនិយោជិត ក្នុងពេលដែលសាមីខ្លួនធ្វើដំណើរពីលំនៅស្ថានខ្លួនត្រង់ឆ្ពោះទៅទីកន្លែងធ្វើការ ឬវិលមកវិញដោយគ្មានឈប់ ឬដោយគ្មានវាងទៅកន្លែងផ្សេងជាប្រយោជន៍ផ្ទាល់ខ្លួន ឬក្រៅពីការងារដែលគេតម្រូវឱ្យទៅ ។

**មាត្រា ១៣**.-

១-ជំងឺដែលបណ្តាលមកពីវិជ្ជាជីវៈ ក៏ត្រូវចាត់ទុកថាជាហានិភ័យការងារដែរ ។ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម និងរដ្ឋមន្ត្រី

ក្រសួងសុខាភិបាលត្រូវចេញប្រកាសរួមស្តីពី ការកំណត់បញ្ជីជំងឺវិជ្ជាជីវៈ ដោយមានភ្ជាប់មកជាមួយនូវបញ្ជីនៃមុខរបរប្រើកំលាំងកាយ មុខរបរដែលប៉ះពាល់ដោយជាតិពុល និងមុខរបរដែលត្រូវអនុវត្តនៅក្នុងលក្ខខណ្ឌ ឬតំបន់មានលក្ខណៈមិនប្រក្រតី ដែលនាំឱ្យអ្នកធ្វើការកើតជំងឺផ្សេងៗ បន្ទាប់ពីការផ្តល់យោបល់ពីក្រុមប្រឹក្សាបច្ចេកទេស ។

២-បញ្ជីនេះត្រូវសើរើពិនិត្យឡើងវិញជាកាលិក ដើម្បីកែលំអបច្ចេកទេសឱ្យបានជឿនលឿន និងជំរុញការយល់ដឹងខាងវេជ្ជសាស្ត្រ សម្រាប់ជាមូលដ្ឋានក្នុងការទប់ស្កាត់គ្រោះថ្នាក់ជំងឺវិជ្ជាជីវៈ ។

៣-ជំងឺដែលគេបានប្រកាសថាជាហានិភ័យការងារ ក្រោយពីកាលបរិច្ឆេទ ដែលកម្មករនិយោជិតបានឈប់ធ្វើការងារហើយនោះ ក៏អាចបើកសិទ្ធិឱ្យអ្នករងគ្រោះទទួលតាវកាលិកសម្រាប់ហានិភ័យការងារបានដែរ បើការប្រកាសនោះស្ថិតក្នុងអំឡុងពេលដែលមានបញ្ជាក់ក្នុងបញ្ជីនៃជំងឺវិជ្ជាជីវៈ ដែលមានចែងក្នុងវាក្យខ័ណ្ឌទី ១ ខាងលើ ។

**មាត្រា ១៤**.-

១-អ្នករងគ្រោះដោយគ្រោះថ្នាក់ការងារ ឬគ្រោះថ្នាក់ក្នុងការធ្វើដំណើរ ឬជំងឺវិជ្ជាជីវៈ ត្រូវជូនដំណឹងជាបន្ទាន់ទៅនិយោជក ឬអ្នកតំណាងនៃនិយោជកនោះអំពីគ្រោះថ្នាក់ដែលធ្លាក់មកលើខ្លួន លើកលែងតែក្នុងករណីប្រធានសក្តិ ឬការមិនមានលទ្ធភាពជាស្ថាពរ ឬក៏មានមូលហេតុសមហេតុសមផល។ កាតព្វកិច្ចដូចគ្នានេះដែរ បើក្នុងករណីមានគ្រោះថ្នាក់បណ្តាលឱ្យបាត់បង់ជីវិតត្រូវធ្លាក់ទៅលើអ្នកសិទ្ធិវន្ត ។

២-និយោជកត្រូវជូនដំណឹងទៅ **ប.ស.ស** ក្នុងរយៈពេលយ៉ាងយូរសែសិបប្រាំបី (៤៨) ម៉ោង ចំពោះគ្រោះថ្នាក់ការងារ ឬគ្រោះថ្នាក់ក្នុងការធ្វើដំណើរ ឬជំងឺវិជ្ជាជីវៈដែលធ្លាក់លើរូបកាយនិយោជិតកម្មករ ដែលធ្វើការក្នុងសហគ្រាសរបស់ខ្លួន ។ ការជូនដំណឹងនេះ ត្រូវធ្វើតាមទំរង់បែបបទ ដែលមានកំណត់ក្នុងប្រកាសរួមនៃក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម និងក្រសួងសុខាភិបាល

តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ។

៣-បែបបទនៃការត្រួតពិនិត្យ និងកាតព្វកិច្ចនៃអ្នករងគ្រោះថ្នាក់ការងារ ឬគ្រោះថ្នាក់ក្នុងការធ្វើដំណើរ ឬជំងឺវិជ្ជាជីវៈ ត្រូវកំណត់ដោយប្រកាសរួមនៃក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម និងក្រសួងសុខាភិបាល ។

**មាត្រា ១៥**.-

តាវកាលិកនៃហានិភ័យការងារមាន ៖

ក-ការថែទាំ និងព្យាបាលមុខរបួសដែលបណ្តាលមកពីគ្រោះថ្នាក់ការងារ ឬគ្រោះថ្នាក់ក្នុងការធ្វើដំណើរ ឬជំងឺវិជ្ជាជីវៈ ទោះបីគ្រោះថ្នាក់នោះបណ្តាលឱ្យមានការអាក់ខានធ្វើការក្តី ឬគ្មានក្តី ។

ខ-ការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់គ្រោះថ្នាក់ការងារ ឬគ្រោះថ្នាក់ក្នុងការធ្វើដំណើរ ឬជំងឺវិជ្ជាជីវៈ ដែលបណ្តាលឱ្យបាត់បង់សមត្ថភាពការងារជាបណ្តោះអាសន្ន ។

គ-ការផ្តល់ធនលាភ ឬប្រាក់វិភាជន៍ សម្រាប់ការបាត់បង់សមត្ថភាពការងារ ចំពោះគ្រោះថ្នាក់ការងារ ឬគ្រោះថ្នាក់ក្នុងការធ្វើដំណើរ ឬជំងឺវិជ្ជាជីវៈដែលបណ្តាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ។

ឃ-ការផ្តល់ប្រាក់វិភាជន៍ជាសោហ៊ុយសម្រាប់បូជាសព និងធនលាភចំពោះឧត្តរជីវីនៃជនរងគ្រោះ ។

**មាត្រា ១៦**.-

ការថែទាំ និងព្យាបាលមានជាអាទិ៍ដូចខាងក្រោម ៖

ក-ការជួយរ៉ាប់រងក្នុងការព្យាបាល ការវះកាត់ កិច្ចការទន្តសាស្ត្រ ព្រមទាំងការពិនិត្យដោយវិទ្យុកាំរស្មី ការពិនិត្យរបស់មន្ទីរពិសោធន៍ និងការវិភាគផ្សេងៗ ។

ខ-ការផ្គត់ផ្គង់ឱសថសម្រាប់ព្យាបាល និងសំភារៈប្រើប្រាស់បន្ទាប់បន្សំសម្រាប់ការព្យាបាល ។

គ-ការផ្តល់ប្រាក់ឧបត្ថម្ភ សម្រាប់ការថែទាំអ្នករងគ្រោះនៅក្នុងមន្ទីរពេទ្យ ឬក្នុងទីផ្សេងទៀត ។

ឃ-ការផ្គត់ផ្គង់ ការថែទាំ ឬជួសជុលជាថ្មីនូវឧបករណ៍អវយវៈសិប្បនិម្មិត ឬការកែទម្រង់កាយដោយគ្រូពេទ្យផ្លូវការ ឬគ្រូពេទ្យទទួលស្គាល់ដោយ **ប.ស.ស** តម្រូវឱ្យធ្វើ ឬការកែលំអសំរបសំរួលមុខងារ ឬការអប់រំវិជ្ជាជីវៈឡើងវិញ ។

ង-ការសម្របសម្រួលមុខងារ ការអប់រំវិជ្ជាជីវៈឡើងវិញ ការចាត់ថ្នាក់ការងារឡើងវិញតាមលក្ខខណ្ឌ ដែលកំណត់ដោយប្រកាស នៃក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម ។

ច-ការដឹកជនរងគ្រោះពីកន្លែងគ្រោះថ្នាក់ ទៅកាន់កន្លែងព្យាបាល ឬទៅកាន់លំនៅស្ថាន ។

**មាត្រា ១៧**.-

ក្នុងករណីដែលមាន ការបាត់បង់សមត្ថភាពការងារជាបណ្តោះអាសន្នដោយមានការបញ្ជាក់យ៉ាងត្រឹមត្រូវពីគ្រូពេទ្យផ្លូវការ ឬគ្រូពេទ្យទទួលស្គាល់ដោយ **ប.ស.ស** អ្នករងគ្រោះមានសិទ្ធិទទួលនូវប្រាក់បំណាច់ប្រចាំថ្ងៃ ។ ប្រាក់បំណាច់ប្រចាំថ្ងៃ ត្រូវបើកឱ្យអ្នករងគ្រោះរហូតដល់ថ្ងៃដែលមុខរបួសបានជាសះស្បើយ ឬដល់ថ្ងៃដែលអ្នករងគ្រោះទទួលមរណភាព ដោយសារមុខរបួស បន្ទាប់ពីមានការព្យាបាលមួយរយៈពេលមក ។ ប្រាក់ឈ្នួលប្រចាំថ្ងៃរបស់កម្មករនិយោជិតសម្រាប់ថ្ងៃផ្អាកការងារដំបូងត្រូវនៅក្នុងបន្ទុករបស់និយោជក ។

**មាត្រា ១៨**.-

បន្ទាប់ពីមានការបញ្ជាក់យ៉ាងត្រឹមត្រូវពីគ្រូពេទ្យផ្លូវការ ឬគ្រូពេទ្យទទួលស្គាល់ដោយ **ប.ស.ស** ថាខ្លួនបានបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍មក អ្នករងគ្រោះមានសិទ្ធិទទួលបាននូវ ៖

ក-ធនលាភ សម្រាប់ការបាត់បង់សមត្ថភាពការងារជា

អចិន្ត្រៃយ៍ ប្រសិនបើកម្រិតនៃការបាត់បង់សមត្ថភាពការងារមានយ៉ាងតិចស្មើនឹង ម្ភៃភាគរយ (២០%) ។

ខ-ប្រាក់វិភាជន៍សំរាប់ការបាត់បង់សមត្ថភាពការងារ ដែលត្រូវបើកឱ្យតែម្តងគត់ ប្រសិនបើកម្រិតនៃការបាត់បង់សមត្ថភាពការងារនោះតិចជាង ម្ភៃភាគរយ (២០%) ។

កម្រិតនៃការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ត្រូវកំណត់ដោយប្រកាសនៃរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ។

## មាត្រា ១៩.-

ក្នុងករណីមាន ហានិភ័យការងាររហូតបណ្តាលឱ្យអ្នករងគ្រោះបាត់បង់ជីវិត បេឡាជាតិរបបសន្តិសុខសង្គម ត្រូវផ្តល់ប្រាក់វិភាជន៍សំរាប់ជាសោហ៊ុយបូជាសព និងប្រាក់ធនលាភចំពោះអ្នកសិទ្ធិវន្តនៃជនរងគ្រោះ ។

## មាត្រា ២០.-

ឧត្តរជីវីនៃជនរងគ្រោះ គឺជនទាំងអស់ដែលមានលក្ខណៈសម្បត្តិដូចខាងក្រោម ៖

ក-ប្រពន្ធ ឬប្តីមិនមានការលែងលះ ឬក៏បែកបាក់គ្នា បានរៀបការពេញច្បាប់ដោយមានចុះបញ្ជីអត្រានុកូលដ្ឋានមុនពេលមានគ្រោះថ្នាក់ ឬមុនពេលជនរងគ្រោះបាត់បង់ជីវិត ទោះជាការរៀបការនេះធ្វើឡើងក្រោយពេលដែលមានគ្រោះថ្នាក់ការងារក៏ដោយ ។

ខ-កូនទាំងអស់ដែលនៅក្នុងបន្ទុកនៃអ្នករងគ្រោះ ដែលត្រូវកំណត់ក្នុងអនុក្រឹត្យស្តីពី ការបង្កើត **ប.ស.ស** ។

គ-ឪពុកម្តាយ ឬមនុស្សចាស់ជរា ដែលស្ថិតនៅក្រោមអាណាព្យាបាល និងនៅក្នុងបន្ទុកដោយផ្ទាល់នៃអ្នករងគ្រោះក្នុងឱកាសដែលមានគ្រោះថ្នាក់ ។

**មាត្រា ២១**.-

១-ចំពោះសមាជិក **ប.ស.ស** ដែលបានទទួលប្រាក់ធនលាភដោយការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ដោយផ្នែក ប៉ុន្តែត្រូវរងនូវហានិភ័យការងារជាថ្មីម្តងទៀត ត្រូវមានការគិតគូរឡើងវិញនូវចំនួនប្រាក់ធនលាភថ្មី ដោយផ្អែកលើកម្រិតនៃការបាត់បង់សមត្ថភាពការងារថ្មីនោះ ។ ទោះជាយ៉ាងនេះក៏ដោយ បើក្នុងពេលរងគ្រោះថ្នាក់ខាងក្រោយនេះ អ្នករងគ្រោះទទួលប្រាក់ឈ្នួលមូលដ្ឋានមធ្យមខ្ពស់ជាងមុន ត្រូវយកប្រាក់ឈ្នួលនេះ សម្រាប់ជាមូលដ្ឋានក្នុងការគណនាប្រាក់ធនលាភថ្មី ។

២-ចំពោះសមាជិក **ប.ស.ស** ដែលកំពុងទទួលប្រាក់វិភាជន៍ដោយការបាត់បង់សមត្ថភាពការងារ ប៉ុន្តែត្រូវរងហានិភ័យការងារជាថ្មីបណ្តាលឱ្យបាត់បង់សមត្ថភាពការងារយ៉ាងតិចម្ភៃភាគរយ (២០%) ជននេះមានសិទ្ធិទទួលនូវប្រាក់ធនលាភតាមកម្រិតបាត់បង់សមត្ថភាពការងារជាក់ស្តែងរបស់ខ្លួន ។ បើនៅពេលរងគ្រោះថ្នាក់ខាងក្រោយនេះ អ្នករងគ្រោះទទួលបានប្រាក់ឈ្នួលមធ្យមខ្ពស់ជាងមុន ត្រូវយកប្រាក់ឈ្នួលនេះ សម្រាប់គណនាប្រាក់ធនលាភ ។

៣-គ្រប់ករណីទាំងអស់ប្រាក់ធនលាភសំរាប់ការបាត់បង់សមត្ថភាពការងារនៅតែចាត់ទុកថាជាប្រាក់បណ្តោះអាសន្នជានិច្ច ។ បេឡាជាតិរបបសន្តិសុខសង្គម ត្រូវរៀបចំឱ្យមានការពិនិត្យសុខភាពជាកាលិកចំពោះអ្នករងគ្រោះដែលទទួលប្រាក់ធនលាភសំរាប់ការបាត់បង់សមត្ថភាពការងារ ។

អ្នករងគ្រោះ មិនអាចជំទាស់នឹងការពិនិត្យសុខភាព ដែលធ្វើឡើងតាមបញ្ជារបស់ បេឡាជាតិរបបសន្តិសុខសង្គមបានឡើយ ។

**មាត្រា ២២**.-

នៅក្នុងក្របខ័ណ្ឌនៃកម្មវិធីសកម្មភាពសុខាភិបាល និងសង្គមកិច្ច **ប.ស.ស** ត្រូវរៀបចំឱ្យមានការបង្ការចំពោះហានិភ័យការងារមានជាអាទិ៍ វិធានការផ្នែកអនាម័យ និងសន្តិសុខការងារចំពោះកម្មករនិយោជិតដែលមានកំណត់នៅក្នុងច្បាប់ស្តីពីការងារ និងអត្ថបទណែនាំអនុវត្តច្បាប់នេះ ។

# ជំពូកទី ៤
# បទប្បញ្ញត្តិផ្សេងៗ

**មាត្រា ២៣**.-

បែបបទនៃការចូលរួមរបស់និយោជក ការចុះឈ្មោះនៃកម្មករនិយោជិត ការបង់ភាគទាន ការទូទាត់តាវកាលិក និងសេវានៃតាវកាលិក ដែលត្រូវធ្លាក់មកក្នុងបន្ទុករបស់និយោជក និងកម្មករនិយោជិតនៅក្នុងដំណើរប្រព្រឹត្តទៅនៃរបបសន្តិសុខសង្គម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ។

**មាត្រា ២៤**.-

១-មូលនិធិផ្នែកសកម្មភាពសុខាភិបាល និងសង្គមកិច្ចរបស់ **ប.ស.ស** ត្រូវបានផ្គត់ផ្គង់ដោយប្រាក់ ដែលជាផលកំរៃនៃប្រាក់ពិន័យដោយសារការយឺតយូររបស់និយោជកក្នុងការមកបង់ភាគទាន និងការផ្តល់តារាងបៀវត្សមិនទាន់តាមកាលកំណត់ ព្រមទាំងប្រាក់បម្រុងដែលបានកាត់ទុកមុនពីប្រាក់ចំណូលដទៃទៀតរបស់ **ប.ស.ស** ។

២-**ប.ស.ស** អាចប្រើប្រាស់ធនធាននានារបស់មូលនិធិខាងសុខាភិបាល និងសង្គមកិច្ចសម្រាប់ ៖

ក-ធ្វើសកម្មភាពនានាក្នុងគោលដៅសម្រាប់ការបង្ការទូទៅ ការបង្ការគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ ការសម្របសម្រួលវិជ្ជាជីវៈ ជាពិសេសសម្រាប់ការសិក្សាស្រាវជ្រាវ និងធ្វើស្ថិតិហានិភ័យការងារ ព្រមទាំងការឃោសនាផ្សព្វផ្សាយដើម្បីជំរុញឱ្យវិធានការបង្ការ និងសម្រួលវិជ្ជាជីវៈមានការអភិវឌ្ឍន៍ ។

ខ-ផ្តល់ជំនួយខាងហិរញ្ញវត្ថុ ឬចូលរួមជាមួយស្ថាប័នសាធារណៈ ឬអង្គការឯកជនក្នុងវិស័យសុខាភិបាល និងសង្គមកិច្ចដែលមានសកម្មភាពជាប្រយោជន៍សម្រាប់សមាជិក **ប.ស.ស** នៃផ្នែកនីមួយៗ ។

**មាត្រា ២៥**.-

១-រយៈពេលដែលបើកសិទ្ធិឱ្យសមាជិក **ប.ស.ស** ទទួលបានតាវកាលិក គឺរយៈពេលទាំងឡាយណាដែលសមាជិកនោះបានទទួលប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ហានិភ័យការងារ ឬរយៈពេលបាត់បង់សមត្ថភាពការងារដែលមិនលើសពីប្រាំមួយ (៦) ខែ ក្នុងករណីមានជំងឺដែលមានការបញ្ជាក់ត្រឹមត្រូវពីគ្រូពេទ្យផ្លូវការ ឬគ្រូពេទ្យដែលទទួលស្គាល់ដោយ **ប.ស.ស** ឬរយៈពេលដែលអវត្តមានក្នុងឱកាសឈប់សំរាកធម្មតា ដោយគិតទាំងរយៈពេលធ្វើដំណើរដែលមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារផងដែរ ។

២-ពាក្យថា "ខែ" សម្រាប់របបសន្តិសុខសង្គមគឺជាខែដែលសមាជិក **ប.ស.ស** បានបំពេញការងារមានរយៈពេលយ៉ាងតិចដប់ប្រាំ (១៥) ថ្ងៃ ។ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម ត្រូវចេញប្រកាសកំណត់បែបបទអនុវត្តក្នុងផ្នែកនេះ ព្រមទាំងលក្ខខណ្ឌសម្រាប់ការកំណត់អំពី "ខែ" សម្រាប់របបសន្តិសុខសង្គម ។

**មាត្រា ២៦**.-

ប្រាក់ធនលាភ និងប្រាក់សោធនទាំងអស់ត្រូវគណនាតាមចំនួនប្រចាំខែ ។ ការគណនាប្រចាំខែនេះ ត្រូវកំណត់តាមស្ថានភាពនៃសមាជិក **ប.ស.ស** គឺនៅថ្ងៃទីមួយនៃខែដែលត្រូវគ្នា ។ ចំនួនទឹកប្រាក់ប្រចាំខែនីមួយៗត្រូវបង្កើន ឬបន្ថយតាមខ្ទង់រយដែលជិតជាង ។

ការបើកប្រាក់ធនលាភ និងប្រាក់សោធនត្រូវធ្វើប្រចាំត្រីមាស ។

**មាត្រា ២៧**.-

១-សិទ្ធិនៃការទាមទារប្រាក់បំណាច់ប្រចាំថ្ងៃ សម្រាប់ហានិភ័យការងារ និងប្រាក់វិភាជន៍បូជាសពត្រូវអស់សុពលភាពត្រឹមរយៈពេលមួយ (១) ឆ្នាំ ។

២-សិទ្ធិនៃការទាមទារប្រាក់ធនលាភនិងប្រាក់សោធន ព្រមទាំងវិភាជន៍ជរាភាព ទុព្វលភាព និងមរណភាពត្រូវអស់សុពលភាពត្រឹមរយៈពេលប្រាំ (៥) ឆ្នាំ ។

**មាត្រា ២៨**.-

ជនដែលបានទទួលប្រាក់ធនលាភ ដោយការបាត់បង់សមត្ថភាពការងារ ឬប្រាក់សោធនទុព្វលភាពណាម្នាក់ ដែលតម្រូវឱ្យមានអ្នកចាំថែរក្សាមានសិទ្ធិទទួលបានការឧបត្ថម្ភបន្ថែមចំនួនហាសិប (៥០%) ភាគរយនៃចំនួនប្រាក់ធនលាភ ឬប្រាក់សោធននោះ ។

**មាត្រា ២៩**.-

តាវកាលិកទាំងអស់មិនអាចផ្ទេរ ឬរឹបអូសបានទេលើកលែងតែមានលក្ខខណ្ឌ និងការកម្រិតដូចគ្នានឹងការផ្ទេរ ឬរឹបអូសប្រាក់ឈ្នួលដែលមានចែងនៅក្នុងច្បាប់ស្តីពីការងារ ។

**មាត្រា ៣០**.-

ក្នុងករណីដែលមានអត្ថប្រយោជន៍ត្រួតគ្នា ទោះជាអត្ថប្រយោជន៍ខាងប្រាក់សោធនក្តី ឬប្រាក់ធនលាភក្តី អនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ សាមីជនមានសិទ្ធិទទួលបានប្រាក់សោធន ឬប្រាក់ធនលាភណាដែលមានចំនួនទឹកប្រាក់ខ្ពស់ជាងគេ ។

**មាត្រា ៣១**.-

វិវាទ ឬបណ្តឹងដែលទាក់ទងនឹងការអនុវត្តបទប្បញ្ញត្តិ និងបទបញ្ជាខាងវិស័យរបបសន្តិសុខសង្គមរវាងសមាជិក **ប.ស.ស** និយោជក និង **ប.ស.ស** ដែលមិនអាចដោះស្រាយបាន ដោយការផ្សះផ្សារបស់គណកម្មការដោះស្រាយវិវាទ ឬបណ្តឹងនៃ **ប.ស.ស** ត្រូវនៅក្រោមសមត្ថកិច្ចនៃតុលាការ ដែលសមាជិក **ប.ស.ស** ឬនិយោជករស់នៅ ។ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម ត្រូវចេញប្រកាសកំណត់អំពីសមាសភាព និងការប្រព្រឹត្តទៅរបស់គណ-កម្មការដោះស្រាយវិវាទ ឬបណ្តឹងនៃ **ប.ស.ស** ។

**មាត្រា ៣២**.-

១-ត្រូវបង្កើតឱ្យមាន ប្រព័ន្ធសម្របសម្រួលមួយរវាងផ្នែកនីមួយៗ ដែលបង្កើតឡើងដោយច្បាប់នេះ ជាមួយនឹងគ្រប់របបធានារ៉ាប់រងនៃផ្នែកសាធារណៈ ដើម្បីធ្វើឱ្យមានសុពលភាពក្នុងការចូលនិវត្តន៍នៃសេវាដែលមានពីមុនមក និងមានសុពលភាពនៃរយៈពេលធានារ៉ាប់រងក្នុងករណីមានការផ្លាស់ប្តូរលក្ខន្តិកៈ ឬរបបធានារ៉ាប់រងនៃភ្នាក់ងារណាមួយ ។

២-បែបបទនៃការអនុវត្តប្រព័ន្ធសម្របសម្រួលនេះ ត្រូវកំណត់ដោយប្រកាសនៃរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម ។

**មាត្រា ៣៣**.-

បេឡាជាតិរបបសន្តិសុខសង្គមត្រូវរួចផុតពីការបង់ពន្ធ និងអាករគ្រប់យ៉ាង ។ ប៉ុន្តែ ប្រតិបត្តិការរបស់បេឡានេះ ដែលមានចរិតជាពាណិជ្ជកម្ម ហើយដែលមានគោលដៅរកផលចំណេញសុទ្ធសាធ ត្រូវជាប់ពន្ធអាករតាមច្បាប់ជាធរមាន ។

## ជំពូកទី ៥
## ទោសប្បញ្ញត្តិ

**មាត្រា ៣៤**.-

ជនប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ ឬត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ឬក៏ត្រូវផ្តន្ទាទោសទាំងពីរ ។

ការពិន័យជាប្រាក់ ត្រូវដាក់បង្ខំដោយនាយកនៃ **ប.ស.ស** ។

**មាត្រា ៣៥**.-

ការពិន័យជាប្រាក់ ត្រូវកំណត់ជាពហុគុណនៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ ។ ប្រាក់ឈ្នួលយោងប្រចាំថ្ងៃ គឺជាប្រាក់ឈ្នួលអប្បបរមាដែលកំណត់

ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៣៦**.-

និយោជកណាដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃមាត្រា ៦ ឬមាត្រា ២៣ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់ (១០) ថ្ងៃ ទៅសាមសិប (៣០) ថ្ងៃ នៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ ឬបើក្នុងករណីមិនរាងចាល ត្រូវពិន័យពីសាមសិប (៣០) ថ្ងៃ ទៅកៅសិប (៩០) ថ្ងៃ នៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ ដោយមិនទាន់គិតដល់ទណ្ឌកម្មចំពោះការបង់ភាគទាន និងប្រាក់ពិន័យដែលត្រូវធ្លាក់លើបន្ទុករបស់និយោជកនោះទេ ។ ការពិន័យនេះ ត្រូវអនុវត្តស្មើនឹងចំនួនមនុស្សដែលត្រូវបានគេប្រើប្រាស់ក្នុងលក្ខខណ្ឌផ្ទុយពីបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៣៧**.-

និយោជកណា ដែលបានដកយកភាគទានពីកម្មករនិយោជិតដោយមិនត្រឹមត្រូវ ដើម្បីដាក់មកក្នុងរបបសោធនដោយការកាត់បន្ថយប្រាក់ឈ្នួលនោះ ត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពីមួយ (១) ខែ ដល់មួយ (១) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយរយម្ភៃ (១២០) ថ្ងៃ ទៅបីរយហុកសិប (៣៦០) ថ្ងៃ នៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ ឬត្រូវផ្តន្ទាទោសណាមួយក្នុងចំណោមទោសទាំងពីរ ។

ក្នុងករណីមិនរាងចាល ក្នុងអំឡុងពេលបី (៣) ឆ្នាំ ត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពីមួយ (១) ឆ្នាំ ដល់ប្រាំ (៥) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយរយម្ភៃ (១២០) ថ្ងៃ ទៅបីរយហុកសិប (៣៦០) ថ្ងៃ នៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ ឬក៏ត្រូវផ្តន្ទាទោសណាមួយក្នុងចំណោមទោសទាំងពីរនេះ ។

**មាត្រា ៣៨**.-

១-ជនណាក៏ដោយដែលធ្វើឯកសារក្លែងបន្លំដោយចេតនា ដើម្បីចង់បានការផ្តល់តាវកាលិកសំរាប់ខ្លួន ឬតតិយជន ដែលមិនគួរត្រូវបាន ត្រូវផ្តន្ទា

ទោសពិន័យជាប្រាក់ពីហុកសិប (៦០) ថ្ងៃ ទៅកៅសិប (៩០) ថ្ងៃ នៃប្រាក់ឈ្នួលយោងប្រចាំថ្ងៃ និងផ្តន្ទាទោសដាក់ពន្ធនាគារពីប្រាំមួយ (៦) ថ្ងៃ ទៅមួយ (១) ខែ ឬក៏ត្រូវផ្តន្ទាទោសណាមួយក្នុងចំណោមទោសទាំងពីរនេះ ។ ការដាក់ទណ្ឌកម្មខាងលើនេះ ត្រូវធ្វើដោយមិនទាន់គិតដល់ទោសកំហុសដទៃទៀត ប្រសិនបើជននេះបានប្រព្រឹត្តផងដែរ ។

២-ក្នុងករណីមិនរាងចាលក្នុងអំឡុងមួយ (១) ឆ្នាំ ត្រូវទទួលការដាក់ទណ្ឌកម្មដល់កំរិតអតិបរមា គឺទណ្ឌកម្មទាំងពីររួមគ្នាតែម្តង ។

**មាត្រា ៣៩**.-

គ្រប់ករណីដូចមានចែងក្នុងមាត្រា ៣៦ និងមាត្រា ៣៧ ខាងលើ តុលាការអាចបញ្ជាឱ្យផ្សព្វផ្សាយនូវសាលក្រមតាមសារពត៌មាន និងបិទប្រកាសផ្សាយនៅតាមទីកន្លែងនានាដែលបានកំណត់ ។ ប្រាក់ចំណាយសម្រាប់ការផ្សព្វផ្សាយនេះ ត្រូវនៅក្នុងបន្ទុករបស់ជនដែលប្រព្រឹត្តល្មើស ។

**មាត្រា ៤០**.-

១-ពាក្យបណ្តឹងសាធារណៈចំពោះការល្មើសរបស់និយោជក ឬអ្នកតំណាងរបស់ខ្លួនលើបទប្បញ្ញត្តិស្តីពីទណ្ឌកម្មដូចមានចែងក្នុងមាត្រា ៣៤ ខាងលើត្រូវមានអាជ្ញាយុកាលរយៈពេលមួយ (១) ឆ្នាំ ដោយគិតចាប់ពីកាលបរិច្ឆេទនៃការចេញលិខិតដាក់កំហិតរយៈពេលដប់ប្រាំ (១៥) ថ្ងៃមក ។

២-ពាក្យបណ្តឹងរដ្ឋប្បវេណីចំពោះការទារភាគទាន ឬប្រាក់ពិន័យដោយការយឺតយូរក្នុងការបង់ប្រាក់របស់និយោជកត្រូវមានអាជ្ញាយុកាលរយៈពេលប្រាំ (៥) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចេញលិខិតដាក់កំហិតរយៈពេលដប់ប្រាំ (១៥) ថ្ងៃមកដោយមិនមានទាក់ទងនឹងបណ្តឹងសាធារណៈ ឬបន្ទាប់ពីការកន្លងផុតនៃបណ្តឹងសាធារណៈ ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ៤១**.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីច្បាប់នេះត្រូវចាត់ទុកជានិរាករណ៍។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០២

ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និង ត្រា**

**ជា ស៊ីម**

ពរល-០២-០៩-០០២៨៨

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ**

**បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា**

**ហត្ថលេខា**

**អ៊ិត សំហេង**

លេខៈ ១៩៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ហត្ថលេខា**

**ឈាឌី តាន់**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម ០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព តាមច្បាប់ស្តីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលដៅបង្កើតយន្តការផ្តល់ជូនសមាជិក ប.ស.ស នូវសេវាបង្ការសុខភាព និងតាវកាលិកព្យាបាលនិងថែទាំវេជ្ជសាស្ត្រ និងការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលនៃការផ្អាកការងារដោយការព្យាបាលជំងឺ ឬគ្រោះថ្នាក់ផ្សេងៗក្រៅពីហានិភ័យការងារ និងការសម្រាកមាតុភាព។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ព្រមទាំងសហព័ទ្ធ និងកូនដែលស្ថិតនៅក្នុងបន្ទុកផ្ទាល់នៃកម្មករនិយោជិតដែលជាសមាជិក ប.ស.ស និងសមាជិក ប.ស.ស ដែលកំពុងទទួលបានប្រាក់ធនលាភ ដោយការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ និងឧត្តរជីវី។

**មាត្រា ៤.-**

វាក្យសព្ទបច្ចេកទេសដែលប្រើនៅក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ៖

- **ថែទាំសុខភាព** សំដៅដល់ការធានារ៉ាប់រងសុខភាពសង្គម ដែលត្រូវផ្តល់តាវកាលិក សេវាបង្ការសុខភាព តាវកាលិកព្យាបាលនិងថែទាំវេជ្ជសាស្ត្រ និងការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលនៃការផ្អាកការងារដោយការព្យាបាលជំងឺ ឬគ្រោះថ្នាក់ផ្សេងៗក្រៅពីហានិភ័យការងារ និងការសម្រាកមាតុភាព។
- **តាវកាលិក** សំដៅដល់ការផ្តល់សេវាបង្ការសុខភាព សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃនៅពេលសម្រាកព្យាបាលជំងឺឬគ្រោះថ្នាក់ផ្សេងៗក្រៅពីហានិភ័យការងារ និងមាតុភាព។
- **សហព័ទ្ធ** សំដៅដល់ ប្រពន្ធ ឬប្តី ដែលនៅមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់។
- **ឧត្តរជីវី** សំដៅដល់អ្នកនៅរស់មានជីវិត ជាប្រពន្ធ ឬ ប្តី និងកូន នៅក្នុងបន្ទុកផ្ទាល់នៃសាមីជនដែលជាសមាជិកប.ស.ស ក្រោយពីទទួលមរណភាពដោយហានិភ័យការងារ។

## ជំពូកទី ២

## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា ៥.-**

បេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស) គឺជាស្ថាប័នប្រតិបត្តិករតែមួយគត់ដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

**មាត្រា ៦.-**

ក្រុមប្រឹក្សាជាន់ខ្ពស់មួយ ដែលជាបញ្ញត្តិករប្រព័ន្ធសន្តិសុខសង្គម ត្រូវបង្កើតឡើងដោយអនុក្រឹត្យដោយឡែក ដើម្បីគ្រប់គ្រងធ្វើអធិការកិច្ច តាមដាន ត្រួតពិនិត្យរាល់ការគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពរបស់ ប.ស.ស និងកំណត់គោលនយោបាយអភិវឌ្ឍន៍ប្រព័ន្ធសន្តិសុខសង្គម។

## ជំពូកទី ៣
## ភាគទាន តាវកាលិក និងប្រាក់ត្រៀមបម្រុងផ្នែកថែទាំសុខភាព

### ផ្នែកទី ១
### ភាគទានផ្នែកថែទាំសុខភាព

**មាត្រា ៧.-**

និយោជក និងកម្មករនិយោជិត ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវមានកាតព្វកិច្ចបង់ភាគទានផ្នែកថែទាំសុខភាពជូនដល់ ប.ស.ស ។ ផ្នែកនៃភាគទានដែលជាបន្ទុករបស់កម្មករនិយោជិត មិនត្រូវលើសពីផ្នែកនៃភាគទានដែលជាបន្ទុករបស់និយោជកឡើយ។

អត្រាភាគទានផ្នែកថែទាំសុខភាព បែបបទ និងនីតិវិធីនៃការបង់ភាគទាននេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃប.ស.ស។

### ផ្នែកទី ២
### តាវកាលិកផ្នែកថែទាំសុខភាព

**មាត្រា ៨.-**

តាវកាលិកផ្នែកថែទាំសុខភាព ដែលកំណត់ក្នុងអនុក្រឹត្យនេះរួមមាន ការផ្តល់សេវាបង្ការសុខភាព ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រ និងការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលនៃការផ្អាកការងារដោយការព្យាបាលជំងឺ ឬគ្រោះថ្នាក់ផ្សេងៗក្រៅពីហានិភ័យការងារ និងការសម្រាកមាតុភាព។

ប្រភេទសេវា និងជំងឺដែលមិនទាន់ត្រូវបានដាក់បញ្ចូលក្នុងតាវកាលិកផ្នែកថែទាំសុខភាព ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើពីក្រុមប្រឹក្សាភិបាល នៃ ប.ស.ស។

បែបបទ និងនីតិវិធី នៃការផ្តល់តាវកាលិកផ្នែកថែទាំសុខភាព ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃប.ស.ស។

យន្តការនៃការទូទាត់ចំណាយសេវាបង្ការសុខភាព ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃប.ស.ស។

**មាត្រា ៩.-**

ការទទួលបានតាវកាលិកថែទាំសុខភាព ត្រូវអនុលោមតាមលក្ខខណ្ឌដែលពាក់ព័ន្ធនឹងរយៈពេលធានារ៉ាប់រង និងរយៈពេលយោង ដែលលក្ខខណ្ឌទាំងនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃប.ស.ស។

## ផ្នែកទី ៣
## ប្រាក់ត្រៀមបម្រុងផ្នែកថែទាំសុខភាព

**មាត្រា ១០.-**

ប្រាក់ត្រៀមបម្រុងអប្បបរមាផ្នែកថែទាំសុខភាព ត្រូវស្មើនឹងចំនួនទឹកប្រាក់ដែលបានចំណាយសម្រាប់តាវកាលិក ក្នុងអំឡុងពេល ០១ (មួយ) ឆ្នាំចុងក្រោយ ។

## ជំពូកទី ៤
## ការទទួលស្គាល់ និងការត្រួតពិនិត្យគុណភាព
## សេវារបស់មូលដ្ឋានសុខាភិបាល
## ផ្នែកទី ១
## ការទទួលស្គាល់គុណភាពសេវា

**មាត្រា ១១.-**

ការព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ត្រូវផ្ដល់ដោយមូលដ្ឋានសុខាភិបាល ដែលមានការទទួលស្គាល់ពីក្រសួងសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ។

ការទទួលស្គាល់គុណភាពសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ ត្រូវអនុវត្តស្របតាមគោលការណ៍ដែលកំណត់ដោយក្រសួងសុខាភិបាល។

## ផ្នែកទី ២
## ការត្រួតពិនិត្យគុណភាពសេវា

**មាត្រា ១២.-**

គុណភាពសេវារបស់មូលដ្ឋានសុខាភិបាល ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ តាមដាន និងឃ្លាំមើលរបស់គណៈកម្មការវេជ្ជសាស្ត្រ នៃប.ស.ស។

សមាសភាព និងតួនាទីភារកិច្ចរបស់គណៈកម្មការវេជ្ជសាស្ត្រ នៃប.ស.ស ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃប.ស.ស។

## ជំពូកទី ៥
## ដំណាក់កាលនៃការអនុវត្ត

**មាត្រា ១៣.-**

ដំណាក់កាលដំបូង ការផ្ដល់សេវាថែទាំសុខភាពត្រូវអនុវត្តចំពោះតែសមាជិក ប.ស.ស និងឧត្តរជីវី។

ការផ្ដល់សេវាថែទាំសុខភាពចំពោះសហព័ទ្ធ និងកូន ដែលនៅក្នុងបន្ទុកផ្ទាល់របស់សាមីជន ត្រូវអនុវត្តជាបន្តបន្ទាប់អនុលោមតាមស្ថានភាព សង្គម សេដ្ឋកិច្ចជាក់ស្ដែង ដែលត្រូវកំណត់ដោយប្រកាសក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃប.ស.ស។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ១៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងនាយកបេឡាជាតិរបបសន្តិសុខសង្គម ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
សូមហត្ថលេខា

| | |
|---|---|
| **រដ្ឋមន្ត្រី**<br>**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** | **រដ្ឋមន្ត្រី**<br>**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** |
| **អូន ព័ន្ធមុនីរ័ត្ន** | **អ៊ិត សំហេង** |

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១៤
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ......១១០............កប/ប្រ.ក

# ប្រកាសរួម
# ស្តីពី
# ការជូនដំណឹងហានិភ័យការងារ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
## និង
## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ ២០០៤ ដែល ប្រកាសឱ្យ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសំរាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ/បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យ លេខ ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ-បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ .ស្តីពីការរៀបចំ និងការប្រព្រឹត្តរបស់ក្រសួងសុខាភិបាល

- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ/បក ចុះថ្ងៃទី ០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម

## សម្រេច

**ប្រការ ១.-**

១.១ កម្មករ និយោជិតសមាជិកនៃ **ប.ស.ស** ត្រូវជូនដំណឹងជាបន្ទាន់ទៅនិយោជក ឬអ្នកតំណាងនិយោជក អំពីហានិភ័យការងារ (គ្រោះថ្នាក់ការងារ គ្រោះថ្នាក់ពេលធ្វើដំណើរ និងជំងឺវិជ្ជាជីវៈ) ដែលធ្លាក់មកលើខ្លួន។ ក្នុងករណីដែលមានគ្រោះថ្នាក់បណ្តាលឱ្យបាត់បង់ជីវិត កាតព្វកិច្ចនៃការជូនដំណឹងនេះត្រូវធ្លាក់លើសិទ្ធិវន្តនៃជនរងគ្រោះ។

១.២ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារហើយដែលបានចុះបញ្ជិកានៅក្នុងបេឡាជាតិរបបសន្តិសុខសង្គម ត្រូវជូនដំណឹងទៅបេឡាជាតិរបបសន្តិសុខសង្គម ក្នុងរយៈពេលយ៉ាងយូរបំផុត ៤៨ (សែសិបប្រាំបី) ម៉ោងនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលដំណឹងអំពីហានិភ័យការងារដែលធ្លាក់មកលើកម្មករនិយោជិតរបស់ខ្លួន។

**ប្រការ ២.-**

ការជូនដំណឹងអំពីហានិភ័យការងារដូចមានចែងក្នុងវាក្យខ័ណ្ឌ ១.២ នៃប្រការ ១ ខាងលើ ត្រូវធ្វើតាមទម្រង់ *"របាយការណ៍ហានិភ័យការងារ"* ដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ៣.**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០០៨

**រដ្ឋមន្ត្រី**
**ក្រសួងសុខាភិបាល**

**វេជ្ជ. នុត-សុខុម**

**រដ្ឋមន្ត្រី**
**ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**វង សូត**

**ចម្លងជូន :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ " ដើម្បីជូនជ្រាប
- កាលប្បវត្តិ និងឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិរបបសន្តិសុខសង្គម
លេខ :.....០០៤.......ប.ស.ស

# បញ្ជីមន្ទីរពេទ្យ ឬមន្ទីរព្យាបាល
# ទទួលស្គាល់ដោយ ប.ស.ស

## ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០២ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសំរាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៥១ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ/បក ចុះថ្ងៃទី ០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- បានឃើញអនុក្រឹត្យលេខ ៥៧២ អនក្រ/តត ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម
- បានឃើញប្រកាសលេខ ១០៩ កប/ប្រក ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាភិបាលលើកទី ៧ នាថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០០៨

## សម្រេច

ប្រការ ១.-

មន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលបេឡាជាតិរបបសន្តិសុខសង្គមទទួលស្គាល់ សម្រាប់ការព្យាបាលមុខរបួស ឬជំងឺវិជ្ជាជីវៈ ដែលបណ្តាលមកពីហានិភ័យការងារមានដូចខាងក្រោមៈ

១. នៅរាជធានីភ្នំពេញ

ស៊ា

ក.មន្ទីរពេទ្យកាល់ម៉ែត្រ

ខ.មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត

គ.មន្ទីរពេទ្យព្រះកុសមៈ

ឃ.មន្ទីរពេទ្យព្រះកេតុមាលា

២. នៅបណ្តាខេត្ត-ក្រុង

ក. មន្ទីរពេទ្យបង្អែកកម្រិត ៣ (ថ្នាក់ខេត្ត ក្រុង)

ខ. មន្ទីរពេទ្យបង្អែកកម្រិត ២ (ថ្នាក់ស្រុក)

ប្រការ ២.-

ចំពោះករណីសង្គ្រោះបន្ទាន់ អាចត្រូវបានសង្គ្រោះនៅមន្ទីរពេទ្យ ឬមន្ទីរព្យាបាលដែលស្ថិតនៅជិតកន្លែងគ្រោះថ្នាក់បំផុត ។

ប្រការ ៣.-

ការទទួលស្គាល់មន្ទីរពេទ្យ ឬមន្ទីព្យាបាលដទៃទៀត នឹងអាចធ្វើឡើងដោយការសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គមទៅតាមសេចក្តីត្រូវការជាក់ស្តែង ។

ប្រការ ៤.-

សេចក្តីសម្រេចនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែ ៥ ឆ្នាំ២០០៨

ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស

ប្រធាន



សេង-សក្តា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

# Sub-Decree

## On

## The establishment of National Social Security Fund

# មាតិកា

**ជំពូកទី ១** បទប្បញ្ញត្តិទូទៅ............................................................ ០២

**ជំពូកទី ២** រដ្ឋបាលបេឡាជាតិរបបសន្តិសុខសង្គម............................. ០៣

២.១ ផ្នែកទី ១ ក្រុមប្រឹក្សាភិបាល ................................................. ០៣

២.២ ផ្នែកទី ២ អង្គការប្រតិបត្តិនៃ ប.ស.ស.................................... ០៨

**ជំពូកទី ៣** ការគ្រប់គ្រងហិរញ្ញវត្ថុ ..................................................... ១១

៣.១ ផ្នែកទី ១ កិច្ចការគណនេយ្យ ................................................. ១១

៣.២ ផ្នែកទី ២ ប្រភពធនធាន ...................................................... ១២

៣.៣ ផ្នែកទី ៣ ការចំណាយ ......................................................... ១៣

៣.៤ ផ្នែកទី ៤ ប្រាក់ត្រៀមបម្រុង ................................................. ១៤

៣.៥ ផ្នែកទី ៥ មូលនិធិបង្វិល ..................................................... ១៤

៣.៦ ផ្នែកទី ៦ ការវិភាគសន្តិសុខសង្គម ........................................ ១៥

**ជំពូកទី ៤** ភាគទាន និងតាវកាលិកសន្តិសុខសង្គម ............................ ១៥

៤.១ ផ្នែកទី ១ ភាគទាន ............................................................. ១៥

៤.២ ផ្នែកទី ២ តាវកាលិក ........................................................... ១៦

**ជំពូកទី ៥** អាណាព្យាបាល ................................................................ ១៦

៥.១ ផ្នែកទី ១ អាណាព្យាបាលបច្ចេកទេស ....................................... ១៦

៥.២ ផ្នែកទី ២ អាណាព្យាលបាលហិរញ្ញវត្ថុ ..................................... ១៩

**ជំពូកទី ៦** បទប្បញ្ញត្តិផ្សេងៗ ........................................................... ២១

**ជំពូកទី ៧** អន្តរប្បញ្ញត្តិ .................................................................... ២៣

**ជំពូកទី ៨** អវសានប្បញ្ញត្តិ ................................................................ ២៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០០៧

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

បង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានបេសកកម្មបម្រើសេវាផ្នែកសាធារណៈមានលក្ខណៈសង្គម មានឈ្មោះថា "បេឡាជាតិរបបសន្តិសុខសង្គម" សរសេរជាអក្សរកាត់ "**ប.ស.ស**"។ **ប.ស.ស** ត្រូវស្ថិតនៅក្រោមអាណាព្យាបាល បច្ចេកទេសនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្ថិតនៅក្រោមអាណាព្យាបាលហិរញ្ញវត្ថុនៃក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប.ស.ស** មានទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ។

**មាត្រា ២.-**

**ប.ស.ស** គឺជានីតិបុគ្គលសាធារណៈដែលមានស្វ័យភាពផ្នែកហិរញ្ញវត្ថុ។

**ប.ស.ស** ត្រូវស្ថិតនៅក្រោមអានុភាពនៃបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងត្រូវគោរពតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

**មាត្រា ៣.-**

**ប.ស.ស** មានភារកិច្ចដូចខាងក្រោម ÷

១- គ្រប់គ្រងរបបសន្តិសុខសង្គម ដោយអនុលោមតាមច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

២- ធានាផ្តល់ឱ្យបានសមស្របនូវតាវកាលិកទាំងឡាយសម្រាប់សមាជិកនៃ**ប.ស.ស** ក្នុងគោលដៅជួយសម្រាលការលំបាកនានានៅពេល ជរាភាព ទុព្វលភាព មរណភាព ហានិភ័យការងារ ឬពេលជួបប្រទះយថាភាពផ្សេងៗទៀតដូចជាជំងឺ មាតុភាព ជាដើម។

៣- ប្រមូលភាគទានពីសមាជិកនៃ**ប.ស.ស** និងនិយោជក ។

៤- សម្របសម្រួល និងរៀបចំឱ្យមានសេវាកម្មផ្នែកសុខាភិបាល និងសង្គមកិច្ចសម្រាប់ជាប្រយោជន៍ដល់សមាជិករបស់ខ្លួន។

៥- សហការជាមួយអង្គភាពពាក់ព័ន្ធដើម្បី ÷

-អប់រំផ្សព្វផ្សាយអំពីរបៀបបង្ការគ្រោះថ្នាក់ការងារ និងជំងឺវិជ្ជាជីវៈ

-ចាត់វិធានការផ្នែកបច្ចេកទេសសន្តិសុខ និង អនាម័យការងារ ។

៦- សហការជាមួយអង្គភាពពាក់ព័ន្ធដើម្បីសិក្សាស្រាវជ្រាវ និងអង្កេតបាតុភាពហានិភ័យការងារ ។

៧- ចាត់ចែង និងគ្រប់គ្រងការវិនិយោគមូលនិធិសន្តិសុខសង្គម ។

## ជំពូកទី ២

## រដ្ឋបាលបេឡាជាតិរបបសន្តិសុខសង្គម

### ផ្នែកទី ១

### ក្រុមប្រឹក្សាភិបាល

**មាត្រា ៤.-**

**ប.ស.ស** ត្រូវបានដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ ដែលមានអំណាចដើម្បីគ្រប់គ្រងគ្រឹះស្ថានក្នុងក្របខ័ណ្ឌនៃបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងក្នុងក្របខ័ណ្ឌនៃបទបញ្ជាផ្ទៃក្នុងរបស់ **ប.ស.ស** ។

ក្រុមប្រឹក្សាភិបាលនេះមានសមាសភាពដូចខាងក្រោម ÷

| | |
|---|---|
| - តំណាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១ (មួយ) រូប | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១ (មួយ) រូប | សមាជិក |
| - តំណាងក្រសួងសុខាភិបាល ១( មួយ) រូប | សមាជិក |
| - តំណាងនិយោជក ២(ពីរ) រូប | សមាជិក |
| - តំណាងកម្មករនិយោជិតសមាជិកនៃ **ប.ស.ស** ២(ពីរ) រូប | សមាជិក |
| - នាយកនៃ **ប.ស.ស** | សមាជិកស្ម័យប្រវត្តិ |

**មាត្រា ៥.-**

ក្រុមប្រឹក្សាភិបាលនៃ**ប.ស.ស** មានបេសកកម្មក្នុងការតម្រង់ទិស និងត្រួតពិនិត្យដំណើរប្រព្រឹត្តទៅនៃ **ប.ស.ស** ។ ក្នុងក្របខ័ណ្ឌនៃបេសកកម្មនេះ ក្រុមប្រឹក្សាភិបាលមានភារកិច្ចដូចតទៅ ÷

- អនុម័តថវិកាប្រចាំឆ្នាំរបស់ **ប.ស.ស** ជាពិសេសសម្រាប់តារាងកាលិកនៃផ្នែកសន្តិសុខសង្គមនីមួយៗ ផ្នែករដ្ឋបាល និងផ្នែកសកម្មភាពសុខាភិបាល និងសង្គមកិច្ច

- ពិនិត្យ និងសម្រេចលើរបាយការណ៍ប្រចាំឆ្នាំស្តីពីការងារគ្រប់គ្រង និងហិរញ្ញវត្ថុនៃ **ប.ស.ស**
- ពិនិត្យ និងសម្រេចលើបទបញ្ជាផ្ទៃក្នុង លក្ខន្តិកៈបុគ្គលិក និងរចនាសម្ព័ន្ធរដ្ឋបាលនៃ **ប.ស.ស**
- ពិនិត្យ និងសម្រេចរចនាសម្ព័ន្ធ និងភារកិច្ចរបស់អង្គភាពចំណុះនៃ **ប.ស.ស**
- កំណត់អំពីបែបបទនៃការជ្រើសរើស ការបញ្ឈប់ពីការងារ ការដំឡើងឋានៈ ឬមុខតំណែង ការដាក់វិន័យ ឬ ការផ្តល់លាភការនៃបុគ្គលិក តាមសំណើរបស់នាយកនៃ **ប.ស.ស**
- សម្រេចចំនួនក្របខ័ណ្ឌនៃបុគ្គលិកដែលអនុញ្ញាតសម្រាប់ **ប.ស.ស**
- ពិនិត្យ និងសម្រេចលើសំណើនៃអត្រាភាគទាននៃផ្នែកសន្តិសុខសង្គមនីមួយៗ
- ពិនិត្យ និងសម្រេចលើសំណើនៃការកំណត់ប្រភេទ និងអត្រាតាវកាលិក
- សម្រេចអំពីកិច្ចសន្យាស្តីពីលទ្ធកម្មនៃ **ប.ស.ស**
- កំណត់កម្មវិធី និងផែនការវិនិយោគនៃ **ប.ស.ស**
- វាយតម្លៃនូវលទ្ធផលការងារនៃ **ប.ស.ស** និងលើកវិធានការកែលម្អការអនុវត្ត
- សហការជាមួយក្រុមប្រឹក្សាបច្ចេកទេសនៃ **ប.ស.ស** សិក្សាស្រាវជ្រាវដើម្បីអភិវឌ្ឍន៍បច្ចេកទេសគ្រប់គ្រង និងរបបសន្តិសុខសង្គមឱ្យបានសមស្របតាមស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ច។

**មាត្រា ៦.-**

ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រី និងអ្នកដែលសកម្មធ្លាប់បម្រើការងារយ៉ាងតិច ៥ (ប្រាំ) ឆ្នាំ ក្នុងចំណោមឥស្សរជនខ្មែរដែលមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានសមត្ថភាព ក្នុងវិស័យសង្គមកិច្ច ឬ សេដ្ឋកិច្ច ឬនីតិសាស្ត្រ និងមិនដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬ ឧក្រិដ្ឋ។

តំណាងនិយោជក និងកម្មករនិយោជិត ត្រូវបានជ្រើសរើសដោយអង្គការវិជ្ជាជីវៈរៀងៗខ្លួន។ តំណាងទាំងនេះត្រូវមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានសមត្ថភាព ក្នុងវិស័យសង្គមកិច្ច ឬ សេដ្ឋកិច្ច ឬ នីតិសាស្ត្រ និង មិនដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬ ឧក្រិដ្ឋ។

ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ដែលមិនមែនជាសមាជិកស្វ័យប្រវត្តិ ត្រូវតែងតាំងដោយអនុក្រឹត្យសម្រាប់អាណត្តិ ៣(បី)ឆ្នាំ រៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រសួង ស្ថាប័ន ឬ អង្គការវិជ្ជាជីវៈ ដែលសមាជិកនោះតំណាងឱ្យ។ អាណត្តិនេះអាចបញ្ចប់ ឬ អាចបន្តទៀតបានតាមសំណើរបស់ ក្រសួង ស្ថាប័ន ឬ អង្គការវិជ្ជាជីវៈ ដែលសមាជិកនោះ តំណាងឱ្យ។

**មាត្រា ៧.-**

ក្រុមប្រឹក្សាភិបាលត្រូវប្រជុំយ៉ាងតិចមួយដងក្នុងរយៈពេល ៣(បី)ខែ។ ទោះជាមានកំណត់ដូច្នេះក្តី ក្រុមប្រឹក្សាភិបាលអាចប្រជុំបានគ្រប់ពេល អាស្រ័យដោយការចាំបាច់របស់ **ប.ស.ស** តាមការអញ្ជើញរបស់ប្រធាន ឬ តាមសំណើរបស់នាយកនៃ**ប.ស.ស** ឬ សមាជិកដែលមានចំនួន ៥ (ប្រាំ) នាក់ យ៉ាងតិចក្នុងចំណោមសមាជិកទាំងអស់។

ក្រុមប្រឹក្សាភិបាលត្រូវពិភាក្សាចំពោះតែបញ្ហាទាំងឡាយដែលមានចុះក្នុងរបៀបវារៈ។ របៀបវារៈនៃអង្គប្រជុំនីមួយៗ ព្រមទាំងឯកសារពាក់ព័ន្ធទាំងអស់ ត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុឱ្យបានយ៉ាងតិចដប់ថ្ងៃប្រតិទិនមុនពេលបើកសម័យប្រជុំ។ នាយកនៃ **ប.ស.ស** ត្រូវចាត់លេខាធិការកត់ត្រានៃអង្គប្រជុំក្រុមប្រឹក្សាភិបាល។

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវចូលរួមក្នុង សម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាល តែមិនមានសិទ្ធិបោះឆ្នោត។

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលនៃ**ប.ស.ស** អាចប្រព្រឹត្តទៅបានលុះត្រាតែមានវត្តមានសមាជិកលើសពី ៥០ (ហាសិប) ភាគរយ នៃចំនួនសមាជិកសរុប។ សមាជិក ក្រុមប្រឹក្សាភិបាល ដែលអវត្តមានពុំអាចត្រូវជំនួសបានទេ។ ប្រសិន បើខ្វះកូរ៉ុមការប្រជុំត្រូវលើកទៅ ១៥(ដប់ប្រាំ) ថ្ងៃប្រតិទិនក្រោយ ហើយត្រូវពិភាក្សាឡើងវិញលើរបៀបវារៈដដែល ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលអាចយកជា ការបាន លុះណាតែមានការអនុម័តដោយសំឡេងភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសំឡេងស្មើគ្នាសំឡេងរបស់ប្រធានក្រុមប្រឹក្សាភិបាលមានឧត្តមានុភាព។

**មាត្រា ៨.-**

សេចក្តីសម្រេចនៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាលត្រូវកត់ត្រាទុកក្នុងកំណត់ហេតុ ដែលត្រូវបញ្ជូនទៅក្រសួងអាណាព្យាបាលនៃ **ប.ស.ស** សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុក្នុងរវាង ១០(ដប់) ថ្ងៃយ៉ាងយូររាប់គិតពីថ្ងៃចុងក្រោយនៃកិច្ចប្រជុំ។

កំណត់ហេតុនៃកិច្ចប្រជុំត្រូវឆ្លុះបញ្ចាំងភាពពិតនៃការពិភាក្សារបស់អង្គប្រជុំ ហើយត្រូវចម្លងចូលបញ្ជី ដែលមានលេខរៀងទំព័រតាមលំដាប់លំដោយ និងមានលេខកូដសំគាល់ត្រឹមត្រូវ។ កំណត់ហេតុនេះត្រូវមានចុះហត្ថលេខាប្រធាន និងលេខាធិការអង្គប្រជុំ។ ក្នុងករណីមានការជំទាស់លើកឡើងដោយសមាជិកណាម្នាក់សម្រាប់ការប្រជុំលើកក្រោយរបស់ក្រុមប្រឹក្សាភិបាល ត្រូវមានកត់ត្រាការជំទាស់ទាំងអស់នោះ ក្នុងកំណត់ហេតុនៃកាប្រជុំចុងក្រោយនេះផង។

**មាត្រា ៩.-**

លាភការនៃមុខងាររបស់សមាជិកក្រុមប្រឹក្សាភិបាលត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស**។

**មាត្រា ១០.-**

សមាជិកក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួន ក្នុងករណីដូចខាងក្រោម ÷

- សមាជិករូបនោះទទួលមរណភាព ឬសុំលាលែង
- សមាជិករូបនោះវិកលចរិត ឬ មានស្មារតីមិនប្រក្រតីដោយមានការបញ្ជាក់ពីក្រសួងសុខាភិបាល
- សមាជិករូបនោះក្ស័យធន
- សមាជិករូបនោះបានទទួលអត្ថប្រយោជន៍ពីកិច្ចសន្យាណាមួយជាមួយ**ប.ស.ស** ឬ បម្រើសេវាកម្មណាមួយឱ្យ **ប.ស.ស** ទោះដោយចំពោះ ឬមិនចំពោះក្តី
- សមាជិករូបនោះត្រូវបានតុលាការផ្តន្ទាទោសពីបទមជ្ឈិម ឬ ឧក្រិដ្ឋ
- សមាជិករូបនោះខកខានមិនបានបង់ភាគទានដែលខ្លួនទទួលបន្ទុក
- សមាជិករូបនោះ ដែលបានជាប់ ជាសមាជិកសភា ឬសមាជិករាជរដ្ឋាភិបាល។

សមាជិកក្រុមប្រឹក្សាភិបាលរូបណាដែលត្រូវបានតុលាការចោទប្រកាន់ ត្រូវព្យួរការងារជាបណ្តោះអាសន្ន។

ការជំនួសសមាជិកក្រុមប្រឹក្សាភិបាលដែលបាត់បង់សមាជិកភាពរបស់ខ្លួនត្រូវអនុវត្តដូចគ្នាតាមនីតិវិធីនៃការតែងតាំងដែរ។

## ផ្នែកទី ២
## អង្គភាពប្រតិបត្តិនៃ ប.ស.ស

**មាត្រា ១១.-**

នាយកនៃ **ប.ស.ស** ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

នាយកនៃ**ប.ស.ស** មានភារកិច្ចចាត់ចែង គ្រប់គ្រងការងារប្រចាំថ្ងៃរបស់**ប.ស.ស** ។

**មាត្រា ១២.-**

នាយកនៃ**ប.ស.ស**ត្រូវបានទទួលអំណាចចាំបាច់សម្រាប់ដំណើរការប្រចាំថ្ងៃដើម្បីមានលទ្ធភាពពេញលេញក្នុងការដឹកនាំគ្រឹះស្ថានស្របតាមច្បាប់ និងជាតំណាងនៃ**ប.ស.ស**ក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់។ អំណាចនេះត្រូវបានប្រគល់ឱ្យតាមរយៈបទបញ្ជាផ្ទៃក្នុងរបស់**ប.ស.ស** និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃ**ប.ស.ស**។

ក្នុងក្របខ័ណ្ឌនៃអំណាចនេះ នាយកនៃ**ប.ស.ស** មានភារកិច្ចសំខាន់ៗដូចតទៅ ÷

- រៀបចំការប្រជុំរបស់ក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស**
- រៀបចំឯកសារដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលសម្រេច
- ចាត់ចែងអនុវត្តគ្រប់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងរាយការណ៍តាមដំណាក់កាលនីមួយៗជូនក្រុមប្រឹក្សាភិបាល អំពីសកម្មភាព និងលទ្ធផលការងាររបស់ **ប.ស.ស**
- ទទួលបន្ទុកដឹកនាំ **ប.ស.ស** ផ្នែករដ្ឋបាល បច្ចេកទេស និងហិរញ្ញវត្ថុ
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ **ប.ស.ស** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និង សម្រេច
- គ្រប់គ្រងបណ្តាភ្នាក់ងារ ឬ មន្ត្រីគ្រប់រូបរបស់ **ប.ស.ស** ដោយគោរពតាម លក្ខន្តិកៈ ឬ ច្បាប់ជាធរមាន និង តាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- លើកសំណើជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេចចំពោះការជ្រើសរើស តែងតាំង ដំឡើងឋានៈ ដាក់វិន័យ ឬ ផ្តល់លាភការដល់បុគ្គលិករបស់ **ប.ស.ស** ដែលនៅក្រៅក្របខ័ណ្ឌនៃមន្ត្រីរាជការ ស៊ីវិល
- លើកសំណើជូនរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈពិនិត្យ និងសម្រេច ចំពោះការជ្រើសរើស តែងតាំង ដំឡើងឋានៈ ដាក់វិន័យ ឬផ្តល់លាភការដល់មន្ត្រីរាជការ នៃ **ប.ស.ស** ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃ មន្ត្រីរាជការស៊ីវិល
- ធ្វើជាតំណាងនៃ **ប.ស.ស**ចំពោះការតវ៉ា ឬការប្តឹងជំទាស់នានាទាក់ទងដល់ប្រតិបត្តិការរបស់ **ប.ស.ស** និង ទទួលខុសត្រូវចំពោះមុខច្បាប់លើគ្រប់កិច្ចការពារផលប្រយោជន៍របស់ **ប.ស.ស**។

នាយកនៃ **ប.ស.ស** មានសិទ្ធិផ្ទេរអំណាចខ្លះ ឬ ទាំងអស់រួមទាំងផ្ទេរសិទ្ធិចុះហត្ថលេខាស្របតាមលក្ខខណ្ឌដែលកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង ឬ កំណត់ដោយក្រុមប្រឹក្សាភិបាល។

**មាត្រា ១៣.-**

គណនេយ្យករនៃ **ប.ស.ស** ត្រូវតែងតាំងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការឯកភាពគ្នាជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ គណនេយ្យករនេះ ត្រូវស្ថិតនៅក្រោមឱវាទផ្ទាល់របស់នាយកនៃ **ប.ស.ស**។

**មាត្រា ១៤.-**

ការត្រួតពិនិត្យនូវការអនុវត្តបទប្បញ្ញត្តិនៃ "ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ" នៅតាមសហគ្រាស គ្រឹះស្ថាន ត្រូវធ្វើដោយអធិការឬអភិបាលរបបសន្តិសុខសង្គម និងក្នុងករណីចាំបាច់ត្រូវសហការជាមួយអធិការការងារ ឬអភិបាលការងារ និងអង្គភាពពាក់ព័ន្ធដទៃទៀត។

ការតែងតាំង ការកំណត់តួនាទីភារកិច្ចរបស់អធិការ ឬអភិបាលរបបសន្តិសុខសង្គម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ**ប.ស.ស**។

**មាត្រា ១៥.-**

បុគ្គលិកអចិន្ត្រៃយ៍របស់**ប.ស.ស**រួមមានមន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬក្រសួងនានា ឬ មន្ត្រីដែលជ្រើសរើសតាមសំណើរបស់នាយកនៃ **ប.ស.ស**។ មន្ត្រីទាំងនេះ ត្រូវបានទទួលបន្តនូវប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗដែលបានកំណត់ដោយមុខងារសាធារណៈពីអង្គភាពដើមរបស់ខ្លួន។

បេឡាជាតិរបបសន្តិសុខសង្គមអាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា និងកម្មករ។ បុគ្គលិកទាំងនេះ ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃបទបញ្ជាផ្ទៃក្នុងរបស់ **ប.ស.ស** និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលស្របតាមច្បាប់ស្តីពីការងារ។

បុគ្គលិកនៃ **ប.ស.ស**ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃបទបញ្ជាស្តីពីបុគ្គលិក ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល។ ក្រុមប្រឹក្សាភិបាលកំណត់ប្រាក់កម្រៃលើកទឹកចិត្តចំពោះបុគ្គលិក ព្រមទាំងបែបបទនៃការទូទាត់ដូចមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុង។

**មាត្រា ១៦.-**

រចនាសម្ព័ន្ធគ្រប់គ្រងនៃ**ប.ស.ស**ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ**ប.ស.ស**។

# ជំពូកទី ៣
# ការគ្រប់គ្រងហិរញ្ញវត្ថុ

## ផ្នែកទី ១
## កិច្ចការគណនេយ្យ

**មាត្រា ១៧.-**

**ម.ស.ស** កាន់កាប់គណនេយ្យស្របតាមគោលការណ៍គណនេយ្យសាធារណៈ និងតាមវិធានគណនេយ្យដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ការិយបរិច្ឆេទគណនេយ្យចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំដដែល ។

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវសម្រេចដោយក្រុមប្រឹក្សាភិបាលមុនថ្ងៃទី៣១ ខែមីនា នៃការិយបរិច្ឆេទបន្ទាប់ ។

របាយការណ៍ហិរញ្ញវត្ថុត្រូវសុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃបន្ទាប់ពីការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា ១៨.-**

**១៨.១-** នាយកនៃ **ម.ស.ស** ជាអាណាប័កដើមខ្សែរបស់គ្រឹះស្ថាន ដែលត្រូវមានភារកិច្ច ÷

- ពិនិត្យប្រាក់ និងទូទាត់ចំណូល
- ចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយ ។

អាណាប័កដើមខ្សែអាចផ្ទេរសិទ្ធិឱ្យអាណាប័កផ្ទេរសិទ្ធិ ឬអាចបង្កើតនូវរជ្ជទេយ្យចំណូល ឬបុរេប្រទានបានដោយមានការយល់ព្រមពីគណនេយ្យករ ។

**១៨.២-** ការគ្រប់គ្រងហិរញ្ញវត្ថុ និងការកាន់កាប់គណនេយ្យ ត្រូវអនុវត្តដោយអនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់**ម.ស.ស** ក្រោមការទទួលខុសត្រូវផ្ទាល់របស់គណនេយ្យករ។ គណនេយ្យករនេះ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់ការងារ ។ គណនេយ្យករនេះ ត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ក្នុងឋានៈជាអ្នក ពិគ្រោះយោបល់ តែឥតមានសំឡេងឆ្នោតឡើយ ។

**១៨.៣-** គណនេយ្យករមានភារកិច្ច ÷

- ប្រមូលចំណូល
- បើកប្រាក់ចំណាយ

- រក្សាទុក និងចាត់ចែងប្រើប្រាស់នូវមូលនិធិ និងធនធានរបស់ **ប.ស.ស**
- រក្សាទុកនូវលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យ ។

**១៨.៤-** គណនេយ្យករអាចផ្ទេរសិទ្ធិខ្លះទៅឱ្យអាជ្ញានុការីរបស់ខ្លួន ។

**មាត្រា ១៩.-**

នៅរៀងរាល់ឆ្នាំយ៉ាងយូរត្រឹមថ្ងៃទី៣០ ខែកញ្ញា ក្រុមប្រឹក្សាភិបាលត្រូវផ្តល់ការយល់ព្រមលើកម្មវិធីអភិវឌ្ឍ និងគម្រោងថវិកាប្រចាំឆ្នាំរបស់**ប.ស.ស**តាមសំណើរបស់នាយកនៃគ្រឹះស្ថាននេះ ។ កម្មវិធី និងគម្រោងទាំងនេះត្រូវបញ្ជូនទៅសុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ផ្នែកទី ២

## ប្រភពធនធាន

**មាត្រា ២០.-**

ប្រភពធនធាននៃ **ប.ស.ស** មានដូចខាងក្រោម ÷

១- ធនធានដំបូងដែលរដ្ឋផ្តល់សម្រាប់ការបង្កើត **ប.ស.ស** ។

២- ការផ្ទេរក្នុងលក្ខណៈជាអន្តរាគមន៍សាធារណៈដែលមានចែងក្នុងថវិការដ្ឋដូចជាឧបត្ថម្ភធនសម្រាប់ដំណើរការ និងឧបត្ថម្ភធនជាមូលធន ។

៣- ភាគទានរបស់សមាជិកនៃ **ប.ស.ស** និង និយោជក ដែលទុកសម្រាប់ហិរញ្ញប្បទានលើផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម ។

៤- ប្រាក់ពិន័យពីការយឺតយូរក្នុងការបង់ភាគទាន ឬការផ្តល់តារាងបៀវត្ស ព្រមទាំងការប្រាក់ពីការយឺតយូរនេះ ។

៥- ផលចំណេញដែលបានមកពីការវិនិយោគ ។

៦- អំណោយ និងអច្ច័យទានផ្សេងៗ ។

៧- ប្រភពធនធានដទៃទៀតដែល **ប.ស.ស** អាចទទួលបានស្របតាមច្បាប់ ។

## ផ្នែកទី ៣
## ការចំណាយ

**មាត្រា ២១.-**

ការចំណាយរបស់**ប.ស.ស** រួមមាន ÷

១- ការចំណាយសម្រាប់តាវកាលិកនៃផ្នែកនីមួយៗ ។

២- ការចំណាយសម្រាប់ការងាររដ្ឋបាលនៃ **ប.ស.ស** ។

៣- ការចំណាយសម្រាប់សកម្មភាពខាងសុខាភិបាល និងសង្គមកិច្ច ។

៤- ការចំណាយលើការវិនិយោគដើម្បីជាប្រយោជន៍របស់ **ប.ស.ស** ។

ទម្រង់ និងបែបបទនៃការចំណាយខាងលើ ត្រូវចែងលំអិតក្នុងប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើពីក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ។

## ផ្នែកទី ៤
## ប្រាក់ត្រៀមបម្រុង

**មាត្រា ២២.-**

ប្រាក់ត្រៀមបម្រុងអប្បបរមាសម្រាប់ផ្នែកហានិភ័យការងារត្រូវស្មើនឹងចំនួនទឹកប្រាក់ចំណាយសម្រាប់ធនលាភដែលបានឧបត្ថម្ភកន្លងទៅ និង ១/២( មួយភាគពីរ) នៃប្រាក់ចំណាយសម្រាប់តាវកាលិកដទៃក្រៅពីធនលាភក្នុងអំឡុងពេល ២( ពីរ) ឆ្នាំចុងក្រោយ ។

ប្រាក់ត្រៀមបម្រុងសម្រាប់ផ្នែកប្រាក់សោធន និងផ្នែកសន្តិសុខសង្គមផ្សេងៗទៀត ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបន្ទាប់ពីបានទទួលសំណើ ពីក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ។

អត្រាភាគទានដែលមានចែងក្នុងមាត្រា ២៥ នៃអនុក្រឹត្យនេះ ត្រូវពិនិត្យឡើងវិញក្នុងករណីដែលប្រាក់ត្រៀមបម្រុងសម្រាប់ផ្នែកនីមួយៗធ្លាក់ចុះទាបជាងកម្រិតអប្បបរមា បន្ទាប់ពីបានទទួលយោបល់ពីក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ។

ប្រាក់ត្រៀមបម្រុងសម្រាប់ផ្នែកនីមួយៗ ការវិនិយោគប្រាក់នេះ និងផលចំណេញដែលបានមកពីការវិនិយោគ ត្រូវចុះបញ្ជីគណនេយ្យដាច់ដោយឡែកពីគ្នា ។

## ផ្នែកទី ៥

## មូលនិធិបង្ខិល

**មាត្រា ២៣.-**

ត្រូវបង្កើតឱ្យមានមូលនិធិបង្ខិលរួមមួយសម្រាប់ការចំណាយនៃផ្នែកទាំងឡាយរបស់របបសន្តិសុខសង្គម ។ មូលនិធិនេះមិនត្រូវតិចជាង២(ពីរ)ដងនៃប្រាក់ចំណាយជាមធ្យមប្រចាំខែរបស់ **ប.ស.ស** នៅក្នុងអំឡុងឆ្នាំចុងក្រោយឡើយ ។

## ផ្នែកទី ៦

## ការវិភាគសន្តិសុខសង្គម

**មាត្រា ២៤.-**

**ប.ស.ស** ត្រូវធ្វើវិភាគហិរញ្ញវត្ថុសម្រាប់របបសន្តិសុខសង្គមយ៉ាងយូរបីឆ្នាំម្តង ។ ក្នុងករណីដែលការវិភាគនេះបង្ហាញថាអាចមានគ្រោះថ្នាក់ដោយសារមានអតុល្យភាពហិរញ្ញវត្ថុនៅក្នុងផ្នែកណាមួយ **ប.ស.ស**ត្រូវស្នើសុំធ្វើការកែតម្រូវអត្រាភាគទាន ឬអាយុចូលនិវត្តន៍ ដើម្បីអាចធានាបាននូវនិរន្តរភាពក្នុងកិច្ចដំណើការរបស់ **ប.ស.ស** ។

រដ្ឋត្រូវផ្តល់ការឧបត្ថម្ភទ្រទ្រង់ឱ្យ **ប.ស.ស** បន្តនិរន្តរភាពនៅពេលជួបប្រទះឱនភាពថវិកា ។

# ជំពូកទី ៤

# ភាគទាន និងតារាងលីកសន្តិសុខសង្គម

## ផ្នែកទី ១

## ភាគទាន

**មាត្រា ២៥.-**

អត្រានៃភាគទានសម្រាប់ផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម ដូចមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់ ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើពីក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស** ។

## ផ្នែកទី ២

## តាវកាលិក

**មាត្រា ២៦.-**

អត្រានៃតាវកាលិកសម្រាប់ផ្នែកនីមួយៗនៃរបបសន្តិសុខសង្គមដូចមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើពីក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស**។

ទម្រង់នៃការស្នើសុំតាវកាលិកទាំងអស់ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើពីក្រុមប្រឹក្សាភិបាលនៃ **ប.ស.ស**។

## ជំពូកទី ៥

## អាណាព្យាបាល

## ផ្នែកទី ១

## អាណាព្យាបាលបច្ចេកទេស

**មាត្រា ២៧.-**

**២៧.១**- ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយពីការប្រជុំក្រុមប្រឹក្សាភិបាលប្រចាំឆ្នាំ នាយកនៃ**ប.ស.ស**ត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវកម្មវិធីអភិវឌ្ឍ និងគម្រោងថវិកាប្រចាំឆ្នាំដើម្បីសុំការយល់ព្រម។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរយៈពេល ១ (មួយ) ខែ ចាប់ពីថ្ងៃដែលបានទទួលឯកសារ ត្រូវរៀបចំយោបល់របស់ខ្លួនជូនរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ រដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេសមានរយៈពេល ២(ពីរ) ខែ គិតចាប់ពីថ្ងៃដែលបានទទួលឯកសារដែលបញ្ជូនដោយនាយកនៃ **ប.ស.ស** ដើម្បីសម្រេចផ្តល់ការយល់ព្រមលើឯកសារទាំងនេះ។

**២៧.២** -លិខិតយល់ព្រមរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវផ្ញើជូនទៅនាយកនៃ **ប.ស.ស** ដោយមានចម្លងជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។នាយកនៃ**ប.ស.ស** ត្រូវបញ្ជូនព័ត៌មាននេះទៅឱ្យក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមិនបានឆ្លើយតបក្នុងរយៈពេលកំណត់ទេនោះ កម្មវិធីអភិវឌ្ឍ និងគម្រោងថវិកាប្រចាំឆ្នាំ ត្រូវចាត់ទុកថាបានទទួលការឯកភាព។

ប្រសិនបើរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជំទាស់លើកម្មវិធីអភិវឌ្ឍ ឬគម្រោងថវិកានេះ ប្រធានក្រុមប្រឹក្សាភិបាលត្រូវរៀបចំការប្រជុំក្រុមប្រឹក្សាភិបាលជាបន្ទាន់ ដើម្បីពិភាក្សា និងរិះរកមធ្យោបាយដោះស្រាយការជំទាស់នេះ ។

កម្មវិធីអភិវឌ្ឍនៃ**ប.ស.ស** និងថវិកាចំណាយជាមូលធនមិនអាចឱ្យអនុវត្តបានឡើយ ក្នុងករណីដែលមានការជំទាស់លើកឡើងដោយប្រធានស្ថាប័នអាណាព្យាបាលបច្ចេកទេស ។

ថវិកាចំណាយជាប្រចាំអាចដាក់ឱ្យអនុវត្តត្រឹមលំនាំបំបែកជា១២(ដប់ពីរ) ប៉ុណ្ណោះនៅពេលដែលមានការជំទាស់ពីប្រធានស្ថាប័នអាណាព្យាបាលបច្ចេកទេស ។ ទោះជាយ៉ាងនេះក្តី ថវិកាចំណាយសម្រាប់តាវកាលិកដែលត្រូវផ្តល់ឱ្យកម្មករនិយោជិតត្រូវដាក់ឱ្យអនុវត្តបាន ។

**មាត្រា ២៨.-**

រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អាចមានយោបល់ជំទាស់លើឯកសារ ដែលត្រូវបានបញ្ជូនមកខ្លួនរួមមាន កម្មវិធីអភិវឌ្ឍ គម្រោងថវិកាប្រចាំឆ្នាំ និងកំណត់ហេតុនៃការប្រជុំក្រុមប្រឹក្សាភិបាល ។ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានរយៈពេល១(មួយ) ខែ សម្រាប់លើកឡើងនូវការជំទាស់ទាំងនោះ ។

នាយកនៃ**ប.ស.ស**ត្រូវជូនព័ត៌មានទៅដល់ក្រុមប្រឹក្សាភិបាលនូវខ្លឹមសារនៃការជំទាស់របស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ ក្រុមប្រឹក្សាភិបាល ត្រូវធ្វើការពិភាក្សាឱ្យបានឆាប់បំផុតលើការជំទាស់របស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរិះរកមធ្យោបាយដោះស្រាយការជំទាស់ទាំងនោះ ។ ប្រសិនបើក្រុមប្រឹក្សាភិបាលសម្រេចពុំយកជាបានការនូវការជំទាស់ទាំងនោះ សេចក្តីសម្រេចនេះត្រូវបញ្ជាក់ពីមូលហេតុ ហើយត្រូវជម្រាបជូនដំណឹងជាបន្ទាន់ភ្លាម ស្តីពីបញ្ហានេះជាលាយលក្ខណ៍អក្សរដល់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**មាត្រា ២៩.-**

**២៩.១-** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈអាចលុប ឬផ្អាកទុកសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬនាយកនៃ **ប.ស.ស** ក្នុងករណីដែលសេចក្តីសម្រេចនោះ ÷

- ផ្ទុយនឹងគោលដៅរបស់ **ប.ស.ស**
- ផ្ទុយនឹងច្បាប់ និងបទបញ្ញា
- ផ្ទុយនឹងបែបបទនៃការប្រជុំដែលមានចែងក្នុងមាត្រា ៧ ។

**២៩.២-** ការលុបចោល ឬការផ្អាកនេះ ត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដោយមានបញ្ជាក់ពីមូលហេតុតាមគំនិតផ្ទាល់ខ្លួន ឬតាមបណ្តឹងពីភាគីនានាដែលពាក់ព័ន្ធ ។ ការលុប

ចោល ឬការផ្អាកសេចក្តីសម្រេចនេះត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់នាយក **ប.ស.ស** ។ នាយកនៃ **ប.ស.ស** ត្រូវជូនព័ត៌មាននេះបន្តទៅក្រុមប្រឹក្សាភិបាល **ប.ស.ស** ក្នុងរយៈពេលដ៏ឆាប់បំផុត ។

**មាត្រា ៣០.-**

រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អាចចាត់ឱ្យធ្វើអធិការកិច្ច ឬការត្រួតពិនិត្យការងារក្នុង **ប.ស.ស** ក្នុងករណីដែលយល់ថាជាការចាំបាច់ស្របតាមលក្ខខណ្ឌ និងបែបបទដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ផ្នែកទី ២

## អាណាព្យាបាលហិរញ្ញវត្ថុ

**មាត្រា ៣១.-**

**៣១.១-** ក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាល នាយកនៃ **ប.ស.ស** ត្រូវធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានរយៈពេល១(មួយ)ខែ គិតចាប់ពីថ្ងៃដែលទទួលឯកសារដើម្បីផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានរយៈពេល ២ (ពីរ)ខែ គិតចាប់ពីថ្ងៃដែលទទួលបានឯកសារដែលបញ្ជូនមកដោយនាយកនៃ**ប.ស.ស**ដើម្បីសម្រេចផ្តល់ ការយល់ព្រមលើឯកសារនេះ ។

**៣១.២-** លិខិតយល់ព្រមដែលចុះហត្ថលេខាត្រឹមត្រូវដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឬអ្នកតំណាងត្រូវផ្ញើទៅនាយកនៃ **ប.ស.ស** ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ នាយកនៃ **ប.ស.ស** ត្រូវជូនព័ត៌មាននេះទៅក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមិនបានឆ្លើយតបក្នុងរយៈពេលកំណត់ខាងលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវចាត់ទុកថាបានទទួលការឯកភាព ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានយោបល់ជំទាស់លើរបាយការណ៍ ប្រធានក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាលឱ្យបានឆាប់រហ័សបំផុតដើម្បីរិះរកមធ្យោបាយដោះស្រាយការជំទាស់ទាំងនោះ ។

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមិនអាចត្រូវបានសម្រេចយល់ព្រមបានឡើយ ក្នុងករណីដែលការជំទាស់លើកឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពុំទាន់ត្រូវបានដោះស្រាយនៅឡើយនោះ ។

មាត្រា ៣២.-

សេចក្តីសម្រេចដូចរៀបរាប់ខាងក្រោមនេះរបស់ក្រុមប្រឹក្សាភិបាល ឬនាយកនៃ**ប.ស.ស**ត្រូវដាក់សុំការអនុញ្ញាតជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមការផ្តល់យោបល់ពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុរួមមាន ÷

- សេចក្តីសម្រេចស្តីពីការលក់ ឬផ្ទេរសិទ្ធិអចលទ្រព្យ
- សេចក្តីសម្រេចស្តីពីការលើកលែងឥណទេយ្យដែលមានទឹកប្រាក់លើសពីការកំណត់ របស់ប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សេចក្តីសម្រេចស្តីពីកិច្ចព្រមព្រៀងខ្ចីប្រាក់ និងកិច្ចព្រមព្រៀងសម្រាប់ការធានា ឬ លិខិតស្រដៀងគ្នានេះ ។

មាត្រា ៣៣.-

ត្រូវដាក់ឱ្យនៅអម**ប.ស.ស**នូវមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុមួយរូប ដែលត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុនេះ មានភារកិច្ចដូចមានចែងនៅក្នុងអនុក្រឹត្យលេខ ៨១អនក្រ-បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតឡើងនូវការត្រួតពិនិត្យហិរញ្ញវត្ថុ លើចំណាយថវិកាតាមក្រសួងអង្គភាពមូលដ្ឋាន តាមបណ្តាខេត្ត ក្រុង និងតាមអង្គភាពសាធារណៈដែលមានលក្ខណៈរដ្ឋបាល ។

ការគ្រប់គ្រងរបស់អាណាប័កដើមខ្សែលើ **ប.ស.ស** ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់អធិការដ្ឋានហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការគ្រប់គ្រងរបស់គណនេយ្យករ ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់គណនេយ្យករកណ្តាលនៃរតនាគារជាតិ និងក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចាត់ចែងធ្វើការផ្ទៀងផ្ទាត់ អធិការកិច្ច ឬការត្រួតពិនិត្យលើ **ប.ស.ស** នៅពេលដែលយល់ថាចាំបាច់ស្របតាមលក្ខខណ្ឌ និងបែបបទដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

## ជំពូកទី ៦
## បទប្បញ្ញត្តិផ្សេងៗ

មាត្រា ៣៤.-

**៣៤.១**- សិទ្ធិវន្តរបស់សមាជិកនៃ **ប.ស.ស** ដែលត្រូវទទួលបាន"តាវកាលិកឧត្តរជីវី" ត្រូវកំណត់ដូចខាងក្រោម ÷

ក-ប្ដី ឬ ប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍ដោយមានចុះបញ្ជីអត្រានុកូលដ្ឋានមុនពេលមានគ្រោះថ្នាក់ការងារ ឬមុនពេលទទួលមរណភាពដោយគ្រោះថ្នាក់ការងារនៃប្ដីឬប្រពន្ធ ដែលជាសមាជិកនៃ **ប.ស.ស**។

ខ-កូនដែលមានអាយុត្រឹម ១៨ (ដប់ប្រាំបី ) ឆ្នាំចុះ ដែលមិនទាន់រៀបអាពាហ៍ពិពាហ៍ និងមានស្ថានភាព ដូចខាងក្រោម ÷

- កូននៃសហព័ទ្ធដែលបានរៀបអាពាហ៍ពិពាហ៍ដោយមានចុះបញ្ជីអត្រានុកូលដ្ឋានត្រឹមត្រូវ។ ក្នុងករណីមានការលែងលះ ឬ ករណីមរណភាពនៃប្ដីឬប្រពន្ធ កូននៃអាពាហ៍ពិពាហ៍ក្រោយក៏មានសិទ្ធិ ដូចកូននៃអាពាហ៍ពិពាហ៍ទី១ដែរ
- កូនចិញ្ចឹមរបស់សមាជិកនៃ **ប.ស.ស**។ ស្ថានភាពរបស់កូនចិញ្ចឹមត្រូវកំណត់ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អាយុកូននៅក្នុងបន្ទុកអាចកំណត់ដល់ ២១(ម្ភៃមួយ) ឆ្នាំ ចំពោះកូនដែលកំពុងទទួលការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ឬ កូនកំពុងរៀននៅក្នុងគ្រឹះស្ថានសិក្សាសាធារណៈ ឬ ឯកជនដែលមានការទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច និង មានលិខិតបញ្ជាក់ការសិក្សាត្រឹមត្រូវ និងកូនពិការ ឬ មានជំងឺរ៉ាំរ៉ៃមិនមានលទ្ធភាពធ្វើការងារដែលមានប្រាក់ឈ្នួល។

គ- ឪពុកម្ដាយ ឬ មនុស្សចាស់ជរាដែលស្ថិតនៅក្នុងបន្ទុកផ្ទាល់របស់សមាជិកនៃ**ប.ស.ស**។

**៣៤.២-** សិទ្ធិវត្តរបស់សមាជិកនៃ**ប.ស.ស**ដែលត្រូវទទួលបាន "តាវកាលិកចំពោះអ្នកនៅក្នុងបន្ទុក" ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈស្ដីពីការរៀបចំតាវកាលិកផ្នែកប្រាក់សោធន។

**៣៤.៣-** សិទ្ធិធនលាភចំពោះឧត្តរជីវី និងសោធនចំពោះអ្នកនៅក្នុងបន្ទុករបស់សហព័ទ្ធត្រូវផុតរលត់ ក្នុងករណីដែលសហព័ទ្ធនោះរៀបអាពាហ៍ពិពាហ៍ជាថ្មី។

**មាត្រា ៣៥.-**

**ប.ស.ស** មានបុព្វសិទ្ធិនៃអំណាចសាធារណៈក្នុងការប្រមូលចំណូល ការឱ្យសងបំណុល និងការការពារទ្រព្យសម្បត្តិ ។ បុព្វសិទ្ធិនេះអាចអនុវត្តនៅពេល ដែលសហគ្រាស គ្រឹះស្ថានក្ស័យធន ឬ ត្រូវបានជម្រះបញ្ជីដោយតុលាការ បន្ទាប់ពីកាលបរិច្ឆេទនៃការចេញសាលក្រមរបស់តុលាការ។ នីតិវិធីនៃការទារបំណុលរបស់**ប.ស.ស** ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។

ភ្នាក់ងារមានសមត្ថកិច្ចតាមច្រក ត្រូវហាមឃាត់មិនឱ្យចាកចេញពីទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះជន ណា ដែលមិនទាន់បានសងបំណុលប.ស.សតាមដីការបស់តុលាការ ។

**មាត្រា ៣៦.-**

មូលនិធិរបស់ប.ស.ស ត្រូវដាក់ចូលក្នុងគណនី នៅរតនាគារជាតិ ឬនៅធនាគារជាតិនៃកម្ពុជា ឬ នៅធនាគារពាណិជ្ជកម្មផ្សេងៗ ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ក្រុមប្រឹក្សាភិបាលនៃប.ស.ស អាចសម្រេចឱ្យប្រើប្រាស់នូវប្រាក់ដែលលើស( ប្រាក់ដែលសល់ពីប្រាក់ត្រៀមបម្រុង)សម្រាប់ការវិនិយោគ បន្ទាប់ពីមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៣៧.-**

រដ្ឋធានាចំពោះតែបំណុលរបស់ប.ស.ស ណា ដែលមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ៣៨.-**

ដំណាក់កាល វិសាលភាព នីតិវិធី និងកាលបរិច្ឆេទដាក់លាក់សម្រាប់ការអនុវត្តផ្នែកនីមួយៗនៃរបបសន្តិសុខសង្គម ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

## ជំពូកទី ៧

## អន្តរប្បញ្ញត្តិ

**មាត្រា ៣៩.-**

ក្រោយអនុក្រឹត្យនេះចូលជាធរមាន នាយកដ្ឋានសន្តិសុខសង្គមនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានផ្ទេរទៅជាបេឡាជាតិរបបសន្តិសុខសង្គម ។ ប្រធាននាយកដ្ឋានសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវទទួលតួនាទីជានាយកនៃបេឡាជាតិរបបសន្តិសុខសង្គម រហូតមានការតែងតាំងនាយកប.ស.ស ថ្មី ។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ៤០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធមានភារកិច្ចអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមិនា ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤១
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ: ០២១/០៨ កប-ប្រក

# ប្រកាស

## ស្តីពី

## បញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសំរាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យ លេខ ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម

# សម្រេច

## ប្រការ ១.- បញ្ជិកាសហគ្រាស គ្រឹះស្ថាន

១.១ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ ស្តីពីការងារត្រូវមានកាតព្វកិច្ច មកចុះបញ្ជិកាសហគ្រាស គ្រឹះស្ថានរបស់ខ្លួនក្នុងបេឡាជាតិរបបសន្តិសុខសង្គម។

១.២ រយៈពេលកំណត់នៃការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន មានដូចតទៅ:

- ចំពោះសហគ្រាស គ្រឹះស្ថានដែលកំពុងដំណើរការ ត្រូវមកចុះបញ្ជិកាក្នុងរយៈពេលយ៉ាងយូរ ៤៥ (សែសិបប្រាំ) ថ្ងៃ បន្ទាប់ពីប្រកាសនេះចូលជាធរមាន
- ចំពោះសហគ្រាស គ្រឹះស្ថានដែលបើកដំណើរការក្រោយកាលបរិច្ឆេទចូលជាធរមាននៃប្រកាសនេះ ត្រូវមកចុះបញ្ជិកាក្នុងរយៈពេលយ៉ាងយូរ ៤៥ (សែសិបប្រាំ) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការចាប់ផ្តើមបើកសហគ្រាស គ្រឹះស្ថានជាស្ថាពរ។

## ប្រការ ២.- បញ្ជិកាកម្មករនិយោជិត

២.១ និយោជក ឬម្ចាស់សហគ្រាស ត្រូវផ្ញើបញ្ជីឈ្មោះកម្មករនិយោជិតនៅក្នុង សហគ្រាសរបស់ខ្លួនមកបេឡាជាតិរបបសន្តិសុខសង្គម ដើម្បីចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម។

២.២ ការផ្ញើបញ្ជីឈ្មោះកម្មករនិយោជិត ត្រូវធ្វើក្នុងពេលដំណាលគ្នានឹងការផ្ញើទម្រង់បញ្ជិកាសហគ្រាស គ្រឹះស្ថាន។

## ប្រការ ៣.- បែបបទនៃបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងបញ្ជិកាកម្មករនិយោជិត

៣.១ ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន ត្រូវធ្វើតាមទម្រង់ "បញ្ជិកាសហគ្រាស គ្រឹះស្ថាន" ឬហៅថា ទម្រង់ "១.០១" ដែលមានចែងក្នុងឧបសម្ព័ន្ធ ១ នៃប្រកាសនេះ។ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវផ្ញើភ្ជាប់មកជាមួយនឹង ទម្រង់ "១.០១ " នូវ "បញ្ជិកាពាណិជ្ជកម្ម" ដែលចេញដោយក្រសួងពាណិជ្ជកម្ម ឬលិខិតូបករណ៍គតិយុត្តសមមូលដទៃទៀត។

៣.២ ការចុះបញ្ជិកាកម្មករនិយោជិត ត្រូវធ្វើតាមទម្រង់ "បញ្ជិកាកម្មករនិយោជិត" ឬហៅថា ទម្រង់ "១.០២ " ដែលមានចែងក្នុងឧបសម្ព័ន្ធ ២ នៃប្រកាសនេះ។ ទម្រង់បញ្ជិកាកម្មករនិយោជិត ដែលត្រូវផ្ញើជូនបេឡាជាតិរបបសន្តិសុខសង្គម អាចធ្វើតាម "ទម្រង់ក្រដាស" ឬ "ទម្រង់អេឡិចត្រូនិច" ដោយមានលិខិតបញ្ជូនដែលចុះហត្ថលេខានាយក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ។

## **ប្រការ ៤.- អត្តសញ្ញាណកម្មសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត**

៤.១ បេឡាជាតិរបបសន្តិសុខសង្គម ត្រូវផ្តល់លេខអត្តសញ្ញាណសម្រាប់សហគ្រាស គ្រឹះស្ថាន នីមួយៗ បន្ទាប់ពីទទួលបានទម្រង់ "បញ្ជិកាសហគ្រាស គ្រឹះស្ថាន"។ សហគ្រាស គ្រឹះស្ថានមួយ ត្រូវទទួលបានលេខអត្តសញ្ញាណតែមួយគត់ ដែលឱ្យឈ្មោះថា "អត្តសញ្ញាណសគ្រាស គ្រឹះស្ថាន"។

៤.២ បេឡាជាតិរបបសន្តិសុខសង្គមត្រូវផ្តល់ "វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន"ជូនសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជិការួច។ វិញ្ញាបនបត្រនេះ ចាំបាច់ត្រូវមានចុះលេខ "អត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន" និងកាលបរិច្ឆេទចុះបញ្ជិកា។ និយោជក ត្រូវដាក់តាំងវិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន នៅនឹងការិយាល័យបើកប្រាក់ឈ្នួលរបស់សហគ្រាស គ្រឹះស្ថាន។

៤.៣ បន្ទាប់ពីទទួលបានទម្រង់ "បញ្ជិកាកម្មករនិយោជិត" បេឡាជាតិរបបសន្តិសុខសង្គមត្រូវផ្តល់លេខអត្តសញ្ញាណ និងចេញ "ប័ណ្ណធានារ៉ាប់រងហានិភ័យការងារ " ជូនកម្មករនិយោជិតម្នាក់ៗដោយឥតគិតថ្លៃ។ "ប័ណ្ណធានារ៉ាប់រងហានិភ័យការងារ" ត្រូវប្រគល់ជូនទៅកម្មករ និយោជិត តាមរយៈនិយោជក។

៤.៤ ក្នុងករណីដែល"ប័ណ្ណធានារ៉ាប់រងហានិភ័យការងារ" ខូច ឬបាត់បង់ សាមីជនដែលជាម្ចាស់ប័ណ្ណត្រូវជូនដំណឹងជាបន្ទាន់ទៅនិយោជក និងត្រូវស្នើសុំទុតិយតា ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងខាងលើ។ ការផ្តល់ប័ណ្ណទុតិយតា តម្រូវឱ្យសាមីជនបង់ប្រាក់ចំនួន ២000 (ពីរពាន់) រៀល ជូនទៅបេឡាជាតិរបបសន្តិសុខសង្គម។

## **ប្រការ ៥.- របាយការណ៍ចំនួនកម្មករនិយោជិត**

៥.១ រៀងរាល់ខែ និយោជកដែលជានាយក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវផ្ញើរបាយការណ៍អំពីចំនួនកម្មករ និយោជិតទៅបេឡាជាតិរបបសន្តិសុខសង្គម ឱ្យបានមុនថ្ងៃទី ១៥ នៃខែបន្ទាប់។

៥.២ របាយការណ៍អំពីចំនួនកម្មករនិយោជិត ត្រូវធ្វើឡើងដូចគ្នានឹងទម្រង់ "បញ្ជិកាកម្មករនិយោជិត"ដោយត្រូវបញ្ជាក់បន្ថែមអំពីចំនួនកម្មករនិយោជិតទាំងអស់ដែលមាននៅក្នុងខែត្រូវរាយការណ៍។ របាយការណ៍អំពីចំនួនកម្មករនិយោជិត ដែលត្រូវផ្ញើជូនបេឡាជាតិរបបសន្តិសុខសង្គមអាចធ្វើតាម "ទម្រង់ក្រដាស" ឬ "ទម្រង់អេឡិចត្រូនិច" ដោយមានលិខិតបញ្ជូនដែលចុះហត្ថលេខានាយក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ។

**ប្រការ ៦.- អន្តរប្បញ្ញត្តិ**

ក្នុងដំណាក់កាលចាប់ដំណើរការដំបូងនៃបេឡាជាតិរបបសន្តិសុខសង្គម ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថានត្រូវអនុវត្តចំពោះតែសហគ្រាស គ្រឹះស្ថានណាដែលមានកម្មករនិយោជិតចំនួន ៨ (ប្រាំបី)នាក់ឡើង។

**ប្រការ ៧.-**

ការប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃប្រកាសនេះ នឹងត្រូវទទួលទោសដូចមានចែងក្នុងជំពូកទី ៥ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសំរាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

**ប្រការ ៨.-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃទី ០១ ខែមីនា ឆ្នាំ២០០៨។

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៨

**រដ្ឋមន្ត្រី**

**វង សូត**

ចម្លងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ " ដើម្បីជូនជ្រាប
- កាលប្បវត្តិ និងឯកសារ

ឧបសម្ព័ន្ធ ១.នៃប្រកាសលេខ:....................

| សំរាប់មន្ត្រី ប.ស.ស |
|---|
| លេខអត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន: ☐☐☐☐☐☐☐ |
| ហត្ថលេខា :................................. / / |

# បញ្ជិកាសហគ្រាសគ្រឹះស្ថាន

១.ឈ្មោះសហគ្រាស គ្រឹះស្ថាន:..........................................................................................................................

ឈ្មោះជាអក្សរឡាតាំង:..........................................................................................................................

២.អាសយដ្ឋានទីស្នាក់ការកណ្ដាល :អគារលេខ..............សង្កាត់-ឃុំ.........................ខណ្ឌ-ស្រុក...............................ខេត្ត-ក្រុង...........................

ទូរស័ព្ទ : ☐☐☐☐☐☐☐☐☐ ទូរសារ: ☐☐☐☐☐☐☐☐☐ សារអេឡិកត្រូនិក:.............................................................................

៣.អាសយដ្ឋាននៃកន្លែងធ្វើការងារ: អគារលេខ................សង្កាត់-ឃុំ.........................ខណ្ឌ-ស្រុក.......................ខេត្ត-ក្រុង...........................

ទូរស័ព្ទ ☐☐☐☐☐☐☐☐☐ ទូរសារ: ☐☐☐☐☐☐☐☐☐ សារអេឡិកត្រូនិក:.............................................................................

( ប្រសិនបើ អាសយដ្ឋានកន្លែងធ្វើការដូចគ្នាជាមួយនឹងអាសយដ្ឋានទីស្នាក់ការកណ្ដាល ចំណុចលេខ ៣ នេះពុំចាំបាច់ត្រូវបំពេញទេ)

៤. លេខបញ្ជិកាពាណិជ្ជកម្ម: ☐☐☐☐☐☐☐☐☐☐☐☐ ប្រភេទសហគ្រាស គ្រឹះស្ថាន: ☐☐☐☐ ( សំរាប់មន្ត្រី ប.ស.ស )

កាលបរិច្ឆេទបើកសហគ្រាសគ្រឹះស្ថាន: .........../.........../............ កាលបរិច្ឆេទមានកម្មករចាប់ពី ០៨ នាក់ ឡើង:.........../.........../....................

៥. ឈ្មោះនិយោជក ឬម្ចាស់សហគ្រាសគ្រឹះស្ថាន : ............................................................ ភេទ : .................សញ្ជាតិ : ............................

ឈ្មោះជាអក្សរឡាតាំង:..........................................................................................................................

អត្តសញ្ញាណប័ណ្ណលេខ ឬលិខិតឆ្លងដែនលេខ :..........................................................................................................................

អាសយដ្ឋានអចិន្ត្រៃយ៍:អគារលេខ.................សង្កាត់-ឃុំ........................ខណ្ឌ-ស្រុក........................ក្រុង-ភ្នំពេញ......................................

ទូរស័ព្ទ : ☐☐☐☐☐☐☐☐☐ ទូរសារ: ☐☐☐☐☐☐☐☐☐ សារអេឡិកត្រូនិក:.............................................................................

៦. ឈ្មោះអ្នកគ្រប់គ្រង/អ្នកតំណាងនិយោជក : ........................................................ ភេទ : .................សញ្ជាតិ : ............................

ឈ្មោះជាអក្សរឡាតាំង:..........................................................................................................................

អត្តសញ្ញាណប័ណ្ណលេខ ឬលិខិតឆ្លងដែនលេខ :..........................................................................................................................

អាសយដ្ឋានអចិន្ត្រៃយ៍:អគារលេខ..............សង្កាត់-ឃុំ.........................ខណ្ឌ-ស្រុក...........................ក្រុង-ភ្នំពេញ......................................

ទូរស័ព្ទ : ☐☐☐☐☐☐☐☐☐ ទូរសារ: ☐☐☐☐☐☐☐☐☐ សារអេឡិកត្រូនិក:.............................................................................

ខ្ញុំសូមសន្យាថារាល់ព័ត៌មានដែលបានផ្ដល់ជូនខាងលើពិតជាត្រឹមត្រូវប្រាកដមែន ។

......................., ថ្ងៃទី ................ខែ.....................ឆ្នាំ .......................

ហត្ថលេខា និងត្រានិយោជក

- ឯកសារត្រូវយកភ្ជាប់មកជាមួយ :
  - បញ្ជិកាពាណិជ្ជកម្ម
  - បញ្ជីកម្មករនិយោជិត (បំពេញតាមទម្រង់ លេខ ១.០២)

ឧបសម្ព័ន្ធ ២ នៃប្រកាសលេខ:.................... **១.០២**

# បញ្ជីភាកម្មករនិយោជិត

១.ឈ្មោះសហគ្រាស:...................................................................ជាអក្សរឡាតាំង :...................................................................លេខអត្តសញ្ញាណសហគ្រាសគ្រឹះស្ថាន: ☐☐☐☐☐☐☐

| ចំនួនកម្មករសរុបដែលបានប្រើប្រាស់នៅក្នុងខែ..................................../.................................. | | | | | | | |
|---|---|---|---|---|---|---|---|
| លេខរៀង | លេខអត្តសញ្ញាណប័ណ្ណប្រជាពលរដ្ឋ | លេខអត្តសញ្ញាណកម្មករនិយោជិត | នាម និងគោត្តនាមកម្មករនិយោជិត | ភេទ | សញ្ជាតិ | ថ្ងៃខែឆ្នាំកំណើត<br>ថ្ងៃ/ ខែ / ឆ្នាំ | ថ្ងៃខែចូលបំរើការងារ<br>ថ្ងៃ/ ខែ / ឆ្នាំ |
| | | | | | | / / | / / |
| | | | | | | / / | / / |
| | | | | | | / / | / / |
| | | | | | | / / | / / |
| | | | | | | / / | / / |
| | | | | | | / / | / / |
| | | | | | | / / | / / |
| | | | | | | / / | / / |
| | | | | | | / / | / / |
| | | | | | | / / | / / |

ខ្ញុំសូមសន្យាថារាល់ព័ត៌មានដែលបានផ្តល់ជូនខាងលើពិតជាត្រឹមត្រូវប្រាកដមែន ។

......................... , ថ្ងៃទី ខែ ឆ្នាំ

ហត្ថលេខា និងត្រានិយោជក

Letter Head Company

(ក្បាលលិខិតរបស់សហគ្រាស)

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ....................................មានតួនាទីជា..........................................................

ធ្វើការនៅក្នុងសហគ្រាសយីហោ.......................................................................................................

អសយដ្ឋានអាគារលេខ............ផ្លូវលេខ...................ភូមិ.........................ឃុំ/សង្កាត់........................ស្រុក/ខណ្ឌ

............................ខេត្ត/ក្រុង.......................លេខទូរស័ព្ទលើតុ (DeskTelephone).......................................

លេខទូរស័ព្ទដៃ (HandPhone)................................ លេខទូរសារ (Fax)..............................សារអេឡិចត្រូនិច

(E-mail) ........................................................... ។

## គោរពជូន

## លោកនាយកបេឡាជាតិរបបសន្តិសុខសង្គម

**<u>កម្មវត្ថុ</u>** : ចុះបញ្ជីកាកម្មករនិយោជិត ក្នុងបេឡាជាតិរបបសន្តិសុខសង្គម ។

**<u>យោង</u>** : ប្រកាសលេខ ០២១/០៨ ក.ប-ប្រ.ក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៨ ស្តីពីការចុះបញ្ជីកា សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តមនាយកបេឡាជាតិរបបសន្តិសុខសង្គមមេត្តាជ្រាបថា ÷ កម្មករនិយោជិត ដែលក្រុមហ៊ុនបានប្រើប្រាស់មានចំនួន........... នាក់ ដូចមាននៅក្នុងរបាយការណ៍ដែលបានថតចម្លងជូនភ្ជាប់មកជាមួយក្នុងថាស CD ឬ USB Flash ។

ខ្ញុំសូមសន្យាថា រាល់ព័ត៌មានដែលនាងខ្ញុំ/ខ្ញុំបាទបានផ្តល់ជូន ពិតជាត្រឹមត្រូវ ប្រាកដមែន ។

...................ថ្ងៃទី.........ខែ..........ឆ្នាំ២០០....

**ហត្ថលេខា និងត្រានិយោជក**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ: ០៦៦/០៩ កប-ប្រក

# ប្រកាស
# ស្តីពី
# ការកំណត់ដំណាក់កាល និងវិសាលភាព
# នៃការអនុវត្តរបបធានារ៉ាប់រងហានិភ័យការងារ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ ២០០៤ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០២ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២៩៧/៩១ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យ លេខ ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម

# សម្រេច

## ប្រការ ១.~

ដំណាក់កាលនៃការអនុវត្តផ្នែកទីមួយៗនៃរបបសន្តិសុខសង្គមដូចមានចែងនៅក្នុងបទប្បញ្ញត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវកំណត់ដូចខាងក្រោមៈ

- របបធានារ៉ាប់រងហានិភ័យការងារត្រូវចាប់ផ្តើមអនុវត្តនៅឆ្នាំ ២០០៨
- ចំពោះរបបធានារ៉ាប់រងសុខភាព ផ្នែកប្រាក់សោធន និងផ្នែកសន្តិសុខសង្គមដទៃទៀតនឹងត្រូវកំណត់ជាបន្តបន្ទាប់នៅពេលក្រោយ ។

## ប្រការ ២.~

នៅក្នុងដំណាក់កាលចាប់ផ្តើមដំបូង ផ្នែកធានារ៉ាប់រងហានិភ័យការងារ ត្រូវអនុវត្តចំពោះតែសហគ្រាស គ្រឹះស្ថាន ដែលមានកម្មករនិយោជិតចាប់ពី ០៨ ( ប្រាំបី) នាក់ឡើង ។ ចំពោះសហគ្រាស គ្រឹះ-ស្ថានផ្សេងពីនេះ ត្រូវនៅបន្តអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងាររហូត ដល់មានការកំណត់ជាថ្មី ។

## ប្រការ ៣.~

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៨

**រដ្ឋមន្ត្រី**

**វង សូត**

ចម្លងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ " ដើម្បីជូនជ្រាប "
- កាលប្បវត្តិ និងឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ......១០៥.......កប/ប្រ.ក

# ប្រកាស
# ស្តីពី
# គាទភាពិគមានិត័យការងារ

## ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសំរាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ/បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យ លេខ ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ/បក ចុះថ្ងៃទី ០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម

## សម្រេច

### ប្រការ ១.- សិទ្ធិទទួលបានតាវកាលិកហានិភ័យការងារ

១.១ កម្មករនិយោជិតទាំងអស់នៃសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គម មានសិទ្ធិទទួលបានតាវកាលិកហានិភ័យការងារ នៅពេលដែលសាមីជនទទួលរងនូវហានិភ័យការងារ ។

១.២ ហានិភ័យការងារ រួមមាន គ្រោះថ្នាក់ការងារ គ្រោះថ្នាក់នៅពេលធ្វើដំណើរដោយត្រង់ទៅកន្លែងធ្វើការ ឬមកពីកន្លែងធ្វើការឆ្ពោះទៅលំនៅស្ថាន និងជំងឺវិជ្ជាជីវៈ ។

១.៣ តាវកាលិកដែលកំណត់ក្នុងប្រកាសនេះត្រូវនៅក្នុងបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម ។

១.៤ មន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល ឬគ្រូពេទ្យព្យាបាល ត្រូវមានការទទួលស្គាល់ពីបេឡាជាតិរបបសន្តិសុខសង្គម ។

### ប្រការ ២.- ការជូនដំណឹងហានិភ័យការងារ

២.១ បន្ទាប់ពីបានទទួលដំណឹងពីកម្មករនិយោជិតដែលជាអ្នករងនូវហានិភ័យការងារ ឬអ្នកតំណាងអ្នករងគ្រោះ និយោជកឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសំរាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលបានចុះបញ្ជិកានៅក្នុងបេឡាជាតិរបបសន្តិសុខសង្គម ត្រូវជូនដំណឹងអំពីឧបទ្ទវហេតុនោះទៅបេឡាជាតិរបបសន្តិសុខសង្គមក្នុងរយៈពេលយ៉ាងយូរបំផុត ៤៨ (សែសិបប្រាំបី) ម៉ោងនៃថ្ងៃធ្វើការ ។

២.២ ការជូនដំណឹងហានិភ័យការងារត្រូវធ្វើតាមទម្រង់បែបបទដែលមានកំណត់នៅក្នុងប្រកាសរួមរវាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសុខាភិបាល ។

### ប្រការ ៣.- ការអង្កេតហានិភ័យការងារ

៣.១ បន្ទាប់ពីទទួលបានរបាយការណ៍ហានិភ័យការងារ ការិយាល័យតាវកាលិក ឬការិយាល័យខេត្តក្រុងនៃបេឡាជាតិរបបសន្តិសុខសង្គម ត្រូវជូនដំណឹងជាបន្ទាន់ទៅអធិការ ឬអភិបាលសន្តិសុខសង្គម ។

អធិការ ឬអភិបាលសន្តិសុខសង្គម ត្រូវធ្វើអង្កេត និងផ្តល់លទ្ធផលលើករណីនីមួយៗមកការិយាល័យតាវកាលិកឱ្យបានយ៉ាងឆាប់បំផុត ។

៣.២ ចំពោះករណីដែលមានលក្ខណៈស្មុគស្មាញ អធិការ ឬអភិបាលសន្តិសុខសង្គមអាចស្នើសុំជំនួយពីអ្នកឯកទេស ឬសុំកិច្ចសហការពីអធិការ ឬអភិបាលការងារ ។ ការចំណាយសម្រាប់ផ្នែកនេះ គឺជាបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម ។

៣.៣ ចំពោះគ្រោះថ្នាក់ពេលធ្វើដំណើរ អធិការ ឬអភិបាលសន្តិសុខសង្គមត្រូវស្នើសុំព័ត៌មានដែលទាក់ទងនឹងទីកន្លែង ពេលវេលា មូលហេតុនៃគ្រោះថ្នាក់ពីសាក្សី ឬអាជ្ញាធរមានសមត្ថកិច្ចនៅនឹងកន្លែងកើតហេតុ ។

## ប្រការ ៤.- ការផ្តល់សេវាសង្គ្រោះបន្ទាន់

ក្នុងករណីដែលគ្រោះថ្នាក់កើតនៅនឹងកន្លែងធ្វើការ និយោជកត្រូវផ្តល់ការសង្គ្រោះបន្ទាន់ ដែលនៅកន្លែងដែលជិតបំផុត និងបន្ទាប់មកត្រូវបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល ដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម។ ការចំណាយលើការសង្គ្រោះបន្ទាន់ និងការបញ្ជូនខាងលើត្រូវស្ថិតនៅក្នុងបន្ទុករបស់បេឡាជាតិរបបសន្តិសុខសង្គម ។ ក្នុងករណីដែលគ្រោះថ្នាក់នៅពេលធ្វើដំណើរ សាមីជន ឬនិយោជកអាចទាមទារការទូទាត់សង លើការចំណាយសម្រាប់ការសង្គ្រោះនេះពីបេឡាជាតិរបបសន្តិសុខសង្គម ។

## ប្រការ ៥.- ការផ្តល់សេវាថែទាំ និងព្យាបាល

៥.១ ការព្យាបាលចំពោះកម្មករនិយោជិត ដែលរងគ្រោះដោយហានិភ័យការងារត្រូវតែប្រព្រឹត្តទៅនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម ។

៥.២ កម្មករនិយោជិត ដែលទទួលរងហានិភ័យការងារ មានសិទ្ធិទទួលបាន ការពិនិត្យព្យាបាល ការសម្រាកព្យាបាល នៅតាមបណ្តាមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម ផ្អែកលើកិច្ចព្រមព្រៀងរវាងបេឡាជាតិរបបសន្តិសុខសង្គមជាមួយនឹងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលសាមី ។

៥.៣ ក្នុងករណីដែល គ្រូពេទ្យព្យាបាលតម្រូវឱ្យទិញឱសថ ឬ សំភារៈឧបករណ៍ដែលចាំបាច់សម្រាប់ការថែទាំ និងព្យាបាលដែលពុំមានចែងនៅក្នុងកិច្ចព្រមព្រៀង បេឡាជាតិរបបសន្តិសុខសង្គមអាចទូទាត់សងទៅជនរងគ្រោះ ឬអ្នកតំណាងវិញបាន លុះណាតែមានវេជ្ជបញ្ជា និងវិក្កយបត្រត្រឹមត្រូវ ។

៥.៤ នាយកបេឡាជាតិរបបសន្តិសុខសង្គម ត្រូវរៀបចំបញ្ជីមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលមានលក្ខណៈសម្បត្តិសមស្របតាមបទដ្ឋានបច្ចេកទេសវេជ្ជសាស្ត្រ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលនៃបេឡា

ជាតិរបបសន្តិសុខសង្គមអនុម័តយល់ព្រម ។

## ប្រការ ៦.- ការគណនាប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ

៦.១ ប្រាក់ឈ្នួលមធ្យម គឺជាផលចែកមធ្យមភាគនៃប្រាក់ឈ្នួលជាប់ភាគទានក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែ មុនកាលបរិច្ឆេទនៃគ្រោះថ្នាក់ ។ ប្រាក់ឈ្នួលជាប់ភាគទាន ត្រូវបានកំណត់ក្នុងតារាងដូចមានចែងក្នុង**ឧបសម្ព័ន្ធ ១** នៃប្រកាសនេះ ។

៦.២ ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ គឺជាផលចែកនៃប្រាក់ឈ្នួលមធ្យមដូចមានចែងក្នុងចំណុច ៦.១ នឹង ៣០ (សាមសិប) ថ្ងៃ ។

៦.៣ ការគណនាប្រាក់ឈ្នួលមធ្យម ដែលកំណត់នៅក្នុងប្រកាសនេះមានអានុភាពចំពោះតែការគណនាតាវកាលិកសន្តិសុខសង្គមប៉ុណ្ណោះ ។

## ប្រការ ៧.-ការផ្តល់តាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន

៧.១ រយៈពេលនៃការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន ត្រូវបានកំណត់ដូចតទៅ:

- រយៈពេលនៃការសម្រាកព្យាបាលមុខរបួស ឬជំងឺវិជ្ជាជីវៈនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល
- រយៈពេលនៃការសម្រាកក្រោយពេលមុខរបួសជាសះស្បើយតាមវេជ្ជបញ្ជា ។

៧.២ ក្នុងរយៈពេលនៃការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន ដូចមានចែងក្នុងវាក្យខ័ណ្ឌ ៧.១ ខាងលើ កម្មករនិយោជិត ដែលរងគ្រោះដោយហានិភ័យការងារមានសិទ្ធិទទួលបានតាវកាលិកពីបេឡាជាតិរបបសន្តិសុខសង្គម ដូចតទៅ:

- ប្រាក់បំណាច់ប្រចាំថ្ងៃ ដែលត្រូវផ្តល់ជូនគិតចាប់ពីថ្ងៃទីពីរ បន្ទាប់ពីកាលបរិច្ឆេទនៃការកើតឧបទ្ទវហេតុបណ្តាលឱ្យទទួលរងនូវហានិភ័យការងារ
- ប្រាក់ឧបត្ថម្ភសម្រាប់អ្នកថែទាំអ្នករងគ្រោះពេលសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល ក្នុងករណី ដែលស្ថានភាពគ្រោះថ្នាក់ធ្ងន់ធ្ងរតម្រូវឱ្យមានអ្នកនៅចាំថែទាំ តាមសំណើសុំរបស់គ្រូពេទ្យព្យាបាល ។

៧.៣ ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្នត្រូវផ្តល់ចំពោះតែហានិភ័យការងារ ដែលតម្រូវឱ្យមានការសម្រាកព្យាបាលលើសពី ០៤(បួន) ថ្ងៃឡើងទៅ ។

៧.៤ ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្នត្រូវស្មើនឹង ៧០ (ចិតសិប) ភាគរយ នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ ។ ប្រាក់ឧបត្ថម្ភសម្រាប់អ្នកថែទាំនៅមន្ទីរពេទ្យ ត្រូវស្មើនឹង ៥០ (ហាសិប) ភាគរយនៃប្រាក់បំណាច់ប្រចាំថ្ងៃរបស់ជនរងគ្រោះ ។

៧.៥ ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្ដោះអាសន្ន អាចផ្ដល់ជូនជនរងគ្រោះដោយហានិភ័យការងារ ក្នុងរយៈពេលយ៉ាងយូរបំផុត ១៨០ ( មួយរយប៉ែតសិប ) ថ្ងៃ ។

## ប្រការ ៨.- គណនាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍

៨.១ កម្មករនិយោជិតដែលទទួលរងហានិភ័យការងារបណ្ដាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍តិចជាង ២០ ភាគរយ មានសិទ្ធិទទួលបានប្រាក់វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារ ។ ប្រាក់វិភាជន៍នេះត្រូវផ្ដល់ជូនអ្នករងគ្រោះតែម្ដងគត់ ដោយគិតតាមរូបមន្តដូចខាងក្រោម:

**វបក = បឈម x ៧០% x កបក x ២០%មតប**

- **វបក:** វិភាជន៍បាត់បង់សមត្ថភាពការងារ
- **បឈម:** ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់ជនរងគ្រោះ
- **កបក:** កម្រិតបាត់បង់សមត្ថភាពការងាររបស់ជនរងគ្រោះ
- **មតប:** មេគុណតម្លៃបច្ចុប្បន្ន

៨.២ កម្មករនិយោជិតដែលទទួលរងហានិភ័យការងារបណ្ដាលឱ្យបាត់បង់សមត្ថភាពការងារចាប់ពី ២០ ភាគរយឡើង មានសិទ្ធិទទួលបានធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ។ប្រាក់ធនលាភសរុបសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ត្រូវបានគិតតាមរូបមន្តដូចខាងក្រោម:

**ធល = បឈម x ៧០ % x [កបក − ១/៥ កបក] x មតប**

- **ធល:** ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារ

៨.៣ ប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ត្រូវចាត់ទុកជាបណ្ដោះអាសន្នជានិច្ច ។ បេឡាជាតិរបបសន្តិសុខសង្គម ត្រូវរៀបចំឱ្យមានការពិនិត្យសុខភាព និងសមត្ថភាពការងារអ្នករងគ្រោះឡើងវិញក្នុងរយៈពេល ១ ( មួយ ) ឆ្នាំយ៉ាងយូរ ។ ជនរងគ្រោះដែលទទួលបានប្រាក់ធនលាភត្រូវមានកាតព្វកិច្ចមកពិនិត្យសុខភាពតាមការកំណត់របស់បេឡាជាតិរបបសន្តិសុខសង្គម ។

៨.៤ កម្រិតនៃការបាត់បង់សមត្ថភាពការងារ ត្រូវបានកំណត់នៅក្នុង **ឧបសម្ព័ន្ធ ២** នៃប្រកាសនេះ ។ មេគុណតម្លៃបច្ចុប្បន្ន ត្រូវបានកំណត់នៅក្នុង **ឧបសម្ព័ន្ធ ៣** ។

## ប្រការ ៩.- ប្រាក់បន្ថែមសម្រាប់អ្នកចាំថែរក្សាជនរងគ្រោះ

កម្មករនិយោជិត ដែលទទួលរងហានិភ័យការងារបណ្ដាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ក្នុងកម្រិត ១០០ ភាគរយ មានសិទ្ធិទទួលបានប្រាក់បន្ថែមសម្រាប់អ្នកចាំថែរក្សាដល់ខ្លួន ។ ប្រាក់បន្ថែម

សម្រាប់អ្នកចាំថែរក្សាត្រូវស្មើ ៥០ ( ហាសិប) ភាគរយនៃប្រាក់ធនលាភរបស់ជនរងគ្រោះ ។

## ប្រការ ១០._ ប្រាក់វិភាជន៍ជាសោហ៊ុយបូជាសព

ក្នុងករណីដែលមានការទទួលរងនូវហានិភ័យការងាររហូតបណ្តាលឱ្យបាត់បង់ជីវិត អ្នកទទួលរ៉ាប់រងក្នុងការចាត់ចែងបូជាសព ត្រូវបានផ្តល់ប្រាក់វិភាជន៍ជាសោហ៊ុយបូជាសព ដែលមានចំនួន ១.០០០.០០០ ( មួយលាន) រៀល ។ ប្រាក់វិភាជន៍នេះ ត្រូវតែផ្តល់ជូនទៅជន ដែលទទួលបន្ទុកផ្ទាល់ក្នុងការចាត់ចែងបូជាសពជនរងគ្រោះ ។

## ប្រការ ១១._ តាវកាលិកឧត្តរជីវី

១១.១ ឧត្តរជីវីនៃជនរងគ្រោះដោយហានិភ័យការងារដូចមានចែងនៅក្នុងមាត្រា ៣៤ នៃអនុក្រឹត្យលេខ ១៦ អនក្រ/បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គមមានសិទ្ធិទទួលបានតាវកាលិកឧត្តរជីវី ។

១១.២ តាវកាលិកឧត្តរជីវី គឺជាប្រាក់ធនលាភដែលត្រូវផ្តល់ឱ្យសិទ្ធិវន្តនៃជនរងគ្រោះ តាមអត្រាដូចខាងក្រោម:

ក. ក្នុងករណីសិទ្ធិវន្ត មានរួមទាំងប្រពន្ធ ឬប្តី កូន និងឪពុកម្តាយ ឬមនុស្សចាស់ជរានៅក្នុងបន្ទុក

- ប្រពន្ធ ឬប្តី = ៣/៥ x ៦៣% បឈម
- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក= ២/៥ x ៦៣% បឈម
- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ៧% បឈម

ខ. ក្នុងករណីសិទ្ធិវន្ត មានតែប្រពន្ធ ឬប្តី និង/ឬ កូន

- ប្រពន្ធ ឬប្តី = ៣/៥ x ៧០%បឈម
- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២/៥ x ៧០%បឈម

គ. ក្នុងករណីសិទ្ធិវន្តមានតែឪពុកម្តាយ ឬមនុស្សចាស់ជរា

- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ២៨%បឈម

ឃ. ក្នុងករណីសិទ្ធិវន្ត មានតែកូន និងឪពុកម្តាយ ឬមនុស្សចាស់ជរា

- ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២៨%បឈម
- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ២៨%បឈម

ង. ក្នុងករណីសិទ្ធិវន្តមានតែ ប្រពន្ធ ឬប្តី និងឪពុកម្តាយ ឬមនុស្សចាស់ជរា

- ប្រពន្ធ ឬប្តី = ២៨%បឈម
- ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ២៨%បឈម

១១.៣ សិទ្ធិវន្ត ជាប្រពន្ធ ឬប្តីនៃជនរងគ្រោះ ត្រូវមានលិខិតបញ្ជាក់អាពាហ៍ពិពាហ៍។ សិទ្ធិទទួលធនលាភចំពោះសិទ្ធិវន្តដែលជាប្រពន្ធ ឬប្តី ត្រូវបានរំលាយនៅពេលដែលសាមីជនរៀបអាពាហ៍ពិពាហ៍ជាថ្មី។ ក្នុងករណីនៃការរៀបអាពាហ៍ពិពាហ៍ជាថ្មី សាមីជនត្រូវជូនដំណឹងមកបេឡាជាតិរបបសន្តិសុខសង្គមយ៉ាងយូរបំផុត ៣០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការចុះលិខិតបញ្ជាក់អាពាហ៍ពិពាហ៍។ ការខកខានមិនបានជូនដំណឹងអំពីការរៀបអាពាហ៍ពិពាហ៍របស់ខ្លួន សាមីជននឹងត្រូវទទួលទោសដូចមានចែងក្នុងមាត្រា ៣៨ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

១១.៤ សិទ្ធិវន្តជា កូនត្រូវមានស្ថានភាពស្របតាមលក្ខខណ្ឌដូចមានចែងនៅក្នុងចំណុច ៣៤.១ ខ មាត្រា ៣៤ នៃអនុក្រឹត្យលេខ១៦ អនក្រ/បកចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧។

១១.៥ សិទ្ធិទទួលធនលាភនៃសិទ្ធិវន្ត ត្រូវបានរំលាយនៅពេលដែលសាមីជនទទួលមរណភាព។

## ប្រការ ១២.- សេវាបុនរីតិសម្បទា

១២.១កម្មករនិយោជិតដែលរងហានិភ័យការងារបណ្តាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ មានសិទ្ធិទទួលបានឧបករណ៍ ឬអវៈយវៈសិប្បនិម្មិតតាមការកំណត់របស់គ្រូពេទ្យផ្លូវការឬគ្រូពេទ្យដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម។

១២.២កម្មករនិយោជិតដែលរងហានិភ័យការងារបណ្តាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ មានសិទ្ធិទទួលបានសេវាសម្របសម្រួលមុខងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ ស្របតាមលក្ខខណ្ឌដែលនឹងកំណត់ក្នុងប្រកាសដោយឡែករបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ប្រការ ១៣.- ការទាមទារតាវកាលិក

១៣.១ ការទាមទារតាវកាលិកសម្រាប់ការថែទាំ និងព្យាបាល អាចត្រូវបានធ្វើឡើងដោយមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលព្យាបាលជនរងគ្រោះ ឬនិយោជក ឬក៏កម្មករនិយោជិតជាជនរងគ្រោះផ្ទាល់តាមទម្រង់ "**តាវកាលិកថែទាំ និងព្យាបាល** " ឬហៅថាទម្រង់ " **៣.០២** "ដូចមានចែងក្នុង **ឧបសម្ព័ន្ធ ៤** នៃប្រកាសនេះ។

១៣.២ ការទាមទារប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្នត្រូវធ្វើដោយជនរងគ្រោះ ឬតំណាងតាមទម្រង់ "**តាវកាលិកបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន** " ឬហៅថាទម្រង់ "**៣.០៣** " ដូចមានចែងក្នុង **ឧបសម្ព័ន្ធ ៥** នៃប្រកាសនេះ។ បែបបទ នៃការទាមទារនេះត្រូវមានភ្ជាប់ជាមួយនូវវេជ្ជបញ្ជា និងលិខិតបញ្ជាក់ពីគ្រូពេទ្យព្យាបាលផ្លូវការ។

១៣.៣ ការទាមទារតាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ត្រូវធ្វើឡើងដោយជនរងគ្រោះតាមទម្រង់ "**តាវកាលិកបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍** " ឬហៅថាទម្រង់

"**៣.០៤** " ដូចមានចែងក្នុង**ឧបសម្ព័ន្ធ ៦** នៃប្រកាសនេះ។ ក្នុងករណីដែល ជនរងគ្រោះមិនអាចមានសមត្ថភាព ក្នុងការទាមទារតាវកាលិកបាន ដោយសារស្ថានភាពនៃការបាត់បង់សមត្ថភាពការងារធ្ងន់ធ្ងរ ការទាមទារនេះអាចត្រូវធ្វើដោយអ្នកតំណាងជនរងគ្រោះ។ អ្នកតំណាងជនរងគ្រោះ អាចជាប្តី ប្រពន្ធ កូន ឬជន ដែលមានភារៈចិញ្ចឹមរក្សាដោយផ្ទាល់ចំពោះជនរងគ្រោះ។

១៣.៤ ការទាមទារតាវកាលិកឧត្តរជីវី និងសោហ៊ុយបូជាសព ត្រូវធ្វើដោយសិទ្ធិវន្តនៃជនរងគ្រោះ ឬអ្នកតំណាង តាមទម្រង់ "**តាវកាលិកឧត្តរជីវី** " ឬហៅថាទម្រង់ " **៣.០៥** " និងទម្រង់ " **វិភាជន៍បូជាសព**" " ឬហៅថា ទម្រង់ "**៣.០៦** " ដូចមានចែងក្នុង **ឧបសម្ព័ន្ធ ៧ និង ៨** នៃប្រកាសនេះ។

១៣.៥ សិទ្ធិនៃការទាមទារប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ហានិភ័យការងារ និងប្រាក់វិភាជន៍បូជាសព ត្រូវអស់សុពលភាពត្រឹមរយៈពេល ១ (មួយ) ឆ្នាំ។ ចំពោះសិទ្ធិក្នុងការទាមទារប្រាក់ធនលាភ ត្រូវអស់សុពលភាពត្រឹមរយៈពេល ៥ (ប្រាំ) ឆ្នាំ។

១៣.៦ ការបើកប្រាក់ធនលាភ ត្រូវធ្វើប្រចាំត្រីមាស។

## ប្រការ ១៤.- ការយល់ព្រមចំពោះការទាមទារតាវកាលិក

១៤.១ តាវកាលិកថែទាំ និងព្យាបាល ដែលត្រូវបានទទួលការយល់ព្រមពីបេឡាជាតិរបបសន្តិសុខសង្គម លុះណាតែការថែទាំនិងព្យាបាលនោះធ្វើនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម។

ប្រសិនបើការថែទាំ និងព្យាបាលធ្វើនៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលផ្សេងក្រៅពីការកំណត់របស់បេឡាជាតិរបបសន្តិសុខសង្គម ការទូទាត់សងវិញត្រូវធ្វើតាមអត្រាតម្លៃដែលបេឡាជាតិរបបសន្តិសុខសង្គមបានកំណត់។

តារាងតម្លៃសម្រាប់ការថែទាំ និងព្យាបាល ត្រូវបានកំណត់តាមកិច្ចព្រមព្រៀងរវាងបេឡាជាតិរបបសន្តិសុខសង្គម និងបណ្តាមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល។

១៤.២ ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន ដែលត្រូវបានទទួលការយល់ព្រមពីបេឡាជាតិរបបសន្តិសុខសង្គម លុះណាតែការទាមទារនោះស្របនឹងលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៧ វាក្យខណ្ឌ ៧.១, ៧.២ និង ៧.៣ នៃប្រកាសនេះ។

១៤.៣ តាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ត្រូវបានយល់ព្រម លុះត្រាតែការបាត់បង់សមត្ថភាពនោះត្រូវបានវាយតម្លៃពីគ្រូពេទ្យផ្លូវការ ឬ គណកម្មការវេជ្ជសាស្ត្រនៃបេឡាជាតិរបបសន្តិសុខសង្គម ស្របតាមតារាងនៃកម្រិតបាត់បង់សមត្ថភាពការងារដូចមានចែងក្នុង**ឧបសម្ព័ន្ធ ២** នៃប្រកាសនេះ។ក្នុងករណីដែល កម្រិតបាត់បង់សមត្ថភាពការងារពុំមានចែងនៅក្នុងតារាងខាងលើ គណកម្មការ

វេជ្ជសាស្ត្រ ត្រូវវាយតម្លៃកម្រិតបាត់បង់សមត្ថភាពតាមបច្ចេកទេសវេជ្ជសាស្ត្រ ដោយមានការចូលរួមពីគ្រូពេទ្យឯកទេសតាម ស្ថានភាពជាក់ស្តែងនីមួយៗ ។

**ប្រការ ១៥.- អន្តរប្បញ្ញត្តិ**

ចំពោះសហគ្រាស គ្រឹះស្ថានដែលពុំទាន់ត្រូវបានចុះបញ្ជិកានៅក្នុងបេឡាជាតិរបបសន្តិសុខសង្គមការផ្តល់តាវកាលិកសម្រាប់ហានិភ័យការងារ ត្រូវបន្តអនុវត្តតាមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ ។

**ប្រការ ១៦.- អវសានប្បញ្ញត្តិ**

ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែ[illegible] ឆ្នាំ២០០៨

រដ្ឋមន្ត្រី

វង សូត

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ " ដើម្បីជូនជ្រាប "
- កាលប្បវត្តិ និងឯកសារ

## តារាងប្រាក់ឈ្នួលជាប់ភាគទាន

| ថ្នាក់ | ចំនួនប្រាក់ឈ្នួលសរុប (រៀល) | ប្រាក់ឈ្នួលជាប់ភាគទាន(រៀល) |
|---|---|---|
| ១ | តិចជាង ២០០.០០០ | ២០០.០០០ |
| ២ | ២០០.០០១ -២៥០.០០០ | ២២៥.០០០ |
| ៣ | ២៥០.០០១-៣០០.០០០ | ២៧៥.០០០ |
| ៤ | ៣០០.០០១-៣៥០.០០០ | ៣២៥.០០០ |
| ៥ | ៣៥១.០០១-៤០០.០០០ | ៣៧៥.០០០ |
| ៦ | ៤០០.០០១-៤៥០.០០០ | ៤២៥.០០០ |
| ៧ | ៤៥០.០០១-៥០០.០០០ | ៤៧៥.០០០ |
| ៨ | ៥០០.០០១-៥៥០.០០០ | ៥២៥.០០០ |
| ៩ | ៥៥០.០០១-៦០០.០០០ | ៥៧៥.០០០ |
| ១០ | ៦០០.០០១-៦៥០.០០០ | ៦២៥.០០០ |
| ១១ | ៦៥០.០០១-៧០០.០០០ | ៦៧៥.០០០ |
| ១២ | ៧០០.០០១-៧៥០.០០០ | ៧២៥.០០០ |
| ១៣ | ៧៥០.០០១-៨០០.០០០ | ៧៧៥.០០០ |
| ១៤ | ៨០០.០០១-៨៥០.០០០ | ៨២៥.០០០ |
| ១៥ | ៨៥០.០០១-៩០០.០០០ | ៨៧៥.០០០ |
| ១៦ | ៩០០.០០១-៩៥០.០០០ | ៩២៥.០០០ |
| ១៧ | ៩៥០.០០១-១.០០០.០០០ | ៩៧៥.០០០ |
| ១៨ | ១.០០០.០០១ ឡើង | ១.០០០.០០០ |

## តារាងកម្រិតនៃការបាត់បង់សមត្ថភាពការងារ

### ផ្នែកទី ១

### បញ្ជីគ្រោះថ្នាក់ដែលបណ្ដាលឱ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ទាំងស្រុង

| ល.រ | ការបរិយាយអំពីគ្រោះថ្នាក់ | ភាគរយនៃការបាត់បង់សមត្ថភាពការងារ |
|---|---|---|
| ១ | បាត់បង់ប្រអប់ដៃទាំងពីរ ឬកាត់នៅផ្នែកខាងលើ | ១០០ |
| ២ | បាត់ប្រអប់ដៃមួយ និងប្រអប់ជើងមួយ | ១០០ |
| ៣ | កាត់ជើងឬភ្លៅ ឬកាត់ជើង ឬភ្លៅម្ខាង និងបាត់ប្រអប់ជើងម្ខាងទៀត | ១០០ |
| ៤ | បាត់បង់ចក្ខុប្រសាទនៅកំរិតណាមួយដែលមិនអាចឱ្យអ្នកទាមទារបំពេញការងារដែលប្រើប្រាស់ក្រសែភ្នែកជាសំខាន់ ( ខ្វាក់មើលមិនឃើញ) | ១០០ |
| ៥ | ការខូចទ្រង់ទ្រាយមុខធ្ងន់ធ្ងរ | ១០០ |
| ៦ | ថ្លង់ទាំងស្រុង | ១០០ |

### ផ្នែកទី ២

### បញ្ជីគ្រោះថ្នាក់ដែលបណ្ដាលឱ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ដោយផ្នែក

| ល.រ | ការបរិយាយអំពីគ្រោះថ្នាក់ | ភាគរយនៃការបាត់បង់សមត្ថភាពការងារ |
|---|---|---|
| | **ការកាត់អវៈយវៈផ្នែកខាងលើ ( ដៃមួយណាក៏ដោយ)** | |
| ១ | កាត់សន្លាក់ស្មា | ៩០ |
| ២ | កាត់ក្រោមស្មាដែលគល់នៅតិចជាង ៨ " ពីចុងនៃ acromion | ៨០ |
| ៣ | កាត់ ៨ " ពីចុងនៃ acromion ទៅតិចជាង 4" ក្រោមចុងនៃ olecranon | ៧០ |
| ៤ | បាត់ប្រអប់ដៃ ឬមេដៃ និងម្រាម ៤ នៃប្រអប់ដៃមួយ ឬកាត់ពី 4 1/2" ក្រោមចុងនៃ olecranon | ៦០ |
| ៥ | បាត់មេដៃ | ៣០ |
| ៦ | បាត់មេដៃ និងឆ្អឹង metacarpal | ៤០ |
| ៧ | បាត់ម្រាមបួននៃប្រអប់ដៃមួយ | ៥០ |
| ៨ | បាត់ម្រាមបីនៃប្រអប់ដៃមួយ | ៣០ |
| ៩ | បាត់ម្រាមពីរនៃប្រអប់ដៃមួយ | ២០ |
| ១០ | បាត់ថ្នាំងចុងក្រោយនៃមេដៃ | ២០ |

| ការកាត់អវៈយវៈផ្នែកក្រោម | | |
|---|---|---|
| ១១ | កាត់ប្រអប់ជើងទាំងពីរបណ្តាលឱ្យដើរខ្វើច | ៩០ |
| ១២ | កាត់តាម feet proximal ទាំងពីរទៅ metatarso-phalangeal joint | ៨០ |
| ១៣ | បាត់ម្រាមជើងទាំងអស់នៃប្រអបជើងទំងពីរតាម metatarso-phalangeal joint | ៤០ |
| ១៤ | បាត់ម្រាមជើងទាំងអស់នៃ feet proximal ទាំងពីរទៅ proximal inter-phalangeal joint | ៣០ |
| ១៥ | បាត់ម្រាមជើងទាំងអស់នៃ feet distal ទាំងពីរទៅ proximal inter-phalangeal joint | ២០ |
| ១៦ | កាត់ត្រគាក | ៩០ |
| ១៧ | កាត់ក្រោមត្រគាកដែលសល់គល់ប្រវែងមិនលើស 5" ដែលវាស់ពីចុង នៃ great trenchanter | ៨០ |
| ១៨ | កាត់ក្រោមត្រគាកដែលសល់គល់ប្រវែងមិនលើស 5" ដែលវាស់ពីចុង នៃ great trenchanter ប៉ុន្តែមិនហួសពីពាក់កណ្តាលភ្លៅ | ៧០ |
| ១៩ | កាត់ក្រោមពាក់កណ្តាលភ្លៅទៅ 3 1/2" ក្រោមជង្គង់ | ៦០ |
| ២០ | កាត់ក្រោមជង្គង់ដែលនៅសល់គល់លើស 3 1/2" ប៉ុន្តែមិនលើស 5" | ៥០ |
| ២១ | កាត់ក្រោមជង្គង់ដោយសល់គលលើសពី 5" | ៤០ |
| ២២ | កាត់ប្រអប់ជើងមួយបណ្តាលឱ្យដើរទប់ខាងចុង | ៣០ |
| ២៣ | កាត់ពី foot proximal មួយទៅ meta torso phalangeal joint | ៣០ |
| ២៤ | បាត់ម្រាមជើងទាំងអស់នៃប្រអបជើងមួយតាម meta torso phalangeal joint | ២០ |
| ២៥ | បាត់ភ្នែកម្ខាងដោយគ្មានភាពស្មុគស្មាញ ហើយម្ខាងទៀតនៅធម្មតា | ៤០ |
| ២៦ | បាត់ចក្ខុវិញ្ញាណនៃភ្នែកម្ខាងដោយគ្មានភាពស្មុគស្មាញ ឬដោយគ្មានការខូចទ្រង់ទ្រាយនៃគ្រាប់ភ្នែក ហើយម្ខាងទៀតនៅធម្មតា | ៣០ |
| ២៧ | ត្រចៀកម្ខាងថ្លង់ទាំងស្រុង | ២០ |
| *ក- ម្រាមដៃឆ្វេង ឬស្តាំ* | | |
| *ចង្អុលដៃ* | | |
| ២៨ | ទាំងមូល | ១៤ |
| ២៩ | ពីរថ្នាំងដៃ | ១១ |
| ៣០ | មួយថ្នាំងដៃ | ៩ |
| ៣១ | កាត់ចុងដោយម៉ាស៊ីនដោយមិនបាត់ឆ្អឹង | ៥ |
| *ម្រាមកណ្តាល* | | |
| ៣២ | ទាំងមូល | ១២ |
| ៣៣ | ពីរថ្នាំងដៃ | ៩ |

bita.

| | | |
|---|---|---|
| ៣៤ | មួយថ្នាំងដៃ | ៧ |
| ៣៥ | កាត់ចុងដោយម៉ាស៊ីនដោយមិនបាត់ឆ្អឹង | ៤ |
| ***នាងដៃ និងកូនដៃ*** | | |
| ៣៦ | ទាំងមូល | ៧ |
| ៣៧ | ពីរថ្នាំងដៃ | ៦ |
| ៣៨ | មួយថ្នាំងដៃ | ៥ |
| ៣៩ | កាត់ចុងដោយម៉ាស៊ីនដោយមិនបាត់ឆ្អឹង | ២ |
| ***ខ-ម្រាមជើងឆ្វេង ឬស្តាំ*** | | |
| ***មេជើង*** | | |
| ៤០ | Through metatarso-phalangeal joint | ១៤ |
| ៤១ | Part, with some loss of bone | ៣ |
| ***ម្រាមជើងដទៃទៀត*** | | |
| ៤២ | Through metatarso-phalangeal joint | ៣ |
| ៤៣ | Part, with some loss of bone | ១ |
| ***ម្រាមពីរនៃប្រអប់ជើងមួយ មិនគិតមេជើង*** | | |
| ៤៤ | Through metatarso-phalangeal joint | ៥ |
| ៤៥ | Part, with some loss of bone | ២ |
| ***ម្រាមបីនៃប្រអប់ជើងមួយ មិនគិតមេជើង*** | | |
| ៤៦ | Through metatarso-phalangeal joint | ៦ |
| ៤៧ | Part, with some loss of bone | ៣ |
| ***ម្រាមបួននៃប្រអប់ជើងមួយ មិនគិតមេជើង*** | | |
| ៤៨ | Through metatarso-phalangeal joint | ៩ |
| ៤៩ | Part, with some loss of bone | ៣ |

(សំគាល់: ការបាត់បង់ទាំងស្រុង និងអចិន្ត្រៃយ៍នៃការប្រើប្រាស់អវៈយវៈណាមួយដែលយោងតាមតារាងនេះ ត្រូវ ចាត់ទុកថាមាន តំលៃស្មើគ្នា "សមមូល" នៃការបាត់បង់អវៈយវៈនោះ) ។

ឧបសម្ព័ន្ធ ៣នៃប្រកាសលេខ ១០៩ បក/ប្រ.ក ស្តីពីតាវកាលិកហានិភ័យការងារ

## តារាងមេគុណតម្លៃបច្ចុប្បន្ន

| អាយុ | មេគុណ |
|---|---|
| 0 | 12,222 |
| 1 | 12,305 |
| 2 | 12,364 |
| 3 | 12,398 |
| 4 | 12,408 |
| 5 | 12,398 |
| 6 | 12,369 |
| 7 | 12,324 |
| 8 | 12,263 |
| 9 | 12,189 |
| 10 | 12,104 |
| 11 | 12,010 |
| 12 | 11,910 |
| 13 | 11,806 |
| 14 | 11,700 |
| 15 | 11,593 |
| 16 | 11,485 |
| 17 | 11,376 |
| 18 | 11,266 |
| 19 | 11,156 |
| 20 | 11,045 |
| 21 | 10,932 |
| 22 | 10,818 |
| 23 | 10,704 |
| 24 | 10,587 |
| 25 | 10,470 |
| 26 | 10,351 |
| 27 | 10,230 |
| 28 | 10,108 |
| 29 | 9,983 |
| 30 | 9,857 |
| 31 | 9,728 |
| 32 | 9,596 |
| 33 | 9,462 |
| 34 | 9,326 |
| 35 | 9,188 |
| 36 | 9,048 |
| 37 | 8,906 |
| 38 | 8,762 |
| 39 | 8,616 |
| 40 | 8,468 |
| 41 | 8,317 |
| 42 | 8,164 |
| 43 | 8,009 |
| 44 | 7,852 |

| | |
|---|---|
| 45 | 7,692 |
| 46 | 7,530 |
| 47 | 7,366 |
| 48 | 7,200 |
| 49 | 7,032 |
| 50 | 6,862 |
| 51 | 6,690 |
| 52 | 6,516 |
| 53 | 6,341 |
| 54 | 6,164 |
| 55 | 5,986 |
| 56 | 5,807 |
| 57 | 5,627 |
| 58 | 5,447 |
| 59 | 5,265 |
| 60 | 5,083 |
| 61 | 4,900 |
| 62 | 4,717 |
| 63 | 4,534 |
| 64 | 4,350 |
| 65 | 4,169 |
| 66 | 3,990 |
| 67 | 3,817 |
| 68 | 3,648 |
| 69 | 3,481 |
| 70 | 3,316 |
| 71 | 3,153 |
| 72 | 2,996 |
| 73 | 2,842 |
| 74 | 2,693 |
| 75 | 2,547 |
| 76 | 2,406 |
| 77 | 2,270 |
| 78 | 2,138 |
| 79 | 2,011 |
| 80 | 1,888 |
| 81 | 1,771 |
| 82 | 1,658 |
| 83 | 1,550 |
| 84 | 1,447 |
| 85 | 1,348 |
| 86 | 1,255 |
| 87 | 1,166 |
| 88 | 1,081 |
| 89 | 1,001 |
| 90 | 926 |
| 91 | 854 |
| 92 | 787 |
| 93 | 723 |
| 94 | 664 |
| 95 | 608 |
| 96 | 555 |

| | |
|---|---|
| 97 | 505 |
| 98 | 459 |
| 99 | 415 |
| 100 | 374 |
| 101 | 333 |
| 102 | 293 |
| 103 | 246 |
| 104 | 174 |
| 105 | 0 |

| សំរាប់មន្ត្រី ប.ស.ស |
|---|
| លេខគាវកាលិក : / |
| ហត្ថលេខា :........................ / / |

# គាវកាលិកថែទាំ និងព្យាបាល

❶ នាមករណ៍សហគ្រាស : ........................................................................ លេខអត្តសញ្ញាណសហគ្រាស:

អាសយដ្ឋានសហគ្រាស :........... លេខផ្លូវ..........សង្កាត់(ឃុំ)................ខណ្ឌ(ស្រុក)................ខេត្ត/ក្រុង.........................

លេខទូរស័ព្ទ : លេខទូរសារ: E-mail address:...........................................

❷ គោត្តនាមនិង នាមកម្មករនិយោជិត : ........................................................ លេខអត្តសញ្ញាណកម្មករនិយោជិត:

អាសយដ្ឋានអចិន្ត្រៃយ៍ :........... លេខផ្លូវ..........សង្កាត់(ឃុំ)................ខណ្ឌ(ស្រុក)................ខេត្ត/ក្រុង.........................

លេខទូរស័ព្ទ : លេខទូរសារ: E-mail address:...........................................

❸ ឈ្មោះមន្ទីរពេទ្យ/គ្លីនិកព្យាបាល:..........................................................................................................

๏ អាសយដ្ឋានមន្ទីរពេទ្យ :........... លេខផ្លូវ..........សង្កាត់(ឃុំ)................ខណ្ឌ(ស្រុក)................ខេត្ត/ក្រុង.........................

លេខវិក័យបត្រ:................................................

ចំនួនថ្ងៃសំរាកព្យាបាល :......................ថ្ងៃ ចាប់ពីថ្ងៃខែឆ្នាំ : / / ដល់ថ្ងៃខែឆ្នាំ: / /

:

❹ លេខហានិភ័យការងារ: / ប្រភេទគ្រោះថ្នាក់ : ☐ ធ្វើដំណើរ ☐ កន្លែងធ្វើការងារ ☐ ជំងឺវិជ្ជាជីវៈ

๏ ថ្ងៃខែឆ្នាំគ្រោះថ្នាក់ : - - ម៉ោងគ្រោះថ្នាក់ : :

ថ្ងៃ - ខែ - ឆ្នាំ ម៉ោង នាទី

๏ទីកន្លែងគ្រោះថ្នាក់ : ..........................................................................................................

๏ មូលហេតុគ្រោះថ្នាក់ : ..........................................................................................................

※ **ព័ត៌មានលំអិតសំរាប់អ្នកតំណាងការទាមទារគាវកាលិកថែទាំ និងព្យាបាល**

❺ គោត្តនាម និងនាមអ្នកតំណាង : ........................................................ ភេទ : ថ្ងៃខែឆ្នាំកំណើត : / /

អាសយដ្ឋានអចិន្ត្រៃយ៍ :........... លេខផ្លូវ..........សង្កាត់(ឃុំ)................ខណ្ឌ(ស្រុក)................ខេត្ត/ក្រុង.........................

លេខទូរស័ព្ទ : លេខទូរសារ: E-mail address:...........................................

លេខអត្តសញ្ញាណប័ណ្ណ/លេខលិខិតឆ្លងដែន: ................................. ចុះថ្ងៃទី : / /

ខ្ញុំសូមសន្យាថារាល់ព័ត៌មានដែលបានផ្ដល់ជូនខាងលើពិតជាត្រឹមត្រូវប្រាកដមែន ។

......................, ថ្ងៃទី ខែ ឆ្នាំ២០០

**ហត្ថលេខាអ្នកស្នើសុំ**

០៣.០៣

# តាវកាលិកបាត់បង់សមត្ថភាពការងារ
## បណ្តោះអាសន្ន

**សំរាប់មន្ត្រី ប.ស.ស**

លេខតាវកាលិក : [ ][ ][ ][ ] / [ ][ ]

ហត្ថលេខា :........................ / /

❶ នាមករណ៍សហគ្រាស : ........................................................................ លេខអត្តសញ្ញាណសហគ្រាស: [ ][ ][ ][ ][ ][ ][ ]

អាសយដ្ឋានសហគ្រាស :........... លេខផ្លូវ..........សង្កាត់(ឃុំ)...............ខណ្ឌ(ស្រុក)................ខេត្ត/ក្រុង..........................

លេខទូរស័ព្ទ : [ ][ ][ ][ ][ ][ ][ ][ ][ ] លេខទូរសារ: [ ][ ][ ][ ][ ][ ][ ][ ][ ] E-mail address:........................................

❷ គោត្តនាម និងនាមកម្មករនិយោជិត : ........................................................ លេខអត្តសញ្ញាណកម្មករនិយោជិត: [ ][ ][ ][ ][ ][ ][ ][ ]

អាសយដ្ឋានអចិន្ត្រៃយ៍ :........... លេខផ្លូវ..........សង្កាត់(ឃុំ)...............ខណ្ឌ(ស្រុក)................ខេត្ត/ក្រុង..........................

លេខទូរស័ព្ទ : [ ][ ][ ][ ][ ][ ][ ][ ][ ] លេខទូរសារ: [ ][ ][ ][ ][ ][ ][ ][ ][ ] E-mail address:........................................

❸ លេខហានិភ័យការងារ: [ ][ ][ ][ ] / [ ][ ] ប្រភេទគ្រោះថ្នាក់ : ❑ ធ្វើដំណើរ ❑ កន្លែងធ្វើការងារ ❑ ជំងឺវិជ្ជាជីវៈ

◉ ថ្ងៃខែឆ្នាំគ្រោះថ្នាក់ : [ ][ ] - [ ][ ] - [ ][ ] (ថ្ងៃ - ខែ - ឆ្នាំ) ម៉ោងគ្រោះថ្នាក់ : [ ][ ] [ ][ ] (ម៉ោង - នាទី)

◉ មូលហេតុគ្រោះថ្នាក់ : ......................................................................................................................................................

......................................................................................................................................................

◉ ចំនួនថ្ងៃសំរាកព្យាបាលក្នុងមន្ទីពេទ្យ :.............ថ្ងៃ ◉ ចាប់ពីថ្ងៃខែឆ្នាំសំរាកព្យាបាល : / /

◉ ចំនួនថ្ងៃសំរាកព្យាបាលនៅផ្ទះ :.............ថ្ងៃ ◉ ចាប់ពីថ្ងៃខែឆ្នាំសំរាកព្យាបាល : / /

❑ មិនអាចកំណត់ថ្ងៃខែចូលធ្វើការងារ ❑ អាចកំណត់ថ្ងៃខែចូលធ្វើការងារ ចាប់ពី : / /

**※ ព័ត៌មានលំអិតសំរាប់អ្នកតំណាងការទាមទារតាវកាលិកបាត់បង់សមត្ថភាពបណ្តោះអាសន្ន**

❹ គោត្តនាមនិង នាមអ្នកតំណាង : ........................................................ ភេទ : ថ្ងៃខែឆ្នាំកំណើត : / /

អាសយដ្ឋានអចិន្ត្រៃយ៍ :........... លេខផ្លូវ..........សង្កាត់(ឃុំ)...............ខណ្ឌ(ស្រុក)................ខេត្ត/ក្រុង..........................

លេខទូរស័ព្ទ : [ ][ ][ ][ ][ ][ ][ ][ ][ ] លេខទូរសារ: [ ][ ][ ][ ][ ][ ][ ][ ][ ] E-mail address:........................................

លេខអត្តសញ្ញាណប័ណ្ណ/លេខលិខិតឆ្លងដែន: .................................. ចុះថ្ងៃទី : / /

ខ្ញុំសូមសន្យាថារាល់ព័ត៌មានដែលបានផ្តល់ជូនខាងលើពិតជាត្រឹមត្រូវប្រាកដមែន ។

..................., ថ្ងៃទី ខែ ឆ្នាំ២០០

**ហត្ថលេខាអ្នកស្នើសុំ**

# តារាងកាលិកបាត់បង់សមត្ថភាពការងារ
# អចិន្ត្រៃយ៍

| សំរាប់មន្ត្រី ប.ស.ស |
|---|
| លេខតាវកាលិក : [ ][ ][ ][ ] / [ ][ ] |
| ហត្ថលេខា :......................... / / |

❶ នាមករណ៍សហគ្រាស : ...................................................................... លេខអត្តសញ្ញាណសហគ្រាស: [ ][ ][ ][ ][ ][ ][ ]

អាសយដ្ឋានសហគ្រាស :.......... លេខផ្លូវ..........សង្កាត់(ឃុំ)................ខណ្ឌ(ស្រុក)................ខេត្ត/ក្រុង.........................

លេខទូរស័ព្ទ : [ ][ ][ ][ ][ ][ ][ ][ ][ ] លេខទូរសារ: [ ][ ][ ][ ][ ][ ][ ][ ][ ] E-mail address:........................................

❷ គោត្តនាម និងនាមកម្មករនិយោជិត : ........................................................ លេខអត្តសញ្ញាណកម្មករនិយោជិត: [ ][ ][ ][ ][ ][ ][ ][ ]

អាសយដ្ឋានអចិន្ត្រៃយ៍ :.......... លេខផ្លូវ..........សង្កាត់(ឃុំ)................ខណ្ឌ(ស្រុក)................ខេត្ត/ក្រុង.........................

លេខទូរស័ព្ទ : [ ][ ][ ][ ][ ][ ][ ][ ][ ] លេខទូរសារ: [ ][ ][ ][ ][ ][ ][ ][ ][ ] E-mail address:........................................

❸ លេខហានិភ័យការងារ [ ][ ][ ][ ] / [ ][ ] ប្រភេទគ្រោះថ្នាក់ : ☐ ធ្វើដំណើរ ☐ កន្លែងធ្វើការងារ ☐ ជំងឺវិជ្ជាជីវៈ

៙ ថ្ងៃខែឆ្នាំគ្រោះថ្នាក់ : [ ][ ] - [ ][ ] - [ ][ ]          ម៉ោងគ្រោះថ្នាក់ : [ ][ ] : [ ][ ]

ថ្ងៃ - ខែ - ឆ្នាំ          ម៉ោង នាទី

៙ មូលហេតុគ្រោះថ្នាក់ : ..........................................................................................................................................

................................................................................................................................................................

៙ ភាគរយនៃការបាត់បង់សមត្ថភាពអចិន្ត្រៃយ៍ : ................%

៙ ថ្ងៃខែឆ្នាំពិនិត្យឡើងវិញ : / /

*** ព័ត៌មានលំអិតសំរាប់អ្នកតំណាងការងារតាមតារាងកាលិកបាត់បង់សមត្ថភាពអចិន្ត្រៃយ៍**

❹ គោត្តនាមនិង នាមអ្នកតំណាង : ........................................................ ភេទ : ថ្ងៃខែឆ្នាំកំណើត : / /

អាសយដ្ឋានអចិន្ត្រៃយ៍ :.......... លេខផ្លូវ..........សង្កាត់(ឃុំ)................ខណ្ឌ(ស្រុក)................ខេត្ត/ក្រុង.........................

លេខទូរស័ព្ទ : [ ][ ][ ][ ][ ][ ][ ][ ][ ] លេខទូរសារ: [ ][ ][ ][ ][ ][ ][ ][ ][ ] E-mail address:........................................

លេខអត្តសញ្ញាណប័ណ្ណ/លេខលិខិតឆ្លងដែន: .................................. ចុះថ្ងៃទី : / /

ខ្ញុំសូមសន្យាថារាល់ព័ត៌មានដែលបានផ្តល់ជូនខាងលើពិតជាត្រឹមត្រូវប្រាកដមែន ។ bika

...................., ថ្ងៃទី ខែ ឆ្នាំ២០០

**ហត្ថលេខាអ្នកស្នើសុំ**

**សំរាប់មន្ត្រី ប.ស.ស**

លេខតាវកាលិក : ☐☐☐☐ / ☐☐

ហត្ថលេខា :......................... / /

# តាវកាលិកឧត្តរជីវី

❸ គោត្តនាមនិង នាមកម្មករនិយោជិត : ....................................................... លេខអត្តសញ្ញាណកម្មករនិយោជិត: ☐☐☐☐☐☐☐☐

❹ អាសយដ្ឋានអចិន្ត្រៃយ៍ :........... លេខផ្លូវ..........សង្កាត់(ឃុំ) ................ខណ្ឌ(ស្រុក) .................ខេត្ត/ក្រុង.........................

លេខទូរស័ព្ទ : ☐☐☐☐☐☐☐☐☐ លេខទូរសារ: ☐☐☐☐☐☐☐☐☐ E-mail address:............................................

❺លេខហានិភ័យការងារ: ☐☐☐☐ ☐☐ ប្រភេទគ្រោះថ្នាក់ : ☐ ធ្វើដំណើរ ☐ កន្លែងធ្វើការងារ ☐ ជម្ងឺវិជ្ជាជីវៈ

◉ ថ្ងៃខែឆ្នាំគ្រោះថ្នាក់ : ☐☐ - ☐☐ - ☐☐ (ថ្ងៃ - ខែ - ឆ្នាំ)     ម៉ោងគ្រោះថ្នាក់ : ☐☐ : ☐☐ (ម៉ោង នាទី)

◉ មូលហេតុគ្រោះថ្នាក់ : ..........................................................................................................................

..........................................................................................................................................

◉ ថ្ងៃខែឆ្នាំទទួលមរណភាព : / /     ◉ លេខលិខិតមរណភាព :...................... ◉ ចុះថ្ងៃទី: / /

**✷ ព័ត៌មានលំអិតសំរាប់ឧត្តរជីវី :**

| ល.រ | គោត្តនាម និងនាមឧត្តរជីវី | លេខអត្តសញ្ញាណប័ណ្ណ | ភេទ | ថ្ងៃខែឆ្នាំកំណើត | ទំនាក់ទំនង |
|---|---|---|---|---|---|
| ១ | ...................................................... | ........................... | ........... | ........................... | ........................... |
| ២ | ...................................................... | ........................... | ........... | ........................... | ........................... |
| ៣ | ...................................................... | ........................... | ........... | ........................... | ........................... |
| ៤ | ...................................................... | ........................... | ........... | ........................... | ........................... |
| ៥ | ...................................................... | ........................... | ........... | ........................... | ........................... |

**※ ព័ត៌មានលំអិតសំរាប់អ្នកតំណាងការទាមទារតាវកាលិកឧត្តរជីវី**

❽ នាម និងគោត្តនាមអ្នកតំណាង : ....................................................... ភេទ :     ថ្ងៃខែឆ្នាំកំនើត : / /

អាសយដ្ឋានអចិន្ត្រៃយ៍ :........... លេខផ្លូវ..........សង្កាត់(ឃុំ) ................ខណ្ឌ(ស្រុក) .................ខេត្ត/ក្រុង.........................

លេខទូរស័ព្ទ : ☐☐☐☐☐☐☐☐☐ លេខទូរសារ: ☐☐☐☐☐☐☐☐☐ E-mail address:.........................................

លេខអត្តសញ្ញាណប័ណ្ណ/លេខលិខិតឆ្លងដែន: ................................. ចុះថ្ងៃទី : / /

ខ្ញុំសូមសន្យាថារាល់ព័ត៌មានដែលបានផ្តល់ជូនខាងលើពិតជាត្រឹមត្រូវប្រាកដមែន ។

...................., ថ្ងៃទី ខែ ឆ្នាំ២០០

**ហត្ថលេខាអ្នកស្នើសុំ**

# ទិតាជន័ទូជាសព

**សំរាប់មន្ត្រី ប.ស.ស**

លេខតាវកាលិក : ☐☐☐☐/☐☐

ហត្ថលេខា :........................ / /

❶ នាមករណ៍សហគ្រាស : ........................................................ លេខអត្តសញ្ញាណសហគ្រាស: ☐☐☐☐☐☐☐

❷ អាសយដ្ឋានសហគ្រាស :.......... លេខផ្លូវ..........សង្កាត់(ឃុំ)...............ខណ្ឌ(ស្រុក)...............ខេត្ត/ក្រុង........................

លេខទូរស័ព្ទ : ☐☐☐☐☐☐☐☐☐ លេខទូរសារ: ☐☐☐☐☐☐☐☐☐ E-mail address:....................................

❸ គោត្តនាម និងនាមកម្មករនិយោជិត : ........................................................ លេខអត្តសញ្ញាណកម្មករនិយោជិត: ☐☐☐☐☐☐☐☐

❹ អាសយដ្ឋានអចិន្ត្រៃយ៍ :.......... លេខផ្លូវ..........សង្កាត់(ឃុំ)...............ខណ្ឌ(ស្រុក)...............ខេត្ត/ក្រុង........................

លេខទូរស័ព្ទ : ☐☐☐☐☐☐☐☐☐ លេខទូរសារ: ☐☐☐☐☐☐☐☐☐ E-mail address:....................................

❺ លេខហានិភ័យការងារ: ☐☐☐☐/☐☐ ប្រភេទគ្រោះថ្នាក់ : ☐ ធ្វើដំណើរ ☐ កន្លែងធ្វើការងារ ☐ ជម្ងឺវិជ្ជាជីវៈ

⊙ ថ្ងៃខែឆ្នាំគ្រោះថ្នាក់ : ☐☐ - ☐☐ - ☐☐ (ថ្ងៃ - ខែ - ឆ្នាំ) ម៉ោងគ្រោះថ្នាក់ : ☐☐ : ☐☐ (ម៉ោង នាទី)

⊙ មូលហេតុគ្រោះថ្នាក់ : ..........................................................................................................

..........................................................................................................

⊙ ថ្ងៃខែឆ្នាំទទួលមរណភាព : / / ⊙ លេខលិខិតមរណភាព :.................... ⊙ ចុះថ្ងៃទី: / /

**※ ព័ត៌មានលំអិតសំរាប់អ្នកតំណាងការទទួលទិតាជន័ទូជាសព**

❻ នាម និងគោត្តនាមអ្នកតំណាង : ........................................................ ភេទ : ថ្ងៃខែឆ្នាំកំណើត : / /

អាសយដ្ឋានអចិន្ត្រៃយ៍ :.......... លេខផ្លូវ..........សង្កាត់(ឃុំ)...............ខណ្ឌ(ស្រុក)...............ខេត្ត/ក្រុង........................

លេខទូរស័ព្ទ : ☐☐☐☐☐☐☐☐☐ លេខទូរសារ: ☐☐☐☐☐☐☐☐☐ E-mail address:....................................

លេខអត្តសញ្ញាណប័ណ្ណ/លេខលិខិតឆ្លងដែន: ................................ ចុះថ្ងៃទី : / /

ខ្ញុំសូមសន្យាថារាល់ព័ត៌មានដែលបានផ្តល់ជូនខាងលើពិតជាត្រឹមត្រូវប្រាកដមែន ។

.........................., ថ្ងៃទី ខែ ឆ្នាំ២០០

**ហត្ថលេខាអ្នកស្នើសុំ**

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## <u>លិខិតបញ្ជូនជនរងគ្រោះដោយ</u>
## <u>គ្រោះថ្នាក់ការងារ</u>

I-<u>ព័ត៌មានសហគ្រាស-គ្រឹះស្ថាន</u>

ឈ្មោះសហគ្រាស គ្រឹះស្ថាន:..................................................................................................

សរសេរជាអក្សរឡាតាំង:..................................................................................................

លេខកូដសហគ្រាស គ្រឹះស្ថាន: ☐☐☐☐☐☐☐☐☐ អាសយដ្ឋាន:អគារលេខ:..........................................

ផ្លូវលេខ......................ភូមិ.....................ឃុំ/សង្កាត់....................................................................

ស្រុក/ខណ្ឌ.......................................ខេត្ត/ក្រុង..........................................................................

លេខទូរស័ព្ទលើតុ(Desk Telephone)..............................លេខទូរស័ព្ទដៃ(Hand Phone)...........................

លេខទូរសារ(Fax).........................សាររអេឡិចត្រូនិច(E-mail)...............................................................

II-<u>ព័ត៌មានកម្មករនិយោជិត(ជនរងគ្រោះ)</u>

ឈ្មោះជនរងគ្រោះ..........................................................ភេទ..................អាយុ...................ឆ្នាំ

លេខអត្តសញ្ញាណកម្មករនិយោជិត(លេខកូដផ្តល់ដោយ ប.ស.ស) ☐☐☐☐☐☐☐☐☐

ថ្ងៃខែឆ្នាំគ្រោះថ្នាក់: ថ្ងៃទី.................ខែ...............ឆ្នាំ................ម៉ោង.....................និង.......................នាទី

មូលហេតុគ្រោះថ្នាក់:..................................................................................................................

☐ គ្រោះថ្នាក់ពេលធ្វើដំណើរ ☐ គ្រោះថ្នាក់ពេលបំពេញការងារ ☐ ជំងឺវិជ្ជាជីវៈ

ធ្វើនៅ...............ថ្ងៃទី...........ខែ.............ឆ្នាំ២០.........

**ហត្ថលេខា និងត្រានិយោជក**
**ឬតំណាង**

*<u>កំណត់សំគាល់:</u>*

I-ព័ត៌មានសហគ្រាស គ្រឹះស្ថានបំពេញឱ្យហើយមុនគ្រោះថ្នាក់

-ហត្ថលេខា ឈ្មោះ និងត្រានិយោជក ឬតំណាងបំពេញមុនគ្រោះថ្នាក់

II-ព័ត៌មានកម្មករនិយោជិត បំពេញពេលគ្រោះថ្នាក់ ឬពេលជូនអ្នកជំងឺជនរងគ្រោះនៅមន្ទីរពេទ្យ

# ឯកសារជំនួយស្មារតីសំរាប់រោងចក្រ សហគ្រាស

## ១-ព័ត៌មានរោងចក្រ សហគ្រាស

- ឈ្មោះរោងចក្រ សហគ្រាស:.......................................................................................

ឈ្មោះជាអក្សរឡាតាំង:.......................................................................................

- លេខអត្តសញ្ញាណសហគ្រាស□□□□□□□□□
- អាសយដ្ឋានរោងចក្រសហគ្រាសអគារលេខ..............ផ្លូវ..................ភូមិ.................ឃុំ/សង្កាត់...........................

ស្រុក/ខណ្ឌ.................................. ខេត្ត/ក្រុង..............................ទូរស័ព្ទលើតុ/ដៃ....................................

## ២-ព័ត៌មានជនរងគ្រោះ

- មុខជំនាញជនរងគ្រោះ..................................................អតីតភាពការងារ........................................................
- ទីលំនៅអចិន្ត្រៃយ៍ ផ្ទះលេខ.............ផ្លូវលេខ................ភូមិ........................ឃុំ/សង្កាត់.....................................

ស្រុក/ខណ្ឌ.........................................ខេត្ត/ក្រុង................................................... ។

- ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ................ផ្លូវលេខ................ភូមិ........................ឃុំ/សង្កាត់.....................................

ស្រុក/ខណ្ឌ.........................................ខេត្ត/ក្រុង................................................... ។

- គ្រោះថ្នាក់នៅថ្ងៃទី............ខែ.........................ឆ្នាំ ២០......... វេលាម៉ោង..............និង............នាទី ។
- ប្រភេទនៃគ្រោះថ្នាក់: □ គ្រោះថ្នាក់នៅកន្លែងធ្វើការ □ គ្រោះថ្នាក់នៅពេលធ្វើដំណើរ □ ជម្ងឺវិជ្ជាជីវៈ

| ល.រ | អ្នកពាក់ពន្ធ័ហេតុការណ៍ | គោត្តនាម និងនាម | លេខអត្តសញ្ញាណកម្មករនិយោជិត | ភេទ | សញ្ជាតិ | ថ្ងៃខែឆ្នាំកំណើត | ទូរស័ព្ទ |
|---|---|---|---|---|---|---|---|
| ១ | ជនរងគ្រោះ | | | | | | |
| ២ | សាក្សី | | | | | | |
| ៣ | រដ្ឋបាល/តំណាងរោងចក្រ សហគ្រាស | | | | | | |
| ៤ | គ្រូពេទ្យប្រចាំរោងចក្រ សហគ្រាស | | | | | | |

**កំណត់ចំណាំ:** សូមភ្ជាប់តារាងបើកប្រាក់ឈ្នួលប្រចាំខែរបស់ជនរងគ្រោះ **៦ខែ**មុនពេលទទួលគ្រោះថ្នាក់ការងារ និងរបាយការណ៍ហានិភ័យការងារ( ទំរង់០៣.០១) ជាមួយឯកសារជំនួយស្មារតីនេះមកបេឡាជាតិរបបសន្តិសុខសង្គម ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិរបបសន្តិសុខសង្គម
លេខ ៖ ១១ /០៥ ប.ស.ស

# សេចក្តីជូនដំណឹង

បេឡាជាតិរបបសន្តិសុខសង្គមមានកិត្តិយសសូមជម្រាបដល់លោកឧកញ៉ា លោក លោកស្រី ឬ អ្នកតំណាងនៃសហគ្រាស គ្រឹះស្ថានទាំងអស់បានជ្រាបថា កន្លងមកមានសហគ្រាស គ្រឹះស្ថានមួយចំនួន បានបញ្ជូនកម្មករនិយោជិតដែលទទួលរងគ្រោះ ឬ មានជំងឺដូចជាជំងឺក្រពះ, គ្រួសក្នុងតម្រងនោម, គ្រួសក្នុងប្រមាត់, គ្រុនពោះវៀន, គ្រុនក្តៅ ជំងឺបេះដូង, ជំងឺស្រឹត, ជំងឺឆ្លងជ្រូក... ។ល។ ហើយមានអាការៈធ្ងន់ធ្ងរ បណ្តាលឱ្យអ្នកជំងឺឈឺចុកចាប់ខ្លាំង ឬសន្លប់នៅកន្លែងធ្វើការ ដែលករណីនេះមិនអាចចាត់ទុកជាគ្រោះថ្នាក់ការងារនោះទេ ប៉ុន្តែសហគ្រាស គ្រឹះស្ថានបានបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យ ដែលទទួលស្គាល់ ដោយ ប.ស.ស ដោយមិនបានទូទាត់សោហ៊ុយព្យាបាលសងមកប.ស.ស វិញទេ។

ក្នុងករណីដែលកម្មករនិយោជិតមានអាការៈឈឺចុកចាប់ខ្លាំង ឬសន្លប់នៅកន្លែងធ្វើការ ហើយលោកឧកញ៉ា លោក លោកស្រី ឬអ្នកតំណាងសហគ្រាស គ្រឹះស្ថានយល់ថា ករណីនេះជាគ្រោះថ្នាក់ការងារ ហើយបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យដែលទទួលស្គាល់ដោយប.ស.ស នោះ បន្ទាប់ពីប.ស.ស ធ្វើការអង្កេតឃើញថាជាជំងឺ ឬគ្រោះថ្នាក់មិនពាក់ព័ន្ធនឹងការងារទេនោះ ការចំណាយសោហ៊ុយព្យាបាលត្រូវស្ថិតនៅក្នុងបន្ទុកផ្ទាល់របស់លោកឧកញ៉ា លោក លោកស្រីជាម្ចាស់ ឬនាយកនៃសហគ្រាស គ្រឹះស្ថាន ហើយក្នុងករណីនេះ ប.ស.ស នឹងទាមទារការទូទាត់សងតាមថ្លៃជាក់ស្តែងរបស់មន្ទីរពេទ្យ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកឧកញ៉ា លោក លោកស្រី ឬអ្នកតំណាងនៃសហគ្រាស គ្រឹះស្ថានទាំងអស់មេត្តាជ្រាប និងអនុវត្តតាមសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែ កក្កដា ឆ្នាំ ២០០៥
អគ្គនាយកបេឡាជាតិរបបសន្តិសុខសង្គម

អ៊ុក_សមវិទ្យា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិរបបសន្តិសុខសង្គម

លេខ ៖ ...២៣/០៩.....ប.ស.ស

# សេចក្តីជូនដំណឹង

បេឡាជាតិរបបសន្តិសុខសង្គម មានកិត្តិយសសូមជម្រាបជូនកម្មករនិយោជិតដែលជាសមាជិកបេឡាជាតិរបបសន្តិសុខសង្គមមេត្តាជ្រាបថា កន្លងមកមានកម្មករនិយោជិតមួយចំនួនទទួល *រងគ្រោះថ្នាក់ការងាររហូតដល់បាត់បង់ជីវិត* ហើយឧត្តរជីវី *(អ្នកនៅក្នុងបន្ទុកផ្ទាល់ដែលជា ប្តី ឬ ប្រពន្ធ និងកូន)* មិនរពេចហានសិទ្ធិទទួលបានតាវកាលិក(អត្ថប្រយោជន៍)ឧត្តរជីវី ពីបេឡាជាតិរបបសន្តិសុខសង្គម។ ការមិនទទួលបាននេះ ដោយសារជនរងគ្រោះ*មិនមានសំបុត្រអាពាហ៍ពិពាហ៍* ដែលជាហេតុបណ្តាលឲ្យអ្នកនៅក្នុងបន្ទុកទាំងនោះពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមច្បាប់ដើម្បីទទួលបានតាវកាលិក(អត្ថប្រយោជន៍)។ ករណីបែបនេះ បេឡាជាតិរបបសន្តិសុខសង្គមមានការសោកស្តាយយ៉ាងខ្លាំង ដែលមិនអាចផ្តល់តាវកាលិកជូនដល់ក្រុមគ្រួសារជនរងគ្រោះដែល*គ្មានសំបុត្រអាពាហ៍ពិពាហ៍*បាន។

ដូចនេះ បេឡាជាតិរបបសន្តិសុខសង្គម សំណូមពរដល់បងប្អូន*កម្មករនិយោជិត ព្រមទាំងឧត្តរជីវី* (អ្នកនៅក្នុងបន្ទុកផ្ទាល់) របស់ខ្លួនទាំងអស់ ត្រូវមានឯកសារចាំបាច់ដូចខាងក្រោម៖

១. សំបុត្រអាពាហ៍ពិពាហ៍ (ចាំបាច់សម្រាប់អ្នកមានគូស្រករ)

២. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

៣. សំបុត្រកំណើត

ដើម្បីចៀសវាងការបាត់បង់ផលប្រយោជន៍ដ៏ច្រើននេះ បេឡាជាតិរបបសន្តិសុខសង្គមសូមរំពាវនាវ ដល់លោក លោកស្រី ជានិយោជក ឬ នាយក សហគ្រាស គ្រឹះស្ថានទាំងអស់ មេត្តាផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់កម្មករនិយោជិតរបស់ខ្លួន តាមគ្រប់លទ្ធភាពដែលអាចធ្វើបាន។

បេឡាជាតិរបបសន្តិសុខសង្គមមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រី និយោជក ឬ នាយកសហគ្រាស គ្រឹះស្ថាន ព្រមទាំងបងប្អូនកម្មករនិយោជិតទាំងអស់ចូលរួម សហការអនុវត្តសេចក្តីជូនដំណឹងនេះ ដើម្បីរួមចំណែកការពារសិទ្ធិស្របច្បាប់នៃអ្នកនៅក្នុងបន្ទុករបស់ជនរងគ្រោះ។

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៩

អគ្គនាយក

អ៊ុក សមវិទ្យា

អាសយដ្ឋាន៖អគារលេខ ៣ មហាវិថីសហព័ន្ធរុស្ស៊ី ទូរស័ព្ទ៖ ០២៣-៨៨ ២៥ ៣៤ . ០២៣ ៥៥ ៨៥ ១៧ ទូរសារ៖ ០២៣-៨៨-២៦-២៣ ប្រអប់សំបុត្រ P.O.Box 70

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ**
លេខ:...១៧៧...............កប/ប្រ.ក

# ប្រកាស

## ស្តីពីសមាសភាព និង ការប្រព្រឹត្តទៅរបស់គណៈកម្មការ ដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស

## ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម ០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ/បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- អនុលោមតាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម

# សម្រេច

**ប្រការ ១.-**

បង្កើតគណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ដើម្បីដោះស្រាយវិវាទ ឬ បណ្តឹងដែលទាក់ទងទៅនឹងការអនុវត្តបទប្បញ្ញត្តិ និង បទបញ្ញាខាងវិស័យសន្តិសុខសង្គម រវាងសមាជិក ប.ស.ស និយោជក និង បេឡាជាតិរបបសន្តិសុខសង្គម ។

**ប្រការ ២.-**

គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស មានភារកិច្ចផ្សះផ្សាវិវាទ ដែលទាក់ទងនឹងបេឡាជាតិរបបសន្តិសុខសង្គមដូចជា៖

- បណ្តឹងតវ៉ារបស់កម្មករនិយោជិតសមាជិក ប.ស.ស ទាក់ទងនឹងការមិនយល់ព្រម ឬ ភាពមិនត្រឹមត្រូវក្នុងការផ្តល់តាវកាលិករបបសន្តិសុខសង្គម
- បណ្តឹងតវ៉ារបស់កម្មករនិយោជិតសមាជិក ប.ស.ស ទាក់ទងនឹងភាពមិនប្រក្រតី នៃការផ្តល់សេវារបបសន្តិសុខសង្គម
- បណ្តឹងតវ៉ារបស់កម្មករនិយោជិតសមាជិកប.ស.សចំពោះការខកខានរបស់និយោជកមិនរាយការណ៍ដើម្បីចុះឈ្មោះខ្លួនក្នុង ប.ស.ស
- បណ្តឹងតវ៉ារបស់និយោជក ចំពោះការអនុវត្តមិនត្រឹមត្រូវតាមច្បាប់ ឬ បទបញ្ញាជាធរមានរបស់មន្ត្រី ប.ស.ស
- បណ្តឹងតវ៉ាផ្សេងទៀត ដែលទាក់ទងនឹងការអនុវត្តបេឡាជាតិរបបសន្តិសុខសង្គម ។

**ប្រការ ៣.-**

គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស មានសមាជិកពេញសិទ្ធិ បី រូប និង សមាជិកបម្រុង ប្រាំមួយ រូប ដូចខាងក្រោម៖

- មួយរូបពេញសិទ្ធិ និង ពីររូបបម្រុង ដែលស្នើដោយនាយកបេឡាជាតិរបបសន្តិសុខសង្គម
- មួយរូបពេញសិទ្ធិ និង ពីររូបបម្រុង ដែលស្នើដោយសមាជិកក្រុមប្រឹក្សាភិបាលតំណាងកម្មករនិយោជិត
- មួយរូបពេញសិទ្ធិ និង ពីររូបបម្រុង ដែលស្នើដោយសមាជិកក្រុមប្រឹក្សាភិបាលតំណាងនិយោជក (មួយរូបពេញសិទ្ធិដែលស្នើដោយនាយកបេឡាជាតិរបបសន្តិសុខសង្គម ជាប្រធានគណៈកម្មការ មួយរូបពេញសិទ្ធិ ដែលស្នើដោយសមាជិកក្រុមប្រឹក្សាភិបាលតំណាងកម្មករនិយោជិត ជាសមាជិក និង មួយរូបពេញសិទ្ធិ ដែលស្នើដោយសមាជិកក្រុមប្រឹក្សាភិបាលតំណាងនិយោជក ជាសមាជិក)

ក្នុងករណីដែលប្រធានគណៈកម្មការអវត្តមាន សមាជិកបម្រុង ដែលស្នើឡើងដោយនាយកបេឡាជាតិរបបសន្តិសុខសង្គម ត្រូវទទួលតួនាទីជាប្រធានស្តីទី

ក្នុងករណីដែលសមាជិកគណៈកម្មការ នៃភាគីណាមួយអវត្តមាន ប្រធានគណៈកម្មការ ឬ ប្រធានស្តីទី អាចអញ្ជើញសមាជិកបម្រុងដែលតំណាងឱ្យភាគីអវត្តមានចូលរួមប្រជុំ

គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬ ប្រធានស្តីទី។ ហើយគណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស មានអាណត្តិរយៈពេលមួយឆ្នាំ

ភាសារដែលត្រូវប្រើក្នុងដំណើរការរបស់គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស គឺភាសារខ្មែរ

ការប្រជុំរបស់គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ត្រូវធ្វើឡើងជាការសម្ងាត់

នីតិវិធីនៃការសម្រេចរបស់ គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ត្រូវចេញដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។

**ប្រការ ៤.-**

សមាជិកនៃគណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម ៖

- មានអាយុយ៉ាងតិច២៥ ឆ្នាំ
- មានការទទួលស្គាល់ អំពីលក្ខណៈសម្បត្តិផ្នែកសីលធម៌
- បទពិសោធន៍ពាក់ព័ន្ធនឹងការងារយ៉ាងតិច០៣ ឆ្នាំ
- បរិញ្ញាបត្រផ្នែកច្បាប់ ឬ មានគុណវឌ្ឍន៍ផ្នែកច្បាប់
- មានចំណេះដឹងអំពីច្បាប់ស្តីពីការងារ ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និង បទបញ្ជាផ្សេងៗទៀត ពាក់ព័ន្ធទៅនឹងវិស័យសន្តិសុខសង្គម ។

**ប្រការ ៥.-**

ប្រធានគណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ត្រូវកោះអញ្ជើញភាគីប្តឹងតវ៉ាមកបំភ្លឺ និង ផ្តល់ឯកសារ ឬ ព័ត៌មានចាំបាច់ផ្សេងៗ នៅចំពោះមុខគណៈកម្មការ ។

**ប្រការ ៦.-**

ភាគីប្តឹងតវ៉ា អាចបង្ហាញខ្លួន ចំពោះមុខគណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ដោយផ្ទាល់ខ្លួនដែលអាចមានអ្នកអម ឬ ដោយតំណាង ដែលទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីសាមីបណ្តឹង

*k*

ក្នុងករណីដែលកម្មករនិយោជិតណាម្នាក់ ត្រូវបានតំរូវអោយចូលរួមផ្សះផ្សាក្នុងម៉ោងធ្វើការ និយោជក ត្រូវតែអនុញ្ញាត បន្ទាប់ពីបានទទួលលិខិតកោះអញ្ជើញ ដោយមិនឲ្យទទួលផលប៉ះពាល់ជាអវិជ្ជមាន ដល់សិទ្ធិកម្មករនិយោជិតនោះឡើយ ។

**ប្រការ ៧.-**

ក្នុងករណីដែលភាគីប្តឹងតវ៉ា ខកខានមិនបានមកបង្ហាញខ្លួនតាមការអញ្ជើញ របស់គណៈកម្មការ ដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ដោយគ្មានមូលហេតុត្រឹមត្រូវ គណៈកម្មការអាចដំណើរការ របស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬ អាចបញ្ឈប់បណ្តឹងតវ៉ាតាមរយៈការចេញសេចក្តីសម្រេច ។

**ប្រការ ៨.-**

ក្នុងរយៈពេល១៥ ថ្ងៃធ្វើការ គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ត្រូវរាយការណ៍ អំពីសេចក្តីសម្រេចរបស់ខ្លួនជាលាយលក្ខណ៍អក្សរ ជូននាយកបេឡាជាតិរបបសន្តិសុខសង្គម។ នាយក បេឡាជាតិរបបសន្តិសុខសង្គម ត្រូវផ្តល់ដំណឹងទៅភាគីប្តឹងតវ៉ាភ្លាម អំពីសេចក្តីសម្រេចនោះដោយផ្ទាល់ ជូនភាគីប្តឹងតវ៉ានោះនូវច្បាប់ចម្លងសេចក្តីសម្រេច ដែលមានបញ្ជាក់ត្រឹមត្រូវចំនួន០១ ច្បាប់

នាយកបេឡាជាតិរបបសន្តិសុខសង្គម អាចមានសិទ្ធិជំទាស់ ឬ បដិសេធសេចក្តីសម្រេចរបស់ គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ក្នុងករណីដែលសេចក្តីសម្រេចនោះផ្ទុយនឹងច្បាប់ ឬ បទបញ្ញាជាធរមាន ហើយនាយក ប.ស.ស ត្រូវជូនដំណឹងទៅប្រធានគណៈកម្មការ ដើម្បីពិនិត្យករណី នេះសារជាថ្មី។

**ប្រការ ៩.-**

ភាគីប្តឹងតវ៉ាអាចជំទាស់ទៅនឹងសេចក្តីសម្រេចរបស់គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ដោយជូនព័ត៌មានជាលាយលក្ខណ៍អក្សរទៅនាយកបេឡាជាតិរបបសន្តិសុខសង្គម ក្នុងរយៈ ពេលប្រាំបីថ្ងៃធ្វើការ បន្ទាប់ពីបានទទួលសេចក្តីសម្រេច។ ក្នុងករណីនេះភាគីប្តឹងតវ៉ាអាចប្តឹងទៅតុលាការ មានសមត្ថកិច្ច ដើម្បីដោះស្រាយបន្ត ។

**ប្រការ ១០.-**

សេចក្តីសម្រេចរបស់គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ត្រូវយកជាបានការ ហើយភាគីប្តឹងតវ៉ាត្រូវអនុវត្តតាម ប្រសិនបើគ្មានការជំទាស់រយៈពេលប្រាំបីថ្ងៃធ្វើការ ។

**ប្រការ ១១.-**

ការចំណាយសម្រាប់ការរៀបចំការប្រជុំគណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ត្រូវនៅក្នុងបន្ទុករបស់ ប.ស.ស ។ លាភការរបស់គណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃ ប.ស.ស ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល នៃ ប.ស.ស ។

**ប្រការ ១២.-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែសីហា ឆ្នាំ២០១០

**រដ្ឋមន្ត្រី**

**ទទ សុត**

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទការល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទការល័យលោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ
- ក្រុមប្រឹក្សាភិបាល នៃ ប.ស.ស
  "ដើម្បីជូនជ្រាប"
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិរបបសន្តិសុខសង្គម
លេខ : ៣២៧/១១ ប.ស.ស

# សេចក្តីជូនដំណឹង

បេឡាជាតិរបបសន្តិសុខសង្គម "ប.ស.ស" ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានបេសកកម្មបម្រើសេវាសាធារណៈមានលក្ខណៈសង្គម មានកិត្តិយសសូមជម្រាប ម្ចាស់ នាយក ឬតំណាង សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតទាំងអស់ឲ្យបានជ្រាបថា ប.ស.ស បានបង្កើតលេខទូរស័ព្ទទំនាក់ទំនងបន្ទាន់ (Hotline) ២៤ ម៉ោង ដែលមានលេខទំនាក់ទំនង ១២៨៦ ដែលអាចហៅចូលបានគ្រប់ប្រព័ន្ធ សម្រាប់ផ្តល់សេវាសង្គ្រោះបន្ទាន់ដល់កម្មករនិយោជិត ដែលជាសមាជិក ប.ស.ស ទទួលរងនូវគ្រោះថ្នាក់ការងារ ។

ដើម្បីបម្រើផលប្រយោជន៍បងប្អូនកម្មករនិយោជិត ជាសមាជិក ប.ស.ស សូមលោក លោកស្រីម្ចាស់ នាយក ឬតំណាង សហគ្រាស គ្រឹះស្ថាន មេត្តាជួយផ្សព្វផ្សាយលេខទូរស័ព្ទទំនាក់ទំនងបន្ទាន់ (Hotline) ២៤ ម៉ោង ដែលមានលេខ ១២៨៦ ។

បេឡាជាតិរបបសន្តិសុខសង្គម សង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រីម្ចាស់ នាយក ឬតំណាង សហគ្រាស គ្រឹះស្ថាននឹងចូលរួមផ្សព្វផ្សាយតាមស្មារតីនៃសេចក្តីជូនដំណឹងនេះជាក់ជាពុំខាន ។

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែ សីហា ឆ្នាំ ២០១១

នាយក

អ៊ុក សមវិទ្យា

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ : ......................១០៧......................ក.ប/ប្រ.ក

# ប្រកាស
# ស្តីពី
# ការតែងតាំងសមាសភាព
# គណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹង នៃប.ស.ស

## ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម ០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ/បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- ប្រកាសលេខ ១៧៧ កប/ប្រ.ក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០ស្តីពីសមាសភាព និងការប្រព្រឹត្តទៅរបស់គណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹង នៃប.ស.ស
- យោងលិខិតលេខ ០០១/០៩/២០១៣-CAMFEBA ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៣ របស់សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា
- យោងលិខិតលេខ ១៩៦ សកក/១៣ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣ របស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ ១**.- ត្រូវបានទទួលស្គាល់សមាសភាពគណៈកម្មការដោះស្រាយវិវាទ ឬ បណ្តឹង នៃប.ស.ស ចំនួន ០៩ រូប សម្រាប់អាណត្តិទី៣ ដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| ១- លោក ម៉េង ហុង | តំណាងបេឡាជាតិរបបសន្តិសុខសង្គម | ប្រធាន |
| ២- លោក កាំង ម៉ូនីកា | តំណាងនិយោជក | សមាជិក |
| ៣- លោក ជួន មុំថុល | តំណាងកម្មករនិយោជិត | សមាជិក |
| ៤- លោក ជាវ ប៊ុនរិទ្ធ | តំណាងបេឡាជាតិរបបសន្តិសុខសង្គម | សមាជិកបំរុង |
| ៥- លោក សុក បូរ៉ា | តំណាងបេឡាជាតិរបបសន្តិសុខសង្គម | សមាជិកបំរុង |
| ៦- លោក ហួន សុខភានាថ | តំណាងនិយោជក | សមាជិកបំរុង |
| ៧- លោក ជាតិ ខេមរា | តំណាងនិយោជក | សមាជិកបំរុង |
| ៨- លោក សោម អូន | តំណាងកម្មករនិយោជិត | សមាជិកបំរុង |
| ៩- លោក ឯក សុភក្តី | តំណាងកម្មករនិយោជិត | សមាជិកបំរុង |

**ប្រការ ២**.- ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ក្រុមប្រឹក្សាភិបាល នៃប.ស.ស
  "ដើម្បីជូនជ្រាប"
- សាមីខ្លួន
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
លេខ :..........២២០..........ក.ប/ប្រ.ក

# ប្រកាស
# ស្តីពី
# ការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទាន សម្រាប់ផ្នែកថែទាំសុខភាព

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម ០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២៤៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- យោងលិខិតលេខ ៤៣៣៧ សហវ-អឧហ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាល នៃបេឡាជាតិរបបសន្តិសុខសង្គម

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះកំណត់អំពីអត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់ផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

**ប្រការ ២.-**

វាក្យស័ព្ទសំខាន់ៗដែលប្រើនៅក្នុងប្រកាសនេះមានដូចតទៅៈ

- **ថែទាំសុខភាព** សំដៅដល់ការធានារ៉ាប់រងសុខភាពសង្គមដែលត្រូវផ្តល់តាវកាលិកសេវាបង្ការសុខភាព តាវកាលិកព្យាបាល និងថែទាំវេជ្ជសាស្ត្រ និងការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលនៃការផ្អាកការងារដោយការព្យាបាលជំងឺ ឬ គ្រោះថ្នាក់ផ្សេងៗក្រៅពីហានិភ័យការងារ និងការសម្រាកមាតុភាព។
- **តាវកាលិក** សំដៅដល់ការផ្តល់សេវាបង្ការសុខភាព សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ ការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃនៅពេលសម្រាកព្យាបាលជំងឺ ឬ គ្រោះថ្នាក់ផ្សេងៗក្រៅពីហានិភ័យការងារ និងមាតុភាព។
- **សហព័ទ្ធ** សំដៅដល់ប្រពន្ធ ឬ ប្តីដែលនៅមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់។
- **ឧត្តរជីវី** សំដៅដល់អ្នកនៅរស់មានជីវិតជាប្រពន្ធ ឬប្តី និងកូននៅក្នុងបន្ទុកផ្ទាល់នៃសាមីជនដែលជាសមាជិក ប.ស.ស ក្រោយពីទទួលមរណៈភាពដោយហានិភ័យការងារ។
- **ជនពិការ** សំដៅដល់ប្រាក់ឧបត្ថម្ភដល់ជនបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ ដោយសារហានិភ័យការងារចាប់ពី ២០% ឡើងទៅ។

**ប្រការ ៣.-**

អត្រាភាគទានផ្នែកថែទាំសុខភាពជាបន្ទុករបស់និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវកំណត់ស្មើនឹង ១,៣ (មួយក្បៀសបី) ភាគរយ នៃប្រាក់ឈ្នួលមធ្យមក្នុងលំដាប់ថ្នាក់ នៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិត។

អត្រាភាគទានផ្នែកថែទាំសុខភាព ជាបន្ទុករបស់កម្មករនិយោជិត ត្រូវកំណត់ស្មើនឹង ១,៣ (មួយក្បៀសបី) ភាគរយ នៃប្រាក់ឈ្នួលមធ្យមក្នុងលំដាប់ថ្នាក់នៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិត។

ចំពោះអត្រាភាគទានដែលជាបន្ទុករបស់ឧត្តរជីវី ឬជនកំពុងទទួលបានប្រាក់ធនលាភ ត្រូវកំណត់ស្មើនឹង ១,៣ (មួយក្បៀសបី) ភាគរយនៃតាវកាលិករបស់សាមីខ្លួន។

ប្រាក់ឈ្នួលមធ្យមប្រចាំខែក្នុងលំដាប់ថ្នាក់នៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិត សម្រាប់ផ្នែកថែទាំសុខភាព ត្រូវបានកំណត់ដូចគ្នានឹងប្រាក់ឈ្នួលមធ្យមក្នុងលំដាប់ថ្នាក់នៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិតសម្រាប់ ផ្នែកហានិភ័យការងារ។ ប្រាក់ឈ្នួលមធ្យមក្នុងលំដាប់ថ្នាក់នៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិត មានកំណត់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

ក្នុងករណីដែលសហគ្រាស គ្រឹះស្ថាន បើកប្រាក់ឈ្នួលជារូបិយប័ណ្ណបរទេសប្រាក់ឈ្នួលមធ្យមប្រចាំខែខាងលើត្រូវគិតជាប្រាក់រៀលតាមអត្រាប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជា។

**ប្រការ ៤**.-

និយោជក និងកម្មករនិយោជិត ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវមានកាតព្វកិច្ចបង់ភាគទានផ្នែកថែទាំសុខភាពជូនដល់ ប.ស.ស។

បន្ទាប់ពីបានចុះបញ្ជិកាផ្នែកថែទាំសុខភាពក្នុងបេឡាជាតិរបបសន្តិសុខសង្គម និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ត្រូវមានកាតព្វកិច្ចប្រមូលភាគទាន និងបង់ភាគទានផ្នែកថែទាំសុខភាពជូនដល់បេឡាជាតិរបបសន្តិសុខសង្គម។

ឧត្តរជីវី ឬ ជនកំពុងទទួលធនលាភដោយការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ មានកាតព្វកិច្ចបង់ភាគទានផ្នែកថែទាំសុខភាពនេះផងដែរ។

អត្រាភាគទានផ្នែកថែទាំសុខភាព អាចត្រូវកំណត់ជាថ្មីដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើពីក្រុមប្រឹក្សាភិបាល នៃប.ស.ស។

**ប្រការ ៥**.-

និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវបង់ភាគទានផ្នែកថែទាំសុខភាពសម្រាប់ខែនីមួយៗយ៉ាងយូរបំផុតត្រឹមថ្ងៃទី១៥ នៃខែបន្ទាប់។

និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវមានកាតព្វកិច្ចប្រមូលភាគទានផ្នែកនេះពីកម្មករនិយោជិត ដោយកាត់ប្រាក់ឈ្នួលតាមចំនួនភាគទានជាក់ស្តែងដែលសាមីជនម្នាក់ៗត្រូវបង់។

**ប្រការ ៦**.-

បែបបទនៃការបង់ភាគទានសម្រាប់ផ្នែកថែទាំសុខភាព ត្រូវអនុវត្តតាមទម្រង់នៃការបង់ភាគទានដែលកំណត់ដោយបេឡាជាតិរបបសន្តិសុខសង្គម។

**ប្រការ ៧.-**

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវផ្តល់សៀវភៅបើកប្រាក់ (តារាងបើកប្រាក់បៀវត្សតាមខែនីមួយៗ) បញ្ជីឈ្មោះកម្មករនិយោជិត និងឯកសារពាក់ព័ន្ធផ្សេងៗជូន ប.ស.ស ដើម្បីពិនិត្យនៅពេលចាំបាច់។

**ប្រការ ៨.-**

ការចាប់ផ្តើមបង់ភាគទានដំបូងសម្រាប់ផ្នែកថែទាំសុខភាព ចំពោះសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកា ត្រូវកំណត់ដោយ ប.ស.ស។

ការចាប់ផ្តើមបង់ភាគទានដំបូង សម្រាប់ឧត្តរជីវី ឬ អ្នកកំពុងទទួលបានធនលាភ ត្រូវកំណត់ដោយ ប.ស.ស។

ចំពោះកម្មករនិយោជិតដែលធ្វើការពីរកន្លែង ឬ ច្រើនកន្លែង ហើយបានបង់ភាគទាននូវចំណែករបស់សាមីជនដែលលើសចំនួនកំណត់ដូចមានចែងក្នុងប្រកាសនេះ ប.ស.ស ត្រូវបង្វិលជូនសាមីជនវិញនៅរៀងរាល់ដំណាច់ឆ្នាំចំពោះចំណែកដែលលើសនេះ។

**ប្រការ ៩.-**

អ្នកប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវទទួលទោសតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ។

**ប្រការ ១០.-**

នាយកបេឡាជាតិរបបសន្តិសុខសង្គម និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន កម្មករនិយោជិត និងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

<u>កន្លែងទទួល</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- គ្រប់ក្រសួងពាក់ព័ន្ធ
- សាលារាជធានី-ខេត្ត

"ដើម្បីជូនជ្រាប"

- គ្រប់អង្គភាពក្រោមឱវាទក្រសួង "ដើម្បីអនុវត្ត"
- សមាគមនិយោជក និងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា
- គ្រប់សហព័ន្ធសហជីព

"ដើម្បីផ្សព្វផ្សាយ"

- គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីផ្សព្វផ្សាយ"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

*ឧបសម្ព័ន្ធនៃប្រកាសលេខ ២២០ កប/ប្រក*
*ស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទានសម្រាប់ផ្នែកថែទាំសុខភាព*

## តារាងភាគទានផ្នែកថែទាំសុខភាព

| ថ្នាក់ | ប្រាក់ឈ្នួលប្រចាំខែ (គិតជារៀល) | ប្រាក់ឈ្នួលមធ្យមប្រចាំខែ (គិតជារៀល) | ភាគទានជាបន្ទុកកម្មករនិយោជិក ១ នាក់ (១,៣%) | ភាគទានជាបន្ទុកនិយោជកសម្រាប់កម្មករនិយោជិត ១ នាក់ (១,៣%) | ភាគទានសរុប |
|---|---|---|---|---|---|
| ១ | តិចជាង ២០០.០០០ | ២០០.០០០ | ២.៦០០ | ២.៦០០ | ៥.២០០ |
| ២ | ២០០.០០១- ២៥០.០០០ | ២២៥.០០០ | ២.៩២៥ | ២.៩២៥ | ៥.៨៥០ |
| ៣ | ២៥០.០០១ -៣០០.០០០ | ២៧៥.០០០ | ៣.៥៧៥ | ៣.៥៧៥ | ៧.១៥០ |
| ៤ | ៣០០.០០១ -៣៥០.០០០ | ៣២៥.០០០ | ៤.២២៥ | ៤.២២៥ | ៨.៤៥០ |
| ៥ | ៣៥០.០០១ -៤០០.០០០ | ៣៧៥.០០០ | ៤.៨៧៥ | ៤.៨៧៥ | ៩.៧៥០ |
| ៦ | ៤០០.០០១ -៤៥០.០០១ | ៤២៥.០០០ | ៥.៥២៥ | ៥.៥២៥ | ១១.០៥០ |
| ៧ | ៤៥០.០០១ -៥០០.០០០ | ៤៧៥.០០០ | ៦.១៧៥ | ៦.១៧៥ | ១២.៣៥០ |
| ៨ | ៥០០.០០១ -៥៥០.០០០ | ៥២៥.០០០ | ៦.៨២៥ | ៦.៨២៥ | ១៣.៦៥០ |
| ៩ | ៥៥០.០០១ -៦០០.០០០ | ៥៧៥.០០០ | ៧.៤៧៥ | ៧.៤៧៥ | ១៤.៩៥០ |
| ១០ | ៦០០.០០១ -៦៥០.០០០ | ៦២៥.០០០ | ៨.១២៥ | ៨.១២៥ | ១៦.២៥០ |
| ១១ | ៦៥០.០០១ -៧០០.០០០ | ៦៧៥.០០០ | ៨.៧៧៥ | ៨.៧៧៥ | ១៧.៥៥០ |
| ១២ | ៧០០.០០១ -៧៥០.០០០ | ៧២៥.០០០ | ៩.៤២៥ | ៩.៤២៥ | ១៨.៨៥០ |
| ១៣ | ៧៥០.០០១ -៨០០.០០០ | ៧៧៥.០០០ | ១០.០៧៥ | ១០.០៧៥ | ២០.១៥០ |
| ១៤ | ៨០០.០០១ -៨៥០.០០០ | ៨២៥.០០០ | ១០.៧២៥ | ១០.៧២៥ | ២១.៤៥០ |
| ១៥ | ៨៥០.០០១ -៩០០.០០០ | ៨៧៥.០០០ | ១១.៣៧៥ | ១១.៣៧៥ | ២២.៧៥០ |
| ១៦ | ៩០០.០០១- ៩៥០.០០០ | ៩២៥.០០០ | ១២.០២៥ | ១២.០២៥ | ២៤.០៥០ |
| ១៧ | ៩៥០.០០១ -១.០០០.០០០ | ៩៧៥.០០០ | ១២.៦៧៥ | ១២.៦៧៥ | ២៥.៣៥០ |
| ១៨ | ១.០០០.០០១ ឡើង | ១.០០០.០០០ | ១៣.០០០ | ១៣.០០០ | ២៦.០០០ |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ: ២៣៨ ក.ប/ប្រ.ក

# ប្រកាស
# ស្តីពី
# ការកំណត់បញ្ជីជំងឺវិជ្ជាជីវៈនៅក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញប្រកាសលេខ ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ស្តីពីតារាងកាលិកថែទាំសុខភាព
- យោងស្មារតីកិច្ចប្រជុំក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម លើកទី៣៣ អាណត្តិទី៣ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់បញ្ជីជំងឺរ៉ាំរ៉ៃនៅក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

**ប្រការ ២.-**

ប្រភេទជំងឺរ៉ាំរ៉ៃ ដែលត្រូវកំណត់ក្នុងប្រកាសនេះមានដូចខាងក្រោម៖

១. ជំងឺខ្សោយបេះដូង (Cardiac Failure)

២. ជំងឺសាច់ដុំបេះដូង (Cardiomyopathy)

៣. ជំងឺរលាកថ្លើមប្រភេទបេរ៉ាំរ៉ៃ (Chronic Hepatitis B)

៤. ជំងឺរលាកថ្លើមប្រភេទសេរ៉ាំរ៉ៃ (Chronic Hepatitis C)

៥. ជំងឺតំរងនោមរ៉ាំរ៉ៃ (Chronic renal disease)

៦. ជំងឺក្រិនថ្លើម (Cirrhosis of the liver)

៧. ជំងឺសរសៃឈាមក្រហមបេះដូង (Coronary Artery Disease)

៨. ជំងឺទឹកនោមផ្អែមប្រភេទទី១ និងទី២ (Diabetes Mellitus Type 1 & 2)

៩. ជំងឺវិបត្តិចង្វាក់បេះដូង (Dysrhythmias)

១០. ជំងឺក្រិនសរីរាង្គ (Multiple Sclerosis)

១១. ជំងឺវិកលចរិត (Schizophrenia)

១២. ជំងឺលុយពុស (Systemic Lupus Erythematosus)

១៣. ជំងឺលើសឈាម (Hypertension)

១៤. ជំងឺតាឡាសស៊ីមី (Thalassemia)

**ប្រការ ៣.-**

បេឡាជាតិរបបសន្តិសុខសង្គម ត្រូវទទួលបន្ទុកផ្តល់សេវាជំងឺពុំរ៉ៃដូចមានចែងក្នុងប្រការ ២ នៃប្រកាសនេះ តាមការកំណត់ក្នុងប្រការ ៥ នៃប្រកាសលេខ ១០៩ កប/ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ស្តីពីតាវកាលិកថែទាំសុខភាព។

**ប្រការ ៤.-**

ការកែសម្រួលបញ្ជីជំងឺពុំរ៉ៃដូចមានចែងក្នុងប្រការ២ នៃប្រកាសនេះ នឹងត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ ៥.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៦.-**

បេឡាជាតិរបបសន្តិសុខសង្គម កម្មករនិយោជិត និយោជក និងមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

__កន្លែងទទួល:__

- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- -ក្រសួងសុខាភិបាល
- -អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- -បេឡាជាតិរបបសន្តិសុខសង្គម "ដើម្បីអនុវត្ត"
- -សាលារាជធានី ខេត្ត
- -កាលប្បវត្តិ-ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :...............១៦៥...............ក.ប/ស.ជ.ណ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការចុះបញ្ជិកាកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបដល់ ម្ចាស់ នាយក សហគ្រាស គ្រឹះស្ថាន ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារថា ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៨ សំដៅដល់ការអភិវឌ្ឍរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ជាពិសេសការរៀបចំ និងដាក់ឲ្យដំណើរការរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងផ្នែកសោធន ក្រសួងតម្រូវឲ្យចុះបញ្ជិកាកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គមឡើងវិញ។

កន្លងមកក្រសួងសង្កេតឃើញថា មានបញ្ហាប្រឈមមួយចំនួន អំពីអត្តសញ្ញាណរបស់កម្មករនិយោជិត ដូចជា ការខ្ចីឈ្មោះអ្នកដទៃប្រើ, ការខុសឈ្មោះ, ការខុសភេទ, ការខុសថ្ងៃខែឆ្នាំកំណើត, ការខុសទីកន្លែងកំណើតជាដើម ដែលអាចបង្ករឲ្យលេចចេញនូវបាតុភាពមិនប្រក្រតីនានា ធ្វើឲ្យភាគីពាក់ព័ន្ធជាពិសេស និយោជក និងកម្មករនិយោជិត មានការព្រួយបារម្ភចំពោះផលប៉ះពាល់តាមផ្លូវច្បាប់នានា ទាក់ទងនឹងការក្លែងឯកសារ, ការបាត់បង់អតីតភាពការងារ, ការបង់ថ្លៃសេវាពិនិត្យកាយសម្បទា, បណ្ណការងារ, សៀវភៅការងារ, បញ្ជិកាអង្គការវិជ្ជាជីវៈ ការបណ្តេញចេញពីការងារ ការចោទប្រកាន់ចំពោះការប្រើប្រាស់ពលកម្មកុមារ។

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ និងចៀសវាងនូវរាល់បាតុភាពជាយថាហេតុ ម្ចាស់ នាយក សហគ្រាស គ្រឹះស្ថាន អង្គការវិជ្ជាជីវៈ កម្មករនិយោជិត និងអង្គភាពដែលពាក់ព័ន្ធត្រូវអនុវត្តដូចខាងក្រោម៖

១.មិនត្រូវចាត់ទុកជាកំហុស ចំពោះគ្រប់រូបភាពមិនប្រក្រតីខាងលើរបស់កម្មករនិយោជិត។

២.នៅពេលចុះបញ្ជិកាឡើងវិញ កម្មករនិយោជិតដែលមានបញ្ហាដូចខាងលើ ត្រូវបានរក្សានូវសិទ្ធិ និងអត្ថប្រយោជន៍ផ្សេងៗ ដូចជា អតីតភាពការងារ តួនាទីក្នុងអង្គការវិជ្ជាជីវៈ និងកិច្ចសន្យាការងារ។/

៣.និយោជក មិនត្រូវទទួលបានការចោទប្រកាន់ថាប្រើប្រាស់ពលកម្មកុមារ ចំពោះករណីដែលកម្មករនិយោជិតប្រើអត្តសញ្ញាណខុសប្រក្រតីនេះទេ។

៤.កម្មករនិយោជិត ដែលទទួលបានការធ្វើនិយ័តកម្មអត្តសញ្ញាណឲ្យបានត្រឹមត្រូវឡើងវិញ មិនតម្រូវឲ្យមានការបង់ថ្លៃសេវាពិនិត្យកាយសម្បទា, បណ្ណការងារ សៀវភៅការងារ និងបញ្ជិកាអង្គការវិជ្ជាជីវៈ ចំពោះរាល់ការធ្វើនិយ័តកម្មឯកសារនេះឡើងវិញ។

៥.ក្នុងការជ្រើសរើសកម្មករនិយោជិតថ្មី សហគ្រាស គ្រឹះស្ថានចាំបាច់ត្រូវទាមទារឯកសារបញ្ជាក់អត្តសញ្ញាណរបស់សាមីខ្លួន ដូចជា អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ សេចក្តីចម្លងសំបុត្រកំណើត ឬលិខិតឆ្លងដែន ឲ្យបានត្រឹមត្រូវ។

នៅក្នុងដំណើរការនៃការចុះបញ្ជិកាឡើងវិញ កម្មករនិយោជិត ត្រូវបំពេញសលាកបត្រព័ត៌មាន និងមានឯកសារផ្ទាល់ខ្លួនសំខាន់ៗ រួមមាន អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន សេចក្តីចម្លងសំបុត្រកំណើត សៀវភៅគ្រួសារ និងសៀវភៅស្នាក់នៅ ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ នាយកសហគ្រាស គ្រឹះស្ថាន អង្គការវិជ្ជាជីវៈ កម្មករនិយោជិត និងអង្គភាពពាក់ព័ន្ធនឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិរបបសន្តិសុខសង្គម

លេខ : ...១០/១៤.......ប.ស.ស

# សេចក្តីជូនដំណឹង
# ស្តីពីនីតិវិធីនៃការបង់ភាគទាន

បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សូមជូនដំណឹងចំពោះគ្រប់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលបានចុះបញ្ជិកាក្នុងបេឡាជាតិរបបសន្តិសុខសង្គមឲ្យបានជ្រាបថា ដើម្បីសម្រួលដល់ដំណើរការនៃការបង់ភាគទាន ប.ស.ស សូមធ្វើការណែនាំដូចខាងក្រោម ៖

និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវបង់ភាគទានចូលទៅក្នុងគណនីបេឡាជាតិរបបសន្តិសុខសង្គម ដែលស្ថិតនៅក្នុងធនាគារដែលបានកំណត់ ។ ការបង់ភាគទានអាចត្រូវបានអនុវត្តតាមរបៀបដូចខាងក្រោម ៖

១- និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន អាចបង់ផ្ទាល់នៅធនាគារដូចមុនដដែល ឬ

២- និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន អាចបង់តាមរយៈសេវាកម្មអ៊ិនធើណែតប៊ែងឃីង (Internet Banking) ឬ សេវាកម្មយូនីធី (Unity) ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០១៥ តទៅ ។ រាល់ការចំណាយសេវាកម្មនេះជាបន្ទុកផ្ទាល់របស់និយោជក ។

៣- ចំពោះបង្កាន់ដៃបង់ភាគទាន របាយការណ៍ចំនួនកម្មករនិយោជិត របាយការណ៍ប្រាក់ឈ្នួល ឬ ឯកសារចាំបាច់នានា និយោជក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវយកមកដាក់ដោយផ្ទាល់នៅការិយាល័យ ប.ស.ស ឬ ផ្ញើតាមប៉ុស្តិ៍ប្រៃសណីយ៍ ឬ ផ្ញើតាមសារអេឡិចត្រូនិច contribution@nssf.gov.kh ។

***បញ្ជាក់ ៖***

ចំពោះលោក-លោកស្រីនាយក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន ដែលបានបង់ភាគទានរួចហើយ ផ្ញើរបាយការណ៍កម្មករនិយោជិតតាមរយៈសារអេឡិចត្រូនិច ត្រូវមានឯកសារដូចជា ៖

- របាយការណ៍កម្មករនិយោជិត (ទម្រង់អេឡិចត្រូនិច E-Form)
- លិខិតប្រកាសបង់ភាគទានហានិភ័យការងារ
- លិខិតបញ្ជាក់ពីនិយោជក (Form B)
- តារាងបើកប្រាក់បៀវត្សរកម្មករ និយោជិត (ទម្រង់អេឡិចត្រូនិច Payroll)

បេឡាជាតិរបបសន្តិសុខសង្គមសង្ឃឹមយ៉ាងមុតមាំថា លោក-លោកស្រីនាយក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន ទាំងអស់ នឹងចូលរួមអនុវត្តតាមសេចក្តីជូនដំណឹងនេះដាក់ជាពុំខាន ។ Vuth

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ២០១៤



អាសយដ្ឋានអគារលេខ ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ: ០២៣-៨៨ ២៤ ៣៤ , ០២៣ ៩៩ ៨៤ ១៧ ០២៣-៩៩ ៨៤ ១៨ , ០២៣ ៩៩ ៨៤ ១៩
ទូរសារ : ០២៣ ៨៨ ២៦ ២៣ , ប្រអប់សំបុត្រ P.O.Box 70
Website : www.nssf.gov.kh

# របៀបបង់ភាគទានសម្រាប់ បេឡាជាតិរបបសន្តិសុខសង្គម ( បសស ) តាមរយៈសេវាអេស៊ីលីដាយូនីធី

# How to pay NSSF contribution via ACLEDA Unity

**1** ជាដំបូងសូមលោកអ្នកចុចលើ "Log On" ដើម្បីចូលទៅប្រើប្រាស់សេវាអេស៊ីលីដាយូនីធី ។
First, please log in ACLEDA Unity.




**2** សូមបញ្ចូលលេខសម្ងាត់ រួចចុច "Enter" ។
Enter your PIN and then click on "Enter".




**3** សូមចុចលើ "Bill Payment" ។
Please select "Bill Payment".




**4** សូមចុច "Make Bill Payment" ។
Please select "Make Bill Payment".




**5** សូមចុច "NSSF" ។
Please select "NSSF".




**6** សូមជ្រើសរើសគណនីណាមួយដែលត្រូវកាត់ប្រាក់ចេញ។
Please select the account to be debited.




**7** សូមចុច "Create New Consumer Number" ដើម្បីបង្កើតលេខវិក្កយបត្រថ្មី ។
Please click on "Create New Consumer Number" to create new number of bill payment.




**8** សូមបញ្ចូលលេខអត្តសញ្ញាណសហគ្រាសដែលមាននៅលើវិក្កយបត្រ ទៅក្នុងប្រអប់ Consumer Number រួចចុច "NEXT" ។
Please enter the organization or company ID Number into the box Consumer Number, then press "NEXT".




**9** សូមបញ្ចូលចំនួនទឹកប្រាក់ត្រូវបង់ជាប្រាក់រៀល រួចចុច "NEXT" ។
Please enter the amount of your contribution, then press "NEXT".




**10** សូមផ្ទៀងផ្ទាត់ព័ត៌មានបង់ប្រាក់លម្អិត រួចចុច "YES" ។
Please verifiy the payment detials then press "YES".




**11** ខាងក្រោមជារបាយការណ៍បញ្ជាក់ពីការបង់ភាគទានសម្រាប់បេឡាជាតិរបបសន្តិសុខសង្គមបានជោគជ័យ ។
Your payment has been processed successfully.



# របៀបបង់ភាគទានសម្រាប់បេឡាជាតិរបបសន្តិសុខសង្គម (បសស)

ACLEDA Bank Internet

## User Manual of NSSF Contribution Payment via ACLEDA Internet Bank

## សម្រាប់ RIB

• របៀបបង់ភាគទាន / **How to make contribution payment**

▸ សូមចូលទៅកាន់វេបសាយធនាគារ អេស៊ីលីដា តាមរយៈ "www.acledabank.com.kh" ជ្រើសរើស "Retail Customer" រួចចុចប៊ូតុង "Login" ។
Please go to ACLEDA Website "www.acledabank.com.kh", select "Retail Customer", then click on "Login".



1

លោកអ្នកអាចជ្រើសរើសភាសាខ្មែរ - អង់គ្លេស ឬ ចិន តាមតម្រូវការ / You can select languages as Khmer, English or Chinese of your choice.

សូមបញ្ចូលឈ្មោះសម្គាល់អ្នកប្រើប្រាស់
Please enter your User ID



④ សូមចុច "Login"
Please click on "Login"

សូមបញ្ចូលលេខសម្ងាត់ផ្ទាល់ខ្លួន
Please enter your own Password

សូមបញ្ចូលលេខសម្ងាត់ដែលទទួលបានពី Soft Token ឬ Hard Token / Please enter One Time Password generated by Soft Token or Hard Token



សូមចុច "Login"
Please click on "Login"

2

សូមចុច "Pay Bills"
Please click on "Pay Bills"

សូមជ្រើសរើសយក "400-NSSF"
Please select "400-NSSF"



សូមជ្រើសរើស "NSSF" រួចចុចប៊ូតុង "Show" ដើម្បីបញ្ចូលលេខអត្តសញ្ញាណសហគ្រាស
Please select "NSSF", then click on the button "Show" to enter consumer ID

3

សូមបញ្ចូល "លេខអត្តសញ្ញាណសហគ្រាស" នៅលើវិក្កយបត្រក្នុងប្រអប់ "Consumer ID" រួចចុចប៊ូតុង "Search"/ Please enter Consumer ID, then click on the button "Search"

សូមជ្រើសរើសលេខគណនី រួចបញ្ចូលចំនួនទឹកប្រាក់ដែលត្រូវទូទាត់
Please select account number and enter amount you wish to make bill payment



⑫ សូមចុចប៊ូតុង "Submit" / Please click on the button "Submit"

4

⑬ បន្ទាប់មកសូមលោកអ្នកផ្ទៀងផ្ទាត់មើលព័ត៌មានលម្អិតខាងក្រោម រួចបញ្ចូលលេខសម្ងាត់ (OTP) ដែលទទួលបានពី Soft Token ឬ Hard Token រួចចុចប៊ូតុង "Confirm" / Please verify the payment details and enter One Time Password generated by Soft Token or Hard Token, then click on the button "Confirm".



5

⑭ ការបង់វិក្កយបត្រទទួលបានជោគជ័យ លោកអ្នកអាចចុចប៊ូតុង "Print" ប្រសិនបើចង់បោះពុម្ពទុកជាឯកសារ, ឬចុច "Register Biller" ដើម្បីរក្សាទុកឈ្មោះក្រុមហ៊ុនសម្រាប់បង់វិក្កយបត្រនៅពេលបន្ទាប់ / Your company bill has been processed successfully, then click on the button "Print" if you want to keep it as reference , or click on "Register Biller" to save company bill for next payment.



6

# សម្រាប់ CIB

## • របៀបបង់ភាគទាន / How to make contribution payment

### ១-១ Maker

▸ សូមចូលទៅកាន់វេបសាយធនាគារ អេស៊ីលីដា តាមរយៈ "www.acledabank.com.kh" ជ្រើសរើស "Corporate Customer" រួចចុចប៊ូតុង "Login" ។
Please go to ACLEDA Website "www.acledabank.com.kh", select "Corporate Customer", then click on "Login".




1

លោកអ្នកអាចជ្រើសរើសភាសាខ្មែរ - អង់គ្លេស ឬ ចិន តាមតម្រូវការ / You can select languages as Khmer, English or Chinese of your choice.

សូមបញ្ចូលលេខសម្ងាត់ដែលទទួលបានពី Soft Token ឬ Hard Token / Please enter One Time Password generated by Soft Token or Hard Token

សូមបញ្ចូលឈ្មោះសម្គាល់អ្នកប្រើប្រាស់
Please enter your User ID





សូមចុច "Login"
Please click on "Login"

សូមបញ្ចូលលេខសម្ងាត់ផ្ទាល់ខ្លួន
Please enter your own Password

សូមចុច "Login"
Please click on "Login"

2

សូមចុច "Bill Payment"
Please click on "Bill Payment"



8 សូមចុច "Pay Bill"
Please click on "Pay Bill"

សូមចុច "Pay Bill"
Please click on "Pay Bill"

3

សូមជ្រើសរើសលេខ biller (400) ដែលត្រូវធ្វើការបង់ប្រាក់
Please select biller number (400) to be paid

សូមជ្រើសរើសយក "NSSF"
Please select "NSSF"




12 សូមបញ្ចូលលេខអត្តសញ្ញាណសហគ្រាសដែលមាននៅលើវិក្កយបត្រ / Please enter consumer ID

សូមចុចប៊ូតុង "Search" / Please click on the button "Search"

14 សូមចុចលើ "NSSF"
Please select on "NSSF"

4

សូមបញ្ចូលចំនួនទឹកប្រាក់ដែលត្រូវទូទាត់
Please enter "Payment Amount"




សូមជ្រើសរើសលេខគណនីដែលត្រូវកាត់ប្រាក់ចេញ
Please select "Debit Account"

សូមចុចប៊ូតុង "Submit"
Please click on the button "Submit"

5

18 បន្ទាប់មកសូមលោកអ្នកផ្ទៀងផ្ទាត់មើលព័ត៌មានលម្អិតខាងក្រោម រួចបញ្ចូលលេខសម្ងាត់ (OTP) ដែលទទួលបានពី Soft Token ឬ Hard Token រួចចុចប៊ូតុង "Confirm" / Please verify the payment details and enter One Time Password generated by Soft Token or Hard Token, then click on the button "Confirm".




6

### ១-២ Checker

សូមចុច "Bill Payment"
Please click on "Bill Payment"



សូមចុច "Pay Bill"
Please click on "Pay Bill"

សូមចុច "View Pending Entries"
Please click on"View Pending Entries"

សូមចុច "Authorize"
Please click on "Authorize"

5 សូមបញ្ចូលលេខសម្ងាត់ដែលទទួលបានពី Soft Token ឬ Hard Token
Please enter One Time Password generated by Soft Token or Hard Token

7

6 ការបង់វិក្កយបត្រទទួលបានជោគជ័យ លោកអ្នកអាចចុចប៊ូតុង "Print" ប្រសិនបើចង់បោះពុម្ពទុកជាឯកសារ / Your company bill has been processed successfully, then click on the button "Print" if you want to keep it as reference.




8